## រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២១

អគ្គលេខាធិការដ្ឋាន
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ







ទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
ផ្លូវលេខ 92 សង្កាត់វត្តភ្នំ
ខណ្ឌដូនពេញ រាជធានីភ្នំពេញ
(+៨៥៥) ៨៥ ៧៧៧ ៩២០

www.facebook.com/gscpfm
gsc@pfm.gov.kh
www.pfm.gov.kh

# បុព្វកថា

ស្ថិតក្នុងម្លប់សុខសន្តិភាព ឯកភាពជាតិ ឯកភាពទឹកដី ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់, រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។ ចាប់តាំងពីឆ្នាំ២០១៣ មក រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសម្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ព្រមទាំងបានផ្តល់អាទិភាព និងចាត់ទុកភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឆ្អឹងខ្នងនៃការអនុវត្តរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចបានប្រកបដោយជោគជ័យ និងចីរភាព។ ក្នុងន័យនេះ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញការអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ជាពិសេសធានានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

ជាក់ស្តែង ការប្រមូលចំណូលថវិការដ្ឋគឺមានភាពរឹងមាំ តាមរយៈការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ដែលចំណូលចរន្តមានកំណើនជាមធ្យមប្រមាណ ១,៤ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំខ្ពស់ជាងគោលដៅ ០,៥ ពិន្ទុភាគរយ នៃ ផ.ស.ស. ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រ។ បន្ថែមពីនេះ តាមរយៈការអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលឆ្នាំ២០១៩-២០២៣ ចំណូលចរន្តបានកើនឡើងខ្ពស់នៅឆ្នាំ២០១៩ ដោយសម្រេចបាន ២៥,១% នៃ ផ.ស.ស. ប៉ុន្តែធ្លាក់ចុះក្នុងទំហំមួយអាចគ្រប់គ្រងបាននៅអំឡុងពេលវិបត្តិនៃជំងឺកូវីដ-១៩ ពោលគឺឆ្នាំ២០២០ សម្រេចបាន ២១,៥% នៃ ផ.ស.ស. និងឆ្នាំ២០២១ សម្រេចបាន ១៨,៩៣%នៃ ផ.ស.ស.។ ទោះជាយ៉ាងនេះក្តី ចាប់ពីឆ្នាំ២០២២ តទៅ, ចំណូលចរន្តមាននិន្នាការកើនឡើង ដោយភាពស៊ាំនៃសហគមន៍តាមរយៈយុទ្ធនាការចាក់វ៉ាក់សាំងទូទាំងប្រទេសរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលឈានដល់ការបើកដំណើរការសេដ្ឋកិច្ចសង្គមឡើងវិញនៅទូទាំងប្រទេស។

សមិទ្ធផលនៃកិច្ចខិតខំគៀរគរចំណូលនេះ បានអនុញ្ញាតឱ្យរាជរដ្ឋាភិបាលអាចសន្សំ និងបង្គរថវិកាកាន់តែច្រើនទៅកាន់វិស័យអាទិភាព ក៏ដូចជាអាចបង្កើនយ៉ាងច្រើននូវធនធានវិនិយោគសាធារណៈក្នុងស្រុក ជាពិសេសលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលជាប្រការជួយលើកស្ទួយមួយកម្រិតដល់ឯករាជ្យភាពផ្នែកថវិការបស់កម្ពុជា។ ក្នុងរយៈពេលប្រមាណ ២ ឆ្នាំ នៃវិបត្តិជំងឺកូវីដ-១៩ កន្លងទៅ, រាជរដ្ឋាភិបាលមានថវិកាគ្រប់គ្រាន់ ដើម្បីគាំទ្រការអនុវត្តគោលនយោបាយ និងវិធានការអន្តរាគមន៍ទាំងឡាយ ដើម្បីជួយរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន ក៏ដូចជារក្សាលំនឹងធុរកិច្ចរបស់វិស័យឯកជន ដែលបាននិងកំពុងបន្តទទួលរងនូវផលប៉ះពាល់ពីវិបត្តិជំងឺកូវីដ-១៩។ ជាក់ស្តែង, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងជនងាយរងគ្រោះចាប់តាំងពីខែមិថុនា ឆ្នាំ២០២០ មក និងបន្តរយៈពេល ៩ ខែទៀតរហូតដល់ដំណាច់ខែកញ្ញា ឆ្នាំ២០២២។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលក៏បានផ្តល់ការអនុគ្រោះផ្នែកពន្ធតាមរយៈការដាក់ចេញនូវវិធានការអន្តរាគមន៍ទាំង ១០ ជុំកន្លងមក ហើយនឹងពិនិត្យ និងវាយតម្លៃយ៉ាងម៉ត់ចត់លើភាពមាំទាំក្នុងការបន្តវិធានការធានាសំដៅជួយដល់ប្រតិបត្តិករនៅក្នុងវិស័យទេសចរណ៍ និងវិស័យអាកាសចរណ៍

ដែលបានរងផលប៉ះពាល់ដោយសារវិបត្តិនៃជំងឺកូវីដ-១៩ ដើម្បីផ្តល់លទ្ធភាពដល់ធុរជនពាក់ព័ន្ធក្នុងការកែលម្អ និងត្រៀមខ្លួនទទួលស្វាគមន៍ភ្ញៀវទេសចរជាតិ និងអន្តរជាតិបន្ទាប់ពីកម្ពុជាត្រូវបានបើកប្រទេសពេញលេញឡើងវិញចាប់ពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០២១។

ទន្ទឹមនឹងការធានាបាននូវភាពជឿទុកចិត្តនៃថវិកាជាសារវន្ត, បុរេលក្ខណៈសំខាន់ៗនៃគណនេយ្យភាពហិរញ្ញវត្ថុត្រូវបាននិងកំពុងកសាង និងបន្តពង្រឹងបន្ថែម ដើម្បីធានាគណនេយ្យភាព និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង តាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS), ការជំរុញការអនុវត្តនីតិវិធីការងារថ្មីតាមប្រព័ន្ធ និងបង្កើនកម្រិតស្វ័យប្រវត្តិកម្ម និងសុក្រឹតភាពនៃការផលិតរបាយការណ៍ និងភាពទាន់ពេលនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងត្រូវបានពង្រឹង និងពង្រីកវិសាលភាពទាំងក្នុងទិដ្ឋភាពនៃការអនុវត្តចំណាត់ថ្នាក់ថវិកា និងក្នុងទិដ្ឋភាពនៃការគ្របដណ្តប់លើស្ថាប័ន និងភ្នាក់ងារចំណាយរបស់រាជរដ្ឋាភិបាលឱ្យស្របតាមស្តង់ដារអន្តរជាតិដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងថវិកានិងរំហូរសាច់ប្រាក់។

ប្រព័ន្ធ FMIS ត្រូវបាននិងកំពុងអភិវឌ្ឍជំហានទី៣ ដោយបានបញ្ចប់ការដាក់ឱ្យអនុវត្តជាផ្លូវការលើការពង្រីកការអនុវត្តតាមគ្រប់ក្រសួង-ស្ថាប័ន, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំង ២៥ រាជធានី-ខេត្ត និងរតនាគាររាជធានី-ខេត្ត ហើយឈានទៅដាក់ឱ្យអនុវត្តនៅតាមបណ្តារដ្ឋបាលថ្នាក់ក្រោមជាតិជាបន្តបន្ទាប់។ ជាមួយគ្នានេះ, មុខងារថ្មីចំនួនពីរ រួមមាន÷ មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅឆ្នាំ២០២១។ មុខងាររៀបចំផែនការថវិកាត្រូវបានដាក់ឱ្យអនុវត្តនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងកិច្ចការនារី ខណៈមុខងារលទ្ធកម្មពេញលេញត្រូវបានដាក់ឱ្យអនុវត្ត នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងកិច្ចការនារី និងក្រសួងព័ត៌មាន។ រីឯនីតិវិធីអនុវត្តការងារថ្មីតាម FMIS លើការទូទាត់ចំណាយបៀវត្ស និងចំណាយទូទាត់ត្រង់ ដែលមានហានិភ័យកម្រិតទាបត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅក្រសួង-ស្ថាប័នចំនួន ២៧។ ជាមួយនឹងការប្តេជ្ញាខ្ពស់ និងផែនការប្រកបដោយមហិច្ឆតា, គ្រប់ប្រតិបត្តិការហិរញ្ញវត្ថុដែលនៅក្រៅប្រព័ន្ធ FMIS នឹងត្រូវធ្វើស្វ័យប្រវត្តិកម្មទាំងស្រុងក្នុងប្រព័ន្ធ ហើយការធ្វើស្វ័យប្រវត្តិកម្មពេញលេញនូវដំណើរការចំណាយចរន្ត និងវិនិយោគនឹងត្រូវអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័នត្រឹមឆ្នាំ២០២៥។

ក្នុងក្របខណ្ឌនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន និងតាមបណ្តារដ្ឋបាលរាជធានី-ខេត្តទាំង២៥។ ការដាក់ឱ្យអនុវត្តថវិកាកម្មវិធីបាននាំមកនូវការកែប្រែលើការគ្រប់គ្រងថវិកាទាំងស្រុង, ដែលពីមុនមានលក្ខណៈមជ្ឈការនៅតាមក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត, ឥឡូវនេះ មានលក្ខណៈវិមជ្ឈការ ពោលគឺអ្នកអនុវត្តគម្រោង, កម្មវិធី និងសកម្មភាពផ្ទាល់ ឬ អ្នកបច្ចេកទេសបានដឹងអំពីថវិការបស់ខ្លួន និងអាចធ្វើសកម្មភាពក្នុងលក្ខណៈបុរេសកម្ម ហើយប្រសិទ្ធភាពនៃការវិភាជថវិកាកាន់តែមានភាពប្រសើរឡើង ដោយបានបែរឆ្ពោះថវិកាទៅរកវិស័យអាទិភាព និងចំគោលដៅ។ ជាការកត់សម្គាល់ ក្រសួង-ស្ថាប័នមួយចំនួនបានចាប់ផ្តើមធ្វើការកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនជាបណ្តើរៗ និងបង្កើនចំនួនអង្គភាពថវិកា និងសិទ្ធិអំណាចអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ដើម្បីឈានឆ្ពោះទៅពង្រឹងសមិទ្ធកម្មថែមទៀត។ ទន្ទឹមនេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ(ថ្មី) និងរៀបចំកែសម្រួលលិខិតបទដ្ឋានគតិយុត្តគាំទ្រ ដើម្បីធានាថាប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មអាចអនុវត្តបានតាមពេលវេលាគ្រោងទុក និងគ្រប់សមាសធាតុគន្លឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, គណនេយ្យភាព និងតម្លាភាព។

ខ្ញុំសូមសំដែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផលលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសម្រេចបានមកដល់ពេលនេះ។ សមិទ្ធផលគួរជាទីលើកទឹកចិត្តនេះ មិនអាចកាត់ផ្តាច់ចេញពីការចូលរួមយ៉ាងសកម្ម និងសស្រាក់សស្រាំប្រកបដោយការទទួលខុសត្រូវក្នុងភាពជាម្ចាស់របស់ក្រសួង-ស្ថាប័នបាននោះទេ ជាពិសេសការគាំទ្រជាប់ជាប្រចាំ និងការប្តេជ្ញាចិត្តឥតងាករេពីថ្នាក់ដឹកនាំ និងស្ថាបនិកគោលនយោបាយ នៃរាជរដ្ឋាភិបាលកម្ពុជា និងកិច្ចសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា យើងនឹងសម្រេចបានគោលដៅគន្លឹះក្នុងដំណាក់កាលទី៣ បូក២ ដែលប្រែក្លាយ “**ថវិកា គឺជាឧបករណ៍គោលនយោបាយ**” ដើម្បីគាំទ្រការអនុវត្តរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យសម្រេចបានជោគជ័យនិងចីរភាពតាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និងគណនេយ្យភាពទាំងផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធីសំដៅផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយដែលកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណ, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, និងផែនការយុទ្ធសាស្ត្រតាមវិស័យ។

ជាទីបញ្ចប់ ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរូបខ្ញុំផ្ទាល់ សូមធ្វើការវាយតម្លៃខ្ពស់ចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, កិច្ចសហប្រតិបត្តិការភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ ដែលបានចូលរួម និងគាំទ្រជាប់ជាប្រចាំនូវការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលបានខិតខំបំពេញមុខងាររបស់ខ្លួនជាឧត្តមសេនាធិការជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងការងារដឹកនាំ, សម្របសម្រួល, គាំទ្រ និងត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងប្រចាំត្រីមាស និងប្រចាំឆ្នាំប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងឆ្លុះបញ្ចាំងទាំងទិដ្ឋភាពការងារកែទម្រង់និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល៕

ថ្ងៃ ចន្ទ ១៤ កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈគឺមានទស្សនវិស័យប្រកបដោយមហិច្ឆិតា និងប្រាកដនិយម ពោល គឺកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាឱ្យស្របតាមស្តង់ដាអន្តរជាតិ សំដៅផ្លាស់ប្តូរប្រព័ន្ធដែលផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការ ឆ្ពោះទៅប្រព័ន្ធដែលផ្តោតលើធាតុចេញ ឬលទ្ធផល និងវិមជ្ឈការ។ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានរៀបចំនិងដាក់ឱ្យអនុវត្តផែនការសកម្មភាពប្រចាំឆ្នាំ ដែលបូកសរុបពីគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន អនុលោមតាមសារាចររបស់រាជរដ្ឋាភិបាល លេខ០៩ សរ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាសេនាធិការជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការរៀបចំរបាយការណ៍ត្រួតពិនិត្យ តាមដានវឌ្ឍនភាពប្រចាំត្រីមាស និងប្រចាំឆ្នាំ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ សម្រាប់របាយការណ៍ប្រចាំឆ្នាំ២០២១ ការបូកសរុបរបាយការណ៍ គឺមិនត្រឹមតែជាការតាមដានការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការវាយតម្លៃរួមលើការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ បូក២ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ដែលគ្រោងនឹងបញ្ចប់នៅឆ្នាំ២០២២ នេះ ដើម្បីជាមូលដ្ឋានត្រៀមរៀបចំឆ្ពោះទៅដំណាក់កាលទី៤ "**គណនេយ្យភាពសមិទ្ធកម្ម**"។ ការរៀបចំរបាយការណ៍អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បូក២ ប្រចាំឆ្នាំ២០២១ នេះ ត្រូវបានរៀបចំតាមវិធីសាស្ត្រមួយចំនួន ក្នុងនោះរួមមាន÷ (១) ការតាមដានវឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, (ការតាមដានវឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងឆ្នាំ២០២១, ការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ បូក២ និងការរៀបចំ សិក្ខាសាលាផ្សព្វផ្សាយស្តីពីបទពិសោធន៍ថវិកាកម្មវិធីសម្រាប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ), (២) ការវាយតម្លៃចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និង (៣) មតិយោបល់របស់ដៃគូអភិវឌ្ឍន៍ (លទ្ធផលបឋមនៃការត្រួតពិនិត្យលើប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ និងលទ្ធផលបឋមនៃការត្រួតពិនិត្យចំណាយសាធារណៈ ដោយធនាគារពិភពលោក)។

ផ្អែកលើលទ្ធផលត្រួតពិនិត្យតាមដានដោយប្រើប្រាស់វិធីសាស្ត្រខាងលើ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបាន និងកំពុងកសាងជាបណ្តើរៗ តាមរយៈការបន្តការរៀបចំ និងការកែលម្អប្រព័ន្ធ ក្របខណ្ឌគតិយុត្ត យន្តការស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស។ ទោះបីជាយ៉ាងនេះក្តី ប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ និងលិខិតបទដ្ឋានគតិយុត្ត គឺនៅមានកម្រិត ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ និងពង្រឹងបន្ថែម។ ក្នុងន័យនេះ ខ្ញុំរំពឹងថារបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២១ នេះ នឹងក្លាយជាធាតុចូលដ៏សំខាន់សម្រាប់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ន និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិង

ហិរញ្ញវត្ថុ សម្រាប់ជាមូលដ្ឋានរៀបចំ និងកែសម្រួលផែនការសកម្មភាពឱ្យកាន់តែមានគុណភាពស្របតាមក្របខណ្ឌផែនការសកម្មភាពរួមតាមដំណាក់កាលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ជាទីបញ្ចប់, ក្នុងនាមអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរូបខ្ញុំផ្ទាល់សូមសម្តែងការដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ និងផ្តល់អនុសាសន៍ណែនាំដ៏មានតម្លៃ និងតម្រង់ទិសទាំងការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចជោគជ័យ និងចីរភាព។ ជាមួយគ្នានេះ, ខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ដែលបានចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដៃគូអភិវឌ្ឍន៍ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការ ដើម្បីរួមចំណែកទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់គាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីដំណាក់កាលទី១ រហូតមកដល់ពេលបច្ចុប្បន្ន៕

ថ្ងៃ ពុធ ១ រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០២២

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់ សីលវ៉ា**

# មាតិកានុក្រម


**បុព្វកថា** ........ i

**អារម្ភកថា** ........ iv

**ខ្លឹមសារសង្ខេបប្រតិបត្តិ** ........ xi

**១. សេចក្តីផ្តើម** ........ 1

១.១. ទិដ្ឋភាពទូទៅ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ 1

១.២. ស្ថានភាពសេដ្ឋកិច្ច ........ 2

១.៣. ស្ថានភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ 3

១.៤. សនិទានកម្ម និងគោលបំណង ........ 5

**២. លទ្ធផលវាយតម្លៃកម្មវិធីកែទម្រង់ និងវឌ្ឍនភាពប្រចាំឆ្នាំ២០២១** ........ 5

**២.១. ការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣បូក២** ........ 6

ផ្នែកទី១ ÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ........ 6

ផ្នែកទី២ ÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ........ 11

ផ្នែកទី៣ ÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ........ 18

ផ្នែកទី៤ ÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម ........ 24

ផ្នែកទី៥ ÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព ........ 27

**២.២. វឌ្ឍនភាពតាមក្រសួង-ស្ថាប័ន រួមទាំងអង្គភាពក្រោមឱវាទ កសហវ.** ........ 31

២.២.១. វឌ្ឍនភាពនៃការអនុវត្តតាមអង្គភាពក្រោមឱវាទ កសហវ. (GDAP3+2) ........ 31

២.២.២. វឌ្ឍនភាពនៃការអនុវត្តតាមក្រសួង-ស្ថាប័ន (MAP3+2) ........ 34

**២.៣. យោបល់ដៃគូអភិវឌ្ឍន៍លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈ** ........ 39

២.៣.១. លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS ........ 39

២.៣.២. លទ្ធផលបឋមនៃការត្រួតពិនិត្យចំណាយសាធារណៈ ........ 44

**២.៤ លទ្ធផលនៃការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ** ........ 49

២.៤.១. លទ្ធផលនៃការវាយតម្លៃ PEFA ឆ្នាំ២០២១ ........ 49

២.៤.២. លទ្ធផលបឋមនៃការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលរាជធានីភ្នំពេញ ........ 50

**៣. បញ្ហាប្រឈម និងវិធានការ** ........ 58

**៤. សន្និដ្ឋាន** ........ 61

**ឧបសម្ព័ន្ធ** ........ 64

ឧបសម្ព័ន្ធទី១ ÷ វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. ប្រចាំឆ្នាំ២០២១ ........ 65

ឧបសម្ព័ន្ធទី២ ÷ តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់អង្គភាពក្រោមឱវាទ កសហវ. ប្រចាំឆ្នាំ២០២១ ........ 75

ឧបសម្ព័ន្ធទី៣ ÷ តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់មន្ទីរ សហវ. រាជធានី-ខេត្ត ប្រចាំឆ្នាំ២០២១ ........ 78

ឧបសម្ព័ន្ធទី៤ ÷ តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់ក្រសួង-ស្ថាប័ន ប្រចាំឆ្នាំ២០២១............................81
ឧបសម្ព័ន្ធទី៥ ÷ តារាងសង្ខេបវឌ្ឍនភាពប្រចាំឆ្នាំ២០២១ (ទម្រង់ CAP3+2).........................................85
ឧបសម្ព័ន្ធទី៦ ÷ បទបង្ហាញស្តីពីរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ PFMRP និងរបាយការណ៍
វឌ្ឍនភាពប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១ សម្រាប់កិច្ចប្រជុំ គ.ក.ហ. នៃ កសហវ.............152
ឧបសម្ព័ន្ធទី៧ ÷ បទបង្ហាញស្តីពីរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ PFMRP និងរបាយការណ៍វឌ្ឍនភាព
ប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១ សម្រាប់កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២១ (ភាសាខ្មែរ)...... 186
ឧបសម្ព័ន្ធទី៨ ÷ ការឆ្លើយតបទៅនឹងមតិយោបល់របស់ដៃគូអភិវឌ្ឍន៍លើរបាយការណ៍ត្រួតពិនិត្យ និង
វាយតម្លៃ PFMRP និងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១ (ភាសាខ្មែរ). 218
ឧបសម្ព័ន្ធទី៩ ÷ បទបង្ហាញស្តីពីរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ PFMRP និងរបាយការណ៍វឌ្ឍនភាព
ប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១ សម្រាប់កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២១ (ភាសាអង់គ្លេស). 235
ឧបសម្ព័ន្ធទី១០ ÷ ការឆ្លើយតបទៅនឹងមតិយោបល់របស់ដៃគូអភិវឌ្ឍន៍លើរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ
PFMRP និងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១ (ភាសាអង់គ្លេស).......... 236
ឧបសម្ព័ន្ធទី១១ ÷ របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ PFMRP និងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤
និងឆ្នាំ២០២១ (ភាសាអង់គ្លេស)...................................................................... 247

# អក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AFD | French Development Agency | ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង |
| BSP | Budget Strategic Plan | ផែនការយុទ្ធសាស្ត្រថវិកា (ផ.យ.ថ) |
| BSRS | Budget System Reform Strategy | យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា |
| CAP | Consolidated Action Plan | ផែនការសកម្មភាពរួម |
| CoA | Chart of Accounts | ប្លង់គណនេយ្យ |
| DMFAS | Debt management and financial analysis system | ប្រព័ន្ធវិភាគហិរញ្ញវត្ថុ និងគ្រប់គ្រងបំណុល |
| EFI | Economics and Finance Institute | វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វ.ស.ហ.) |
| GDICDM | General Department of International Cooperation and Debt Management | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អ.ស.ប.) |
| FMIS | Financial Management Information System | ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| FMWG | FMIS project Management Working Group | ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| GDB | General Department of Budget | អគ្គនាយកដ្ឋានថវិកា (អ.ថ.) |
| GDCE | General Department of Customs and Excise | អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អ.គ.រ.) |
| GDIA | General Department of Internal Audit | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង (អ.ស.ក.) |
| GDNT | General Department of National Treasury | អគ្គនាយកដ្ឋានរតនាគារជាតិ (អ.រ.ជ.) |
| GDPP | General Department of Public Procurement | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ (អ.ល.ស.) |
| GDSNAF | General Department of Sub-National Administration Finance | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ (អ.ហ.ថ.) |
| GDSPNR | General Department of State Property and Non-Tax Revenue | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច.) |
| GDT | General Department of Taxation | អគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) |
| GDP | General Department of Policy/ Gross Domestic Product | ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) |
| GFS | Government Financial Statistics | ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល |
| GSC | General Secretariat of Public Financial Management Reform Steering Committee | អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(អ.គ.ហ) |

| | | |
|---|---|---|
| IMF | International Monetary Fund | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| LM | Line ministry | ក្រសួង ស្ថាប័ន |
| LCs | Legal Council Secretariate | លេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម (ល.ក.ន.) |
| MEF | Ministry of Economy and Finance | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ.) |
| MTBF | Medium-Term Budget Framework | ក្របខណ្ឌថវិការយៈពេលមធ្យម |
| MTFF | Medium-Term Fiscal Framework | ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម |
| NAA | National Audit Authority | អាជ្ញាធរសវនកម្មជាតិ (អ.ស.ជ.) |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| PFM | Public Financial Management | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| WB | World Bank | ធនាគារពិភពលោក |
| PFMRC | Public Financial Management Reform Commission | គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) |
| PFMSC | Public Financial Management Reform Steering Committee | គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| MOEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| EFMS | Education Financial Management System | ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា |
| PB | Program Budgeting | ថវិកាកម្មវិធី |
| NRMIS | Non-tax Revenue Management Information System | ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ |
| SARMIS | State Asset Register Management Information System | ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងសារពើភណ្ឌទ្រព្យ-សម្បត្តិរដ្ឋ |
| PPCA | Phnom Penh Capital Administration | រដ្ឋបាលរាជធានីភ្នំពេញ |
| PPCC | Phnom Penh Capital Council | ក្រុមប្រឹក្សារាជធានីភ្នំពេញ |

## បញ្ជីតារាង


តារាងទី 1 ÷ ការប្រែប្រួលក្របខណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី២, ៣ និង ៣បូក២ .................... 2

តារាងទី 2 ÷ សូចនាករសេដ្ឋកិច្ច ឆ្នាំ២០១៦-២០២១ .................... 2

តារាងទី 3 ÷ ស្ថិតិនៃការរៀបចំប័ណ្ណកម្មសិទ្ធិលើអចលនទ្រព្យរបស់រដ្ឋឆ្នាំ២០២០ .................... 14

តារាងទី 4 ÷ សូចនាករបំណុលសាធារណៈឆ្នាំ ២០១៨-២០២១ .................... 16

តារាងទី 5 ÷ វឌ្ឍនភាពតាមក្រសួង-ស្ថាប័ន .................... 34

តារាងទី 6 ÷ ការគ្រោង និងអនុវត្តថវិកាឆ្នាំ២០១៨-២០២០ .................... 47

តារាងទី 7 ÷ ពិន្ទុតាមសូចនាករសមិទ្ធកម្ម PEFA ថ្នាក់ក្រោមជាតិ សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ......................55

## បញ្ជីដ្យាក្រាម

ដ្យាក្រាមទី 1 ÷ ការអនុវត្តផែនការប្រមូលចំណូលឆ្នាំ២០១៣-២០២១.......................................................4
ដ្យាក្រាមទី 2 ÷ ការអនុវត្តថវិការដ្ឋឆ្នាំ២០១៣-២០២១....................................................................5
ដ្យាក្រាមទី 3 ÷ ចំណាយថវិកាតាមអង្គភាពគាំទ្រ PFMRP ឆ្នាំ២០០៤-២០២១.............................................6
ដ្យាក្រាមទី 4 ÷ ចំណាយថវិកាតាមប្រភេទគាំទ្រ PFMRP ឆ្នាំ២០០៤-២០២១...............................................6
ដ្យាក្រាមទី 5 ÷ សន្និធិបំណុលសាធារណៈក្រៅប្រទេស (គិតត្រឹមឆមាសទី១ ឆ្នាំ២០២២)................................16
ដ្យាក្រាមទី 6 ÷ វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ. ..........................................................31
ដ្យាក្រាមទី 7 ÷ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់ មន្ទីរ សហវ. រាជធានី-ខេត្ត.............................32
ដ្យាក្រាមទី 8 ÷ ការអនុវត្តថវិកា និងវឌ្ឍនភាព (%) ប្រចាំឆ្នាំ២០២១ របស់មន្ទីរ សហវ. រាជធានី-ខេត្ត.................33
ដ្យាក្រាមទី 10 ÷ ថវិកាវិស័យកសិកម្ម......................................................................................45
ដ្យាក្រាមទី 11 ÷ ការចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (% ចំណាយសរុប)..........................................45
ដ្យាក្រាមទី 12 ÷ អនុសាសន៍កែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅ MAFF.......................................46
ដ្យាក្រាមទី 13 ÷ ការវិភាជថវិកាដល់រដ្ឋបាលក្រុង ស្រុកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច........................................47
ដ្យាក្រាមទី 14 ÷ ការវិភាជថវិកាដល់រដ្ឋបាលឃុំ សង្កាត់តាមចំណាត់ថ្នាក់សេដ្ឋកិច្ច.......................................48
ដ្យាក្រាមទី 15 ÷ ការងារគន្លឹះត្រូវពង្រឹងបន្ថែមតាមវដ្តថវិកា ដោយធៀបនឹងស្តង់ដា PEFA..............................50
ដ្យាក្រាមទី 16 ÷ សង្ខេបពិន្ទុនៃប្រព័ន្ធ PFM នៃរដ្ឋបាលរាជធានីភ្នំពេញ....................................................52

# ខ្លឹមសារសង្ខេបប្រតិបត្តិ

១. ផ្អែកលើបទពិសោធន៍ជាអន្តរជាតិ និងបទពិសោធន៍ជាវិជ្ជមានរបស់កម្ពុជាខ្លួនឯងផ្ទាល់ក្នុងរយៈពេល ១៦ ឆ្នាំចុងក្រោយនេះ បង្ហាញយ៉ាងច្បាស់ថា ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់មិនអាចខ្វះបានសម្រាប់ជំរុញការអភិវឌ្ឍប្រទេសជាតិ, ការធានានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ ជាពិសេសការលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អាទិភាព និងចាត់ទុកភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឆ្អឹងខ្នងនៃការអនុវត្តរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចបានប្រកបដោយជោគជ័យ និងចីរភាព ដើម្បីឆ្លើយតបនឹងការវិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយជវភាព បរិយាប័ន្ន ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព។

២. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងកសាង និងពង្រឹងលើមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន "**ប្រព័ន្ធ ក្របខណ្ឌគតិយុត្ត យន្តការស្ថាប័ន និងធនធានមនុស្ស**"។ បច្ចុប្បន្ន, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្ថិតក្នុង **ដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** ក្នុងគោលបំណងផ្លាស់ប្តូរជាបណ្តើរៗ នូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ តាមរយៈការពង្រឹង និងពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តថវិកាកម្មវិធី និងការអនុវត្តអង្គភាពថវិកា ខណៈត្រូវពង្រឹងសមិទ្ធផលដែលសម្រេចបានក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ កន្លងទៅផងដែរ។ ដំណាក់កាលទី៣ នេះត្រូវបានបន្តអនុវត្តពីរឆ្នាំបន្ថែម ដើម្បីបញ្ចប់ការងារសេសសល់ និងកសាងនូវលក្ខខណ្ឌចាំបាច់ទាំងឡាយ ដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មដែលជាគន្លឹះក្នុងការកសាង "**វប្បធម៌សមិទ្ធកម្ម**"។ ក្នុងន័យនេះ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានដាក់ចេញផែនការសកម្មភាពរួម ៣បូក២ (CAP3+2) ដែលមានរយៈពេលពីរឆ្នាំ (២០២១-២០២២) ដោយបានកែសម្រួលរចនាសម្ព័ន្ធនៃផែនការសកម្មភាពរួមដំណាក់កាលទី៣ ព្រមទាំងផ្លាស់ប្តូរពីការផ្តោតលើសកម្មភាពមកជាសមិទ្ធកម្មគន្លឹះ សម្រាប់ជាមូលដ្ឋាន ក្នុងការកសាងនូវ ផែនការសកម្មភាពរួម ដំណាក់កាលទី ៤ "**គណនេយ្យភាពសមិទ្ធកម្ម**" ដែលរំពឹងថានឹងត្រូវចាប់ផ្តើម ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧។

៣. គោលបំណងនៃការរៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងវឌ្ឍនភាពប្រចាំឆ្នាំ២០២១ ដើម្បីផ្តល់ជាធាតុចូលសម្រាប់ការរៀបចំផែនការសកម្មភាពរួមដំណាក់កាលទី៤។

៤. នៅឆ្នាំ២០២១, ក្នុងកម្រិតគោលបំណងនៃក្របខណ្ឌផែនការសកម្មភាពរួមឆ្នាំ២០២១ សូចនាករសមិទ្ធកម្មគន្លឹះគ្រោង ចំនួន៤២ សម្រេចបានចំនួន២៦, មិនទាន់សម្រេចបានតាមគោលដៅចំនួន១៤ និងពុំមានព័ត៌មានបញ្ជាក់ចំនួន២។

| របាយវ័ន្ត | សូចនាករ សមិទ្ធកម្ម (គ្រោង) | សូចនាករសម្រេចបាន | |
|---|---|---|---|
| | | បៃតង (សម្រេចបាន តាមគោលដៅ) | ក្រហម (មិនទាន់សម្រេចបាន តាមគោដៅ) |
| ផ្នែកទី ១ | ៧ | ៦ | ១ |
| ផ្នែកទី ២ | ៩ | ៧ | ២ |
| ផ្នែកទី ៣[1] | ១០ | ៨ | ១ |
| ផ្នែកទី ៤[2] | ៨ | ១ | ៦ |
| ផ្នែកទី ៥ | ៨ | ៥ | ៣ |
| សកម្មភាពសរុប | **៤២** | **២៦** | **១៤** |

៥. ក្នុងកម្រិតចង្កោមសកម្មភាព នៃក្របខណ្ឌផែនការសកម្មភាពរួមឆ្នាំ២០២១ សូចនាករសមិទ្ធកម្មគន្លឹះគ្រោងចំនួន ១១៣ សម្រេចចំនួន៦០, មិនទាន់សម្រេចបានចំនួន៣១ និងពុំមានព័ត៌មានពេញលេញក្នុងការវាយតម្លៃចំនួន ១៧។

| របាយវ័ន្ត | ចំនួនសូចនាករ សមិទ្ធកម្ម (គ្រោង) | សូចនាករសម្រេចបាន | |
|---|---|---|---|
| | | បៃតង (សម្រេចបានតាមគោល ដៅ) | ក្រហម (មិនទាន់សម្រេចបាន តាមគោដៅ) |
| ផ្នែកទី ១[3] | ២៣ | ១១ | ៩ |
| ផ្នែកទី ២ | ២៦ | ២០ | ៦ |
| ផ្នែកទី ៣[4] | ២៩ | ២២ | ២ |
| ផ្នែកទី ៤[5] | ១៧ | ៨ | ៥ |
| ផ្នែកទី ៥[6] | ១៨ | ៧ | ៨ |
| សកម្មភាពសរុប | **១១៣** | **៦២** | **៣១** |

---

[1] ផ្នែទី៣÷ សគ.៧ ពុំទទួលបានព័ត៌មាន

[2] ផ្នែកទី៤÷ សគ៨ ពុំអនុវត្ត

[3] ផ្នែកទី១ មានសូចនាករចំនួន ៣ ពុំទទួលបានព័ត៌មានពេញលេញ។

[4] ផ្នែកទី៣ មានសូចនាករចំនួន ៥ ពុំទទួលបានព័ត៌មានពេញលេញ។

[5] ផ្នែកទី៤ មានសូចនាករចំនួន ៤ ពុំទទួលបានព័ត៌មានពេញលេញ។

[6] ផ្នែកទី៥ មានសូចនាករចំនួន ៣ ពុំទទួលបានព័ត៌មានពេញលេញ។

៦. អង្គភាពក្រោមឱវាទ កសហវ. បានគ្រោងសកម្មភាពសរុបចំនួន ២៦៧ ដោយក្នុងនោះសកម្មភាពសម្រេចបានតាមគោលដៅមានចំនួន ២១០ (៧៨,៦៥%) និងពុំសម្រេចតាមគោលដៅមានចំនួន ៥៧ (២១,៣៥%)។ រីឯក្រសួង-ស្ថាប័នបានគ្រោងសកម្មភាពសរុបចំនួន ៧៧៩ ដោយក្នុងនោះសកម្មភាពសម្រេចបានតាមគោលដៅមានចំនួន ៦០២ (៧៧,២៧%) និងពុំសម្រេចតាមគោលដៅមានចំនួន ១៧៧ (២២,៧៣%)។

### ផ្នែកទី១ "ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា"

៧. ការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ (Fiscal policy) ÷ ភាពជឿទុកចិត្តនៃថវិកានៅតែរក្សាភាពធន់ដោយបន្តពង្រឹងការគ្រប់គ្រងការប្រមូលចំណូល (តាមរយៈទំនើបកម្មរដ្ឋបាលចំណូល និងគោលនយោបាយពន្ធ) និងការពង្រឹងលើប្រសិទ្ធភាពចំណាយ។

៨. ចំពោះការពង្រឹងការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូលថវិការដ្ឋឆ្នាំ២០២១ (ចំណូលចរន្ត+ មូលធនក្នុងប្រទេស) សម្រេចបាន ២២ ១៥៥ ២០៨ លានរៀល ឬស្មើនឹង ១០៤,៤៩% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះចំណូលចរន្តសម្រេចបាន ២២ ០៩៨ ៣២៦ លានរៀល ឬស្មើ ១០៥,៣២% នៃច្បាប់ហិរញ្ញវត្ថុ និងចំណូលមូលធនក្នុងប្រទេសសម្រេចបាន ៥៦ ៨៨២ លានរៀល ឬស្មើ ២៥,៧១% នៃច្បាប់ហិរញ្ញវត្ថុ។

៩. ចំពោះចំណូលសារពើពន្ធថ្នាក់ជាតិសម្រេចបាន ១៨ ៣៨០ ០៧៤ លានរៀល ឬស្មើ ១០៤,៩១% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះអគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) សម្រេចបាន ៩ ២៣៩ ០៥៣ លានរៀល ឬស្មើ ១១៥,១៤%នៃច្បាប់ហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (អ.គ.រ.) សម្រេចបាន ៩ ១៤១ ០២១ លានរៀល ឬស្មើ ៩៦,២៦% នៃច្បាប់ហិរញ្ញវត្ថុ។

១០. ការប្រមូលចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិសម្រេចបាន ១ ៧២១ ៨៧២ លានរៀល ឬស្មើ ៧៨,៧៧%នៃច្បាប់ហិរញ្ញវត្ថុ។

១១. ចំណែកការអនុវត្តចំណូលថវិកាថ្នាក់រដ្ឋបាលរាជធានី-ខេត្ត[7] សម្រេចបាន ១ ៩៩៦ ៣៨០ លានរៀល ឬស្មើនឹង ១៥៦,៣៨% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះចំណូលសារពើពន្ធសម្រេចបាន ១ ៧៦៧ ១៨៧លានរៀល ឬស្មើនឹង ១៦៨,២៥% នៃច្បាប់ហិរញ្ញវត្ថុ និងចំណូលមិនមែនសារពើពន្ធសម្រេចបាន ២២៩ ១៩៣ លាន-រៀល ឬស្មើនឹង ១០១,២៧% នៃច្បាប់ហិរញ្ញវត្ថុ។

១២. ការអនុវត្តថវិការដ្ឋសរុបឆ្នាំ២០២១ (ទិន្នន័យបណ្តោះអាសន្ន) សម្រេចបាន ២៧ ៤២៥ ០៥៧ លានរៀល ឬស្មើ ៩៥,៣៦% នៃច្បាប់ហិរញ្ញវត្ថុ (ប្រសិនបើធៀបនឹងថវិកាបន្ទាប់ពីធ្វើវិចារណកម្មចំណាយការអនុវត្តថវិកាឆ្នាំ២០២១ សម្រេចបាន ៩៨,៧៩%)។ រីឯការចំណាយប្រចាំឆ្នាំ ចាប់ពីត្រីមាសទី២ ដល់ត្រីមាសទី៤ មានភាពយឺតយ៉ាវជាងគោលដៅ ដែលបានកំណត់ក្នុងកម្មវិធីកែទម្រង់ (គោលដៅ ត.ម ១=១៥%, ត.ម ២=៤៥%, ត.ម ៣=៦៧% និង ត.ម ៤=៩៦%)។ ចំណែកឯចំណាយថវិកាតាមប្រភេទ (គោលដៅកំណត់មិនត្រូវតិចជាង ៩៨% សម្រាប់បៀវត្ស ៩៥% សម្រាប់ទំនិញ/សេវា និង ៨៥% សម្រាប់មូលធន) សម្រេចបាន (១) បៀវត្សសម្រេចបាន ៩៦,០៦%

[7] តួលេខចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិខាងលើ ជាតួលេខថវិការាជធានី-ខេត្ត និងខណ្ឌ។

នៃច្បាប់ហិរញ្ញវត្ថុ, ទំនិញ/សេវា សម្រេចបាន ៩៥,១៨%នៃច្បាប់ហិរញ្ញវត្ថុ(ប៉ុន្តែបើធៀបនឹងថវិកាក្រោយវិចារណកម្ម ចំណាយសម្រេចបាន ១០៦,៦១%) និងចំណាយមូលធនសម្រេចបាន ៩២,២៤% នៃច្បាប់ហិរញ្ញវត្ថុ។

### ផ្នែកទី២ "ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"

១៣. គម្រោង FMIS ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តជំហានទី១ នៅឆ្នាំ២០១៤ និងជំហានទី២ នៅឆ្នាំ២០១៧។ មុខងារស្នូល និងចំណាត់ថ្នាក់ថវិកាត្រូវបានដាក់បញ្ចូលក្នុងប្រព័ន្ធ FMIS ជាបន្តបន្ទាប់ស្របតាមជំហានយុទ្ធសាស្ត្រនៃប្រព័ន្ធ។ គ្រប់ក្រសួង-ស្ថាប័ន, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត និងរតនាគាររាជធានី-ខេត្ត ត្រូវបានដាក់ឱ្យប្រើប្រាស់ FMIS។ ឆ្នាំ២០២១ មានអ្នកប្រើប្រាស់សរុបប្រមាណ ១ ៩៤២នាក់ និងការដ្ឋានចំនួន ១៣១។ ផែនការពង្រីកការអនុវត្តគម្រោង FMIS ជំហានទី៣ ឆ្នាំ២០២១-២០២៥ មានវិសាលភាពគ្របដណ្តប់ការពង្រីកការអនុវត្ត មុខងារស្នូលទៅរដ្ឋបាលរាជធានី-ខេត្តទាំង២៥, មន្ទីរជំនាញអាទិភាពនៅទូទាំងប្រទេស, អង្គភាពថវិកាអាណាប័ក ផ្ទេរសិទ្ធិពេញលេញនៅថ្នាក់កណ្តាល រួមទាំងថ្នាក់មូលដ្ឋានថ្មីៗបន្ថែមទៀត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល, ការពង្រីកការអនុវត្តមុខងាររៀបចំផែនការថវិកា និងមុខងារពាក់ព័ន្ធនឹងកិច្ចលទ្ធកម្ម និងការគ្រប់គ្រងកិច្ចសន្យា ទៅគ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពនៅថ្នាក់មូលដ្ឋាន, និងការគិតគូររៀបចំ និងអភិវឌ្ឍបន្ថែមលើមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងគ្រប់គ្រងសន្និធិនៅក្នុងប្រព័ន្ធ FMIS។

១៤. មុខងារថ្មីចំនួនពីរ រួមមាន មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញត្រូវបានដាក់ឱ្យអនុវត្តសាកល្បង នៅឆ្នាំ២០២១។ មុខងាររៀបចំផែនការថវិកាត្រូវបានដាក់ឱ្យអនុវត្តនៅ កសហវ., និងក្រសួងកិច្ចការនារី រីឯមុខងារលទ្ធកម្មពេញលេញត្រូវបានដាក់ឱ្យអនុវត្តនៅ កសហវ., ក្រសួងកិច្ចការនារី និងក្រសួងព័ត៌មាន។

១៥. នីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS លើការទូទាត់ចំណាយបៀវត្ស និងចំណាយទូទាត់ត្រង់ ដែលមានហានិភ័យ ក្នុងកម្រិតទី១ ត្រូវបានដាក់ឲ្យអនុវត្តជាផ្លូវការនៅក្រសួង-ស្ថាប័នចំនួន ២៧ ហើយក្រសួង-ស្ថាប័នចំនួន ១០ ផ្សេងទៀត ដែលមាននីតិវិធីដោយឡែក ត្រូវបានសិក្សាអំពីនីតិវិធីរួចរាល់ និងដាក់របាយការណ៍សិក្សាឆ្លងការសម្រេច ក្នុងកម្រិតថ្នាក់ដឹកនាំ FMWG។ ដោយឡែក នីតិវិធីធានាចំណាយ និងទូទាត់ចំណាយផ្សេងទៀតត្រូវបានធ្វើការសិក្សា និងរៀបចំសេចក្តីព្រាងលំហូរនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS នៅក្នុងក្របខណ្ឌ កសហវ. រួចរាល់។

១៦. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS) ត្រូវបានផ្តួចផ្តើមឡើងចាប់ពីឆ្នាំ២០១៦ មក ក្នុងគោលបំណងត្រួតពិនិត្យ តាមដាន កត់ត្រា និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមក្រសួង-ស្ថាប័ន, អង្គភាពប្រើប្រាស់ និងអង្គភាពកាន់កាប់ទ្រព្យសម្បត្តិរដ្ឋឱ្យមានប្រសិទ្ធភាពខ្ពស់។ នៅឆ្នាំ២០២១ ក្រសួង-ស្ថាប័នត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ SARMIS ប៉ុន្តែមិនទាន់រលូននៅឡើយដោយធនធានមនុស្ស និងសម្ភារៈ នៅមានកម្រិត។

### ផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"

១៧. ការអនុវត្តថវិកាកម្មវិធីត្រូវបានដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័នចាប់ពីឆ្នាំ២០១៥-២០១៨ និងគ្រប់រដ្ឋបាលរាជធានី-ខេត្ត ឆ្នាំ២០១៧-២០២១។

១៨. នៅឆ្នាំ២០២១ អង្គភាពថវិកាមានចំនួនសរុប ៩២៦ ដែលក្នុងនោះរដ្ឋបាលថ្នាក់កណ្តាលមានចំនួន ៣២៣ និងថ្នាក់មូលដ្ឋាន (មន្ទីរជំនាញរាជធានី-ខេត្ត) ចំនួន ៦០៣។ សម្រាប់ថ្នាក់កណ្តាល អង្គភាពថវិកាចំនួន ៣២៣ ក្នុងនោះ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិមានចំនួន ៨៣ និងមិនទាន់ផ្ទេរសិទ្ធិ ២៤០ និងសម្រាប់ថ្នាក់មូលដ្ឋានគ្រប់អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិចំនួន ៦០៣។ ទន្ទឹមនេះ, ក្រសួង-ស្ថាប័នចំនួន ៣ បាននិងកំពុងរៀបចំបង្កើតអង្គភាពថវិកាក្នុងនោះរួមមាន៖ ក្រសួងមហាផ្ទៃ, ក្រសួងមុខងារសាធារណៈ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ សម្រាប់ ថ្នាក់ក្រោមជាតិ៖ រដ្ឋបាលរាជធានី-ខេត្ត មានតែមួយអង្គភាពថវិកានៃរដ្ឋបាលរាជធានី-ខេត្តនីមួយៗ ហើយខណ្ឌ ដែលចំណុះឱ្យរដ្ឋបាលរាជធានីភ្នំពេញ នឹងត្រូវបង្កើតជាអង្គភាពថវិកា ដោយហេតុថាខណ្ឌចំណុះរដ្ឋបាលរាជធានី ភ្នំពេញមានទាំងធនធានហិរញ្ញវត្ថុ និងមនុស្សគ្រប់គ្រាន់។

១៩. ផ្អែកលើឯកសារ MTBF ចំណាយចរន្ត និងចំណាយមូលធនត្រូវបានធ្វើសមាហរណកម្មថវិកាចូលក្នុងកម្មវិធីផ្អែកលើពិតានថវិកាសម្រាប់ថវិកាកម្មវិធីនៅក្រសួងចំនួន ៤ រួមមាន៖ ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងសាធារណការ និងដឹកជញ្ជូន, ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងអប់រំ យុវជន និងកីឡា។ កម្មវិធីផ្អែកលើពិតានថវិកាអនុវត្តពេញលេញ ហើយក្រសួងចំនួន ៥ ទៀត បាននិងកំពុងអនុវត្តសាកល្បងរួមមាន៖ ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងមហាផ្ទៃ, ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២០. គម្លាតនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ មានភាពប្រសើរឡើងដោយក្នុងឆ្នាំ ២០២១ នេះ គឺមានគម្លាតត្រឹមតែ ៩,៨% ប៉ុណ្ណោះ។ រីឯការតម្រឹមផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិ រវាងរដ្ឋបាលរាជធានី-ខេត្ត ជាមួយនឹងថវិកាមន្ទីរជំនាញ ក៏កំពុងមានវឌ្ឍនភាព ប៉ុន្តែគុណភាព និងភាពទាន់ពេលវេលា ចាំបាច់ត្រូវពង្រឹងបន្ថែមទៀត។

២១. បន្ថែមពីនេះ, ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជនត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្ត បន្ទាប់មកនឹងឈានទៅរៀបចំបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិរួម (SOP) សម្រាប់រៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP ត្រូវបាននិងកំពុងរៀបចំ។ SOP នេះមានចំនួន ៣ ភាគ ក្នុងនោះ **ភាគ១** អំពីគោលនយោបាយនិងនីតិវិធី SOP, **ភាគ២** អំពីគោលការណ៍ណែនាំចំនួន៧ និង**ភាគ ៣** អំពីនីតិវិធីកិច្ចលទ្ធកម្ម។

## ផ្នែកទី៤ "ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់"

២២. ក្នុងផ្នែកការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់, គសហវ. បានបញ្ចប់ការរៀបចំលិខិតបទដ្ឋានគតិយុត្តិសំខាន់ៗរួមមាន៖

២៣. **ការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)**៖ គណៈកម្មាធិការពិនិត្យសេចក្តីព្រាងបឋមនៃវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) សម្រេចបាន ០២ ជំពូក, សរុប ៤៦ មាត្រា និងប្រជុំក្រុមការងារបច្ចេកទេស ទី១ ពិនិត្យសេចក្តីព្រាងបឋម សម្រេចបាន ០៤ ជំពូក, សរុប ៨៨ មាត្រា។ កាលបរិច្ឆេទបញ្ចប់ការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ត្រូវកែសម្រួលកាលបរិច្ឆេទកំណត់ ដោយនឹងត្រូវបញ្ជូនទៅគណៈរដ្ឋមន្ត្រីពិនិត្យ និងអនុម័តនៅត្រីមាសទី៣ ឆ្នាំ២០២២ និងបញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិនៅត្រីមាសទី៤ ឆ្នាំ២០២២។

២៤. ការកែសម្រួលអនុក្រឹត្យលេខ ៨១ អនក្រ.បក÷ បានបញ្ចប់ការពិភាក្សាត្រឹមកម្រិតអគ្គនាយកដ្ឋានថវិកា (អ.ថ) និងបានបញ្ជូនទៅជំនាញការបារាំង ដើម្បីផ្តល់ធាតុចូល និងត្រៀមពិភាក្សាអន្តរអគ្គនាយកដ្ឋាន និងដាក់បញ្ចូលជាមួយសេចក្តីព្រាងកែសម្រួលអនុក្រឹត្យលេខ ៨២ អនក្រ.បក។ ការកែសម្រួលអនុក្រឹត្យលេខ ៨២ អនក្រ.បក÷ បានពិនិត្យ និងកែសម្រួលឡើងវិញជាបណ្តើរៗ លើសេចក្តីព្រាងអនុក្រឹត្យលេខ៨២ អនក្រ.បក ដោយផ្អែកលើស្មារតីនៃកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំលើសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)។ អនុក្រឹត្យទាំងពីរនឹងត្រូវរួមបញ្ចូលគ្នានៅត្រីមាសទី៣ ឆ្នាំ២០២២ ហើយគ្រោងនឹងដាក់ជូនថ្នាក់ដឹកនាំ កសហវ. នៅត្រីមាសទី៤ ឆ្នាំ ២០២២ ព្រមទាំងបញ្ជូនទៅគណៈរដ្ឋមន្ត្រីនៅត្រីមាសទី១ ឆ្នាំ២០២៣។

### ផ្នែកទី៥ “ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព”

២៥. ការលើកកម្ពស់ការចូលរួមកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលឆ្លុះបញ្ចាំងតាមរយៈការរៀបចំផែនការសកម្មភាពលម្អិត (GDAP3/MAP3) និងរាយការណ៍អំពីវឌ្ឍនភាពជាប្រចាំបង្ហាញអំពីឆន្ទៈ ការចូលរួម និងការទទួលខុសត្រូវក្នុងការងារកែទម្រង់។ ក្នុងន័យនេះ ការពង្រឹងយន្តការផ្ទៃក្នុងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង-ស្ថាប័ន រួមមានទាំងអង្គភាពក្រោមឱវាទ កសហវ. គឺចាំបាច់ត្រូវពង្រឹងការ-សម្របសម្រួល និងត្រួតពិនិត្យតាមដានបន្ថែម។

២៦. ប្រព័ន្ធលើកទឹកចិត្តសម្រាប់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷ មូលនិធិ PFMRP ឆ្នាំ២០២១ នេះ ត្រូវបានផ្តល់ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ន ចំនួន ៣៥០ រូប ឬស្មើនឹងទឹកប្រាក់សរុបប្រមាណ ២ ៥២៦ លានរៀល និងចំពោះការផ្តល់ប្រាក់ឧបត្ថម្ភមុខងារជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃអង្គភាពក្រោមឱវាទ កសហវ. មានចំនួន ៤៨៩ នាក់ ស្មើនឹងទឹកប្រាក់ សរុបប្រមាណ ៤ ៩១០ លានរៀល, និងមន្ទីរ សហវ. រាជធានី-ខេត្ត ៥០ នាក់ ស្មើនឹងទឹកប្រាក់សរុបប្រមាណ ៣១៥ លានរៀល។

២៧. ផែនការយុទ្ធសាស្ត្រកសាង និងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ត្រូវបានអនុម័តដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** តាមចំណារចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២១ លើលិខិតលេខ ៣៨៣ សហវ/អគហ។ ទន្ទឹមនឹងនេះ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (វសហ.) បានបញ្ចប់ការរៀបចំឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំបទដ្ឋានគតិយុត្ត ដែលជាឧបករណ៍សម្រាប់កំណត់គុណវុឌ្ឍិមន្ត្រីដែលនឹងកាន់មុខងារ ឬទទួលបន្ទុកការងារលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

### ការផ្តល់យោបល់របស់ដៃគូអភិវឌ្ឍន៍

– *លទ្ធផលបឋមនៃការវាយតម្លៃចំណាយសាធារណៈ*

២៨. អ.គ.ហ. បានសហការជាមួយធនាគារពិភពលោក ធ្វើការវាយតម្លៃចំណាយសារធារណៈទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះធនាគារពិភពលោកបានបញ្ចប់ការរៀបចំរបាយការណ៍បឋមចំណាយសា-ធារណៈ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលខេត្តព្រះសីហនុ។

២៩. **លទ្ធផលវាយតម្លៃចំណាយសាធារណៈ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ÷** លទ្ធផលបឋមជារួមបានបង្ហាញថា មានចំណុចចំនួន ៥ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវការពង្រឹងបន្ថែម ក្នុងនោះរួមមាន÷ ការពង្រឹងការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រថវិកាជាមួយថវិកាប្រចាំឆ្នាំ, ការពង្រឹងការចូលរួមក្នុងការកំណត់អាទិភាព ថវិកាវិនិយោគដោយការសម្របសម្រួលកាន់តែទូលាយ ក្នុងវិស័យពាក់ព័ន្ធនឹងគម្រោងវិនិយោគហិរញ្ញ-ប្បទានពីប្រភពខាងក្រៅ, ការធ្វើសាមញ្ញកម្ម និងទំនើបកម្មម៉ាទ្រីសសមិទ្ធកម្ម, ការពង្រឹងការធានាចំណាយ និងផែនការ សម្រាប់កិច្ចលទ្ធកម្មឱ្យទាន់ពេលវេលា, និងការពង្រឹងក្របខណ្ឌត្រួតពិនិត្យ។

៣០. **លទ្ធផលវាយតម្លៃចំណាយសាធារណៈនៅខេត្តព្រះសីហនុ÷** លទ្ធផលបឋមនៃការវាយតម្លៃបានបង្ហាញថា នៅរដ្ឋបាលខេត្ត សមត្ថភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ នៅមានកម្រិត, មានគម្លាតខ្ពស់រវាងការអនុវត្តថវិកា និងផែនការ (ការព្យាករចំណូលទាបធៀបនឹងការអនុវត្ត និងសំណើបន្ថែមឥណទានថវិកាមានកម្រិតខ្ពស់), សំណើសម្រាប់ការបន្ថែមឥណទានថវិកាមានភាពយឺតយ៉ាវ, ដំណើការធានាចំណាយ និងកិច្ចលទ្ធកម្មត្រូវការពេលវេលាយូរ, និងដំណើរការរៀបចំការទទួលទំនិញ និងការទូទាត់ត្រូវការរយៈពេលយូរ។ សម្រាប់រដ្ឋបាលក្រុងស្រុក÷ ការផ្ទេរមុខងារចំនួន ៥៥ មុខងារ ទៅរដ្ឋបាលក្រុង ស្រុក ប៉ុន្តែ រដ្ឋបាលក្រុង ស្រុក ទទួលបានថវិកាតិចបំផុត និងមិនមានការផ្ទេរថវិកា ទៅតាមមុខងារទាំង ៥៥។ សម្រាប់រដ្ឋបាលឃុំ សង្កាត់÷ សមត្ថភាពមន្ត្រីបច្ចេកទេសនៅមានកម្រិត ដែលនាំឱ្យមានការពន្យារពេលក្នុងការរៀបចំឯកសារគម្រោង, តម្លាភាព និងដំណើរការកិច្ចលទ្ធកម្ម។

៣១. លទ្ធផលខាងលើជាលទ្ធផលបឋមប៉ុណ្ណោះធនាគារពិភពលោកនឹងសហការបន្ថែមទៀតជាមួយ អ.គ.ហ. ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងរដ្ឋបាលខេត្តព្រះសីហនុ ដើម្បីពិភាក្សា និងធ្វើសុពលភាពបន្ថែមទៅលើរបកគំហើញខាងលើនេះ។

– *លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS*

៣២. អ.គ.ហ. បានសហការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ធ្វើការវាយម្លៃការអនុវត្តប្រព័ន្ធ FMIS ជំហានទី១ ជំហានទី២ ដើម្បីឆ្លុះបញ្ចាំងក្នុងជំហានទី៣។ លទ្ធផលបឋមជារួមបង្ហាញថា ផែនការពង្រីកប្រព័ន្ធ FMIS ជំហានទី១ និងជំហានទី២ ទទួលបានជោគជ័យ។ មុខងារនៃប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់ ប៉ុន្តែពុំទាន់ត្រូវបានអនុវត្តពេញលេញនៅឡើយ ជាពិសេសការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីប្រព័ន្ធ FMIS។ របាយការណ៍របស់ IMF បានផ្តល់ជាអនុសាសន៍តម្រង់ទិស ដើម្បីពង្រឹងការអនុវត្តឱ្យបានពេញលេញនូវមុខងារនៃប្រព័ន្ធ FMIS, ការតម្រង់ទិសនីតិវិធីអនុវត្តការងារ (Business Process Streamlining), ការផលិតរបាយការណ៍, ការធ្វើសន្ធានកម្មជាមួយប្រព័ន្ធផ្សេងៗ, និងការពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងការផ្លាស់ប្តូរ។

### ◆ បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

– *លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ*

៣៣. ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានប្រើប្រាស់ក្របខណ្ឌ PEFA ដែលធ្លាប់បានប្រើប្រាស់សម្រាប់ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈចំនួន៣ លើករួចមកហើយគឺនៅឆ្នាំ២០១០, ២០១៥ និងឆ្នាំ២០២១។

៣៤. បច្ច័យលើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ គឺធ្វើការប្រៀបធៀបលើលទ្ធផលទាំង ៣ លើក និងទាញការសន្និដ្ឋានលើលទ្ធផលវាយតម្លៃជាកម្រិតម៉ាក្រូ ក្នុងនោះរួមមាន÷ (១)វិន័យថវិកា, (២)ប្រសិទ្ធភាពវិភាជន៍ថវិកា និង (៣) ស័ក្តិសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ។

៣៥. របកគំហើញពីការវាយតម្លៃ PEFA ឆ្នាំ២០២១ ដែលប្រើប្រាស់ក្របខណ្ឌ PEFA ឆ្នាំ២០១១ បង្ហាញថាមានការកែលម្អក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងពិន្ទុ នៃសូចនាករសមិទ្ធកម្ម (PIs) ចំនួន ១០ ក្នុងនោះរួមមាន ÷ PI-2, PI-6, PI-7, PI-10, PI-13, PI-14, PI-19, PI-21, PI-23 និង PI-25 រីឯ PI-3 ទទួលបានពិន្ទុទាបដោយសារមានគម្លាតខ្ពស់រវាងផែនការ និងលទ្ធផលប្រមូលចំណូលចាប់ពីឆ្នាំ២០១៧, ២០១៨ និង២០១៩។ អ.គ.ហ. បាននិងកំពុងរៀបចំក្របខណ្ឌវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង-ស្ថាប័ន (កំពុងស្ថិតក្នុងសេចក្តីព្រាង) ដោយនឹងសាកល្បងវាយតម្លៃនៅឆ្នាំ២០២២ នេះ។

– *លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិ*

៣៦. អ.គ.ហ. បានរៀបចំសេចក្តីព្រាងបឋម និងប្រជុំពិគ្រោះយោបល់នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ ដោយប្រើប្រាស់ទិន្នន័យ ឆ្នាំ២០១៦, ២០១៧, និង២០១៨។ អ.គ.ហ. បានធ្វើបច្ចុប្បន្នភាពរបាយការណ៍ដោយប្រើប្រាស់ទិន្នន័យឆ្នាំ២០១៨, ២០១៩ និង២០២១ ស្របតាមក្របខ័ណ្ឌគោលការណ៍វាយតម្លៃ PEFA ថ្នាក់ក្រោមជាតិឆ្នាំ២០២០។ របាយការណ៍នេះ ត្រូវបានរៀបចំជាសេចក្តីព្រាង និងបានផ្ញើជូនសមាជិកក្រុមការងារ, ដៃគូអភិវឌ្ឍន៍ និងលេខាធិការដ្ឋានPEFA ដើម្បីពិនិត្យ និងផ្តល់យោបល់ ។ បច្ចុប្បន្ន, អ.គ.ហ. បាននិងកំពុងកែសម្រួលដែលទទួលបានធាតុចូលបន្ថែមពីគ្រប់អង្គភាព និងគ្រោងបញ្ចប់ក្នុងត្រីមាសទី១ ឆ្នាំ២០២២ នេះ។

៣៧. ផ្អែកលើលទ្ធផលនៃការវាយតម្លៃ និងត្រួតពិនិត្យនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២១, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) ធ្វើការវាយតម្លៃ និងសន្និដ្ឋានជារួមនៃការអនុវត្តគ្រប់ផ្នែក នៃផែនការសកម្មភាពរួម ដំណាក់កាលទី៣ បូក ២ ដូចខាងក្រោម។

៣៨. **ថវិកានៅតែមានភាពជឿទុកចិត្ត** គឺនៅតែរក្សាបានជាសារវន្តដោយរក្សាបាននូវភាពរឹងមាំនៃការប្រមូលចំណូល, អនុបាតបំណុលសាធារណៈនៅមានកម្រិតទាប, លុបបំបាត់ចំណាយកកស្ទះ និងការអនុវត្តថវិកាខិតទៅរកគោលដៅ។

៣៩. **បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពហិរញ្ញវត្ថុ** ត្រូវបាននិងកំពុងកសាង និងបន្តពង្រឹងបន្ថែម ដើម្បីធានាគណនេយ្យភាព និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង តាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS, ការជំរុញការអនុវត្តនីតិវិធីការងារថ្មីតាមប្រព័ន្ធ និងបង្កើនកម្រិតស្វ័យប្រវត្តិកម្ម និងសុក្រឹតភាពនៃការផលិតរបាយការណ៍ និងភាពទាន់ពេលនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងត្រូវបានពង្រឹង និងពង្រីកវិសាលភាព ទាំងក្នុងទិដ្ឋភាពនៃការអនុវត្តចំណាត់ថ្នាក់ថវិកា និងក្នុងទិដ្ឋភាពនៃការគ្របដណ្តប់លើស្ថាប័ន និងភ្នាក់ងារចំណាយរបស់រាជរដ្ឋាភិបាល ឱ្យស្របតាមស្តង់ដាអន្តរជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងថវិកា និងលំហូរសាច់ប្រាក់។

៤០. **ក្របខណ្ឌថវិកាកម្មវិធី** ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្តទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយការរៀបចំ និងអនុវត្តសាកល្បងក្របខណ្ឌថវិការយៈពេលមធ្យម ដោយបញ្ចូលការកំណត់ពិតានចំណាយ និងបែងចែកធានធានថវិកាបម្រើឱ្យគោលបំណង គោលនយោបាយរបស់ក្រសួង-ស្ថាប័ន ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

៤១. **បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពសមិទ្ធកម្ម** ត្រូវបាននិងកំពុងរៀបចំជាបណ្តើរ ប៉ុន្តែស្ថិតក្នុងដំណាក់កាលបឋមនៅឡើយ។ ក្នុងន័យនេះ, បុរេលក្ខណៈសំខាន់ៗត្រូវបានកំណត់ និងបញ្ចូលក្នុងផែនការសកម្មភាពដំណាក់កាលអន្តរកាលឆ្ពោះទៅដំណាក់កាលទី៤។

៤២. **សមត្ថភាពមន្ត្រីនៅតាមក្រសួង-ស្ថាប័នក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ត្រូវបានពង្រឹងជាបណ្តើរៗព្រមទាំងកម្រិតនៃការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុមានការកើនឡើងជាលំដាប់។

៤៣. ការវាយតម្លៃ PEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានផ្តល់ជាលទ្ធផលគោល/បន្ទាត់ មូលដ្ឋាន (Baseline) អំពីស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ដើម្បីផ្តល់ជាធាតុចូលសម្រាប់រៀបចំក្របខណ្ឌផែនការសកម្មភាព តាមរយៈការកំណត់ការដ្ឋានអាទិភាព សម្រាប់ដោះស្រាយជាដំណាក់កាលៗ ដើម្បីឈានទៅសម្រេចឱ្យបានចក្ខុវិស័យនិងបេសកកម្មនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងគោលការណ៍ទាំង៣ រួមមាន÷ បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ ទាំងក្នុងផ្នែកប្រតិបត្តិការ, និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

# ១. សេចក្តីផ្តើម

## ១.១. និន្នាការទូទៅ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃ ព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ក្នុងគោលបំណងកែប្រែជាជំហានៗ នូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅ ឧត្តមានុវត្តន៍អន្តរជាតិ ដោយប្រកាន់យកអភិក្រមជាខឿន និងបែងចែកជា ៤ ដំណាក់កាល។

២. **ដំណាក់កាលទី១ "ភាពជឿទុកចិត្តនៃថវិកា"** ដែលអនុវត្តចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០០៨ បានបញ្ចប់នូវស្ថានភាពកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ មកជាអតិរេកសាច់ប្រាក់ តាមរយៈការលុបបំបាត់ទាំងស្រុងនូវបំណុលកកស្ទះ នៅរតនាគារជាតិដែលជាហេតុធ្វើឱ្យរាជរដ្ឋាភិបាលកម្ពុជាដោះស្រាយបាននូវការបើកប្រាក់បៀវត្សទៀងទាត់ និងទាន់ពេលវេលាជូនមន្ត្រីរាជការ។ ការបង្កើតគណនីទោលនៅរតនាគារជាតិ ដែលជាការប្រមូលផ្តុំគណនីទាំងអស់របស់រាជរដ្ឋាភិបាលបានក្លាយជាមូលដ្ឋានដ៏សំខាន់សម្រាប់បោះជំហានទៅរកដំណាក់កាលទី២។

៣. **ដំណាក់កាលទី២ "បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ"** ដែលត្រូវបានអនុវត្តពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥ ដោយមានការកែលម្អជាច្រើនលើនីតិវិធីអនុវត្តថវិកា ជាពិសេសការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មីព្រមទាំងការដាក់ឱ្យដំណើរការនូវប្រព័ន្ធ FMIS។

៤. **ដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៦ រហូតដល់ឆ្នាំ២០២០ ក្នុងគោលបំណងផ្លាស់ប្តូរជាបណ្តើរៗ នូវប្រព័ន្ធគ្រប់គ្រងដែលផ្អែកលើធាតុចូល និងមជ្ឈការឆ្ពោះទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ តាមរយៈការពង្រឹង និងពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការអនុវត្តថវិកាកម្មវិធី និងការអនុវត្តអង្គភាពថវិកា រួមទាំងការអនុវត្តដំណាក់កាលទី១ និងទី២ កន្លងមក។ ដំណាក់កាលទី៣នេះត្រូវបានពន្យារពេលពីរឆ្នាំ ដើម្បីបញ្ចប់ការងារសេសសល់ចាប់តាំងពីដំណាក់កាលទី១, ទី២ និងទី៣។ ដំណាក់កាលអន្តរកាលឆ្ពោះទៅដំណាក់កាលទី៤ មានគោលដៅសំខាន់ឆ្ពោះទៅកសាងនូវលក្ខខណ្ឌចាំបាច់ទាំងឡាយដើម្បីឈានទៅដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័តិមានសមិទ្ធកម្មដែលជាគន្លឹះក្នុងការកសាង"**វប្បធម៌សមិទ្ធកម្ម**" ក្នុងក្របខណ្ឌរាជរដ្ឋាភិបាលទាំងមូល។ ផែនការសកម្មភាពរួម៣បូក២ មានរយៈពេលពីរឆ្នាំ (ឆ្នាំ២០២១-២០២២) ហើយត្រូវបានរៀបចំដោយពិនិត្យឡើងវិញនូវរចនាសម្ព័ន្ធនៃផែនការសកម្មភាពរួមដំណាក់កាលទី៣ ទាំងគោលបំណង និងចង្កោមសកម្មភាព ព្រមទាំងផ្លាស់ប្តូរពីការផ្តោតលើសកម្មភាពមកជាសមិទ្ធកម្មគន្លឹះសម្រាប់ជាមូលដ្ឋានក្នុងការកសាងនូវផែនការសកម្មភាពរួមដំណាក់កាលទី៤ នៅក្នុងឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧។

៥. **ដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម"** គ្រោងអនុវត្តចាប់ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៧។ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានកំណត់ទិសដៅកែទម្រង់ប្រព័ន្ធថវិកាឆ្ពោះទៅប្រព័ន្ធថវិកាសមិទ្ធកម្មក្នុងម៉ូដែលជា "**ថវិកាព័តិមានសមិទ្ធកម្ម**"។ យុទ្ធសាស្ត្រនេះ បានរក្សាទុកគោលបំណងដើមនៃការអនុវត្តថវិកាកម្មវិធីពេញលេញ មានន័យថាប្រើប្រាស់កម្មវិធីជាឧបករណ៍ដើម្បីផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយឱ្យបាននៅឆ្នាំ២០២០ ហើយបន្ទាប់ពីនោះ នឹងចាប់ផ្តើមឈានទៅអនុវត្តថវិកាសមិទ្ធកម្មចាប់ពីឆ្នាំ២០២២ តទៅ

ដោយពង្រឹងជាបណ្តើរៗនូវព័ត៌មានសមិទ្ធកម្ម/លទ្ធផល និងគណនេយ្យភាព ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការត្រៀមខ្លួនសម្រាប់អនុវត្តថវិកាសមិទ្ធកម្មពេញលេញនៅឆ្នាំ២០២៥។

តារាងទី 1 ÷ ការប្រែប្រួលក្របខណ្ឌផែនការសកម្មភាពរួមដំណាក់កាលទី២, ៣ និង ៣បូក២

| វេចនាសម្ព័ន្ធ CAP | CAP2 | CAP2 New | CAP3 2016-2020 | CAP3 2017-2020 | CAP3 2018-2020 | CAP 3+2 (2021) |
|---|---|---|---|---|---|---|
| ផ្នែក | ៣ | ៤ | ៥ | ៥ | ៥ | ៥ |
| គោលបំណង | ១៤ | ១៦ | ២១ | ២១ | ២១ | ១៩ |
| ចង្កោមសកម្មភាព | ៦២ | ៧១ | ៦៨ | ៦៩ | ៦៨ | ៥៩ |

## ១.២. ស្ថានភាពសេដ្ឋកិច្ច

៦. បន្ទាប់ពីកំណើនសេដ្ឋកិច្ចរឹងមាំជាប់ៗគ្នាជាង ២ទសវត្សរ៍, កម្ពុជាបានចាកចេញពីប្រទេសចំណូលទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបកាលពីឆ្នាំ២០១៥ និងត្រូវបានប្រសិទ្ធិនាមថាជា "**ខ្លាសេដ្ឋកិច្ចថ្មីមួយនៅអាស៊ី**" ក្នុងឆ្នាំ២០១៦។ សមិទ្ធផលពីកំណើនសេដ្ឋកិច្ចជាមធ្យមក្នុងរង្វង់ ៧% ក្នុង ១ឆ្នាំ បានចែកផ្លែផ្កាជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធ តាមរយៈការដំឡើងប្រាក់បៀវត្សជាប្រចាំឆ្នាំ ព្រមទាំងប្រជាពលរដ្ឋទូទៅតាមរយៈការបង្កើតការងារ និងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត។

៧. សេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០២០ មានកំណើនអវិជ្ជមាន -៣,១% ដោយសារឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩ ដែលបានបណ្តាលឱ្យវិស័យជំរុញកំណើនសំខាន់ៗទទួលរងផលប៉ះពាល់គួរឱ្យកត់សម្គាល់ក្នុងនោះរួមមាន÷ អនុវិស័យសណ្ឋាគារ និងភោជនីយដ្ឋាន, អនុវិស័យកាត់ដេរ, អនុវិស័យលក់ដុំ និងលក់រាយ, អនុវិស័យសំណង់ និងអចលនទ្រព្យ និងអនុវិស័យដឹកជញ្ជូន។ លើមូលដ្ឋាននេះ, ផ.ស.ស. សម្រាប់មនុស្សម្នាក់ បានធ្លាក់ចុះមកនៅត្រឹម ១ ៦០៤ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២០ ពី ១ ៧០០ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩។ ទន្ទឹមនេះ, អតិផរណាជាមធ្យម បានកើនឡើងមកក្នុងអត្រា ២,៩% ក្នុងឆ្នាំ២០២០ ពីអត្រា ១,៩% ក្នុងឆ្នាំ២០១៩ ស្របពេលដែលអត្រាប្តូរប្រាក់ស្ថិត ក្នុងកម្រិត ៤ ០៨០ រៀល ក្នុងមួយដុល្លារអាមេរិកក្នុងឆ្នាំ២០២០។

៨. សេដ្ឋកិច្ចកម្ពុជាឆ្នាំ២០២១ រំពឹងថាមានកំណើន ៣,០% រីឯអតិផរណាជាមធ្យមក្នុងអត្រា ២,៩% និងអត្រាប្តូរប្រាក់រក្សាបានក្នុងកម្រិត ៤ ០៦៨ រៀល។

តារាងទី 2 ÷ សូចនាករសេដ្ឋកិច្ច ឆ្នាំ២០១៦-២០២១

| សូចនាករសេដ្ឋកិច្ច | 2016 | 2017 | 2018 | 2019 | 2020 ប. | 2021 ប. |
|---|---|---|---|---|---|---|
| **ផសស ថ្លៃបច្ចុប្បន្ន (លានដុល្លារអាមេរិក)** | ២០ ០៣០ | ២២ ២០៨ | ២៤ ៦១០ | ២៧ ១៣០ | ២៥ ៩៤៥ | ២៧ ២៧៩ |
| **ផលិតផលពិតក្នុងស្រុកសរុប (កំណើនជា%)** | ៦,៩ | ៧,០ | ៧,៥ | ៧,១ | -៣,១ | ៣,០ |
| វិស័យកសិកម្ម | ១,៣ | ១,៧ | ១,១ | -០,៥ | ០,៦ | ១,១ |
| វិស័យឧស្សាហកម្ម | ១០,៦ | ៩,៧ | ១១,៦ | ១១,៣ | -១,៤ | ៧,៤ |
| វិស័យសេវាកម្ម | ៦,៨ | ៧,០ | ៦,៨ | ៦,២ | -៦,៥ | -០,៤ |

| សូចនាករសេដ្ឋកិច្ច | 2016 | 2017 | 2018 | 2019 | 2020 ប. | 2021 ប. |
|---|---|---|---|---|---|---|
| ផសស សម្រាប់ម្នាក់ (ដុល្លារអាមេរិក) | ១ ៣០៨ | ១ ៤៣០ | ១ ៥៦៣ | ១ ៧០០ | ១ ៦០៤ | ១ ៦៦៥ |
| អតិផរណាជាប្រាក់រៀល (កំណើនមធ្យមប្រចាំឆ្នាំជា %) | ៣,០ | ២,៩ | ២,៥ | ១,៨ | ២,៩ | ២,៩ |
| អត្រាប្តូរប្រាក់ (រៀល/ដុល្លារ) | ៤ ០៥៦ | ៤ ០៤៥ | ៤ ០៤៥ | ៤ ០៥៥ | ៤ ០៨០ | ៤ ០៦៨ |
| សមតុល្យគណនីចរន្ត (% នៃ ផសស) (រួមបញ្ចូលបង្វែរ) | -៨,៧ | -៨,១ | -១១,៨ | -១៥,០ | -៨,៥ | -៣៨,៦ |
| ទុនបម្រុងអន្តរជាតិ (ចំនួនខែនៃការនាំចូលទំនិញ និងសេវា) | ៦,៦ | ៨,០ | ៨,០ | ៨,៨ | ១៣,៤ | ៨,០ |

*ប្រភព៖ អ.គ.ប នៃ កសហវ.*

៩. ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺបានរួមចំណែកស្តារ និងកសាងភាពធន់សេដ្ឋកិច្ច និងរក្សាលំនឹងជីវភាពប្រជាពលរដ្ឋ ដែលត្រូវបានរងផលប៉ះពាល់ធ្ងន់ធ្ងរដោយជំងឺកូវីដ-១៩។ រាជរដ្ឋាភិបាលកម្ពុជានឹងជំរុញការអនុវត្ត "ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣" ដោយឈរលើសសរស្តម្ភចំនួន ៣ (ឬហៅថា 3Rs) ដូចតទៅ៖

១០. **សសរស្តម្ភទី១-ការស្តារ (Recovery)** តាមរយៈការកសាងមូលដ្ឋានរឹងមាំ សម្រាប់ជំរុញសេដ្ឋកិច្ចឱ្យវិលទៅស្ថិតលើមាគ៌ានៃកំណើនឡើងវិញ ដោយផ្តោតលើការធានាសុវត្ថិភាព, ការគ្រប់គ្រងផលប៉ះពាល់, ការរក្សាលំនឹង និងការធ្វើឱ្យរស់រវើកឡើងវិញនូវធុរកិច្ចដែលមានសក្តានុពល ជាពិសេស ក្នុងវិស័យដែលទទួលរងផលប៉ះពាល់ខ្លាំង និងការបង្កើតការងារបន្ថែមឱ្យបានច្រើន និងឆាប់រហ័ស សំដៅលើកស្ទួយជីវភាពប្រជាជន។

១១. **សសរស្តម្ភទី២-ការកែទម្រង់ (Reform)** តាមរយៈការបន្តដាក់ចេញនូវវិធានការកែទម្រង់សំខាន់ៗជារចនាសម្ព័ន្ធ ដែលរួមមានជាអាទិ៍៖ ការធ្វើឱ្យប្រសើរឡើងនូវបរិយាកាស និងកិច្ចសម្រួលពាណិជ្ជកម្មសម្រាប់ការវិនិយោគ និងធុរកិច្ច, ការជំរុញ និងការអភិវឌ្ឍឌីជីថលូបនីយកម្មក្នុងប្រព័ន្ធសេដ្ឋកិច្ច ទាំងវិស័យសាធារណៈ និងវិស័យឯកជន ។

១២. **សសរស្តម្ភទី៣-ការកសាងភាពធន់ (Resilience)** តាមរយៈការពង្រឹងការត្រៀមខ្លួន ដើម្បីឆ្លើយតបទៅនឹងជំងឺ ឬស្ថានភាពស្រដៀងគ្នា ដែលអាចផ្ទុះឡើងនាពេលអនាគត ដោយផ្តោតលើការអភិវឌ្ឍប្រព័ន្ធសុខាភិបាល និងប្រព័ន្ធគាំពារសង្គមដែលរឹងមាំ និងមានប្រសិទ្ធភាពដូចជា ផ្តោតលើវិស័យគន្លឹះមួយចំនួនទៀតដែលមានសារៈសំខាន់សម្រាប់ការធានានូវចីរភាព បរិយាប័ន្ន នៃការស្តារ និងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។

## ១.៣. ស្ថានភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១៣. ខណៈកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាប ក្នុងទិដ្ឋភាពហិរញ្ញវត្ថុកម្ពុជាជួបប្រទះបញ្ហាប្រឈមសំខាន់ រួមមាន៖ (១) ការថយចុះហិរញ្ញប្បទានឥណទានសំណង/ឥណទានសម្បទានធៀបនឹង ផ.ស.ស. សម្រាប់គម្រោងវិនិយោគ, (២) ការកើនឡើងបន្ទុកបុគ្គលិក និង (៣) ការបង្កើនចំណាយវិនិយោគ ដើម្បីគាំទ្រសេដ្ឋកិច្ច ខណៈដែលមូលដ្ឋានគតិយុត្តត្រូវបាននិងកំពុងរៀបចំ និងដាក់ឱ្យអនុវត្តជាបណ្តើរៗ។

១៤. ចំពោះការពង្រឹងការគ្រប់គ្រង និងអនុវត្តផែនការប្រមូលចំណូលថវិការដ្ឋ[8] ឆ្នាំ២០២១ (ទិន្នន័យបណ្តោះអាសន្ន គិតត្រឹមថ្ងៃ៣១ ខែមករា ឆ្នាំ២០២២) សម្រេចបាន ២២ ១៥៥ ២០៨ លានរៀល ឬស្មើនឹង ១០៤,៤៩% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះចំណូលចរន្តសម្រេចបាន ២២ ០៩៨ ៣២៦ លានរៀល ឬស្មើ ១០៥,៣២% នៃច្បាប់ហិរញ្ញវត្ថុ និងចំណូលមូលធនក្នុងប្រទេសសម្រេចបាន ៥៦ ៨៨២ លានរៀល ឬស្មើ ២៥,៧១% នៃច្បាប់ហិរញ្ញវត្ថុ។

១៥. ចំពោះចំណូលសារពើពន្ធថ្នាក់ជាតិសម្រេចបាន ១៨ ៣៨០ ០៧៤ លានរៀល ឬស្មើ ១០៤,៩១% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះអគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) សម្រេចបាន ៩ ២៣៩ ០៥៣ លានរៀល ឬស្មើ ១១៥,១៤% នៃច្បាប់ហិរញ្ញវត្ថុ និង អ.គ.រ. សម្រេចបាន ៩ ១៤១ ០២១ លានរៀល ឬស្មើ ៩៦,២៦% នៃច្បាប់ហិរញ្ញវត្ថុ។

១៦. ការប្រមូលចំណូលមិនមែនសារពើពន្ធថ្នាក់ជាតិសម្រេចបាន ១ ៧២១ ៨៧២ លានរៀល ឬស្មើ ៧៨,៧៧% នៃច្បាប់ហិរញ្ញវត្ថុ។

១៧. ចំណែកការអនុវត្តចំណូលថវិកាថ្នាក់រដ្ឋបាលរាជធានី-ខេត្ត[9] សម្រេចបាន ១ ៩៩ ៣៨០ លានរៀល ឬស្មើនឹង ១៥៦,៣៨% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះ ចំណូលសារពើពន្ធសម្រេចបាន ១ ៧៦៧ ១៨៧លានរៀល ឬស្មើនឹង ១៦៨,២៥% នៃច្បាប់ហិរញ្ញវត្ថុ និងចំណូលមិនមែនសារពើពន្ធសម្រេចបាន ២២៩ ១៩៣ លានរៀល ឬស្មើនឹង ១០១,២៧% នៃច្បាប់ហិរញ្ញវត្ថុ។

ដ្យាក្រាមទី 1 ÷ ការអនុវត្តផែនការប្រមូលចំណូលឆ្នាំ២០១៣-២០២១







*ប្រភព÷ អ.វ.ជ (តួលេខឆ្នាំ២០២១ គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២)*

១៨. ដ្យាក្រាមទី២ បង្ហាញអំពីការអនុវត្តថវិការដ្ឋសរុបឆ្នាំ២០២១ (ទិន្នន័យបណ្តោះអាសន្នគិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២) សម្រេចបាន ២៧ ៤២៥ ០៥៧ លានរៀល ឬស្មើ ៩៥,៣៦% នៃច្បាប់ហិរញ្ញវត្ថុ (ប្រសិនបើធៀបនឹងថវិកាបន្ទាប់ពីធ្វើវិចារណកម្មចំណាយការអនុវត្តថវិកាឆ្នាំ២០២១ សម្រេចបាន ៩៨,៧៩%)។ រីឯការចំណាយប្រចាំត្រីមាស មានភាពយឺតជាងគោលដៅ ដែលបានកំណត់ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គោលដៅ ត.ម ១ =១៥%, ត.ម ២= ៤៥%, ត.ម ៣= ៦៧% និង ត.ម ៤= ៩៦%)។ ចំណែកឯ, ចំណាយថវិកាតាមប្រភេទ (គោលដៅកំណត់មិនត្រូវតិចជាង ៩៨% សម្រាប់បៀវត្ស ៩៥% សម្រាប់ទំនិញ/សេវា និង៨៥% សម្រាប់មូលធន) សម្រេចបាន (១) បៀវត្សសម្រេចបាន ៩៦,០៦% នៃច្បាប់ហិរញ្ញវត្ថុ, ទំនិញ/សេវា សម្រេច

---

[8] ចំណូលចរន្ត+ មូលធនក្នុងប្រទេស

[9] តួលេខចំណូលថវិការដ្ឋបាលថ្នាក់ក្រោមជាតិខាងលើ ជាតួលេខថវិការាជធានី-ខេត្ត និងខណ្ឌ

បាន ៩៥,១៨% នៃច្បាប់ហិរញ្ញវត្ថុ (ប៉ុន្តែបើធៀបនឹងថវិកាក្រោយវិចារណកម្មចំណាយសម្រេចបាន ១០៦,៦១%) និងចំណាយមូលធនសម្រេចបាន ៩២,២៥% នៃច្បាប់ហិរញ្ញវត្ថុ។

ដ្យាក្រាមទី 2 ÷ ការអនុវត្តថវិការដ្ឋឆ្នាំ២០១៣-២០២១







*ប្រភព÷ អ.វ.ជ (គិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២)*

## ១.៤. សនិដ្ឋានកម្ម និងគោលបំណង

១៩. ការរៀបចំរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២១ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣បូក២ គឺជាធាតុចូលសំខាន់ដើម្បីត្រៀមរៀបចំក្របខណ្ឌផែនការសកម្មភាពរួម ដំណាក់កាលទី៤។

- របាយការណ៍នេះ ត្រូវបានរៀបចំតាមវិធីសាស្ត្រដូចខាងក្រោម÷
- វឌ្ឍនភាពនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ការតាមដានវឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស ក្នុងឆ្នាំ២០២១[10]
- ការអនុវត្តផែនការសកម្មភាពរួមដំណាក់កាលទី៣ បូក២
- ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីបទពិសោធន៍ថវិកាកម្មវិធីសម្រាប់ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់-ក្រោមជាតិ
- ការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷ លទ្ធផលបឋមនៃការត្រួតពិនិត្យលើប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FIMS) ដោយ IMF និងលទ្ធផលបឋមនៃការត្រួតពិនិត្យចំណាយសាធារណៈ ដោយធនាគារពិភពលោក។

## ២. លទ្ធផលវាយតម្លៃកម្មវិធីកែទម្រង់ និងវឌ្ឍនភាពប្រចាំឆ្នាំ២០២១

២០. គិតចាប់ពីឆ្នាំ២០០៤ រហូតដល់ឆ្នាំ២០២១, ចំណាយសម្រាប់អនុវត្ត PFMRP សរុប មានទំហំ ៣៥២ ៣២៩ លានរៀល ឬ ៨៧,២១ លានដុល្លារសហរដ្ឋអាមេរិក ក្នុងនោះចំណាយលើក្រុមការងារគ្រប់គ្រងគម្រោង FMIS ចំនួន

---

[10] ក្នុងសេចក្តីសម្រេចនេះ គ.ហ.ស ជ្រើសរើសពីគ្រប់ផ្នែកសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣។

៤៧,២៤%, អង្គភាពក្រោមឱវាទ កសហវ. ចំនួន ៣១,៧៨%, ក្រសួង-ស្ថាប័នចំនួន ៤,៣៤%, មន្ទីរសហវ. រាជធានី-ខេត្តចំនួន ០,៣៤%, និងប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ១៦,៥៨%។ បើគិតចំណាយតាមប្រភេទវិញ ចំណាយលើទំនិញនិងការអភិវឌ្ឍប្រព័ន្ធ FMIS ចំនួន ៣៨,៣៣%, ទីប្រឹក្សាចំនួន ២១,៧៩%, បណ្តុះបណ្តាល/សិក្ខាសាលា ចំនួន ២១,៨៥%, ប្រតិបត្តិការចំនួន ១,៥៥%, និងប្រាក់ឧបត្ថម្ភលើកទឹកចិត្តចំនួន ១៦,៥៨%។

ដ្យាក្រាមទី 3 ÷ ចំណាយថវិកាតាមអង្គភាពគាំទ្រ PFMRP ឆ្នាំ២០០៤-២០២១




ដ្យាក្រាមទី 4 ÷ ចំណាយថវិកាតាមប្រភេទគាំទ្រ PFMRP ឆ្នាំ២០០៤-២០២១




## ២.១. ការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី៣ ប្លុក២

### ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា

២១. ផ្នែកនេះ ផ្តោតលើគោលបំណងចំនួន ៣ រួមមាន (១) បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល (២) ពង្រឹងការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយនិង (៣) កែលម្អដំណើរការនៃការអនុវត្តថវិកា។

***គោលបំណង១១ ÷ បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល***

២២. ក្នុងក្របខណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការប្រមូលចំណូលនៅតែមានភាពរឹងមាំ។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨, ចំណូលចរន្តមានកំណើនជាមធ្យមប្រមាណ ១,៤ ពិន្ទុភាគរយនៃ ផ.ស.ស. ក្នុងមួយឆ្នាំ ខ្ពស់ជាងគោលដៅ ០,៥ ពិន្ទុភាគរយនៃ ផ.ស.ស. ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រ។ យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ មានគោលបំណងធ្វើទំនើបភាវូបនីយកម្មរដ្ឋបាល និងគោលនយោបាយចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ ដើម្បីធានាការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់, កែលម្អបរិយាកាសវិនិយោគ, និងតម្រង់ទិសការវិនិយោគ, ពង្រឹងភាពប្រកួតប្រជែង និងជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ។

២៣. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួន២ ហើយសម្រេចបានដូចតទៅ÷

| **សូចនាករសមិទ្ធកម្មគន្លឹះ** | **លទ្ធផលគោល** | **គោលដៅ និងលទ្ធផលសម្រេចបាន** | |
|---|---|---|---|
| | | **គោលដៅឆ្នាំ២០២១** | **លទ្ធផលសម្រេចបាន** |
| *សគ ១. ភាគរយនៃការអនុវត្តចំណូលថវិកាធៀបនឹងច្បាប់ថវិកា* | នៅឆ្នាំ២០១៩ ចំណូលចរន្តសម្រេចបាន ១៣០,៥ % ធៀបនឹងច្បាប់ថវិកា | ការអនុវត្តចំណូលចរន្តសម្រេចបានក្នុងរង្វង់ +/-៥% ធៀបនឹងច្បាប់ថវិកាជារៀងរាល់ឆ្នាំ | ១០៤,៩៩% នៃច្បាប់ថវិកា |
| *សគ ២. កំណើនចំណូលចរន្តធៀបនឹង ផ.ស.ស.* | នៅឆ្នាំ២០១៩ ចំណូលចរន្តកើន ៣,០១ ពិន្ទុភាគរយនៃ ផ.ស.ស. ជាមធ្យម ឆ្នាំ ២០១៤-២០១៨ | យ៉ាងតិច ០,៣ ពិន្ទុភាគរយនៃ ផ.ស.ស | -២,៦៨ ពិន្ទុភាគរយ នៃ ផ.ស.ស. |

២៤. ដោយឡែក សូចនាករសមិទ្ធកម្មគន្លឹះកម្រិតចង្កោមសកម្មភាព ដែលគាំទ្រដល់ការសម្រេចបានសូចនាករកម្រិតគោលបំណង សម្រេចបានដូចខាងក្រោម។

២៥. ***ទី១. ផ្នែកសារពើពន្ធ÷*** ភាគរយនៃអ្នកជាប់ពន្ធបង់ប្រាក់ពន្ធទាន់ពេលវេលាសម្រេចបាន ៧៨% នៃអ្នកជាប់ពន្ធសរុបដោយឡែកបណ្តឹងតវ៉ានៃករណីកំណត់ពន្ធឡើងវិញចំនួន ១ ៨៥២ ករណី ត្រូវបានដោះស្រាយដែលស្មើនឹងប្រមាណ ៧៩,៧៩% ធៀបនឹងបណ្តឹងតវ៉ាសរុបចំនួន ២ ៣២១ ករណី។ បំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២០ មានចំនួន ៦ ៣១០ ០៣៩ ០៦៥ ១៤៨ រៀល។ ការប្រមូលបំណុលពន្ធក្នុងឆ្នាំ២០២១ សម្រេចបានចំនួន ១ ០៨៧ ០៥៧ ៦៩៣ ៧៣៦ រៀល ស្មើនឹងប្រមាណ ១៧,២៣% នៃបំណុលពន្ធដែលអាចប្រមូលបានក្នុងឆ្នាំ២០២០។ ចំពោះការចាត់ថ្នាក់បំណុលពន្ធដែល "អាចប្រមូលបាន" និង "មិនអាចប្រមូលបាន" ត្រូវបានកំណត់ដូចតទៅ÷ បំណុលពន្ធក្នុងបញ្ជីអាចប្រមូលបាន (អាយុកាលតិចជាង ៣ឆ្នាំ) មានចំនួន ៣ ៥៧០ សហគ្រាស និងមានប្រាក់បំណុលពន្ធចំនួន ៦ ២១៥ ៥៦១ លានរៀល ខណៈដែលបំណុលពន្ធក្នុងបញ្ជីមិនអាចប្រមូលបាន (អាយុកាលលើស ៣ឆ្នាំ) មានចំនួន ៤ ៩៣៤ សហគ្រាស និងមានប្រាក់បំណុលពន្ធចំនួន ៩ ១៥៧ ១៩២ លានរៀល។ ក្នុងន័យនេះ, ព័ត៌មានបំណុលពន្ធរបស់អ្នកជាប់ពន្ធត្រូវបានបញ្ចូល និងធ្វើបច្ចុប្បន្នភាពក្នុងប្រព័ន្ធសម្រាប់ការគ្រប់គ្រងបំណុលពន្ធបានចំនួន ៥ ៩២៧ សហគ្រាស ស្មើនឹង ៧៧,១៧% (សហគ្រាសត្រូវបញ្ចូលក្នុងប្រព័ន្ធ

មានចំនួន ៧ ៦៨០)។ ចំពោះការបង្កើនចំនួនសមាជិកក្រុមធុរជនល្អបំផុតក្នុងឆ្នាំ២០២១ ត្រូវបានគ្រោងបន្ថែមចំនួន ៥ ប៉ុន្តែសម្រេចបានត្រឹមតែ ៣ ដែលសរុប ៤៣។ រីឯ ឆ្នាំ២០២១នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចូលរួម អនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ដែលសរុបមានក្រសួង-ស្ថាប័នចំនួន ៦ ចូលរួមអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ ដំណាក់កាលទី ២។

២៦. ***<u>ទី២. ផ្នែកចំណូលមិនមែនសារពើពន្ធ÷</u>*** បំណុលមិនមែនសារពើពន្ធបានកើនឡើងចំនួន ៥,៩១% ដែលមានទំហំទឹកប្រាក់សរុបប្រមាណ ៥៥ លានដុល្លារអាមេរិក ដោយហេតុថា (១).បំណុលអាកាសចរស៊ីវិលចំនួន ៤ ០១៥ ១៣៧ ដុល្លារអាមេរិក ជាបំណុលភុំរ៉ែរបស់ក្រុមហ៊ុនអាកាសចរណ៍ President Airline ចំនួន ២ ០២០ ៤៧២ ដុល្លារអាមេរិក និង Royal Phnom Penh Airways ចំនួន ១ ៣៦០ ៨៥៨ ដុល្លារអាមេរិក និងបំណុលចាស់របស់ក្រុមហ៊ុនតូចៗ មួយចំនួន (បំណុលភុំរ៉ែ), (២).បំណុលវិស័យរ៉ែ (ក្រុមការងារទារបំណុលអន្តរក្រសួង) កើនឡើងដោយសារក្រសួងរ៉ែ និងថាមពលបានស្នើសុំតឹងទារបំណុលរបស់ក្រុមហ៊ុន ស៊ីខ្វី (ខេមបូឌា) ដែលជំពាក់ចំនួន ៤ ៥១១ ០២០,៨៣ ដុល្លារអាមេរិក និងបំណុលក្រុមការងារបានរកឃើញថ្មី និងចាត់វិធានការក្រុមហ៊ុនចំនួន ៤ នៅតំបន់ភ្នំធំ ស្រុកបាធាយ ខេត្តកំពង់ចាម និង (៣). បំណុលសម្បទាននេសាទ និង (៤). បំណុលពីភាស៊ីមានការកើនឡើងខ្លាំង ដោយសារមិនមានការទូទាត់សងបំណុលចាស់ និងបំណុលចរន្តឆ្នាំ២០២១ កើនឡើងដោយសារអាជីវកម្មនេះមិនបានអនុវត្ត ស្របតាមការដេញថ្លៃបាន ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ ដោយឡែក, បំណុលវិស័យប្រៃសណីយ៍ ថយចុះប្រមាណ ១៣,០៨% ដោយសារក្រសួងសាមីបានចាត់វិធានការតឹងទារបំណុលដល់ក្រុមហ៊ុនប្រតិបត្តិករ ដែលនៅជំពាក់បំណុលរដ្ឋ តាមរយៈវិធានការប្រកាសផ្សព្វផ្សាយជាសាធារណៈ និងដកហូតអាជ្ញាបណ្ណ ជាដើម។

២៧. **ចំនួនក្រសួង-ស្ថាប័នប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) និង e-payment**[11] ÷ ប្រព័ន្ធ NRMIS ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពប្រមូលចំណូលនៅរដ្ឋបាលថ្នាក់ជាតិ ២៣ ក្រសួង-ស្ថាប័ន មន្ទីរ អង្គភាពជំនាញរាជធានី-ខេត្ត ចំនួន ១៨ និងដាក់អនុវត្តនៅរដ្ឋបាលរាជធានី-ខេត្ត។ បន្ថែមពីនេះ ការធ្វើសន្ទានកម្មប្រព័ន្ធ FMIS និងប្រព័ន្ធ NRMIS សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបន្តជំរុញបន្ថែម ដើម្បីជៀសវាងការបង្កើតបន្ទុកការងារបន្ថែម។ E-payment ត្រូវបានប្រើប្រាស់នៅក្រសួងឧស្សាហកម្ម, វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងបរិស្ថាន, ក្រសួងទេសចរណ៍, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងរ៉ែ និងថាមពល, ក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ តាមរយៈសារាចរលេខ ០០៨ សហវ. ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ e-payment សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធដំហានទី២។ សិក្ខាសាលាផ្សព្វផ្សាយស្តីពីការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិក សម្រាប់ការបង់ចំណូលមិនមែនសារពើពន្ធ (e-payment) ជំហានទី២ ត្រូវបានរៀបចំនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១។

---

[11] សារាចរលេខ០០៨ សហវ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់ e-Payment សម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ជំហានទី២។

២៨. សេចក្ដីព្រាងច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានដាក់ឆ្លងសិក្ខាសាលាពិគ្រោះយោបល់អន្តរក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍន៍, តំណាងសង្គមស៊ីវិល និងកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ កសហវ.។ ក្រុមការងារបានបញ្ចប់កិច្ចប្រជុំពិនិត្យពិភាក្សាលើជំពូកទី១០ (ស្ដីពីទោសប្បញ្ញត្តិ) ជាមួយក្រសួងយុត្តិធម៌ និងអង្គភាពប្រឆាំងអំពើពុករលួយ។ ឯកសារគោល (blueprint) ស្ដីពីការកែទម្រង់ប្រព័ន្ធចំណូលមិនមែនសារពើពន្ធត្រូវបានរៀបចំរួចរាល់ជាភាសាអង់គ្លេស ដោយទទួលបានជំនួយបច្ចេកទេសពីធនាគារពិភពលោក ដែលបាននិងកំពុងបកប្រែជាភាសាខ្មែរ។

## *គោលបំណង ១២៖ ពង្រឹងការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ*

២៩. គោលបំណងនេះមានសូចនាករសមិទ្ធកម្ម *"សគ៣. ភាគរយនៃការអនុវត្តចំណាយធៀបនឹងច្បាប់ថវិកាប្រចាំឆ្នាំ"* មានបរិយាយវឌ្ឍនភាពលម្អិតក្នុងកថាខណ្ឌលេខ១៨។

## *គោលបំណង ១៣៖ កែលម្អដំណើរការនៃការអនុវត្តថវិកា*

៣០. យុទ្ធសាស្ត្រនៃការទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ បានកំណត់នូវទិសដៅជាយុទ្ធសាស្ត្រអាទិភាពលើការកែទម្រង់គន្លឹះៗ រួមមាន (១)ការរៀបចំ និងការអនុម័តផែនការលទ្ធកម្ម, (២) ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ, (៣) ការត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តកិច្ចលទ្ធកម្ម(សវនកម្មកិច្ចលទ្ធកម្ម), (៤) ការពង្រឹងឯករាជ្យភាពនៃយន្តការដោះស្រាយបណ្ដឹងតវ៉ា និងបង្កើតឱ្យមានរបបដាក់ទោសទណ្ឌ និង (៥) ហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ ដែលរួមមានការកែលម្អក្របខណ្ឌគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈ, ការរៀបចំសៀវភៅណែនាំស្ដីពីលទ្ធកម្មសាធារណៈ, ការសិក្សាអំពីការប្រើប្រាស់លទ្ធកម្មសាធារណៈតាមប្រព័ន្ធអេឡិចត្រូនិក និងការកសាងសមត្ថភាព។

៣១. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនបី ហើយសម្រេចបានលទ្ធផល ដូចតទៅ៖

### *សគ ៤. ភាគរយនៃផែនការលទ្ធកម្មត្រូវបានអនុម័តមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា*

**គោលដៅ**៖ ៩០% នៃផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា។

**សម្រេចបាន**៖ ក្រសួង-ស្ថាប័ន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ ដែលបានផ្ញើសេចក្ដីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ២០២១ មក កសហវ. និងត្រូវបានពិនិត្យអនុម័តពី កសហវ. (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០) មានដូចខាងក្រោម៖

- ក្រសួង-ស្ថាប័ន បានផ្ញើមកសរុបចំនួន ៥៣ ស្ថាប័ន ឬស្មើ៩៨,១៥% និងបានអនុវត្តរួចរាល់ចំនួន៤៩ ស្ថាប័ន ឬស្មើ ៩២,៤៥%
- សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល បានផ្ញើមកសរុបចំនួន ៣៨ ស្ថាប័ន ឬស្មើ ៩៤,៨៧% និងបានអនុវត្តរួចរាល់ចំនួន ២៥ ស្ថាប័ន ឬស្មើ ១០០%
- រដ្ឋបាលរាជធានី-ខេត្ត បានផ្ញើមកសរុបចំនួន ២៥ ស្ថាប័ន (១០០%) និងបានអនុម័តចំនួន ២៥ ស្ថាប័ន (១០០%)
- អង្គភាពថវិកាបានផ្ញើមកសរុបចំនួន ៦១៨ អង្គភាព ឬស្មើ៩៦,១១% និងបានអនុម័តចំនួន៥៩៣ ស្ថាប័ន ឬស្មើ ៩៥,៩៥%។

ដោយឡែក, គម្រោងផែនការលទ្ធកម្មប្រចាំឆ្នាំ២០២២ របស់ស្ថាប័នអនុវត្តលទ្ធកម្ម/អង្គភាពថវិកាចំនួន ៦៨% ប៉ុណ្ណោះ ត្រូវបានដាក់ប្រជុំចរចា និងពិនិត្យសម្រេចនៅក្នុងកិច្ចប្រជុំចរចាថវិកាក្នុងកម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន ជាមួយ កសហវ.។

*សគ ៥. ភាគរយនៃអង្គភាពថវិការបស់ក្រសួង-ស្ថាប័នផ្តល់របាយការណ៍អនុវត្តកិច្ចលទ្ធកម្ម*

**គោលដៅ÷** យ៉ាងតិច ៦០% នៃអង្គភាពថវិកាផ្តល់របាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ.។

**សម្រេចបាន÷** ក្នុងឆ្នាំ២០២០ អង្គភាពថវិកាបានផ្ញើរបាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ. មានសរុបចំនួន ៣៩១ អង្គភាព ស្មើនឹង ៦១,១៨%។

*សគ ៦. ការបោះជំហានទៅបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈរបស់ស្ថាប័នអនុវត្តលទ្ធកម្ម*

វិមជ្ឈការកិច្ចលទ្ធកម្មសាធារណៈជំហានទី១ ត្រូវបានបន្តអនុវត្ត ដោយបានបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេច ទទួលខុសត្រូវលើកិច្ចលទ្ធកម្មសាធារណៈ ជូនស្ថាប័នដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ អនុលោមតាមប្រកាសលេខ ០១០ សហវ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៩ ស្តីពីការផ្តល់កម្រិតទឹកប្រាក់សិទ្ធិសម្រេចក្នុងកិច្ចលទ្ធកម្មសាធារណៈ។

*សគ ៧. កំណើនជាភាគរយនៃការប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងលទ្ធកម្ម*

**គោលដៅ÷** យ៉ាងតិច ៦០% នៃទំហំទឹកប្រាក់ការប្រគល់កិច្ចសន្យាសរុប (លើកលែងកិច្ចសន្យារបស់ក្រសួង MPWT, MWRAM និង MRD) ដែលមានគោលការណ៍ពីរាជរដ្ឋាភិបាលចុះកិច្ចសន្យាដោយផ្ទាល់ជាមួយអង្គភាពជំនាញរបស់រដ្ឋ)។

**សម្រេចបាន÷** ក្នុងឆ្នាំ២០២០ ទំហំទឹកប្រាក់កិច្ចសន្យាសរុបប្រចាំឆ្នាំប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងលទ្ធកម្ម មានចំនួន ៦០,៦២%។

ដោយឡែក សូចនាករសមិទ្ធកម្មគន្លឹះកម្រិតចង្កោមសកម្មភាព ដែលគាំទ្រដល់ការសម្រេចបានសូចនាករកម្រិតគោលបំណងសម្រេចបានដូចតទៅ÷

៣២. គោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(PFMM) គឺមានសារៈសំខាន់ ក្នុងការបណ្តុះបណ្តាល/ណែនាំដល់ក្រសួង-ស្ថាប័ន ដើម្បីរៀបចំគោលការណ៍ណែនាំផ្ទាល់របស់ក្រសួង-ស្ថាប័ន។ ក្រុមការងារបច្ចេកទេសបាននិងកំពុងពិនិត្យ និងកែសម្រួល សេចក្តីព្រាងលើកទី៦ មុនដាក់ពិភាក្សាក្នុងសិក្ខាសាលា ពិគ្រោះយោបល់។ ការដាក់ឱ្យក្រសួង-ស្ថាប័នចំនួន ១០ រៀបចំគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុង (ជាសេចក្តីព្រាង) ពុំទាន់មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ព្រោះ PFMM របស់រាជរដ្ឋាភិបាល ត្រូវបានពន្យារពេល។ នៅឆ្នាំ២០២២ នេះ ក្រសួង-ស្ថាប័នចំនួន ១៣ នឹងត្រូវបានជ្រើសរើស ដើម្បីរៀបចំគោលការណ៍ FMM របស់ក្រសួង-ស្ថាប័នសាមី ក្នុងនោះរួមមាន÷ (១).ក្រសួងអភិវឌ្ឍន៍ជនបទ, (២). ក្រសួងធនធានទឹក និងឧតុនិយម, (៣). ក្រសួងអប់រំ យុវជន និងកីឡា, (៤).ក្រសួងសាធារណការ និងដឹកជញ្ជូន, (៥).ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, (៦). ក្រសួងសុខាភិបាល, (៧). ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, (៨). ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, (៩).ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, (១០). ក្រសួងបរិស្ថាន, (១១). ក្រសួងមុខងារសាធារណៈ, (១២). ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង (១៣). ក្រសួងយុត្តិធម៌។

៣៣. ក្នុងឆ្នាំ២០២១ ការអនុវត្តការទូទាត់ចំណាយថវិកាជាតិតាម EFT សម្រេចបានប្រមាណ ៥៨% នៃចំណាយសរុប។ កសហវ. បានសហការជាមួយធនាគារជាតិ និងធនាគារកាណាឌីយ៉ា ហើយគ្រោងពង្រីកវិសាលភាពដោយសហការជាមួយធនគារអេស៊ីលីដា។

**៣៤. ការសន្និដ្ឋានផ្នែកទី១ "ភាពជឿទុកចិត្តនៃថវិកា" គឺរក្សាបាននូវភាពរឹងមាំ ដែលឆ្លុះបញ្ចាំងអំពីភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលបានកសាងកន្លងមក។ ទោះបីជាយ៉ាងនេះក្តី ការធ្វើស្ថាបនីយកម្មយន្តការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ នៅមានលទ្ធភាពកែលម្អបន្ថែមទៀត។ ចំពោះប្រសិទ្ធភាពចំណាយថវិកា នឹងត្រូវពង្រឹងលើបៀវត្ស, ទំនិញ/សេវា និងវិនិយោគតាមរយៈការរៀបចំ និងអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដូចមានកំណត់ក្នុងយុទ្ធសាស្ត្រគន្លឹះ ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ផ្អែកលើមូលដ្ឋាននៃការកែទម្រង់ប្រព័ន្ធថវិកា និងលទ្ធផល នៃការអនុវត្តតាមសូចនាករទាំង៦,ថវិកាឆ្នាំ២០២១ បានបំពេញជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលអាចជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យផងទាំងពួង ទាំងក្នុង និងក្រៅប្រទេស ដើម្បីប្រយុទ្ធ ការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គមសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជន ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្តារនិងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ នៅក្រោយពេលស្រាកស្រាន្តពីវិបត្តិជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីធានាសុខសន្តិភាព ស្ថិរភាព សង្គម និងចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជា ជាមួយនឹងការបន្តលើកស្ទួយសុខុមាលភាពរបស់ប្រជាជន។**

## ផ្នែកទី២÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

៣៥. ផ្នែកនេះ ផ្តោតលើគោលបំណងចំនួន ៥ រួមមាន (១) ពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS, (២) ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យ ប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ថ្មី, (៣) ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (ទ្រព្យសកម្មរយៈពេលវែង), (៤) ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងហានិភ័យ នៃកាតព្វកិច្ចបំណុលយថាហេតុ និងហានិភ័យបំណុលពាក់ព័ន្ធ ប្រកបដោយចីរភាព, និង (៥) ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ។

៣៦. គម្រោង FMIS ត្រូវបានចាប់ផ្តើមដាក់អនុវត្តចាប់ពីឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ន (ជំហានទី១ ២០១៤-២០១៦ និងជំហានទី២ ២០១៧-២០២០)។ ផែនការពង្រីក FMIS ជំហានទី៣ ឆ្នាំ២០២១-២០២៥ ផ្តោតសំខាន់លើ *ការដាក់ឱ្យប្រើប្រាស់ FMIS នៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន, បន្តអនុវត្តនីតិវិធីតម្រង់ទិសសម្រាប់ការទូទាត់បៀវត្ស ទូទាត់ត្រង់ និងនីតិវិធីអនុវត្តផ្សេងៗតាមផែនការ, ការដាក់ឱ្យប្រើប្រាស់គម្រោង FMIS នៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ, ការអភិវឌ្ឍមុខងារ២ថ្មីបន្ថែមនៅក្នុងប្រព័ន្ធ FMIS (មុខងារគ្រប់គ្រងសន្និធិ និងមុខងារគ្រប់គ្រងទ្រព្យសម្បត្តិ), ការដាក់ឱ្យប្រើប្រាស់មុខងាររៀបចំផែនការថវិកាជាជំហានៗ, ការដាក់ឱ្យប្រើប្រាស់មុខងារលទ្ធកម្មជាជំហានៗ និងគោលដៅចាំបាច់ផ្សេងៗ (អភិវឌ្ឍន៍កម្មវិធីគ្រប់គ្រងអ្នកប្រើប្រាស់, បន្តការធ្វើសន្ធានកម្មជាមួយប្រព័ន្ធខាងក្រៅ, ជំរុញការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិច, ជំរុញការអនុវត្តចំណាត់ថ្នាក់ថវិកាទាំង ៧ និងជំរុញការប្រើប្រាស់របាយការណ៍ ដែលផលិតចេញពីប្រព័ន្ធ)។*

៣៧. ជាមួយគ្នានេះ ការធ្វើស្វ័យប្រវត្តិកម្មសម្រាប់ការអនុវត្តថវិកាតាមប្រព័ន្ធ FMIS តាមរយៈការអនុវត្តនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS ស្របតាម "ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ឆ្នាំ ២០២០-២០២៥" នឹងកាត់បន្ថយនីតិវិធីអនុវត្តការងារខាងក្រៅប្រព័ន្ធជាអតិបរមាស្របតាមទិសដៅវិមជ្ឈការហិរញ្ញវត្ថុ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### *គោលបំណង ២១÷ ពង្រឹង និងពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS*

៣៨. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនបី ហើយសម្រេចបានលទ្ធផលដូចតទៅ÷

#### *សត ១. ចំនួនមុខសញ្ញាចំណាយធ្វើស្វ័យប្រវត្តិកម្មសម្រាប់អនុវត្តថវិកាតាមប្រព័ន្ធ FMIS នៅរដ្ឋបាលថ្នាក់កណ្តាល*

**គោលដៅ÷** នីតិវិធីធានាចំណាយ និងទូទាត់ចំណាយផ្សេងៗកម្រិត ១ និងកម្រិត ២ ត្រូវបានដាក់ឱ្យអនុវត្តផ្លូវការនៅ កសហវ. និង ៧ ក្រសួងផ្សេងទៀត។

**សម្រេចបាន÷** នីតិវិធីធានាចំណាយ និងទូទាត់ចំណាយផ្សេងទៀតបានធ្វើការសិក្សា និងរៀបចំសេចក្តីព្រាងលំហូរនីតិវិធីអនុវត្តន៍ការងារថ្មីតាមប្រព័ន្ធ FMISដែលមានហានិភ័យកម្រិតទី១ និងកម្រិតទី២ នៅក្នុងក្របខណ្ឌ កសហវ.។ នីតិវិធី អនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS លើការទូទាត់ចំណាយបៀវត្ស និងចំណាយទូទាត់ត្រង់ ដែលមានហានិភ័យ ក្នុងកម្រិតនីមួយៗ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅតាមក្រសួង-ស្ថាប័នចំនួន ២៧ ហើយក្រសួង-ស្ថាប័ន ចំនួន ១០ ផ្សេងទៀតដែលមាន នីតិវិធីដោយឡែក ត្រូវបានសិក្សាអំពីនីតិវិធីរួចរាល់ ព្រមទាំងបានដាក់របាយការណ៍សិក្សាឆ្លងការសម្រេចក្នុងកម្រិតថ្នាក់ដឹកនាំ FMWG។ និតិវិធីធានាចំណាយ និងទូទាត់ចំណាយផ្សេងទៀតត្រូវបានធ្វើការសិក្សា និងរៀបចំសេចក្តីព្រាងលំហូរនីតិវិធីអនុវត្ត ការងារថ្មីតាមប្រព័ន្ធ FMIS ដែលមានហានិភ័យកម្រិតទី៣ នៅក្នុងក្របខណ្ឌ កសហវ.។

#### *សត ២. មុខងារពីរបន្ថែមថ្មីក្នុងប្រព័ន្ធ FMIS ត្រូវបានពង្រីកការអនុវត្ត*

៣៩. គម្រោង FMIS ជំហានទី៣ ក៏នឹងត្រូវបានដាក់ពង្រីកឱ្យប្រើប្រាស់ជាជំហានៗ លើមុខងារថ្មីពីរបន្ថែមទៀតគឺ មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញសម្រាប់ការប្រើប្រាស់នៅតាមបណ្តាក្រសួង- ស្ថាប័ន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**គោលដៅ÷** មុខងារថ្មីចំនួន២ (រៀបចំផែនការថវិកា និងលទ្ធកម្មពេញលេញ)ត្រូវបានដាក់ឱ្យសាកល្បងនៅ កសហវ. និងក្រសួងព័ត៌មាន។

**សម្រេចបាន÷** មុខងាររៀបចំផែនការថវិកាត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងនៅ កសហវ. និងក្រសួងកិច្ចការនារី និងមុខងារលទ្ធកម្មពេញលេញត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងនៅ កសហវ. ក្រសួងកិច្ចការនារី និងក្រសួងព័ត៌មាន ព្រមទាំងបានរៀបចំត្រៀមរួចរាល់សម្រាប់ការពង្រីកការប្រើប្រាស់ក្នុងឆ្នាំ២០២២ ខាងមុខដែលមាន ១១ ក្រសួងសម្រាប់មុខងាររៀបចំផែនការថវិកា និងគ្រប់ក្រសួង- ស្ថាប័នទាំងអស់សម្រាប់មុខងារលទ្ធកម្មពេញលេញ។

ក្រសួង- ស្ថាប័នចំនួន ៣៧ និងមន្ត្រីចំនួន ១០០ រូប យ៉ាងតិចទទួលបានការបណ្តុះបណ្តាល ជំនាញវិជ្ជាជីវៈលើការប្រើប្រាស់មុខងារថ្មីទាំងពីរ ហើយ អ្នកប្រើប្រាស់ចំនួន ២៥០រូប យ៉ាងតិចទទួលបានការបំប៉នសមត្ថភាព ចំណេះដឹងថ្មីៗបន្ថែម។

ការដាក់ឱ្យអនុវត្តដាក់ឱ្យអនុវត្តមុខងារនីមួយៗត្រូវគិតគូបន្ថែមលើផែនការដាក់ឱ្យអនុវត្ត ដើម្បីឱ្យក្រសួង-ស្ថាប័ន ត្រៀមខ្លួនរួចរាល់ក្នុងការអនុវត្ត និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងដាក់ឱ្យអនុវត្តនៅដើមឆ្នាំ តាមរយៈលិខិតបទដ្ឋានគតិយុត្ត។

*សគ ៣. ចំនួនការដ្ឋានអនុវត្តគម្រោង FMIS បន្ថែមថ្មី (ពង្រីកការប្រើប្រាស់មុខងារស្នូលរបស់ប្រព័ន្ធ FMIS ទៅកាន់អង្គភាពថ្នាក់ជាតិ, អង្គភាពថ្នាក់ក្រោមជាតិ, និងគ្រឹះស្ថានសាធារណៈរដ្ឋបាល)*

៤០. គម្រោង FMIS ជំហានទី៣[12] នឹងត្រូវចាប់ផ្តើមពង្រីកការដាក់ឱ្យប្រើប្រាស់នូវមុខងារស្នូលចំនួន ៤ របស់ប្រព័ន្ធ FMIS ដែលមានស្រាប់ គឺ**មុខងារវិភាជន៍ថវិកា, មុខងារគណនីត្រូវសង, មុខងារការទិញ**, និង**មុខងារគណនីត្រូវទារ** ទៅកាន់រដ្ឋបាលថ្នាក់ក្រោមជាតិ, គ្រឹះស្ថានសាធារណៈរដ្ឋបាល, មន្ទីរជំនាញ និង អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញបន្ថែមថ្មី។

**គោលដៅ**÷ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីចំនួន២ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS និងរដ្ឋបាលរាជធានី-ខេត្ត ទាំង ២៥ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS សម្រាប់ការត្រៀមដាក់ឱ្យប្រើប្រាស់នៅឆ្នាំ ២០២២។

**សម្រេចបាន**÷ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញបន្ថែមថ្មីចំនួន ២ (លេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ) បានប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការសម្រាប់ប្រតិបត្តិការឆ្នាំ២០២១។ ទន្ទឹមនេះ, រដ្ឋបាលរាជធានី-ខេត្តទាំង ២៥ ត្រូវបានប្រកាសជាផ្លូវការចូលរួមអនុវត្តគម្រោង FMIS ជំហានទី៣ ហើយឯកសារនីតិវិធីអនុវត្តការងារបច្ចុប្បន្ន និងឯកសារនីតិវិធីអនុវត្តការងារថ្មី តាមប្រព័ន្ធ FMIS សម្រាប់រដ្ឋបាលរាជធានី-ខេត្តទាំង២៥ ត្រូវបានរៀបចំរួចរាល់ ព្រមទាំងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញចំនួន ១០ ទៀត ត្រូវបានរៀបចំដំឡើងប្រព័ន្ធ FMIS សម្រាប់ការប្រើប្រាស់នៅឆ្នាំ២០២២។

## *គោលបំណង ២២÷ ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យ ប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ថ្មី*

៤១. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនពីរ ហើយសម្រេចបានដូចតទៅ÷

*សគ ៤. ភាពទាន់ពេលវេលានៃការបិទកិច្ចបញ្ជីគណនេយ្យ*

**គោលដៅ**÷ការបិទបញ្ជីគណនេយ្យក្នុងរយៈពេលពី ៦ខែ ទៅ ៩ខែ។

**សម្រេចបាន**÷ ការបិទបញ្ជីគណនេយ្យត្រូវបានប្រើប្រាស់រយៈពេល ៩ខែ ដោយហេតុថាមានការពន្យារពេលក្នុងបិទបញ្ជីការថវិការហូតដល់រយៈពេល ២-៣ខែ បន្ទាប់ពីបញ្ចប់ការិយបរិច្ឆេទថវិកា។

*សគ ៥. កម្រិតអនុលោមភាពនៃរបាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដា IPSAS Cash Basis*

**គោលដៅ**÷របាយការណ៍ហិរញ្ញវត្ថុអាចទទួលយកបានស្របតាម IPSAS Cash Basis

**សម្រេចបាន**÷របាយការណ៍ហិរញ្ញវត្ថុស្របតាម IPSAS Cash basis ត្រូវបានកែលម្អកាន់តែប្រសើរឡើងតាមរយៈការវាយតម្លៃពីជំនាញការ IMF និងនិយ័តករគណនេយ្យ និងសវនកម្ម។ សមាសធាតុសំខាន់មួយចំនួនត្រូវបានកែលម្អ

[12] សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏មិនខុសគ្នាពីក្រសួង-ស្ថាប័នដែរ គឺមិនតម្រូវឱ្យប្រើប្រាស់មុខងារសៀវភៅធំ និង មុខងារគ្រប់គ្រងសាច់ប្រាក់នោះទេ។

ដោយបានលាតត្រដាងកាន់តែលម្អិតនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុ ដោយបានដាក់បង្ហាញព័ត៌មានអំពីសាច់ប្រាក់កម្ចី ដែលមិនទាន់ប្រើប្រាស់ និងព័ត៌មានអំពីអង្គភាពថវិកាដែលរាយការណ៍ជាដើម។

សេចក្តីព្រាងយុទ្ធសាស្ត្រ នៃការអនុវត្តស្តង់ដាគណនេយ្យសាធារណៈកម្ពុជាមូលដ្ឋានបង្គរ ឆ្នាំ២០២១-២០៣១ ត្រូវបានទទួលការឯកភាពជំខ្ពង់ខ្ពស់ដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ និងកំពុងបន្តនីតិវិធីគោរពជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យនិងអនុម័ត នៅត្រីមាសទី១ ឆ្នាំ២០២២។

*សគ ៦. ភាពទាន់ពេលវេលានៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (IPSAS Cash Basis)*

**គោលដៅ**÷ របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៩ ត្រូវបានរៀបចំរួចរាល់ក្នុងត្រីមាសទី២ ឆ្នាំ២០២១។

**សម្រេចបាន**÷ សេចក្តីព្រាងបឋមច្បាប់ទូទាត់ថវិកាទូទៅរបស់រដ្ឋប្រចាំឆ្នាំត្រូវបានរៀបចំ និងផ្ញើជូនអាជ្ញាធរសវនកម្មជាតិ អំឡុងពេលធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ គឺស្ថិតក្នុងរយៈពេល ៦ ខែបន្ទាប់ពីបញ្ចប់ការបិទបញ្ជីចំណូល-ចំណាយថវិកា។

### *គោលបំណង២៣. ពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ (ទ្រព្យសកម្មរយៈពេលវែង)*

៤២. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនមួយ ហើយសម្រេចបានលទ្ធផលដូចតទៅ÷

*សគ ៧. មានរបាយការណ៍បូកសរុបទ្រព្យសម្បត្តិរដ្ឋ (Consolidation report) របស់ក្រសួង-ស្ថាប័ន, មន្ទីរអង្គភាពជំនាញថ្នាក់មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ*

**គោលដៅ**÷មានរបាយការណ៍បូកសរុបទ្រព្យសម្បត្តិរដ្ឋកម្រិតក្រសួង-ស្ថាប័ន, មន្ទីរអង្គភាពជំនាញថ្នាក់មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ

**សម្រេចបាន**÷ តារាងកើនឡើងនិងថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២០÷ អ.ទ.ច. បានទទួលបញ្ជីពី ១ ៤៧០ អង្គភាព ស្មើនឹង៨៩% (គិតត្រឹមថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១)។

ស្ថិតិបច្ចុប្បន្នភាពទីតាំងដីរដ្ឋឆ្នាំ២០២១÷ ទីតាំងដែលពុំទាន់ធ្វើប័ណ្ណកម្មសិទ្ធិចំនួន១០ ៧៩៦ កន្លែង ស្មើនឹង៣៨%។

តារាងទី3÷ ស្ថិតិការរៀបចំប័ណ្ណកម្មសិទ្ធិលើអចលនទ្រព្យរបស់រដ្ឋឆ្នាំ២០២០

| | ចំនួនអង្គភាពត្រូវធ្វើ | ចំនួនប្លង់សរុប | ចំនួនប្លង់បានធ្វើរួច | ចំនួនប្លង់ពុំទាន់បានធ្វើ | ភាគរយបានធ្វើ |
|---|---|---|---|---|---|
| ក្រសួង-ស្ថាប័ន (ថ្នាក់កណ្តាល) | ២៤៤ | ១ ៤២៨ | ៣៥៨ | ១ ០៧០ | ២៥% |
| មន្ទីរ អង្គភាពជំនាញ (ថ្នាក់មូលដ្ឋាន) | ៧៦៩ | ១១ ៦៥៧ | ៣ ៨៥១ | ៧ ៨០៦ | ៣៣% |
| រដ្ឋបាលរាជធានី-ខេត្ត | ២៥ | ២៥៩ | ១៥៨ | ១០១ | ៦១% |
| រដ្ឋបាលក្រុង ស្រុក ខណ្ឌ | ២០៣ | ៥៥៣ | ២១៣ | ៣៤០ | ៣៩% |
| រដ្ឋបាលឃុំ សង្កាត់ | ១ ៦៤៦ | ២ ៦៤២ | ១ ៧៩៣ | ៩៣៩ | ៦៤% |
| **សរុប** | **២ ៨៨៧** | **១៦ ៥៣៩** | **៦ ២៨៣** | **១០ ២៥៦** | **៣៨%** |

*ប្រភព÷ អ.ទ.ច.*

ចំពោះការរៀបចំប័ណ្ណកម្មសិទ្ធិដីធ្លីនៃទ្រព្យសម្បត្តិរដ្ឋ, អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋបានធ្វើប័ណ្ណកម្មសិទ្ធិរួចរាល់លើទីតាំងចំនួន ១៧ ៧៦៤ កន្លែង ស្មើនឹង ៦២% នៃទីតាំងសរុបចំនួន ២៨ ៥៦០ កន្លែង ចំណែកទីតាំងដែលគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីទ្រព្យសម្បត្តិរដ្ឋចំនួន ៣៨% ស្មើនឹង ១០ ៧៩៦ កន្លែង កំពុងត្រូវបានរៀបចំ និងអនុវត្តកិច្ចការទូទៅ។ ចំពោះការរៀបចំឯកសារគោលស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ នៅមិនទាន់បានរៀបចំសេចក្ដីព្រាងឯកសារទស្សនាទាននៅឡើយទេ បច្ចុប្បន្នទើបតែបង្កើតក្រុមការងារអន្តរអគ្គនាយកដ្ឋាននៃ កសហវ. ដើម្បីរៀបចំសិក្សា និងកសាងឯកសារគោលនេះ និងពិភាក្សាលើមាតិកា។

ក្នុងទិដ្ឋភាពនៃការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋប្រព័ន្ធ SARMIS ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន ប៉ុន្តែពុំទាន់ត្រូវបានអនុវត្តដោយរលូន ដោយសារជួបប្រទះកត្តាប្រឈមរួមមានសមត្ថភាព និងសម្ភារៈបច្ចេកវិទ្យាព័ត៌មាន។ អ.ទ.ច. ក្រោមការសម្របសម្រួលពី អ.គ.ហ. បានបន្តរៀបចំវគ្គបណ្ដុះបណ្ដាលបន្ថែមទៀត ដែលមានលក្ខណៈជាក់លាក់សម្រាប់ឱ្យក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិអាចអនុវត្តបានពេញលេញ។ ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពី SARMIS ជូនក្រសួង-ស្ថាប័ន មន្ទីរជំនាញរដ្ឋបាលរាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ចាប់ពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដល់ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២។ ទន្ទឹមនេះ អ.គ.ហ. នឹងពិនិត្យលទ្ធភាពថវិកាផ្គត់ផ្គង់ កុំព្យូទ័រជូនក្រសួង-ស្ថាប័ន, សាលារាជធានី-ខេត្ត និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីសម្រួល និងពង្រីកការអនុវត្តប្រព័ន្ធ SARMIS។

### *គោលបំណង ២៤៖ ពង្រឹងការគ្រប់គ្រងបំណុលសាធារណៈ រួមទាំងហានិភ័យនៃកាតព្វកិច្ចបំណុលយថាហេតុ និងហានិភ័យបំណុលពាក់ព័ន្ធ ប្រកបដោយចីរភាព*

៤៣. យុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣ ត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តនៅថ្ងៃទី ២២ ខែតុលា ឆ្នាំ២០១៩។ យុទ្ធសាស្ត្រនេះដាក់ចេញនូវវិធានការជាយុទ្ធសាស្ត្រចំនួន ១០ ហើយនៅតែបន្តអនុវត្តគោលការណ៍គន្លឹះទាំង ៥។

៤៤. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនបួន ហើយសម្រេចបានលទ្ធផលដូចតទៅ៖

#### សគ ៨. សូចនាករបំណុលគន្លឹះទាំង ៥ ធៀបទៅនឹងពិតាន

**គោលដៅ៖** សូចនាករបំណុលគន្លឹះទាំង ៥ បានត្រូវបន្តរក្សាក្រោមពិតានដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ។

**សម្រេចបាន៖** ក្នុងការគ្រប់គ្រងបំណុលសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាប្រកាន់ខ្ជាប់នូវស្មារតីប្រុងប្រយ័ត្នខ្ពស់ដោយបានអនុវត្តយ៉ាងម៉ឺងម៉ាត់នូវគោលការណ៍គន្លឹះៗទាំង ៥ ដែលមានក្នុងយុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ២០១៩-២០២៣។ ស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាមានលក្ខណៈល្អប្រសើរជាលំដាប់។ ផ្អែកតាមការវិភាគចីរភាពបំណុលបង្ហាញថាអនុបាតបំណុលទាំង ៥ របស់កម្ពុជា សុទ្ធតែស្ថិតក្រោមអនុបាតគោលទាំងអស់ ដូចមានបញ្ជាក់ក្នុងតារាងទី៣។ តាមបទដ្ឋានបច្ចេកទេសអន្តរជាតិលទ្ធផលនេះបញ្ជាក់ថាស្ថានភាពបំណុលសាធារណៈកម្ពុជាមាន “**ចីរភាព**” និង “**ហានិភ័យកម្រិតទាប**”។

តារាងទី 4 ÷ សូចនាករបំណុលសាធារណៈឆ្នាំ ២០១៨-២០២១

| សូចនាករ | អនុបាតគោល | ២០១៨ | ២០១៩ | ២០២០ | ២០២១ (ប៉ាន់ស្មាន) |
|---|---|---|---|---|---|
| តម្លៃបច្ចុប្បន្ន នៃបំណុលសាធារណៈសរុប | | | | | |
| ធៀបនឹង ផសស | ៥៥ | ២១,៤៨ | ២០,៨ | ២៤ | ២៥,១ |
| តម្លៃបច្ចុប្បន្ន នៃបំណុលសាធារណៈក្រៅប្រទេស | | | | | |
| ធៀបនឹង ផសស | ៤០ | ២១,៤៦ | ២០,៨ | ២៤,៣ | ២៥,១ |
| ធៀបនឹងចំណូល | ១៨០ | ២៨,៤ | ២៦,៧ | ៣២,៨ | ៣៧,១ |
| សេវាបំណុលសាធារណៈក្រៅប្រទេស | | | | | |
| ធៀបនឹងការនាំចេញ | ១៥ | ១,៤ | ១,៥ | ១,៨ | ២,០ |
| ធៀបនឹងចំណូល | ១៨ | ៤,៩ | ៤,៥ | ៦,៣ | ៦,២ |

*ប្រភព÷ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជាលេខ ១២ (ទំព័រលេខ១២)*

ដ្យាក្រាមទី 5 ÷ សន្និធិបំណុលសាធារណៈក្រៅប្រទេស (គិតត្រឹមឆមាសទី១ ឆ្នាំ២០២២)




*ប្រភព÷ ខ្លឹមសារសង្ខេបប្រតិបត្តិស្ដីពីសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២*

អនុក្រឹត្យស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ត្រូវបានពិនិត្យឡើងវិញដោយភ្ជាប់ជាមួយការសិក្សាពីគោលការណ៍ណែនាំជាសកល និងសិក្សាស្រាវជ្រាវបទពិសោធនៃប្រទេសនានាក្នុងតំបន់ រួមមាន ប្រទេសថៃ វៀតណាម ហ្វីលីពីន និង ឥណ្ឌូនេស៊ី។ ចំណែកឯ, ក្របខណ្ឌគោលនយោបាយបឋមស្ដីពីការអភិវឌ្ឍមូលបត្ររដ្ឋ ត្រូវបានរៀបចំ និងទទួលបានការអនុម័ត ដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល កាលពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពចាំបាច់ចំពោះមុខ របស់រាជរដ្ឋាភិបាល ក្នុងការស្ដារសេដ្ឋកិច្ចឡើងវិញពីវិបត្តិនៃជំងឺកូវីដ-១៩ ហើយផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយបឋមនេះក៏ត្រូវបានរៀបចំផងដែរ។ ទន្ទឹមនេះ សេចក្ដីព្រាងក្របខណ្ឌគោលនយោបាយរួមស្ដីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២២-២០២៨ ត្រូវបាននិងកំពុងរៀបចំ និង

គ្រោងស្នើសុំការពិនិត្យ និងអនុម័តដាក់ឱ្យប្រើប្រើប្រាស់នៅឆ្នាំ២០២២។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យពាក់ព័ន្ធនឹងកាតព្វកិច្ចបំណុលជាយថាហេតុត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តកាលពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០២១។ ជាមួយគ្នានេះ, ទំនើបកម្មឧបករណ៍វិភាគធាតុអំណោយ និងទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យរួមសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ (In-house Database for PDM) ត្រូវបានអនុម័តនិងដាក់ឱ្យអនុវត្តនៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០២១ ផងដែរ។

*សគ ៩. ហានិភ័យបំណុលត្រូវបានកំណត់*

**គោលដៅ÷**ការវិភាគហានិភ័យបំណុលពាក់ព័ន្ធ និងហានិភ័យកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវបានរៀបចំដាក់បញ្ចូលនៅក្នុងរបាយការណ៍ដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ

**សម្រេចបាន÷** អ.ស.ប បានរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រ របាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានខ្លឹមសារហានិភ័យបំណុលសាធារណៈ ដោយបង្ហាញហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ (Contingent Liabilities), ហានិភ័យថវិកា (Fiscal Risk), ហានិភ័យទីផ្សារ (Market Risk), ហានិភ័យប្រតិបត្តិការ (Operational Risk), ហានិភ័យសន្ទនីយភាពក្នុងការទូទាត់សេវាបំណុល (Liquidity Risk), ហានិភ័យហិរញ្ញប្បទាននៃគម្រោង (Project Funding Risk) និងហានិភ័យឥណទាន (Credit Risk) ប្រចាំត្រីមាសទី១, ទី២, និងទី៣ ឆ្នាំ២០២១ ព្រមទាំងផ្សព្វផ្សាយលើគេហទំព័រផ្លូវការរបស់ អ.ស.ប.។

***គោលបំណង ២៥÷ ពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាលនិងសហគ្រាសសាធារណៈ***

៤៥. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួន២ ហើយសម្រេចបានលទ្ធផលដូចទៅ÷

**សគ ១០. មានយន្តការច្បាស់លាស់ក្នុងការតាមដានគ្រឹះស្ថានសាធារណៈរដ្ឋបាល កម្រិត កសហវ.**

**គោលដៅ÷** ទី១) លក្ខណៈវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងទី២) របាយការណ៍សិក្សាអំពីវិធីសាស្ត្រវាយតម្លៃគ្រឹះស្ថានសាធារណៈកម្រិត កសហវ.។

**សម្រេចបាន÷** អ.ថ បានរៀបចំរបាយការណ៍សិក្សាលើការកំណត់លក្ខណៈវិនិច្ឆ័យអប្បរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈ។ សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល, ក្នុងចំណោមគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ២៩ មានគ្រឹះស្ថានចំនួន ២៧ ដែលបានផ្ញើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២០ មក អ.រ.ជ។ អ.រ.ជ អាចធ្វើការបូកសរុបរបាយការណ៍បញ្ចូលគ្នាបានត្រឹមតែ ២៣ គ្រឹះស្ថានសាធារណៈរដ្ឋបាលប៉ុណ្ណោះ ពីព្រោះរបាយការណ៍របស់គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ៤ ទៀត គឺតួលេខនៅពុំទាន់មានសង្គតិភាពនិងគ្រប់ជ្រុងជ្រោយនៅឡើយ។ រីឯ គ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន ២ ផ្សេងទៀត គឺនៅមិនទាន់ផ្ញើរបាយការណ៍ បើទោះបីជាមានការក្រើនរំលឹក។

*សគ ១១. មានយន្តការច្បាស់លាស់ក្នុងការតាមដានសហគ្រាសសាធារណៈកម្រិត កសហវ.*

**គោលដៅ÷** សេចក្តីព្រាងច្បាប់ស្តីពីសហគ្រាសសាធារណៈត្រូវបានដាក់ឆ្លងទីស្តីការគណៈរដ្ឋមន្ត្រីនិងអង្គនីតិបញ្ញត្តិ។

**សម្រេចបាន÷** សេចក្តីព្រាងច្បាប់ស្តីពីសហគ្រាសសាធារណៈត្រូវបានតាក់តែងជាទម្រង់ច្បាប់ និងខ្លឹមសាររួចរាល់ក្នុងកម្រិតក្រុមការងារបច្ចេកទេសនៃ កសហវ. និងរង់ចាំទទួលធាតុចូលពីទីប្រឹក្សាបច្ចេកទេសទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD) នៅត្រីមាសទី១ ឆ្នាំ២០២២។ អ.ទ.ច. គ្រោងនឹងធ្វើសិក្ខាសាលាពិគ្រោះយោបល់នាត្រីមាសទី២ ឆ្នាំ២០២២

ជាមួយសហគ្រាសសាធារណៈ, ក្រសួង-ស្ថាប័ន និងអ្នកពាក់ព័ន្ធ និងគ្រោងនឹងបញ្ជូនទៅទីស្ដីការគណៈរដ្ឋមន្ត្រីនាត្រីមាសទី៣ ឆ្នាំ២០២២។ ទន្ទឹមនេះ, ក្រុមការងារនៃ កសហវ. បាននិងកំពុងរៀបចំឯកសារយុទ្ធសាស្ត្រកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ ដែលជាផែនទីបង្ហាញផ្លូវនៃការកែទម្រង់សហគ្រាសសាធារណៈ និងជាធាតុចូលដ៏សំខាន់សម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់នេះ។

ចំពោះការងារត្រួតពិនិត្យតាមដានសហគ្រាសសាធារណៈ ក្រុមការងារបច្ចេកទេស ក៏បានរៀបចំរបាយការណ៍ស្ដីពីការវាយតម្លៃស្ថានភាពហិរញ្ញវត្ថុសហគ្រាសសាធារណៈ ដើម្បីដាក់ជូនថ្នាក់ដឹកនាំ កសហវ. ពិនិត្យ និងសម្រេច ដោយបានផ្ដោតលើចំណុចសំខាន់ៗចំនួន ៤ រួមមាន (១) ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលអាជីវកម្មសម្រាប់ការិយបរិច្ឆេទឆ្នាំ ២០២០, (២) បណ្ដាខ្ទង់ទូទាត់ជាមួយថវិការដ្ឋសម្រាប់ឆ្នាំ២០២០, (៣) ការបង់ភាគលាភចូលថវិការដ្ឋឆ្នាំ២០២០ របស់សហគ្រាសសាធារណៈ និង(៤) ស្ថានភាពមូលធន នៃក្រុមហ៊ុនចម្រុះដែលរដ្ឋមានភាគកម្មសាធារណៈជាចំនួនភាគតិចសម្រាប់ការិយបរិច្ឆេទ ឆ្នាំ២០២០។

៤៦. **ជាការសន្និដ្ឋាន សម្រាប់ផ្នែកទី២ "គណនេយ្យភាពហិរញ្ញវត្ថុ" FMIS ជាប្រព័ន្ធស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ ហើយត្រូវបានពង្រីក និងដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័ន។ ការដាក់ឱ្យអនុវត្តមុខងារថ្មីចំនួន ២ និងនីតិវិធីអនុវត្តការងារថ្មីគួរមានការគិតគូរអំពីវិសាលភាព នៃការប្រើប្រាស់មុខងារថ្មីចំនួន ២ និងការសិក្សាឱ្យបានស៊ីជម្រៅអំពីហានិភ័យនៃការដាក់ឱ្យអនុវត្តនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS។ ក្នុងន័យនេះ, ក្រុមការងារគ្រប់គ្រងគម្រោង FMIS គួរបន្តពិនិត្យ និងជំរុញការងារអាទិភាពនេះដើម្បីឱ្យស្របទៅនឹងទិសដៅប្រព័ន្ធថវិកា ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនៃកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។**

## ផ្នែកទី៣÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

៤៧. នៅក្នុងផ្នែកផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ គឺផ្ដោតលើគោលបំណងចំនួន ៥ រួមមាន÷(១) ពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី និងការត្រួតពិនិត្យថវិកា, (២) រៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា, (៣) រៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព, (៤) ពង្រឹងការរៀបចំគោលនយោបាយ និងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ និង (៥) ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ។

៤៨. យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានកំណត់ទិសដៅកែទម្រង់ប្រព័ន្ធថវិកាឆ្ពោះទៅប្រព័ន្ធថវិកាសមិទ្ធកម្មក្នុងម៉ូដែលជា "**ថវិកាព័ត៌មានសមិទ្ធកម្ម**"។ ផែនការសកម្មភាពត្រូវបានបែងចែកជាផ្នែកទាំង ៥ នេះមាន ១៥ គោលបំណង ដែលចែកជាពីរដំណាក់កាល រួមមាន÷ ដំណាក់កាលទី១ ចាប់ពីឆ្នាំ២០១៧-២០២១ ផ្ដោតលើការកសាងមូលដ្ឋានចាំបាច់សម្រាប់ការចាប់ផ្ដើមអនុវត្តថវិកាសមិទ្ធកម្ម និងដំណាក់កាលទី២ ចាប់ពីឆ្នាំ ២០២២-២០២៥ ផ្ដោតលើការអនុវត្តសាកល្បងថវិកាសមិទ្ធកម្ម។ មួយផ្នែកនៃយុទ្ធសាស្ត្រនេះ គឺអនុវត្តក្នុងផ្នែកទី៣ ដើម្បីកសាង និងបង្កើតប្រព័ន្ធថវិការយៈពេលមធ្យម ដែលផ្សារភ្ជាប់ជាមួយយុទ្ធសាស្ត្រចតុកោណ, ផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យ។

### *គោលបំណង ៣១÷ រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌហិរញ្ញវត្ថុសាធារណៈ និងថវិការយៈពេលមធ្យម*

៤៩.	គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនបី ហើយសម្រេចបានលទ្ធផលដូចទៅ៖

*សគ ១.ការដាក់ឆ្លងក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី និងអនុវត្តជាប្រចាំ*

**គោលដៅ៖** ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ ត្រូវបានរៀបចំ និងស្នើសុំការអនុម័តពីប្រមុខរាជរដ្ឋាភិបាល។

**សម្រេចបាន៖** ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ ការរៀបចំនេះ ត្រូវបានអនុលោមតាមការសម្រេចរបស់ថ្នាក់ដឹកនាំ កសហវ. ក្នុងការពន្យារពេលដាក់ឱ្យអនុវត្តនូវ MTFF ដោយសារភាពមិនប្រាកដប្រជានៃការរីករាលដាលជំងឺកូវីដ-១៩ និងផលប៉ះពាល់លើសេដ្ឋកិច្ចកម្ពុជា។ ជាមួយគ្នានេះ, អ.គ.ប. ក៏បានបន្តរៀបចំសេចក្ដីព្រាង MTFF និងបានដាក់ជូនថ្នាក់ដឹកនាំ កសហវ. ពិនិត្យ និងសម្រេច។

*សគ ២. ការអនុម័តក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) ដោយមានពិតានថវិកាតាមវិស័យតាមក្រសួង-ស្ថាប័នដោយប្រមុខរាជរដ្ឋាភិបាល*

**គោលដៅ៖** សេចក្ដីព្រាងឯកសារ MTBF ដោយមានកំណត់ពិតានថវិកាតាមវិស័យ

**សម្រេចបាន៖** ការរៀបចំឯកសារ MTBF ដោយមានកំណត់ពិតានតាមវិស័យតាម ក្រសួង-ស្ថាប័ន ត្រូវបានអនុម័ត ដោយប្រមុខរាជរដ្ឋាភិបាល។

*សគ ៣. ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំដោយមានសូចនាករសមិទ្ធកម្ម*

**គោលដៅ៖** ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំដោយមានសូចនាករសមិទ្ធកម្ម

**សម្រេចបាន៖** ក្រសួងអនុវត្តថវិកាកម្មវិធីចំនួន១៥ ត្រូវបានត្រួតពិនិត្យ និងវាយតម្លៃលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ដោយពិនិត្យឃើញដូចខាងក្រោម៖

- គោលបំណងគោលនយោបាយ៖ ការរៀបចំជាទូទៅអាចទទួលយកបាន។
- កម្មវិធី៖ ភាគច្រើនអាចទទួលយកបាន តែឈ្មោះកម្មវិធី រចនាសម្ព័ន្ធផ្ទៃក្នុងកម្មវិធី និងមុខងារកម្មវិធីរបស់ក្រសួងខ្លះតម្រូវឱ្យកែសម្រួល។
- សូចនាករ៖ នៅតែជាបញ្ហាប្រឈម ព្រោះភាគច្រើនក្រសួង-ស្ថាប័នមិនអាចញែកដាច់រវាងសូចនាករធាតុចូល សូចនាករលទ្ធផល និងសូចនាករដំណើរការ ខណៈដែលសូចនាករខ្លះមិនអាចវាស់វែងបាន។ ទោះជាយ៉ាងណា កសហវ. កំពុងសម្របសម្រួលជួយពង្រឹងបន្ថែម។
- ការគ្រោងចំណូល-ចំណាយ៖ ភាគច្រើនឆ្លុះបញ្ចាំងពីលទ្ធភាពប្រមូលចំណូលជាក់ស្ដែង តែការគ្រោងចំណាយនៅមិនទាន់គោរពបានតាម។

ផ្អែកលើ MTBF ក្រសួង-ស្ថាប័នចំនួន ០៩ ត្រូវបានធ្វើសមាហរណកម្មចំណាយចរន្ត និងចំណាយមូលធនរដ្ឋចូលក្នុងកម្មវិធីផ្អែកលើពិតានថវិកាក្នុងផែនការយុទ្ធសាស្ត្រថវិកា និងក្រសួង-ស្ថាប័នចំនួន ០៤ ត្រូវបានធ្វើសមាហរណកម្មចំណាយចរន្ត និងចំណាយមូលធនរដ្ឋចូលក្នុងកម្មវិធីផ្អែកលើពិតានថវិកាសម្រាប់ថវិកាកម្មវិធី។

### *គោលបំណង ៣២÷ ពង្រឹងការគ្រប់គ្រងវិនិយោគសាធារណៈ*

៥០. យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ ត្រូវបានប្រមុខរាជរដ្ឋាភិបាល អនុម័តកាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ និងប្រកាសដាក់ឱ្យអនុវត្ត នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្នុងគោលបំណងបង្កើតឱ្យបាននូវប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈរួមមួយរបស់ជាតិ ដែលធានាបាននូវភាពឆ្លើយតប ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងស្របតាមឧត្តមានុវត្តន៍ និងបរិការណ៍ និងពង្រឹងសមត្ថភាព ប្រកបដោយចីរភាពនៃការបែងចែក និងការប្រើប្រាស់ធនធានសាធារណៈស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ និងបរិការណ៍ជាក់ស្តែងរបស់កម្ពុជា សំដៅរួមចំណែកបង្កើនល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង ដែលជាមូលដ្ឋានគ្រឹះក្នុងការធានាបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាបន្នឆ្ពោះទៅសម្រេចបង្គោលចរឆ្នាំ២០៣០និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

៥១. យុទ្ធសាស្ត្រនេះ មានវិសាលភាពគ្របដណ្តប់លើគ្រប់គម្រោងវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន (ទាំងពីថវិកាជាតិ, ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ និងទុនវិនិយោគឯកជនតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន) និងនៅគ្រប់កម្រិតរដ្ឋបាល(ទាំងថ្នាក់ជាតិ ទាំងរដ្ឋបាលថ្នាក់ក្រោមជាតិ, គ្រឹះស្ថានសាធារណៈ រដ្ឋបាល, សហគ្រាសសាធារណៈ និងអង្គភាពសាធារណៈប្រហាក់ប្រហែល)។

៥២. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនបី ហើយសម្រេចបានលទ្ធផលដូចទៅ÷

#### *សគ ៤. ការរៀបចំយន្តការគ្រប់គ្រងវដ្តគម្រោងវិនិយោគសាធារណៈ*

**គោលដៅ÷** អនុក្រឹត្យចំនួន ១, យន្តការ ១, ប្រកាសចំនួន ៣ និងគោលការណ៍ណែនាំចំនួន ៤ ត្រូវបានអនុម័ត និងផ្សព្វផ្សាយ។

**សម្រេចបាន÷** ផ្អែកលើការអនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រស្តីពីការកែទម្រង់ការគ្រប់គ្រងវិនិយោគសាធារណៈ២០១៩-២០២៥ សូចនាករគន្លឹះដែលបានកំណត់ក្នុងគោលដៅឆ្នាំ២០២១ សម្រេចបានដូចតទៅ÷

៥៣. សេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិរួម (SOP) សម្រាប់រៀបចំ និងគ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការ PPP ត្រូវបាននិងកំពុងរៀបចំ។ SOP នេះមានចំនួន ៣ភាគ ក្នុងនោះ ភាគ១ អំពីគោលនយោបាយនិងនីតិវិធី SOP, ភាគ២ អំពីគោលការណ៍ណែនាំចំនួន៧ និងភាគ៣ អំពីនីតិវិធីកិច្ចលទ្ធកម្ម។

៥៤. យន្តការ១÷ គណៈកម្មការវិនិយោគសាធារណៈ (គ.វ.ស.) និងលេខាធិការដ្ឋានត្រូវបានបង្កើតឡើងតាមរយៈសេចក្តីប្រកាស ដែលត្រូវបានចុះហត្ថលេខាដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** នៅថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១។ រីឯការរៀបចំយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោងថវិកា គឺក្រុមការងារ ជំនាញបច្ចេកទេសសម្រាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគម្រោងវិនិយោគសាធារណៈ ត្រូវបានបង្កើតឡើងតាមរយៈប្រកាសលេខ ៧៥០ សហវ.ប្រក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០។ ជាមួយគ្នានេះ, ការបង្កើតអង្គភាព និងដំណើរការអង្គភាពគ្រប់គ្រងមូលនិធិគាំទ្រការសិក្សាសមិទ្ធិលទ្ធភាពនិងការរៀបចំគម្រោងវិនិយោគសាធារណៈ គឺនៅពុំទាន់មានវឌ្ឍនភាពនៅឡើយ។

៥៥. ប្រកាសចំនួន ៣÷ (១) សេចក្តីព្រាងបឋមប្រកាសស្តីពីនីតិវិធីប្រតិបត្តិ នៃការគ្រប់គ្រង រៀបចំ និងអនុវត្ត គម្រោងវិនិយោគសាធារណៈហិរញ្ញប្បទានដោយថវិកាថ្នាក់ជាតិ (គម្រោងវិនិយោគផ្ទាល់) បានដាក់ឱ្យពិភាក្សា ដើម្បីទទួលបានធាតុចូលសម្រាប់ រៀបចំកែលម្អ នៅកម្រិតអន្តរក្រសួង និងកម្រិតថ្នាក់ដឹកនាំ កសហវ.។(២) សេចក្តី-ព្រាង ប្រកាសស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំរួចរាល់ និងបាន រៀបចំកិច្ចប្រជុំពិភាក្សាពិគ្រោះយោបល់ដោយ មានការចូលរួមពី អង្គភាពពាក់ព័ន្ធក្រោមឱវាទ កសហវ., មន្ទីរ សហវ., ក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានី-ខេត្តទាំង២៥ ព្រមទាំងបានបញ្ជូនសេចក្តីព្រាងនីតិវិធីនេះទៅក្រសួង-មហាផ្ទៃ ដើម្បីពិនិត្យនិងផ្តល់យោបល់នៅក្នុងអំឡុងខែមីនា ឆ្នាំ២០២១។(៣) សេចក្តីព្រាងប្រកាសស្តីពីគោល-ការណ៍ រួមសម្រាប់ការគ្រប់គ្រងគម្រោងថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ត្រូវបានអនុម័ត។

៥៦. គោលការណ៍ណែនាំចំនួន ៤÷ ការរៀបចំគោលការណ៍ណែនាំគឺមានវឌ្ឍនភាពតិចតួច និងកែសម្រួលផែនការ អនុវត្ត ដោយក្នុងនោះ (១) គោលការណ៍ណែនាំសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិលនឹងត្រូវ បានរៀបចំបញ្ចប់ក្នុងឆ្នាំ២០២២, (២) គោលការណ៍ណែនាំស្តីពីការរៀបចំសំណើគម្រោង (វដ្តនៃគម្រោង វិនិយោគសាធារណៈ) នឹងត្រូវបានបញ្ចប់នៅឆ្នាំ២០២៣, (៣) គោលការណ៍ និងនីតិវិធីគ្រប់គ្រងយន្តការគាំទ្រ ហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាពនិងរៀបចំគម្រោង នឹងត្រូវបញ្ចប់នៅឆ្នាំ២០២៣ និង (៤)សេចក្តីព្រាង ទស្សនាទានគោលការណ៍និងនីតិវិធីគ្រប់គ្រងយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំ គម្រោង ត្រូវបានរៀបចំជាមួយជំនាញការ ADB។

### *គោលបំណង៣៣÷ ពង្រឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធី ដោយផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រថវិកា*

៥៧. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនបួន ហើយសម្រេចបានលទ្ធផលដូចតទៅ÷

#### *សគ ៥.ការញែកបន្ទុកបុគ្គលិកបានតាមកម្មវិធីនីមួយៗឆ្នាំ N+1*

**គោលដៅ÷** ការសិក្សាសាកល្បងញែកបន្ទុកបុគ្គលិក។

**សម្រេចបាន÷** អគ្គនាយកដ្ឋានថវិកា បានរៀបចំឯកសារទស្សនាទានស្តីពីការញែកបន្ទុកបុគ្គលិក កសហវ. បានចាប់ផ្តើមសាកល្បងញែកបន្ទុកបុគ្គលិកតាមកម្មវិធី។ ក្រសួង-ស្ថាប័នមានការលំបាកក្នុងការញែកបន្ទុកបុគ្គលិក ទៅតាមកម្មវិធី ដោយហេតុថាបច្ចុប្បន្នបន្ទុកបុគ្គលិកត្រូវបានដាក់ក្នុងកម្មវិធីគាំទ្រ ដែលចាំបាច់តម្រូវឱ្យមានការសិក្សា ច្បាស់លាស់ នៅតាមក្រសួង-ស្ថាប័ននីមួយៗ។

#### *សគ ៦.ការកាត់បន្ថយគម្លាតរវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ (N+1)*

**គោលដៅ÷** គម្លាតរវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ (N+1) ត្រូវបានរក្សាមិនឱ្យលើស ជាអតិបរមាត្រឹម ២០%។

**សម្រេចបាន÷** គម្លាតរវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ២០២១ សម្រេចបាន ៩,៨%។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័នចំនួន ១០ ត្រូវបានពិនិត្យលើការផ្សារភ្ជាប់រវាងផែនការយុទ្ធសាស្ត្រថវិកា និងយុទ្ធសាស្ត្រចតុ-កោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ហើយក៏វាយតម្លៃលើគុណភាពផែនការយុទ្ធសាស្ត្រថវិកា

របស់ក្រសួង-ស្ថាប័នចំនួន ១៥[13]។ ចំពោះគម្លាតនៃផែនការយុទ្ធសាស្ត្រថវិកា២០២១-២០២៣ និងថវិកាកម្មវិធីប្រចាំឆ្នាំ ២០២១ សម្រាប់ផ្នែកចំណាយថវិកា កសហវ. មានទំហំ ៣,១% និងក្រសួងអប់រំ យុវជន និងកីឡា មានទំហំ ៥,៣៦%។

*សគ ៧.(១) ចំនួនក្រសួង-ស្ថាប័នត្រួតពិនិត្យលក្ខណៈសម្បត្តិអង្គភាពថវិកា និង(២) ក្របខណ្ឌវាយតម្លៃអង្គភាពថវិកា*

៥៨. ក្រសួង-ស្ថាប័នមួយចំនួនក៏នៅរក្សាការគ្រប់គ្រងថវិកាតាមបែបប្រមូលផ្តុំនៅឡើយ ដោយអនុញ្ញាតឱ្យមានអង្គភាពថវិកាចំនួនតិចតួច ដែលមានន័យថាថវិកាផ្តល់ដល់អង្គភាពអនុវត្តផ្ទាល់ ក៏មានតិចតួចផងដែរ។ ក្នុងន័យនេះ ការបង្កើនចំនួនអង្គភាពថវិកា និងអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិ ជាការងារសំខាន់ ដែលចាំបាច់ត្រូវជំរុញ និងពង្រឹងសមត្ថភាពបន្ថែម។ ក្នុងទិសដៅវិមជ្ឈការហិរញ្ញវត្ថុនៅតាមក្រសួង-ស្ថាប័ន, រាជរដ្ឋាភិបាលបានដាក់ចេញអនុក្រឹត្យលេខ ២៤២ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការរៀបចំ អនុវត្តថវិកា ព្រមទាំងត្រួតពិនិត្យលទ្ធផលនៃការអនុវត្តសកម្មភាពការងារ និងថវិកា។ ទន្ទឹមនេះ, កសហវ.បានចេញប្រកាសលេខ ៥៤៤ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២១ ស្តីពីសិទ្ធិអំណាច ការទទួលខុសត្រូវ និងនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់អង្គភាពថវិកា ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ក្នុងការអនុវត្តថវិកាតាមរយៈការប្រគល់អាណត្តិកិច្ចច្បាស់លាស់ ដើម្បីសម្រេចបានសមិទ្ធកម្មការងារ។

៥៩. រីឯការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព នៃការរៀបចំ និងបង្កើតអង្គភាពថវិកា(ការត្រួតពិនិត្យនិងរៀបចំលក្ខណៈសម្បត្តិកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន និងការកសាងសមត្ថភាព) ដែលរៀបចំឡើងដោយក្រសួង-ស្ថាប័ន ពុំទាន់មានវឌ្ឍនភាពនៅឡើយ។

*សគ ៨.ចំនួនអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិត្រូវបានបង្កើតអនុលោមតាមគោលការណ៍ណែនាំរបស់កសហវ.*

***គោលដៅ÷*** ទី១)-បន្ថែមចំនួន ៣ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិថែមទៀត និងទី២)-បន្ថែម ១០ អង្គភាពថវិកា នៅតាមក្រសួង-ស្ថាប័ន

**សម្រេចបាន÷** នៅឆ្នាំ២០២១ អង្គភាពថវិកាមានចំនួនសរុប ៩២៦ ដែលកើនឡើងចំនួន ១២ អង្គភាពថវិកា(ឆ្នាំ ២០២០មានចំនួន ៩១៤) ដែលក្នុងនោះរដ្ឋបាលកណ្តាលមានចំនួន ៣២៣ (កើនឡើង១២) និងថ្នាក់មូលដ្ឋាន (មន្ទីរជំនាញរាជធានី-ខេត្ត)ចំនួន ៦០៣។ សម្រាប់ថ្នាក់កណ្តាល អង្គភាពថវិកាចំនួន ៣២៣ ក្នុងនោះ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិមានចំនួន ៨៣(ឆ្នាំ២០២០ មានចំនួន ៦១) និងមិនទាន់ផ្ទេរសិទ្ធិ ២៤០(ឆ្នាំ២០២០ មានចំនួន ២៥០) និងសម្រាប់ថ្នាក់មូលដ្ឋានគ្រប់អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិចំនួន ៦៨៦ (ឆ្នាំ២០២០ មានចំនួន ៦៦៤)។ ទន្ទឹមនេះ, ក្រសួង-ស្ថាប័នចំនួន ៣ បាននិងកំពុងរៀបចំបង្កើតអង្គភាពថវិកាក្នុងនោះរួមមាន÷ ក្រសួងមហាផ្ទៃ, ក្រសួងមុខងារសាធារណៈ និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

[13] ក្រសួងការពារជាតិ, ក្រសួងយុត្តិធម៌, ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ,ក្រសួងព័ត៌មាន,ក្រសួងសុខាភិបាល, ក្រសួងរ៉ែ និងថាមពល, ក្រសួងពាណិជ្ជកម្ម, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងបរិស្ថាន, ក្រសួងកិច្ចការនារី, ក្រសួងទេសចរណ៍, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងអភិវឌ្ឍន៍ជនបទ,ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

### *គោលបំណង ៣៤÷ ជំរុញការធ្វើវិមជ្ឈការហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ*

៦០. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនពីរ ហើយសម្រេចបានលទ្ធផលដូចទៅ÷

*សគ ៩. សមាហរណកម្មផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិរវាងរាជធានី-ខេត្ត ជាមួយនឹងថវិកាក្រុង ស្រុក និង ថវិកាឃុំ សង្កាត់*

**គោលដៅ÷** តម្រឹមផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិ រវាងរាជធានី-ខេត្ត ជាមួយនឹងថវិកាមន្ទីរជំនាញផ្តល់សិទ្ធិដល់រដ្ឋបាលរាជធានី-ខេត្តធ្វើនិយ័តក្នុងកម្រិតអនុគណនី និងកម្រិតគណនីនៃជំពូកតែមួយ (ក្នុងចង្កោមសកម្មភាពតែមួយ) និងក្នុងកម្រិតអនុគណនីនៃគណនីតែមួយ (ពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយទៀតក្នុងអនុកម្មវិធីតែមួយ) ដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តសាមី។

**សម្រេចបាន÷** ការតម្រឹម និងធ្វើសមាហរណកម្មបណ្តើរៗផែនការរដ្ឋបាលថ្នាក់ក្រោមជាតិរហូតសម្រេចបានពេញលេញនៅឆ្នាំ២០២៣ ដោយត្រូវអនុវត្តតាមជំហានៗ ក្នុងនោះការតម្រឹមជាមួយមន្ទីរជំនាញ (ឆ្នាំ២០២១), សមាហរណ-កម្មផែនការជាមួយរដ្ឋបាលក្រុងស្រុក(ឆ្នាំ២០២២) និងសមាហរណកម្មផែនការជាមួយរដ្ឋបាលឃុំ សង្កាត់ (ឆ្នាំ២០២៣)។

*សគ ១០. ការធ្វើប្រតិភូកម្មសិទ្ធិអំណាចនៃការធ្វើនិយ័តថវិកាជូនរដ្ឋបាលថ្នាក់ក្រោមជាតិ*

**គោលដៅ÷**ផ្តល់សិទ្ធិដល់រដ្ឋបាលរាជធានី-ខេត្តធ្វើនិយ័តក្នុងកម្រិតអនុគណនី និងកម្រិតគណនី នៃជំពូកតែមួយ (ក្នុងចង្កោមសកម្មភាពតែមួយ) និងក្នុងកម្រិតអនុគណនីនៃគណនីតែមួយ (ពីចង្កោមសកម្មភាពមួយទៅចង្កោមសកម្មភាពមួយទៀតក្នុងអនុកម្មវិធីតែមួយ) ដោយសេចក្តីសម្រេចរបស់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តសាមី

**សម្រេចបាន÷** កសហវ. បានដាក់ឱ្យអនុវត្តប្រកាសស្តីពីនីតិវិធីដាក់ឱ្យអនុវត្តថវិកាកម្មវិធីរដ្ឋបាលរាជធានី-ខេត្ត។

៦១. ដោយឡែក ការអនុវត្តគម្រោងតាមរយៈការអនុវត្តកិច្ចលទ្ធកម្មដោយឡែកជាមួយស្ថាប័នរដ្ឋ គឺមិនតម្រូវឱ្យមានកក់ប្រាក់ដើម្បីធានាសុពលភាពទេ។ នៅពេលអនុវត្តគម្រោងចប់ គឺបើកប្រាក់ត្រឹម ៩០% ប៉ុណ្ណោះ ហើយសល់ ១០%ទៀតរក្សាទុកសម្រាប់ធានាសុពលភាពគម្រោងក្នុងរយៈពេល ១២ ខែ។ ប្រសិនបើគម្រោងនោះមានគុណភាពល្អ នោះ ១០% ទៀតនឹងបើកជូន។ ក្នុងករណីស្ថិតក្នុងឆ្នាំថវិកាតែមួយ គឺមិនមានបញ្ហាសម្រាប់ការទូទាត់នោះទេ ប៉ុន្តែក្នុងករណីឆ្លងឆ្នាំថវិកា មិនអាចដកប្រាក់ ១០% ដោយសារថវិកាដែលសល់ត្រូវបង្វែរចូលថវិកាជាតិវិញអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ដូចនេះរដ្ឋបាលរាជធានីភ្នំពេញពុំមានឥណ-ទានសម្រាប់ទូទាត់ ១០%នេះទេ។ អាស្រ័យនេះ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងអគ្គនាយក-ដ្ឋានលទ្ធកម្មសាធារណៈនៃ កសហវ. ពិនិត្យ និងសិក្សាលើបញ្ហាប្រឈមនេះ។

៦២. **ជាការសន្និដ្ឋានផ្នែកទី៣ ក្របខណ្ឌថវិការយៈពេលមធ្យមត្រូវបានរៀបចំ និងអនុវត្តសាកល្បង និង ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ-២០២៣ នឹងត្រូវរៀបចំសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២៣-២០២៥ និងថវិកាប្រចាំឆ្នាំ២០២៣។ កិច្ចការនេះ នឹងបង្កលក្ខណៈងាយស្រួលដល់ក្រសួង-ស្ថាប័ន ក្នុងការរៀបចំថវិកា ដោយមានកំណត់ថវិកាទាំងវិស័យ និងក្រសួង-ស្ថាប័នពិសេសការធ្វើសមាហរណកម្មថវិកាចរន្ត និងវិនិយោគ រួមទាំងពេលវេលាអនុលោមតាមប្រតិទិននៃការរៀបចំថវិកា។**

ជាមួយគ្នានេះ ការកែទម្រង់វិមជ្ឈការហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដោះស្រាយជាកញ្ចប់ ហើយមានលក្ខណៈជាប្រព័ន្ធ។

## ផ្នែកទី៤÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម

៦៣. ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ផ្តោតលើគោលបំណងចំនួន ៤ រួមមាន (១) បង្កើតក្របខណ្ឌថវិកាផ្អែកលើព័ត៌មានសមិទ្ធកម្ម, (២)រៀបចំ និងដាក់ឱ្យអនុវត្តក្របខណ្ឌគណនេយ្យភាពសមិទ្ធកម្ម, (៣) ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យ, និង(៤) រៀបចំ និងអនុវត្តផែនការកសាងសមត្ថភាព (ដោយរួមបញ្ចូលទាំងស្ថាប័ននីតិប្បញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ)។

### *គោលបំណង ៤១÷ ដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម*

៦៤. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនពីរ ហើយសម្រេចបានលទ្ធផលដូចទៅ÷

*សត ១. សាកល្បងរៀបចំផែនការសមិទ្ធកម្មគន្លឹះ*

**គោលដៅ÷** សាកល្បងរៀបចំផែនការសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ២០២១។

**សម្រេចបាន÷** តាមផែនការសកម្មភាពនៃយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, ថវិកាព័ត៌មានសមិទ្ធកម្ម ដែលត្រូវបានហៅកាត់ថា ថវិកាសមិទ្ធកម្ម នឹងត្រូវអនុវត្តសាកល្បងនូវការរៀបចំគម្រោងថវិកាឆ្នាំ២០២៣។ ដូចនេះ ផែនការសមិទ្ធកម្មគន្លឹះនេះ នឹងត្រូវរៀបចំឡើង នៅពេលទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្ត។ ក្នុងន័យនេះ អ.ថ. បានរៀបចំ និងដាក់ឱ្យអនុវត្តនូវទម្រង់កិច្ចព្រមព្រៀងសមិទ្ធកម្មតាមរយៈប្រកាសលេខ ១៤៩ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២២។

*សត ២.វិសោធនកម្មអនុក្រឹត្យលេខ ៨១ អនក្រ.បក ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋ និងអនុក្រឹត្យលេខ៨២អនក្រ.បក ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ និងការអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម*

**គោលដៅ÷** សេចក្តីព្រាងអនុក្រឹត្យលេខ ៨១ អនក្រ.បក ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសេចក្តីព្រាងអនុក្រឹត្យលេខ ៨២ អនក្រ.បក ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈដាក់ជូនថ្នាក់ដឹកនាំពិនិត្យ។

**សម្រេចបាន÷** វិសោធនកម្មអនុក្រឹត្យលេខ ៨១ អនក្រ.បក÷ អថ ពិនិត្យបញ្ចប់កម្រិតអគ្គនាយកដ្ឋាន ដោយទទួលបានធាតុចូលពីជំនាញការក្រសួងហិរញ្ញវត្ថុនៃសាធារណរដ្ឋបារាំង។ វិសោធនកម្មអនុក្រឹត្យលេខ ៨២ អនក្រ.បក÷ អ.រ.ជ. បានពិភាក្សាផ្ទៃក្នុងរួចរាល់ ដោយរង់ចាំកែសម្រួលនិងធ្វើបច្ចុប្បន្នភាព ស្របតាមច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ អនុក្រឹត្យទាំងពីរនឹងត្រូវដាក់បញ្ចូលគ្នានៅត្រីមាសទី២ និងដាក់ជូនថ្នាក់ដឹកនាំនៅត្រីមាសទី៣ និងបញ្ជូនទៅរាជរដ្ឋាភិបាលនៅត្រីមាសទី៤។

៦៥. ទន្ទឹមនេះ ការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុថ្មីគឺបានជួបប្រទះបញ្ហាប្រឈម ដែលបណ្តាលឱ្យមានភាពយឺតយ៉ាវ ដូចតទៅ÷ កត្តាពេលវេលា÷ សមាជិកក្រុមការងារបច្ចេកទេសមួយចំនួន ត្រូវចូលរួមក្នុងកិច្ចប្រជុំចរចាថវិកាសម្រាប់រៀបចំច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២១, និងការរីករាលដាលនៃជំងឺកូវីដ-១៩ ដែលធ្វើឱ្យមានការអាក់-

ខានក្នុងការជួបប្រជុំជាមួយជំនាញការបារាំង ដើម្បីទទួលបានធាតុចូលសម្រាប់ការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី និង កត្តាវិសាលភាព÷ ច្បាប់នេះគ្របដណ្តប់ប្រព័ន្ធហិរញ្ញវត្ថុទាំងមូល ដូចនេះគ្រប់ ភាគីពាក់ព័ន្ធទាំងអស់ ត្រូវសិក្សា និងស្វែងយល់ពីគោលការណ៍ជាច្រើន ម្យ៉ាងទៀតច្បាប់នេះត្រូវមានសង្គតិភាពជាមួយនឹងច្បាប់ និងឯកសារបទដ្ឋានគតិយុត្តផ្សេងៗ។

### *គោលបំណង ៤២÷ ដាក់ឱ្យអនុវត្តប្រព័ន្ធតាមដាន និងពិនិត្យសមិទ្ធកម្មតាមក្រសួង-ស្ថាប័ន*

៦៦. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនប្រាំមួយ ហើយសម្រេចបានលទ្ធផលដូចទៅ÷

#### *សគ ៣. ក្រសួងចំនួន ៦ មានយន្តការតាមដាន និងពិនិត្យសមិទ្ធកម្ម នៅគ្រប់ក្រសួង-ស្ថាប័ន*

**គោលដៅ**÷ប្រកាសស្តីពីយន្តការរៀបចំថវិកា និងប្រកាសស្តីពីយន្តការតាមដាន និងត្រួតពិនិត្យការអនុវត្តថវិកា។

**សម្រេចបាន**÷ កសហវ.បានចេញប្រកាសលេខ ១១៣ សហវ.ប្រក ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម ដើម្បីជួយដល់រាជរដ្ឋាភិបាលក្នុងការរៀបចំវិភាគ និងអនុវត្តគោលនយោបាយ, ជួយកំណត់អាទិភាពសំខាន់ៗ ដែលគាំទ្រដល់ការរៀបចំផែនការ និងគម្រោងថវិកាកាន់តែមានប្រសិទ្ធភាព ព្រមទាំងឆ្លើយតបទៅតាមលទ្ធភាពធនធាន, និងបង្កើនគណនេយ្យភាព និងតម្លាភាពក្នុងការសម្រេចនូវគោលបំណងគោលនយោបាយ ដែលបានដាក់ចេញ និងជាជំនួយដល់ការគ្រប់គ្រងសកម្មភាពការងារ។

#### *សគ ៤. ការរៀបចំផែនការប្រតិបត្តិថវិកាប្រចាំឆ្នាំ នៅគ្រប់ក្រសួង-ស្ថាប័ន*

**គោលដៅ**÷

១) គ្រប់ក្រសួង-ស្ថាប័នមានយន្តការគ្រប់គ្រងការអនុវត្តថវិកាតាមក្របខណ្ឌគ្រប់គ្រងសមិទ្ធកម្ម និង

២) ក្រសួង-ស្ថាប័នមានយន្តការគ្រប់គ្រងសមិទ្ធកម្ម។

**សម្រេចបាន**÷ ពុំមានវឌ្ឍនភាព។ ប៉ុន្តែ ទស្សនាទានស្តីពីការៀបចំផែនការប្រតិបត្តិថវិកា ប្រចាំឆ្នាំ ត្រូវបានរៀបចំ។ នៅជំហានបន្ទាប់ អគ្គនាយកដ្ឋានថវិកា នឹងរៀបចំទម្រង់នៃផែនការប្រតិបត្តិរបស់ក្រសួង-ស្ថាប័ន ដែលនឹងដាក់ឱ្យអនុវត្តដោយប្រកាសរបស់ កសហវ. នៅដើមឆ្នាំ ២០២៤។

#### *សគ ៥. យន្តការតាមក្រសួង-ស្ថាប័នធ្វើការត្រួតពិនិត្យនិងវាយតម្លៃថវិកាកម្មវិធី*

**គោលដៅ**÷កសហវ.បានចេញប្រកាសលេខ ១១៣ សហវ.ប្រក ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម។ ជាការងារបន្ទាប់, អគ្គនាយកដ្ឋានថវិកានឹងរៀបចំ ប្រកាសស្តីពីការដាក់ឱ្យអនុវត្តយន្តការសម្រាប់ធ្វើការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្មឆ្នាំ២០២៤ និងដាក់ឱ្យអនុវត្តសាកល្បងនៅឆ្នាំ២០២៥។

### *គោលបំណង ៤៣÷ ពង្រឹងប្រសិទ្ធភាពប្រព័ន្ធត្រួតពិនិត្យសមិទ្ធកម្ម (សវនកម្មផ្ទៃក្នុងអធិការកិច្ចហិរញ្ញវត្ថុ និងសវនកម្មឯករាជ្យ)*

#### *សគ ៦. ការរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ស្របតាមប្រព័ន្ធថវិកាសមិទ្ធកម្ម*

**គោលដៅ**÷ ឯកសារទស្សនាទានស្តីពីដំណើរការប្រព្រឹត្តទៅនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងត្រូវបានរៀបចំ។

**វឌ្ឍនភាព÷** អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងបានរៀបចំឯកសារប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងបានកែសម្រួលបញ្ចប់សេចក្តីព្រាងអនុក្រឹត្យថ្មីស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង និងចេញប្រកាសស្តីពីគោលការណ៍ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន។

### *សត ៧. ការអនុវត្តប្រព័ន្ធសវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន*

**គោលដៅ÷**សវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន ត្រូវបានអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន។

**សម្រេចបាន÷** អនុវត្តសវនកម្មសមិទ្ធកម្មសាកល្បងជាករណីសិក្សាជូនក្រសួង ចំនួន ៦ និងអនុវត្តសវនកម្មបច្ចេកវិទ្យាព័ត៌មានសាកល្បងជាករណីសិក្សាជូនក្រសួង ចំនួន ៤។

៦៧. ដោយឡែក អ.ស.ក បានទទួលការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់គន្លងសវនកម្ម (Audit log) ក្នុងប្រព័ន្ធ FMIS ចំនួន ១វគ្គ, និងបានអនុវត្តសាកល្បងលើការប្រើប្រាស់ Audit log លើមុខងារចំនួន ៤ រួមមាន មុខងារវិភាជន៍ថវិកា (BA), មុខងារគ្រប់គ្រងសាច់ប្រាក់ (CM), មុខងារគណនីត្រូវទារ (AR) និងមុខងារគណនីត្រូវសង (AP)។

### *សត ៨. ការផលិតរបាយការណ៍សវនកម្មសមិទ្ធកម្មដោយសវនកម្មឯករាជ្យ*

**គោលដៅ÷**មានរបាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៥ ត្រូវបានរៀបចំដោយអាជ្ញាធរសវនកម្មជាតិ និងបញ្ជូនទៅអង្គនីតិបញ្ញត្តិ។

**សម្រេចបាន÷** អាជ្ញាសវនកម្មជាតិ បន្តធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ (Performance Audit) សម្រាប់ការិយបរិច្ឆេទ ២០២១ ចំនួន ៥ សម្រាប់ការិយបរិច្ឆេទ២០២០ជូនអង្គនីតិបញ្ញត្តិ។

៦៨. **ការរៀបចំក្របខណ្ឌអធិការកិច្ច÷** ផែនការយុទ្ធសាស្ត្រអធិការកិច្ចហិរញ្ញវត្ថុ ២០២១-២០២៥ ត្រូវបានធ្វើការផ្សព្វផ្សាយអនុវត្ត និងបានចុះស្រាវជ្រាវ និងរៀបចំរបាយការណ៍លើការអនុវត្តតួនាទីភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ចចំនួន ១២ក្រសួង។

## *គោលបំណង ៤៤÷ លើកកម្ពស់តម្លាភាពថវិកា*

៦៩. **កសហវ. បានបន្តយកចិត្តទុកលើការបើកចំហរ** ឱ្យមានការចូលរួមមតិយោបល់ពីវិស័យឯកជន, ដៃគូអភិវឌ្ឍន៍, អ្នកសិក្សាស្រាវជ្រាវ, និស្សិត, សាធារណជន, អង្គការមិនមែនរដ្ឋាភិបាល និង បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ នៅក្នុងវេទិកាពិគ្រោះយោបល់ផ្សេងៗនៅក្នុងដំណើរការ នៃការរៀបចំថវិកា និងការពង្រីកការបើកទូលាយព័ត៌មានថវិកាជាសាធារណៈ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការវិភាជថវិកា និងការប្រើប្រាស់ធនធានប្រកបដោយ ប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព, តម្លាភាព និងគណនេយ្យភាព។

៧០. **ការបង្កើនការចូលរួមពីសាធារណជនក្នុងដំណើរការថវិកា÷** ដើម្បីបង្កើនការចូលរួមពីសាធារណជន, អ.គ.ប និង អ.ថ បានរៀបចំវេទិកាសាធារណៈស្តីពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌថវិកាប្រចាំឆ្នាំ[14] ។ **ការរៀបចំសៀវភៅថវិកាពលរដ្ឋ (Citizen Budget) និងវេទិកាផ្សព្វផ្សាយពីថវិកាកម្មវិធីរបស់ក្រសួង-ស្ថាប័នសាមីជូន**

[14] ប្រព្រឹតទៅនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

**សាធារណជន៖** សេចក្តីណែនាំស្តីពីការរៀបចំវេទិកាសាធារណៈ និងសៀវភៅថវិកាពលរដ្ឋ ដើម្បីផ្សព្វផ្សាយអំពីកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងនីមួយៗ ជូនដល់ដៃគូពាក់ព័ន្ធ និងសាធារណជន ត្រូវបានដាក់ចេញតាមរយៈលិខិតលេខ ១៩៤៨ សហវ.អថ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០២២ ដោយជ្រើសរើសក្រសួងចំនួន ៤ ដែលរួមមាន៖ (១) ក្រសួងអប់រំ យុវជន និងកីឡា, (២) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, (៣) ក្រសួងធនធានទឹក និងឧតុនិយម និង (៤) ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់ការចាប់ផ្តើមអនុវត្តនៅក្នុងឆ្នាំ ២០២២។

៧១. **ការបង្កើនការផ្សព្វផ្សាយឯកសារថវិកា**[15] **៖** កសហវ. បានធ្វើការផ្សព្វផ្សាយជាសាធារណៈនូវឯកសារថវិកាជាទៀងទាត់លើគេហទំព័រ រួមមាន (១) ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ, (២) សារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំ, (៣) ខ្លឹមសារសង្ខេបប្រតិបត្តិស្តីពីសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ, (៤) សៀវភៅថវិកាសង្ខេបនៃច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ, (៥) សារាចរស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១, (៥) របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ (ស្តង់ដា TOFE & GFS) ប្រចាំខែ, (៦) ច្បាប់ស្តីពីការទូទាត់ថវិកា, (៧) របាយការណ៍និន្នាការសេដ្ឋកិច្ចសង្គមប្រចាំខែ, (៨) ព្រឹត្តិបត្រស្ថិតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រចាំត្រីមាស និង (៩) ព្រឹត្តប័ត្រស្ថិតិបំណុលសាធារណៈ។ ជាមួយគ្នានេះ អាជ្ញាធរសវនកម្មជាតិ បានផ្សព្វផ្សាយរបាយការណ៍សវនកម្មស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

៧២. **ការបង្កើនតម្លាភាពកិច្ចលទ្ធកម្មសាធារណៈ៖** អ.ល.ស បានផ្សព្វផ្សាយព្រឹត្តិបត្រស្ថិតិលទ្ធកម្មសាធារណៈ និងផែនការលទ្ធកម្ម, សេចក្តីជូនដំណឹង និងការប្រគល់កិច្ចសន្យាលើគេហទំព័រផងដែរ។

៧៣. **ជារួម ការឈានទៅអនុវត្តដំណាក់កាលទី៤ នឹងត្រូវត្រៀមខ្លួនរួចរាល់សម្រាប់ដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០២៣តទៅ តាមរយៈការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី), ការរៀបចំអនុក្រឹត្យលេខ៨១ និង ៨២ (ថ្មី) ព្រមទាំងការរៀបចំក្របខណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម ដែលរំពឹងថាត្រូវបញ្ចប់ក្នុងឆ្នាំ២០២២។ ទន្ទឹមនេះ, មុខងារសវនកម្មផ្ទៃក្នុង (ជាពិសេសការធ្វើសវនកម្មសមិទ្ធកម្ម) និងអធិការកិច្ច នៅគ្រប់ក្រសួង-ស្ថាប័នត្រូវពង្រឹងបន្ថែមជាបណ្តើរៗ ដើម្បីធានាក្រសួង-ស្ថាប័នមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរឹងមាំ ស្របពេលរាជរដ្ឋាភិបាលបាននិងកំពុងធ្វើវិមជ្ឈការហិរញ្ញវត្ថុដល់ក្រសួង-ស្ថាប័ន។**

## ផ្នែកទី៥៖ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព

៧៤. ផ្នែកគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព ផ្តោតលើគោលបំណងចំនួន ៣ រួមមាន (១) បង្កើនភាពជាអ្នកដឹកនាំ, សមត្ថភាពគ្រប់គ្រង, និងបណ្តុះឆន្ទៈកំណែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ, (២) បង្កើនប្រសិទ្ធភាពនៃការ កសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត, និង (៣) ពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣។

[15] ឯកសារថវិកាអាចស្វែងរកបាននៅលើគេហទំព័ររបស់ កសហវ. www.mef.gov.kh និងរបស់អាជ្ញាធរសវនកម្មជាតិ www.naacambodia.com។

៧៥. ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃស្ថាប័នសាធារណៈត្រូវឆ្លុះបញ្ចាំងនូវសមត្ថភាពស្ថាប័ន÷ ការដឹកនាំ និងការអនុវត្ត, ការសម្របសម្រួលស្ថាប័ន/មុខងារ, ការកសាងធនធានមនុស្សទាំងបរិមាណ និងគុណភាព និងការលើកទឹកចិត្ត/សមិទ្ធកម្ម/គុណាធិបតេយ្យ។

*គោលបំណង ៥១÷ ពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាព ក្នុងការគ្រប់គ្រងភាពជាម្ចាស់ និងការទទួលខុសត្រូវ ក្នុងការកែទម្រង់*

៧៦. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនពីរ ហើយសម្រេចបានលទ្ធផលដូចទៅ÷

*សគ ១. ភាពទាន់ពេលវេលានៃការផ្តល់ផែនការ GDAP/MAP និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំមក អ.គ.ហ.*

**គោលដៅ÷** ផែនការ GDAP & MAP និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ត្រូវបានផ្តល់ត្រឹមកាលបរិច្ឆេទកំណត់ដោយ អ.គ.ហ.។

**សម្រេចបាន÷** ផែនការ GDAP ១៧/១៧ បានផ្ញើមក អ.គ.ហ.បានទាន់ពេលវេលា និងក្រសួង-ស្ថាប័នចំនួន ៣៤/៤១ បានផ្ញើផែនការ MAP មក អ.គ.ហ. បានទាន់ពេលវេលា។ រីឯការផ្ញើរបាយការណ៍នៃការអនុវត្ត GDAP ទទួលបាន ១៧/១៧ បានទាន់ពេលវេលា និងរបាយការណ៍នៃការអនុវត្ត MAP ទទួលបាន ៣៩/៤១។

*សគ ២. កសាងផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈរយៈពេល ៥ឆ្នាំ (ដំណាក់កាលទី៤) ភ្ជាប់ជាមួយនឹង Certificate Program*

៧៧. ផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍសមត្ថភាពនេះ ត្រូវបានអនុម័តដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** តាមចំណារចុះថ្ងៃទី៤ ខែតុលា ឆ្នាំ២០២១ លើលិខិតលេខ ៣៨៣ សហវ/អគហ។ ទន្ទឹមនេះ, វសហ. បានបញ្ចប់ការរៀបចំឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបានគោរពស្នើសុំ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** គាំទ្រ និងផ្តល់ការណែនាំដើម្បីជាមូលដ្ឋានសម្រាប់រៀបចំបទដ្ឋានគតិយុត្ត ដែលជាឧបករណ៍សម្រាប់កំណត់គុណវុឌ្ឍិមន្ត្រីដែលនឹងកាន់មុខងារ ឬទទួលបន្ទុកការងារលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមក្រសួង-ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

*គោលបំណង ៥២÷ ធានាចលនាការនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*

៧៨. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនបី ហើយសម្រេចបានលទ្ធផលដូចតទៅ÷

*សគ ៣. កហស និងលក្ខខណ្ឌយោង (TOR) ត្រូវបានធ្វើបច្ចុប្បន្នភាព ទៅតាមគោលការណ៍កំណត់ និងតម្រូវការរបស់អង្គភាព*

**គោលដៅ÷** លក្ខខណ្ឌយោងតួនាទីភារកិច្ចនៃសមាជិកក្រុមការងារកែទម្រង់ PFM គ្រប់ក្រសួង-ស្ថាប័ន ត្រូវបានសម្រួច និងតម្រឹមតាមគោលបំណង/សកម្មភាពគន្លឹះក្នុងម៉ាទ្រីសតាមផែនការ GDAP/MAP ឆ្នាំ២០២១។

**សម្រេចបាន÷** អ.គ.ហ. បានណែនាំដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធាណៈ នៃ កសហវ. និងក្រសួង-ស្ថាប័នរៀបចំលក្ខខណ្ឌយោងឱ្យស្របតាមផែនការសកម្មភាព ដោយមន្ត្រីទទួលបន្ទុកច្បាស់លាស់។

*សគ ៤. ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាពនៃកម្មវិធីកែទម្រង់ត្រូវបានរៀបចំ និងអនុវត្ត*

**គោលដៅទី១÷** របាយការណ៍ស្តីពីការដាក់សាកល្បងផ្ទៃក្នុង អ.គ.ហ. លើប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព (PMAS)។

**វឌ្ឍនភាព÷** ជាសារវតានៃការដាក់ឲ្យសាកល្បងលើការប្រើប្រាស់ប្រព័ន្ធ PMAS នៅផ្ទៃក្នុង អ.គ.ហ. ដែលបានរៀបចំវគ្គបណ្តុះបណ្តាលចាប់តាំងពីថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ និងដាក់ឲ្យដំណើរការក្នុងត្រីមាសទី២ ឆ្នាំ២០២២ កន្លងទៅ។ មុខងាររបស់ប្រព័ន្ធ PMAS ក្នុងដំណាក់កាលទី១ នេះត្រូវបានរៀបចំតាមមុខងារ (Module) ចំនួន៤ រួមមានការរៀបចំផែនការគ្រប់គ្រងគោលបំណង, គ្រប់គ្រងលំហូរឯកសារ និងការអនុម័តឌីជីថល។

**គោលដៅទី២÷ នីតិវិធីអនុវត្តការងារ និងអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព (PMAS) សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។**

**សម្រេចបាន÷** ក្នុងការរៀបចំកិច្ចដំណើរការប្រព័ន្ធ PMAS ក្នុងដំណាក់កាលទី២ នេះ មន្ត្រីជំនាញបច្ចេកទេសនៃ អ.គ.ហ. ដែលទទួលបន្ទុកលើការរៀបចំប្រព័ន្ធបានសិក្សាពីតម្រូវការ និងប្រវត្តិប្រើប្រាស់របស់អង្គភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបានចងក្រងជាឯកសារដែលរួមមាន÷ (១).ទម្រង់ប្រភេទលិខិត, (២).ប្រវត្តិរឿងអ្នកប្រើប្រាស់, (៣). កំណត់ទិបំហំការងារក្នុងប្រព័ន្ធ និង (៤). កំណត់ច្បាប់ប្រើប្រាស់ក្នុងប្រព័ន្ធ។

៧៩. ការរៀបចំគោលការណ៍ណែនាំគ្រប់គ្រងលទ្ធផល÷ បន្ទាប់ពីពិភាក្សាផ្ទៃក្នុង អ.គ.ហ. និងពិគ្រោះយោបល់ជាមួយជំនាញការសហភាពអឺរ៉ុបជាបន្តបន្ទាប់ក្នុងត្រីមាសទី២ និងទី៣ ឆ្នាំ២០២១ សេចក្តីព្រាងគោលការណ៍នេះគ្រោងនឹងបញ្ចប់ការរៀបចំ និងដាក់ជូនថ្នាក់ដឹកនាំ ដើម្បីពិនិត្យនិងសម្រេចក្នុងត្រីមាសទី១ ឆ្នាំ២០២២ និងគ្រោងធ្វើការផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់អង្គភាពអនុវត្តគម្រោងក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងត្រីមាសទី២ ឆ្នាំ២០២២។

*សគ ៥. ក្របខណ្ឌលើកទឹកចិត្តផ្សារភ្ជាប់សមិទ្ធកម្មក្នុងកម្មវិធីកែទម្រង់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត*

**គោលដៅ÷ក្របខណ្ឌលើកទឹកចិត្តផ្សារភ្ជាប់សមិទ្ធកម្មត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២១។**

**សម្រេចបាន÷** បច្ចុប្បន្នក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង-ស្ថាប័ន និងអង្គភាពក្រោមឱវាទ កសហវ.ទទួលបានប្រាក់ឧបត្ថម្ភមុខងារ ប៉ុន្តែពុំទាន់ផ្សារភ្ជាប់នឹងសមិទ្ធកម្មពេញលេញនៅឡើយ។ ប្រព័ន្ធលើកទឹកចិត្តសម្រាប់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ÷ មូលនិធិ PFMRP ឆ្នាំ២០២១ នេះ បានផ្តល់ជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង-ស្ថាប័ន ចំនួន ៣៥០ រូប ឬស្មើនឹងទឹកប្រាក់សរុបប្រមាណ ២ ៥២៦ លានរៀល និងចំពោះការផ្តល់ប្រាក់ឧបត្ថម្ភមុខងារជូនក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃអង្គភាពក្រោមឱវាទ កសហវ. មានចំនួន ៤៨៩ នាក់ ស្មើនឹងទឹកប្រាក់សរុបប្រមាណ ៤ ៩១០ លានរៀល, និងមន្ទីរ សហវ. រាជធានី-ខេត្ត ចំនួន ៥០ នាក់ ស្មើនឹងទឹកប្រាក់សរុបប្រមាណ ៣១៥ លានរៀល។

*គោលបំណង ៥៣÷ ពង្រឹងភាពប្រទាក់ក្រឡាគ្នារវាងការដ្ឋាននៃកម្មវិធីកែទម្រង់ផ្សេងៗទៀត*

៨០. គោលបំណងនេះមានសូចនាករសមិទ្ធកម្មចំនួនពីរ ហើយសម្រេចបានលទ្ធផលដូចទៅ÷

*សគ ៦. ការបន្តកិច្ចប្រជុំធ្វើបច្ចុប្បន្នភាពនៃកម្មវិធីកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល*

**គោលដៅទី១÷** កិច្ចប្រជុំកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំប្រចាំ។

**សម្រេចបាន÷** ពុំមានវឌ្ឍនភាពដោយរង់ចាំការរៀបចំកិច្ចប្រជុំផ្លាស់ប្តូរវេនដោយលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.)។

**គោលដៅទី២÷** កិច្ចប្រជុំកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំប្រចាំត្រីមាស និងយ៉ាងតិច ៩០%នៃផែនការសកម្មភាពត្រូវបានអនុវត្ត។

**សម្រេចបាន÷** ពុំមានវឌ្ឍនភាព។

### សគ ៧. ការកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១ របស់រាជរដ្ឋាភិបាល

**គោលដៅ÷** ឯកសារទស្សនាទាន ស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១។

**សម្រេចបាន÷** សេចក្តីព្រាងឯកសារទស្សនាទានចក្ខុវិស័យកែទម្រង់ ៣ បូក១ ត្រូវបានរៀបចំ និងបានឆ្លងកិច្ចប្រជុំលេខាធិការដ្ឋានកម្មវិធីកែទម្រង់ទាំង៤ ដោយបានឯកភាពរួចរាល់លើមាតិកា អភិក្រម និងក្របខណ្ឌពេលវេលា។

៨១. **ជាការសន្និដ្ឋាន ការអនុវត្តផ្នែកទី៥ នេះ រងផលប៉ះពាល់តិចតួចចំពោះការរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងសិក្ខាសាលាផ្សព្វផ្សាយ ដោយសារក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២១, តួអង្គដែល មានការពាក់ព័ន្ធបានផ្លាស់ប្តូរវិធីសាស្ត្រនៃការបណ្តុះបណ្តាល ឬសិក្ខាសាលាតាមរយៈប្រព័ន្ធអនឡាញ។ ក្រុមការងារ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមអង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន បានខិតខំ អនុវត្តតាមផែនការ និងបានផ្ញើរបាយការណ៍សមិទ្ធកម្មមក អ.គ.ហ. ទាន់ពេលវេលា បើទោះជាមានភាពយឺតយ៉ាវសម្រាប់ក្រសួង-ស្ថាប័នមួយចំនួនក្តី។ ដើម្បីជំរុញចលនការនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គប្បីអនុវត្តវិធានការបន្ថែមរួមមាន ការបន្តពង្រឹងយន្តការអនុវត្ត និងបុរេសកម្មបំពេញតួនាទីភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ ដែលបានកំណត់ក្នុងលក្ខខណ្ឌយោងការងារ និងបន្តពង្រឹងយន្តការសម្របសម្រួល តាមដាន និងរាយការណ៍នៃការអនុវត្តផែនការសកម្មភាពដូចមានកំណត់ ក្នុង GDAP &MAP។**

## ២.២. វឌ្ឍនភាពតាមក្រសួង-ស្ថាប័ន រួមទាំងអង្គភាពក្រោមឱវាទ កសហវ.

៨២. របាយការណ៍ត្រួតពិនិត្យនេះ ត្រូវបានធ្វើការបូកសរុប និងវាយតម្លៃផ្អែកលើផែនការសកម្មភាព និងសូចនាករ ឆ្នាំ ២០២១ ដែលសម្រេចបានដោយអង្គភាពទាំង ១៧ ក្រោមឱវាទ កសហវ., មន្ទីរ សហវ. ទាំង២៥ រាជធានី-ខេត្ត និងក្រសួង-ស្ថាប័ន។

៨៣. **គោលការណ៍ដាក់ពិន្ទុទូទៅ÷** វិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ ដើម្បីត្រួតពិនិត្យសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពប្រចាំត្រីមាស និងឆ្នាំ២០២១ នេះ ផ្អែកលើមូលដ្ឋានចំនួន ០២ សំខាន់ គឺ(១) សកម្មភាពការងារសម្រេចបានជាក់ស្តែងធៀបនឹងសកម្មភាពដែលបានគ្រោងអនុវត្ត, និង (២) លទ្ធផលសម្រេចបានជាក់ស្តែងធៀបនឹងសូចនាករគោលដៅ ឬ សូចនាករដែលបានដាក់ចេញ។ ក្នុងនោះ, ការផ្តល់និទ្ទេសវាយតម្លៃលើសមិទ្ធកម្មសម្រេចបានត្រូវបានកំណត់ជា ៣ កម្រិត សម្រាប់គោលបំណង និងចង្កោមសកម្មភាព គឺ÷ ល្អប្រសើរ (៩៦% - ១០០%), ល្អ (៨៦% - ៩៥%), ល្អបង្គួរ (៧១% -៨៥%), មធ្យម (៦១% -៧០%) និង ខ្សោយ (ក្រោម ៦០%)។

### ២.២.១. វឌ្ឍនភាពនៃការអនុវត្តតាមអង្គភាពក្រោមឱវាទ កសហវ. (GDAP3+2)

៨៤. របាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពឆ្នាំ២០២១ ក៏បានឆ្លុះបញ្ចាំងសមិទ្ធកម្មតាមអង្គភាពក្រោមឱវាទ កសហវ. ទាំង ១៧។ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់អង្គភាពទាំង ១៧ ទទួលបានលទ្ធផលលើសពី ៨៦% ដូចមានក្នុងដ្យាក្រាមទី៦។

ដ្យាក្រាមទី 6 ÷ វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ.




៨៥. ទន្ទឹមនេះ មន្ទីរ សហវ. ទាំង ២៥ រាជធានី-ខេត្ត បានផ្តោតសកម្មភាពកែទម្រង់ពាក់ព័ន្ធនឹងមុខងាររបស់មន្ទីរ រួមមាន ការជំរុញការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធនៅថ្នាក់ក្រោមជាតិ, ការជំរុញការប្រើប្រាស់ប្រព័ន្ធ FMIS, ការជំរុញ ការធ្វើបណ្ណកម្មសិទ្ធិអចលនទ្រព្យ ដែលកាន់កាប់ដោយ កសហវ. នៅថ្នាក់មូលដ្ឋាន និងបណ្ណកម្មសិទ្ធិអចលនទ្រព្យ នៃរដ្ឋបាលថ្នាក់ក្រោមជាតិ, ការជំរុញការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់មន្ទីរជំនាញ

និងរដ្ឋបាលរាជធានី-ខេត្ត, ការជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា, ថវិកាកម្មវិធី និងអង្គភាពថវិកា, និងការជំរុញការអនុវត្តការផ្ទេរភារកិច្ចមុខងារ និងធនធាន។

៨៦. ជាលទ្ធផល, វឌ្ឍនភាពសំខាន់ៗដែលសម្រេចបាន រួមមាន÷

- បានចុះត្រួតពិនិត្យការអនុវត្តសៀវភៅបន្ទុកនៅរាជធានី-ខេត្ត សរុបបានចំនួន ៤៤៩ ទីតាំង ឬស្មើនឹង ១០០% ធៀបនឹងគោលដៅប្រចាំឆ្នាំ។
- បានត្រួតពិនិត្យការអនុវត្តប្រកាសស្តីពីការផ្តល់សេវាសាធារណៈនៅច្រកចេញ-ចូលតែមួយនៅរាជធានី-ខេត្ត សរុបបានចំនួន ៣១៦ មន្ទីរ និងអង្គភាពជំនាញ ឬស្មើនឹង ៩២% ធៀបនឹងគោលដៅប្រចាំឆ្នាំ។
- បានធ្វើបណ្ណកម្មសិទ្ធិអចលនទ្រព្យ ដែលស្ថិតក្រោមការកាន់កាប់របស់ កសហវ. នៅថ្នាក់មូលដ្ឋាន ចំនួន ៩ បណ្ណ ឬស្មើនឹង ៥៦% ធៀបនឹងគោលដៅប្រចាំឆ្នាំ។
- បានធ្វើបណ្ណកម្មសិទ្ធិអចលនទ្រព្យនៃមន្ទីរនិងអង្គភាពជំនាញ និងរដ្ឋបាលរាជធានី-ខេត្ត ក្រុងស្រុក-ខណ្ឌ សរុបបានចំនួន ១៣៤ បណ្ណ ឬស្មើនឹង ៨៨% ធៀបនឹងគោលដៅប្រចាំឆ្នាំ។
- បានរៀបចំតារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២០ របស់មន្ទីរ និងអង្គភាពជំនាញជុំវិញរាជធានី-ខេត្ត បានសរុបចំនួន ៨០៣ មន្ទីរ និងអង្គភាព ឬស្មើនឹង ៩៩% នឹងគោលដៅប្រចាំឆ្នាំ។
- បានរៀបចំតារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២០ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សរុបចំនួន ១ ១២១ ឬស្មើនឹង ៨៩% ធៀបនឹងគោលដៅប្រចាំឆ្នាំ។

ដ្យាក្រាមទី 7 ÷ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់ មន្ទីរ សហវ. រាជធានី-ខេត្ត




| | ១១.២.១. សៀវភៅបន្ទុក | ១១.២.២. ការអនុវត្តប្រកាសស្តីពីការផ្តល់សេវាសាធារណៈនៅមន្ទីរ-អង្គភាពជំនាញ | ២៣.១.១. បណ្ណកម្មសិទ្ធិអចលនទ្រព្យ ក្រោម កសហវ. នៅថ្នាក់មូលដ្ឋាន | ២៣.១.២. បណ្ណកម្មសិទ្ធិអចលនទ្រព្យនៃមន្ទីរ-អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ២៣.១.៣. តារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២០របស់មន្ទីរ-អង្គភាពជំនាញ | ២៣.១.៤. តារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
|---|---|---|---|---|---|---|
| គោលដៅប្រចាំឆ្នាំ | 451 | 345 | 16 | 153 | 813 | 1253 |
| វឌ្ឍនភាពប្រចាំឆ្នាំ | 449 | 316 | 9 | 134 | 803 | 1121 |
| % ធៀបប្រចាំឆ្នាំ | 100% | 92% | 56% | 88% | 99% | 89% |

ដ្យាក្រាមទី 8 ÷ ការអនុវត្តថវិកា និងវឌ្ឍនភាព (%) ប្រចាំឆ្នាំ២០២១ របស់មន្ទីរ សហវ. រាជធានី-ខេត្ត




% ថវិកា (អនុវត្ត+ ឧបត្ថម្ភ) ធៀបនឹងថវិកា មន្ទីរ សរុប   N/N, % ចំនួនសកម្មភាព និងពិន្ទុសិទ្ធកម្ម

### ២.២.២. វឌ្ឍនភាពនៃការអនុវត្តតាមក្រសួង-ស្ថាប័ន (MAP3+2)

៨៧. **របាយការណ៍វឌ្ឍនភាពនៃផែនការសកម្មភាព (MAP) របស់ក្រសួង-ស្ថាប័ន ទាំង ៤០ ÷** ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ស្ថាប័នចំនួន ៥ រួមមាន ÷ (១) ស្ថាប័នសេវាសេដ្ឋកិច្ចមានចំនួន ១១ ក្រសួង-ស្ថាប័ន, (២) ស្ថាប័នសេវាហិរញ្ញវត្ថុការបរទេស និងសេវាសាធារណៈទូទៅ មានចំនួន ៨ ក្រសួង-ស្ថាប័ន, (៣) ស្ថាប័ន សេវាការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ មានចំនួន ៥ ក្រសួង-ស្ថាប័ន, (៤) ស្ថាប័នសេវាសង្គមកិច្ច មានចំនួន ៦ ក្រសួង-ស្ថាប័ន និង (៥) ស្ថាប័ន កំពូល និងឯករាជ្យ មានចំនួន ១១ ក្រសួង-ស្ថាប័ន។

៨៨. ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យ តាមដានវឌ្ឍនភាព នៃការអនុវត្ត MAP3+2 ឆ្នាំ២០២១, ការរៀបចំ MAP3+2 មានភាពច្បាស់លាស់ជាងមុន និងកាត់បន្ថយការរៀបចំសកម្មភាពប្រចាំថ្ងៃ។ ទោះបីជាយ៉ាងនេះក្តី, ការដាក់ចេញផែនការសកម្មភាពកែទម្រង់ (MAP) របស់ក្រសួង-ស្ថាប័ន ពុំទាន់ឆ្លើយតបតាមការដ្ឋានកែទម្រង់អាទិភាពនៅឡើយ ដែលចាំបាច់ធានាក្រសួង-ស្ថាប័នចូលរួមអនុវត្តផែនការសកម្មភាពតាមលំដាប់លំដោយអាទិភាព។ អ.គ.ហ. និងអគ្គនាយកដ្ឋានបង្គោលនៃ កសហវ. កំណត់ផែនការសកម្មភាពកែទម្រង់អាទិភាពដើម្បីជំរុញក្រសួង-ស្ថាប័ន រៀបចំ MAP និងអនុវត្តប្រចាំឆ្នាំ។

៨៩. **ខណៈតួនាទីរបស់ក្រសួង-ស្ថាប័នកាន់តែសំខាន់ ក្នុងការចូលរួមចំណែកក្នុង PFMRP ជាពិសេសក្នុងដំណាក់កាលទី៣ និងទី៤**, ការពង្រឹងសមត្ថភាពអង្គភាពនៃក្រសួង-ស្ថាប័ន (អង្គភាពហិរញ្ញវត្ថុ និងអង្គភាពថវិកា) ជាកិច្ចការមួយដែលត្រូវយកចិត្តទុកដាក់ និងជំរុញបន្ថែម ក្រោមការគាំទ្ររបស់អង្គភាពហិរញ្ញវត្ថុ ប្រកបដោយសកម្ម, បុរេសកម្ម និងអន្តរសកម្ម។ ក្រសួង-ស្ថាប័នស្ថិតក្នុងវិស័យតែមួយ គួររៀបចំគោលនយោបាយឱ្យមានភាពប្រទាក់ក្រឡាគ្នាដើម្បីសម្រេចឱ្យបានលទ្ធផលចុងក្រោយ គឺធានាការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ការកំណត់សកម្មភាពអាទិភាពសម្រាប់ការរៀបចំ និងអនុវត្តសម្រាប់ក្រសួង-ស្ថាប័ន នៅក្នុងឆ្នាំ២០២១ ជាពិសេសបន្តលើកកម្ពស់ និងពង្រឹងការរៀបចំ និងការអនុវត្ត "ការពង្រឹងការគ្រប់គ្រងនិងអនុវត្តផែនការប្រមូលចំណូល និងចំណាយ", "ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ" និង "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"។ លទ្ធផលសម្រេចគន្លឹះសម្រេចបាន និងសង្ខេបដូចក្នុងតារាងខាងក្រោម។

តារាងទី 5 ÷ វឌ្ឍនភាពតាមក្រសួង-ស្ថាប័ន

| សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅឆ្នាំ២០២១ | វឌ្ឍនភាព |
|---|---|---|
| **ផ្នែកទី ១ ÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា** | | |
| ១. ចំនួនក្រសួង-ស្ថាប័នប្រើប្រាស់ប្រព័ន្ធ NRMIS និង E-payment | ការបង់ចំណូលតាម E-Payment ដល់ ១០ ក្រសួង-ស្ថាប័នបន្ថែម | - ប្រព័ន្ធ NRMIS ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់អង្គភាពប្រមូលចំណូល ចំនួន ២៣ក្រសួង-ស្ថាប័ន និងដាក់អនុវត្តសាកល្បងរដ្ឋបាលរាជធានី។<br>- E-payment ត្រូវបានប្រើប្រាស់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍, ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ, ក្រសួងបរិស្ថាន, ក្រសួងទេសចរណ៍, ក្រសួងការងារ |

| | | |
|---|---|---|
| | | និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងរ៉ែ និងថាមពល, ក្រសួងពាណិជ្ជកម្ម និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ |
| ២. ចំនួនក្រសួង-ស្ថាប័នផ្ញើផែនការរជ្ជទេយ្យបុរេប្រទានមក កសហវ. ទាន់ពេលវេលា | គ្រប់ក្រសួង-ស្ថាប័នផ្ញើផែនការរជ្ជទេយ្យបុរេប្រទានមក កសហវ. ទាន់ពេលវេលា | ក្រសួង-ស្ថាប័នចំនួន ១០ លើ ៣៨ (ស្មើនឹង២៧%) បានរៀបចំផែនការរជ្ជទេយ្យបុរេប្រទានតាមស្មារតីប្រកាសលេខ ៦៦៣សហវ.ប្រក។ ដោយឡែកក្រសួង-ស្ថាប័នចំនួន ២៨ ទៀតនៅមិនទាន់បានរៀបចំទាន់ពេលវេលានៅឡើយ។ |
| ៣. ចំនួនក្រសួង-ស្ថាប័នទូទាត់ថវិកាបុរេប្រទានទាន់ពេលវេលា សម្រាប់ថវិកាចរន្ត | គ្រប់ក្រសួង-ស្ថាប័នទូទាត់ថវិកាបុរេប្រទាន (សម្រាប់ថវិកាចរន្ត) ទាន់ពេលវេលា | នៅក្នុងឆ្នាំ២០២១ ក្រសួង-ស្ថាប័ន ចំនួន២៣ បានទទួលបុរេប្រទាន (សម្រាប់ថវិកាចរន្ត) ហើយមានក្រសួងចំនួន៦ប៉ុណ្ណោះដែលទូទាត់ថវិកាបុរេប្រទានទាន់ពេលវេលាក្នុងឆ្នាំថវិកា។ |
| ៤. ចំនួនក្រសួង-ស្ថាប័ន បើក-ប្រាក់បេសកកម្ម តាមប្រព័ន្ធធនាគារ | គ្រប់ក្រសួង-ស្ថាប័នបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ | ប្រាក់បេសកកម្មរបស់ក្រសួង-ស្ថាប័នសាមីត្រូវបានបើកផ្តល់តាមប្រព័ន្ធធនាគារក្នុងឆ្នាំ២០២១ |
| ៥. ភាគរយនៃផែនការលទ្ធកម្មត្រូវបានអនុម័តមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា | ៩០% ផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានអនុម័តឱ្យបានមុនថ្ងៃទី ៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា | ក្រសួង-ស្ថាប័ន អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិដែលបានផ្ញើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ២០២១ មក កសហវ. និងត្រូវបានពិនិត្យអនុម័តពី កសហវ. (គិត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០) មានដូចខាងក្រោម÷<br>- ក្រសួង-ស្ថាប័ន បានផ្ញើមកសរុបចំនួន ៥៣ស្ថាប័ន ឬស្មើ៩៨,១៥% និងបានអនុវត្តរួចរាល់ចំនួន៤៩ ស្ថាប័នឬស្មើ ៩២,៤៥%<br>- សហគ្រាសសាធារណៈនិងគ្រឹះស្ថានសាធារណៈរដ្ឋបាល បានផ្ញើមកសរុបចំនួន៣៨ស្ថាប័ន ឬស្មើ៩៤,៨៧% និងបានអនុវត្តរួចរាល់ចំនួន២៥ ស្ថាប័ន ឬស្មើ ១០០% និងបានអនុវត្តរួចរាល់ចំនួន២៥ស្ថាប័ន ឬស្មើ១០០%<br>- រដ្ឋបាលរាជធានី-ខេត្ត បានផ្ញើមកសរុបចំនួន ២៥ ស្ថាប័ន (១០០%)និងបានអនុម័តចំនួន ២៥ ស្ថាប័ន (១០០%)<br>- អង្គភាពថវិកាបានផ្ញើមកសរុបចំនួន ៦១៨អង្គភាព ឬស្មើ៩៦,១១% និងបានអនុម័តចំនួន៥៩៣ ស្ថាប័ន ឬស្មើ ៩៥,៩៥%។ |

| | | |
|---|---|---|
| ៦. ភាគរយនៃអង្គភាពថវិការបស់ក្រសួង-ស្ថាប័នផ្តល់របាយការណ៍អនុវត្តកិច្ចលទ្ធកម្ម | យ៉ាងតិច ៦០% នៃអង្គភាពថវិកាផ្តល់របាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលាមក កសហវ. | ក្នុងឆ្នាំ២០២០ អង្គភាពថវិកាបានផ្ញើរបាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលាមក កសហវ. មានសរុបចំនួន ៣៩១ អង្គភាព ឬស្មើនឹង ៦១,១៨ភាគរយ។ |
| **ផ្នែកទី ២ ÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ** | | |
| ១. ចំនួនមុខសញ្ញាចំណាយធ្វើស្វ័យប្រវត្តិកម្មសម្រាប់អនុវត្តថវិកាតាម FMIS នៅរដ្ឋបាលថ្នាក់កណ្តាល | នីតិវិធីធានាចំណាយ និងទូទាត់ចំណាយផ្សេងៗ កម្រិត ១ និងកម្រិត ២ ត្រូវបានដាក់ឱ្យអនុវត្តផ្លូវការនៅ កសហវ. និង ៧ ក្រសួង ផ្សេងទៀត | - នីតិវិធីធានាចំណាយនិងទូទាត់ចំណាយផ្សេងទៀតបានធ្វើការសិក្សានិងរៀបចំសេចក្តីព្រាងលំហូរនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS ដែលមានហានិភ័យកម្រិតទី១ និងកម្រិតទី២ នៅក្នុងក្របខណ្ឌ កសហវ.<br>- នីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS លើការទូទាត់ចំណាយបៀវត្ស និងចំណាយទូទាត់ត្រង់ ដែលមានហានិភ័យក្នុងកម្រិតទី១ ត្រូវបានដាក់ឲ្យអនុវត្តជាផ្លូវការនៅក្រសួង-ស្ថាប័ន ចំនួន ២៧ ហើយក្រសួង-ស្ថាប័ន ចំនួន ១០ ផ្សេងទៀត ដែលមាននីតិវិធីដោយឡែក ត្រូវបាននិងសិក្សាអំពីនីតិវិធីរួចរាល់ និងដាក់ជូនរបាយការណ៍សិក្សាឆ្លងការសម្រេចក្នុងកម្រិតថ្នាក់ដឹកនាំ FMWG។ |
| ២. ចំនួនក្រសួង-ស្ថាប័នដាក់ឱ្យអនុវត្ត SARMIS | ប្រព័ន្ធ SARMIS ត្រូវបានដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន | គ្រប់ក្រសួង-ស្ថាប័នត្រូវបានដាក់ឱ្យអនុវត្តប្រព័ន្ធ SARMIS ប៉ុន្តែពុំទាន់ត្រូវបានអនុវត្តដោយរលូន ដោយសារជួបប្រទះកត្តាប្រឈមរួមមាន សមត្ថភាព និងសម្ភារៈបច្ចេកវិទ្យា។ |
| **ផ្នែកទី ៣ ÷ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** | | |
| ១. កំណត់អត្រាគម្លាតរវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ | ភាគរយ គម្លាតនៃផែនការយុទ្ធ-សាស្ត្រថវិកា ៣ឆ្នាំរំកិល និងផែនការថវិកាប្រចាំឆ្នាំដែលអនុម័តត្រូវបានកាត់បន្ថយ | - ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ២០២១ មានគម្លាត ៩,៨%។<br>- ក្រសួង-ស្ថាប័នចំនួន ១៧ ត្រូវបានពិនិត្យឡើងវិញលើការផ្សារភ្ជាប់នៃផែនការយុទ្ធសាស្ត្រថវិកាទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់-កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។ |
| ២. ចំនួនក្រសួង-ស្ថាប័នរៀបចំថវិកាសមាហរណកម្ម ដែលមានកំណត់ក្នុងសារាចរស្តីពីការរៀបចំ BSP និងថវិកាប្រចាំឆ្នាំ | ចំនួន ៤ ក្រសួង-ស្ថាប័នត្រូវបានធ្វើសមាហរណកម្មចំណាយចរន្តនិងចំណាយមូលធនរដ្ឋចូលក្នុងកម្មវិធីផ្អែកលើពិតានថវិកា | ក្រសួង-ស្ថាប័នចំនួន ៩ បានធ្វើសមាហរណកម្មចំណាយចរន្តនិងចំណាយមូលធនរដ្ឋចូលក្នុងកម្មវិធីផ្អែកលើពិតានថវិកា។ |

| | | |
|---|---|---|
| **ផ្នែកទី ៤ ÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម** | | |
| ១. ចំនួនក្រសួង- ស្ថាប័នអនុវត្តសាកល្បងក្របខណ្ឌសវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេក-វិទ្យាព័ត៌មាន | • ចំនួន ៦ អង្គភាពសវនកម្មតាមក្រសួងស្ថាប័នចាប់ផ្តើមអនុវត្តសាកល្បង ក្របខណ្ឌសវនកម្មសមិទ្ធកម្ម<br>• ចំនួន ៤ អង្គភាពសវនកម្មតាមក្រសួងស្ថាប័នចាប់ផ្តើមអនុវត្តសាកល្បងក្របខណ្ឌសវនកម្មបច្ចេកវិទ្យាព័ត៌មាន | - ចំនួន ៦ អង្គភាពសវនកម្មតាមក្រសួង- ស្ថាប័នចាប់ផ្តើមអនុវត្តសាកល្បងក្របខណ្ឌសវនកម្មសមិទ្ធកម្ម<br>- ចំនួន ៤ អង្គភាពសវនកម្មតាមក្រសួង- ស្ថាប័នចាប់ផ្តើមអនុវត្តសាកល្បងក្របខណ្ឌសវនកម្មបច្ចេកវិទ្យាព័ត៌មាន។ |
| ២. ចំនួនអង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួង- ស្ថាប័នផ្ញើរបាយការណ៍សវនកម្មផ្ទៃក្នុងជូន អ. ស. ជ. | គ្រប់អង្គភាពសវនកម្មផ្ទៃក្នុងនៃក្រសួង- ស្ថាប័នផ្ញើរបាយការណ៍សវនកម្មផ្ទៃក្នុងជូន អ. ស. ជ. | ឆ្នាំ២០២១ របាយការណ៍សវនកម្មផ្ទៃក្នុងមានចំនួន ២០៨ ត្រូវបានផ្ញើទៅ អ. ស. ជ ដោយទទួលបានពីក្រសួង- ស្ថាប័ន និងសហគ្រាស សាធារណៈ។ ប៉ុន្តែនៅមានអង្គភាពសវនកម្មនៃក្រសួង- ស្ថាប័នមួយចំនួនពុំបានផ្ញើរបាយការណ៍ជូន អ. ស. ជ. នៅឡើយ។ |
| ៣. ចំនួនអង្គភាពសវនកម្មនៃក្រសួង- ស្ថាប័នមានផែនការយុទ្ធសាស្ត្រសវនកម្មផែនការសវនកម្មប្រចាំឆ្នាំ និងរបាយ-ការណ៍សវនកម្មស្តង់ដា | ផែនការយុទ្ធសាស្ត្រសវនកម្ម, ផែនការសវនកម្ម/ របស់ក្រសួងស្ថាប័នត្រូវបានរៀបចំ | - បានតាមដានលើការរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នចំនួន ២០<br>- បានត្រួតពិនិត្យប្រសិទ្ធភាពនៃមុខងារសវនកម្មផ្ទៃក្នុងនៅក្រសួង- ស្ថាប័នចំនួន ៨<br>- បានអនុវត្តផែនការសកម្មភាពនៃផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំសម្រេចបាន ៥អង្គភាព/ ៨០អង្គភាព<br>- តាមដានការអនុវត្តផែនការសវនកម្ម ចំនួន ៨ក្រសួង- ស្ថាប័ន ដែលបានជ្រើសរើសសម្រេចបាន ១០០អង្គភាព/ ៣១២អង្គភាព<br>- បានពិនិត្យ និងផ្តល់យោបល់កែលម្អលើរបាយការណ៍សវនកម្មផ្ទៃក្នុងនៃក្រសួង- ស្ថាប័នចំនួន ២០របាយការណ៍។ |
| **ផ្នែកទី ៥ ÷ ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត** | | |
| ១. ភាពទាន់ពេលវេលានៃការផ្ញើផែនការសកម្មភាព MAP ប្រចាំឆ្នាំ២០២១ | គ្រប់ក្រសួង- ស្ថាប័នរៀបចំផែនការសកម្មភាព MAP និងផ្ញើមក អ. គ. ហ. ទាន់ពេលវេលា | ក្រសួង- ស្ថាប័នចំនួន ៣៤/ ៤១ បានផ្ញើរៀបចំ និងផ្ញើមក អ. គ. ហ. បានទាន់ពេលវេលា។ |

| | | |
|---|---|---|
| ២. ភាពទាន់ពេលវេលានៃ ការផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្ត MAP ប្រចាំឆ្នាំ | របាយការណ៍វឌ្ឍនភាពនៃការអនុវត្ត MAP ប្រចាំត្រីមាស ទាំងអស់ត្រូវបានផ្តល់ត្រឹមកាលកំណត់ | ក្រសួង-ស្ថាប័នចំនួន ៣៩/៤១ បានផ្ញើរបាយការណ៍វឌ្ឍនភាពមក អ.គ.ហ. បានទាន់ពេលវេលា។ |
| ៣. ភាពទាន់ពេលវេលានៃការស្នើសមាសភាព ក.ហ.ស. ទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ប្រចាំឆ្នាំ | គ្រប់ក្រសួង-ស្ថាប័នរៀបចំសមាសភាព ក.ហ.ស. ទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត ប្រចាំឆ្នាំ តាមកាលកំណត់របស់ អ.គ.ហ. | គ្រប់ក្រសួង-ស្ថាប័នបានរៀបចំសមាសភាព ក.ហ.ស. ទទួលបានប្រាក់ឧបត្ថម្ភលើកទឹកចិត្ត និងផ្ញើមក អ.គ.ហ. ប៉ុន្តែមានមួយចំនួនប៉ុណ្ណោះបានទាន់ពេលវេលា ដែលនាំឱ្យការរៀបចំការបើកផ្តល់ប្រាក់ឧបត្ថម្ភមុខងារមានភាពយឺតរហូតដល់ត្រីមាសទី២។ |

៩០. វឌ្ឍនភាព (%) តាមក្រសួង-ស្ថាប័នភាគច្រើនប្រមាណជាង ៧០% អនុវត្តផែនការសកម្មភាពទទួលបានលទ្ធផលលើសពី ៨៦% លើកលែងតែក្រសួង ដូចមានបង្ហាញក្នុងដ្យាក្រាមទី ៩។

ដ្យាក្រាមទី 9 ÷ ការអនុវត្តថវិកា និងវឌ្ឍនភាព (%) ប្រចាំឆ្នាំ២០២១ របស់ក្រសួង-ស្ថាប័ន



## ២.៣. យោបល់ដៃគូអភិវឌ្ឍន៍លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុហិរញ្ញវត្ថុសាធារណៈ

### ២.៣.១ លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS

៩១. អ.គ.ហ. បានសហការជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានរៀបចំសេចក្តីព្រាងរបាយការណ៍វាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS ជំហានទី១ (ឆ្នាំ២០១៤-២០១៦) និងជំហានទី២ (ឆ្នាំ២០១៧-២០២០) ដើម្បីតម្រង់ទិសបន្ថែមលើការអនុវត្តជំហានទី៣ ឆ្នាំ២០២១-២០២៥ និងចូលរួមចំណែកក្នុងការរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៤។

៩២. ក្នុងទស្សនវិស័យនៃការធ្វើទំនើបកម្មការហិរញ្ញវត្ថុ, ប្រព័ន្ធ FMIS គឺជាឧបករណ៍គាំទ្រ ជំរុញ និងពន្លឿនសកម្មភាពទូទៅរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅគ្រប់ដំណាក់កាលដើម្បីបង្កើននូវគណនេយ្យភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ដែលអាចផ្តល់ នូវព័ត៌មានចំណូល-ចំណាយថវិកាជាតិគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា និងឈានទៅការធ្វើស្វ័យប្រវត្តិកម្មលើការរៀបចំថវិកា និងការអនុវត្តថវិកា។ ជាមួយគ្នានេះ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ បានគូសបញ្ជាក់ថាប្រព័ន្ធ FMIS នឹងជំរុញឱ្យមានការផ្លាស់ប្តូរនីតិវិធីការងារ ហើយគោលដៅឆ្នាំ២០២៥ ប្រព័ន្ធ FMIS នឹងស្វ័យប្រវត្តិកម្មការរៀបចំថវិកា ការជួយសម្រួលដល់ការផ្ទេរឥណទានថវិកាទៅដល់អង្គភាពថវិកា និង សម្រាប់ការគ្រប់គ្រង និងត្រួតពិនិត្យចំណាយរបស់ក្រសួង-ស្ថាប័ន។

៩៣. ក្នុងន័យនេះ, លោក **Holger van Eden**, លោកស្រី **Delphine Moretti**, លោក **Kris Kauffmann** និងលោក **Anumpam Raj** បានសិក្សាស្រាវជ្រាវ ព្រមទាំងផ្សារភ្ជាប់ទៅការអនុវត្តល្អ (Good practice) ជាមួយបណ្តាប្រទេសផ្សេងៗទៀត ជាពិសេសលើអាទិភាពគន្លឹះរួមមាន÷ (ទី១) ស្ថានភាពបច្ចុប្បន្ននៃការបំពាក់បណ្តាញ និងដំណើរការប្រព័ន្ធ FMIS នៅតាមក្រសួង-ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត, (ទី២) ការអភិវឌ្ឍបច្ចេកទេសនៃប្រព័ន្ធ FMIS, (ទី៣) មុខងារប្រព័ន្ធ FMIS ទាំងការរៀបចំផែនការថវិកា, ការអនុវត្តថវិកា, ការផលិតរបាយការណ៍ថវិកា និងការធ្វើសន្ទានកម្មប្រព័ន្ធ FMIS ជាមួយប្រព័ន្ធផ្សេងទៀត, (ទី៤) ការគ្រប់គ្រងការផ្លាស់ប្តូរ និង (ទី៥) ការគិតពិចារណាលើតម្លៃនៃលុយ (Value for Money)។

#### ក. យុទ្ធសាស្ត្រពង្រីកប្រព័ន្ធ FMIS

៩៤. ប្រព័ន្ធ FMIS ជំហានទី១ និងទី២ ត្រូវបានពង្រីក និងដាក់ឱ្យប្រើប្រាស់នៅគ្រប់ក្រសួង-ស្ថាប័ន, មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុទាំង ២៥, និងគ្រប់រតនាគាររាជធានី-ខេត្ត ដែលផ្តោតសំខាន់លើមុខងារអនុវត្តថវិកា និងគណនេយ្យ។ ក្នុងដំណាក់កាលនេះ ការប្រើប្រាស់ប្រព័ន្ធ FMIS គឺនៅមានបញ្ហាប្រឈមមួយចំនួនរួមមាន ការរៀបចំមុខងារនីតិវិធីអនុវត្តការងារខាងក្រៅ គឺយឺតជាងការអភិវឌ្ឍប្រព័ន្ធបច្ចេកទេស, ក្របខណ្ឌគតិយុត្ត និងការកែសម្រួលនីតិវិធីអនុវត្តការងារនៅមានកម្រិត, ការគ្រប់គ្រងការផ្លាស់ប្តូរនៅមានភាពទន់ខ្សោយ និងការអនុវត្តការងារត្រូវធ្វើឡើងទាំងដៃផង និងប្រព័ន្ធផង។ រីឯ ការធ្វើសន្ទានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធផ្សេងទៀត (ការគ្រប់គ្រងសាច់ប្រាក់, ធនាគារពាណិជ្ជ, ប្រព័ន្ធពន្ធដារ, គយ, ប្រព័ន្ធចំណូលមិនមែនសារពើពន្ធ, ប្រព័ន្ធបៀវត្ស, និងប្រព័ន្ធគ្រប់គ្រងបំណុល) នៅមិនទាន់ពេញលេញនៅឡើយ ហើយប្រព័ន្ធ FMIS និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រសួងអប់រំ យុវជន និងកីឡា (Education Management Information

System) គឺនៅមិនទាន់ធ្វើសន្ទានកម្មនៅឡើយ[16]។ ការពង្រីក FMIS ជំហានទី៣ ការដាក់ឱ្យអនុវត្តមុខងារថ្មីពីរ (មុខងាររៀបចំផែនការថវិកា និងលទ្ធកម្មពេញលេញ) បង្ហាញនូវការកើនឡើងចំណាយថវិកាសម្រាប់ប្រព័ន្ធ, ចំនួនបុគ្គលិក និងបន្ទុកការងារ។

**ហានិភ័យចម្បង÷** លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS បាននិងកំពុងពង្រីកដែនសមត្ថកិច្ចលើសកម្រិតរបស់ខ្លួន ដោយសារតែអគ្គនាយកដ្ឋានកាន់មុខងារ (functional department) គឺនៅតែអកម្ម (Passive) ខ្លាំង, ហើយឧបករណ៍បច្ចេកវិទ្យា (Hardware) ដែលបានពង្រីក និងបំពាក់សម្រាប់អ្នកប្រើប្រាស់ប្រព័ន្ធ គឺមិនទាន់ឃើញមានសារៈប្រយោជន៍ ជាពិសេសអ្នកប្រើប្រាស់នៅតាមក្រសួង-ស្ថាប័ន ដោយសារការអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធទាំងស្រុងមិនទាន់ដល់ពេលអនុវត្ត[17]។

**អនុសាសន៍÷** ផ្អាកការពង្រីកប្រព័ន្ធបណ្ដោះអាសន្នក្នុងរយៈពេល ២ឆ្នាំ និងផ្តោតលើការធ្វើឱ្យដំណើរការមុខងារប្រព័ន្ធសម្រាប់ កសហវ. និងក្រសួង-ស្ថាប័នសម្រាប់មុខងារទាំង៨, ការកែលម្អអភិបាលកិច្ចនិងការគ្រប់គ្រងការផ្លាស់ប្តូរ, ការពង្រឹងសមត្ថភាពបុគ្គលិក IT និងការកែទម្រង់ PFM ខណៈពេលជំរុញការត្រួតពិនិត្យលើការចំណាយតាមប្រព័ន្ធ។[18]

**ខ.ការអភិវឌ្ឍបច្ចេកទេសនៃប្រព័ន្ធ** FMIS

៩៥. ការអភិវឌ្ឍប្រព័ន្ធមានវឌ្ឍនភាពទៅមុខយ៉ាងល្អប្រសើរ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធគ្រប់ការដ្ឋានដែលភ្ជាប់ប្រព័ន្ធ FMIS ជាពិសេសការអភិវឌ្ឍ Data warehouse សម្រាប់ផ្ទុកនិងទាញយកទិន្នន័យ មកវិញ។ ទោះបីជាយ៉ាងនេះក្តី ក៏មានបញ្ហាប្រឈមមួយចំនួនដែលអ្នកប្រើប្រាស់ជួបប្រទះផងដែរ ទាក់ទងភាព-យឺតយ៉ាវនៃការប្រើប្រាស់ប្រព័ន្ធ, និងប្រសិទ្ធភាពនៅមានកម្រិត ដែលបង្ហាញនូវហានិភ័យសម្រាប់ការពង្រីកប្រព័ន្ធ FMIS ជំហានទី៣។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ចំណុចកែលម្អមួយចំនួនគួរតែត្រូវធ្វើឡើង ដែលរួមមាន÷ (១) ការតាមដានលំហូរនៃដំណើរការទូទាត់សម្រាប់ការអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធ FMIS (Business Process Streamlining), (២) ការជួចផ្តើមឱ្យមានការប្រើប្រាស់ហត្ថលេខាអេឡិចត្រូនិក, (៣) ការពង្រឹងតួនាទីសវនកម្មផ្ទៃក្នុងនិងផ្ទៃក្រៅ ដែលដើរតួសំខាន់ក្នុងការវាយតម្លៃមុខងារ និងដំណើការប្រព័ន្ធ, (៤) ក្នុងជំហានទី៣, ប្រព័ន្ធ FMIS នឹងត្រូវពង្រីកការដ្ឋានបន្ថែមរហូតដល់ ១៤៨ និងបន្ថែមអ្នកប្រើប្រាស់ ១ ៩០០ នាក់, ដូចនេះការតេស្តមាត្រដ្ឋានប្រព័ន្ធ គឺជាការចាំបាច់ដើម្បីបញ្ជាក់អំពីសមត្ថភាពប្រព័ន្ធ, ដំណើរការប្រព័ន្ធ និង database ដែលអាចទ្រទ្រង់សម្រាប់ផែនការនាពេលខាងមុខ។

---

[16] ដោយសារប្រព័ន្ធ EFMS របស់ ក្រសួងអប់រំ យុវជន និងកីឡា កំពុងអភិវឌ្ឍន៍ជំនាន់ទី៣ ដែលតាមការគ្រោងទុកប្រព័ន្ធនេះ នឹងរួចរាល់សម្រាប់មុខងារបញ្ជាទិញ និងគណនីត្រូវសង នៅខែមេសា ឆ្នាំ២០២២។

[17] គួសបញ្ជាក់បន្ថែមដោយលេខាធិការដ្ឋានគ្រប់គ្រងគម្រោង FMIS

[18] បន្ថែមពីអនុសាសន៍របស់ IMF, លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS បានគូសបញ្ជាក់បន្ថែមថា ការពង្រឹងការអនុវត្តនីតិវិធីថ្មីតាមប្រព័ន្ធទាំងស្រុងបាន លុះត្រាតែគ្រប់អង្គភាពថវិកាបានចូលរួមប្រើប្រាស់ប្រព័ន្ធ ហេតុនេះ ការពង្រីកត្រូវដំណើរការទន្ទឹមនឹងការពង្រឹង និង ត្រូវពង្រីកឱ្យកាន់តែលឿនបន្ថែម។

**គ.មុខងារប្រព័ន្ធ** FMIS

៩៦. បើទោះបីជាមានការសម្រេចបាននូវមុខងារប្រព័ន្ធមួយចំនួនក្នុងជំហានទី១ និងជំហានទី២ប៉ុន្តែនៅមានគម្លាតជាច្រើនក្នុងជំហានទាំង២។ ផែនការពង្រីក FMIS ជំហានទី៣ គឺមិនទាន់មានមហិច្ឆតាគ្រប់គ្រាន់នៅឡើយ។

**មុខងារអនុវត្តថវិកា**

- ប្រព័ន្ធ FMIS បានគាំទ្រពេញលេញសម្រាប់ប្រតិបត្តិការតាមប្រព័ន្ធអេឡិចត្រូនិកដោយបញ្ចូលព័ត៌មានដែលមានក្នុងវិក្កយបត្រ និងធ្វើការទូទាត់។
- ក្របខ័ណ្ឌគ្រប់គ្រងមានប្រសិទ្ធភាព និងសម្រួលសម្រាប់ការទូទាត់ដែលមានហានិភ័យទាប ប៉ុន្តែនៅតែបញ្ហាប្រឈមសម្រាប់ការទូទាត់ផ្សេងទៀត ដែលតម្រូវឱ្យកត់ត្រាប្រតិបត្តិការដោយដៃផងដែរ។
- មុខងារបញ្ជាទិញមិនត្រូវបានប្រើប្រាស់សម្រាប់ត្រួតពិនិត្យការធានាចំណាយ។
- បញ្ហាត្រួតពិនិត្យថវិកាសំខាន់ៗ÷ កង្វះសំណុំទិន្នន័យពេញលេញ ដែលមិនអាចរកបាននៃគំរូរបាយការណ៍ ការកែតម្រូវទិន្នន័យដោយដៃ កំណត់ត្រាទិន្នន័យដោយដៃស្របគ្នា។
- ប្លង់គណនេយ្យ (CoA) និងការវិភាជថវិកាលម្អិតនៅមានកម្រិត ដែលតម្រូវឱ្យក្រសួងពាក់ព័ន្ធបង្កើតប្រព័ន្ធបំពេញបន្ថែម (MoEYS)។

**អនុសាសន៍**÷ (១) បន្តកាត់បន្ថយនីតិវិធីអនុវត្តការងារស្របតាមផែនការ និង (២) អភិវឌ្ឍមុខងារពេញលេញនៃមុខងារអនុវត្តថវិកាស្នូលទាំង កសហវ. និងក្រសួង-ស្ថាប័ន ដែលត្រូវលុបការត្រួតពិនិត្យ (control) និងការកត់ត្រា (records) ដោយដៃស្របគ្នា។

**មុខងារគណនេយ្យ និងរបាយការណ៍**

- ប្លង់គណនេយ្យឆ្លុះបញ្ចាំងពីគោលការណ៍រៀបចំតាមបែបទំនើប ប៉ុន្តែចំណាត់ថ្នាក់ផ្នែករដ្ឋបាល និងកម្មវិធីពុំទាន់ស៊ីជម្រៅនៅឡើយ។
- របាយការណ៍ស្តង់ដាដែលត្រូវបានបង្កើតឡើង និងមាននៅក្នុង FMIS - រួមទាំងរបាយការណ៍ស្តង់ដាសម្រាប់ផលិតរបាយការណ៍ស្តីពីច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុ IPSAS។
- ទោះជាយ៉ាងណាក៏ដោយ របាយការណ៍គ្រប់គ្រងថវិកាជាច្រើនសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងមិនត្រូវបានបង្កើតឡើងទេ (dashboards គឺកំពុងរៀបចំ)។
- វិធានសម្រាប់កិច្ចបញ្ជិកាគណនេយ្យត្រូវបានរឹតបន្តឹង ដើម្បីធ្វើឱ្យប្រសើរឡើងនូវគុណភាពទិន្នន័យ និងភាពទាន់ពេលវេលា ដែលច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មីនឹងរួមចំណែកលើការដោះស្រាយចំណុចនេះ។
- ចំណុចខ្វះខាតទិន្នន័យសំខាន់ៗទាក់ទងនឹងបុរេប្រទាន និងការចំណាយដែលទទួលហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ដែលបង្ហាញនូវការកែទម្រង់ពុំទាន់មានមហិច្ឆតា។

**អនុសាសន៍**÷ ផ្តល់អាទិភាពក្នុងការដោះស្រាយបញ្ហាមុខងារបច្ចុប្បន្ន។

**មុខងាររៀបចំផែនការថវិកា**

- មុខងារនេះដែលទទួលបាន និងបំពាក់គ្រាន់តែដើម្បីគាំទ្រដល់ការរួមផ្សំនៃការប៉ាន់ប្រមាណថវិកា ពោលគឺមិនទាន់មានគម្រោងប្រើប្រាស់សម្រាប់ការដាក់ស្នើ និងការចរចាថវិកា។

- ភាពមានកម្រិតទៅលើទស្សនាទាន នៃការប្រើប្រាស់មុខងាររៀបចំផែនការថវិកាសម្រាប់ដំណើរការថវិកានាពេលអនាគត (ឧទាហរណ៍÷ ការប្រើប្រាស់សម្រាប់កំណត់ពិតានថវិកា, MTBF, ថវិកាព័ត៌មានសមិទ្ធកម្មពហុឆ្នាំដូចមានរំលេចនៅក្នុង BSRS)។
- ការរៀបចំថវិកាមូលធនពហុឆ្នាំ គឺមិនមានសង្គតិភាពជាមួយប្រព័ន្ធ FMIS បច្ចុប្បន្ន ដែលបញ្ហានេះត្រូវបាន និងកំពុងពិនិត្យ និងដោះស្រាយនៅក្នុងបរិបទនៃច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី។
- ការដាក់ឱ្យអនុវត្តមុខងាររៀបចំផែនការថវិកា ត្រូវបានកម្រិតត្រឹមបញ្ចូលព័ត៌មានថវិកា ដែលមិនទាន់មានមហិច្ឆិតាគ្រប់គ្រាន់។

**អនុសាសន៍÷** ការបង្កើតនីតិវិធីអនុវត្តការងារសម្រាប់ការដាក់ឱ្យប្រើប្រាស់ពេញលេញនៃមុខងាររៀបចំផែនការថវិកា ដើម្បីគាំទ្រ BSRS និងដើម្បីធានាបាននូវមុខងារសម្រាប់សមាហរណកម្មថវិកាចរន្ត និងមូលធន។

**ធនាគារ និងការទូទាត់**

- ប្រព័ន្ធ FMIS មានលទ្ធភាពលុបបំបាត់ការបើកផ្ដល់ប្រាក់ក្រោមរូបភាពជាសាច់ប្រាក់ ដោយអគ្គនាយកដ្ឋានរតនាគារជាតិ ប៉ុន្តែរចនាសម្ព័ន្ធ TSA អាចត្រូវបានកែលម្អបន្ថែមទៀត។
- ការធ្វើសមាហរណកម្មជាមួយធនាគារជាតិ (NBC) និងធនាគារពាណិជ្ជបានអនុញ្ញាតបើកដំណើរការការផ្លាស់ប្ដូរពីការប្រើប្រាស់មូលប្បទានប័ត្រទៅជាការប្រើប្រាស់ EFT ប៉ុន្តែបណ្ដុំឯកសារ (batch) នៅតែមានបន្តបញ្ចូលការចាត់ចែងទិន្នន័យដោយដៃ (ឧទាហរណ៍÷ តារាងបៀវត្ស)។
- ការទទួលយកសេវាធនាគារចល័ត និងបច្ចេកវិទ្យាហិរញ្ញវត្ថុផ្សេងទៀតផ្ដល់នូវការរំពឹងទុកដែលថាប្រព័ន្ធរតនាគារ និងការផ្ដល់សេវាកាន់តែមានប្រសិទ្ធភាព (ប្រសិនបើ/នៅពេលបានភ្ជាប់ទៅប្រព័ន្ធ FMIS)។

**អនុសាសន៍÷** រៀបចំឯកសារទស្សនទានយុទ្ធសាស្ត្រសម្រាប់ការធ្វើសន្ទានកម្មរវាងរចនាសម្ព័ន្ធធនាគាររបស់រដ្ឋាភិបាល និងប្រព័ន្ធទូទាត់ក្នុងបរិបទនៃគំនិតផ្ដួចផ្ដើមឌីជីថលនីយកម្មកាន់តែទូលំទូលាយ។

**មុខងារលទ្ធកម្មពេញលេញ**

- មុខងារលទ្ធកម្មត្រូវបានអភិវឌ្ឍដោយផ្នែក ដែលត្រូវស្វែងរកវិធីសាស្ត្រឌីជីថលដែលមានស្រាប់ចំពោះលទ្ធកម្ម។
- ខ្វះគោលបំណងតម្លាភាព និងការផ្លាស់ប្ដូរទៅជាលទ្ធកម្មអេឡិចត្រូនិក (e-procurement)។[19]
- ការពង្រីកមុខងារលទ្ធកម្មត្រូវបានគ្រោងទុកសម្រាប់តែលទ្ធកម្ម នៃការចំណាយចរន្តបច្ចុប្បន្នប៉ុណ្ណោះ ដោយសារនាយកដ្ឋានវិនិយោគ នៃអគ្គនាយកដ្ឋានថវិកា (GDB/DI) មិនទាន់ប្រើប្រាស់មុខងារបញ្ជាទិញ (PO)។

**អនុសាសន៍÷** (១) ផ្ដល់អាទិភាពដល់ការដោះស្រាយបញ្ហា PO, (២) បញ្ចូលការចំណាយមូលធននៅក្នុងប្រព័ន្ធ និង (៣) ដាក់ឱ្យដំណើរការមុខងារលទ្ធកម្មពេញលេញដល់គ្រប់ក្រសួង-ស្ថាប័នជាដំណាក់កាល។ ក្នុងរយៈពេលមធ្យម គឺបន្តធ្វើការកែទម្រង់លើកិច្ចលទ្ធកម្មបន្ថែមទៀត ហើយបញ្ចូលក្នុងមុខងារនេះ។

[19] ការឈានទៅ E-procurement គឺត្រូវស្របទៅតាមការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ។

**ឃ.អភិបាលកិច្ច**

- គម្រោង FMIS បាននិងកំពុងដំណើរការដោយយោងតាមផែនទីបង្ហាញផ្លូវដែលបានព្រមព្រៀងគ្នាជាមួយនឹងគោលបំណងរបស់ CAP ប៉ុន្តែមិនមានការពិគ្រោះយោបល់ផ្លូវការ និងទៀងទាត់អំពីវឌ្ឍនភាពជាមួយនឹងចរន្តនៃការទម្រង់ផ្សេងទៀត និងការពិភាក្សាអំពីបញ្ហាប្រឈមចម្បងៗជាមួយនឹងល្បឿន និងវឌ្ឍនភាពផ្សេងៗដែលសម្រេចបាន។
- មិនមានយន្តការសម្របសម្រួលច្បាស់លាស់រវាងក្រុមការងារ FMWG និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលនាំឱ្យលេខាធិការដ្ឋាន FMIS អនុម័តក្នុងករណីជាច្រើននូវវិធីសាស្ត្រនៃការបញ្ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដូចការអនុវត្តនាពេលបច្ចុប្បន្ន ជាជាងការកំណត់ជាប្រព័ន្ធ និងការរំពឹងទុកការចំពោះផ្លាស់ប្តូរដែលមានក្នុងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី។
- យន្តការសម្របសម្រួលចាំបាច់ត្រូវតម្រង់ទិសមិនត្រឹមតែរាយការណ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្ពោះទៅការធ្វើសេចក្តីសម្រេចចិត្តឱ្យបានទាន់ពេលវេលា (មុនពេលបញ្ហានេះកាន់តែរីកធំឡើង ហើយមិនអាចដោះស្រាយបានយ៉ាងងាយ) និងមានគោលបំណងជំរុញភាពជាអ្នកដឹកនាំលើវឌ្ឍនភាពនៃការទម្រង់ទាំងមូល។

**អនុសាសន៍÷** ក្រុមការងារ FMIS គួរបញ្ចូលសមាសភាពតំណាងក្រុមអ្នកប្រើប្រាស់, និងគួរមានការសម្របសម្រួលជាផ្លូវការ និងទៀងទាត់ជាងពេលបច្ចុប្បន្ននេះ(គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ក្រុមការងាររៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី និងក្រុមការងារ FMWG)។

**ង.ការគ្រប់គ្រងការផ្លាស់ប្តូរ**

៩៧. ប្រព័ន្ធ FMIS ត្រូវបានគ្រប់គ្រងដោយក្រុមការងារ FMWG ដែលបង្កើតឡើងនៅឆ្នាំ២០១៧ ដែលក្នុងនោះមានសមាជិក ៣២នាក់ មកពីថ្នាក់ដឹកនាំ កសហវ. និងប្រជុំជារៀងរាល់ត្រីមាស ហើយក្នុងការអនុវត្តការងារប្រចាំថ្ងៃក្រុមការងារ FMWG មានលេខាធិការដ្ឋានមួយ ដែលមានបុគ្គលិកចំនួន ១៤០ នាក់។ បញ្ហាក្របខណ្ឌអភិបាលកិច្ចមួយចំនួនក៏គួរត្រូវបានដោះស្រាយរួមមាន (១) ការពង្រឹងភាពជាអ្នកដឹកនាំ និងការចូលរួមរបស់នាយកដ្ឋានបង្គោលក្នុងក្រុមការងារ FMWG, (២) ការបន្ថែមតំណាងក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកប្រើ-ប្រាស់ដទៃទៀតក្នុងក្រុមការងារ FMWG, (៣) អគ្គនាយកដ្ឋានកាន់មុខងារ (functional department) ត្រូវចូលរួមឱ្យសកម្ម (Active) ជាមួយលេខាធិការដ្ឋាន FMWG, (៤) ការបែងចែក និងតួនាទីភារកិច្ចរបស់ក្រុមការងារ FMWG និងក្រសួង-ស្ថាប័ន និង (៥) ការកំណត់ប្រព័ន្ធស្វ័យប្រវត្តិកម្ម, ការកាត់បន្ថយនីតិវិធីការងារ និងការរៀបចំរចនាសម្ព័ន្ធការងារឡើងវិញ។

**អនុសាសន៍÷**

- ភាពជាអ្នកដឹកនាំ និងគណនេយ្យភាពសម្រាប់ការកែទម្រង់នីតិវិធីការងារចាំបាច់ត្រូវពង្រឹង និងនៅជាមួយអគ្គនាយកដ្ឋានមុខងារនីមួយៗ ជាមួយនឹងតួនាទីប្រឹក្សារបស់លេខាធិការដ្ឋាន FMWG។
- ពង្រឹងការយល់ដឹងអំពីការកែទម្រង់ PFM នៅក្នុងអគ្គនាយកដ្ឋានជំនាញ, ក្រសួង-ស្ថាប័ន និងលេខាធិការដ្ឋាន FMWG តាមរយៈទីប្រឹក្សា PFM។

- ពង្រឹងសកម្មភាពផ្សព្វផ្សាយរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់លើហេតុផល និងអត្ថប្រយោជន៍នៃការប្រើប្រាស់ប្រព័ន្ធ FMIS។
- បង្កើតវេទិកាអ្នកប្រើប្រាស់ ដើម្បីពិភាក្សាអំពីបញ្ហាប្រតិបត្តិការ និងការអភិវឌ្ឍប្រព័ន្ធ FMIS ជាប្រចាំ។[20]

**ច. តម្លៃនៃលុយ** (Value for Money)

៩៨. ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ ការចំណាយលើប្រព័ន្ធ FMIS មានការកើនឡើងខ្ពស់ ប៉ុន្តែចំណាយនេះមិនសូវជាមានប្រសិទ្ធភាពដោយសារ (១) ការចំណាយច្រើនលើឧបករណ៍បច្ចេកវិទ្យា (ក្នុងនោះមួយចំនួនចាប់ផ្តើមចាស់ប្រើលែងបាន), (២) មុខងារស្នូលរបស់ប្រព័ន្ធមួយចំនួនមិនអនុវត្តបានពេញលេញ, (៣) ការកើនឡើងនៃចំនួនអ្នកប្រើប្រាស់, (៤) ការកែសម្រួលរចនាសម្ព័ន្ធការងារបន្ទាប់ពីមុខងារត្រូវបានបង្កើត ដែលធ្វើឱ្យចំណាយកើនឡើងទ្វេដង និង (៥) ចំនួនបុគ្គលិកនាយកដ្ឋានព័ត៌មានវិទ្យាកើនឡើង ប៉ុន្តែមិនសូវមានប្រសិទ្ធភាព។

៩៩. **ជារួម, ផ្អែកលើការសិក្សា និងការអនុវត្តប្រព័ន្ធ FMIS កន្លងមក, អ.គ.ហ. សូមផ្តល់អនុសាសន៍ជារួមជូន (ទី១) ក្រុមការងារ FMWG ត្រូវបន្តគិតគូរក្នុងនោះរួមមាន÷ (១) ការពង្រីកប្រព័ន្ធ FMIS ត្រូវមានភាពប្រយ័ត្នប្រយែង ដើម្បីឱ្យការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធភាព និងសន្សំសំចៃ, (២) ពង្រឹងមុខងារអនុវត្តប្រព័ន្ធ FMIS និងចូលរួមរបស់អគ្គនាយកដ្ឋានជំនាញក្រោមឱវាទ កសហវ.ក្នុងក្រុមការងារ FMWG, (៣) ការផលិតបាននូវរបាយការណ៍ថវិកាគ្រប់ជ្រុងជ្រោយស្របតាមទម្រង់ និងតម្រូវការ និង (៤) ត្រូវជំរុញការធ្វើស្វ័យប្រវត្តិកម្មការអនុវត្តថវិកាព្រមទាំងត្រូវពន្លឿនការកែសម្រួលនីតិវិធីអនុវត្តការងារនៅតាមក្រសួង-ស្ថាប័នឱ្យស្របតាមបរិបទនៃការកែទម្រង់ និងប្រព័ន្ធ FMIS។ (ទី២) អ្នកប្រើប្រាស់ប្រព័ន្ធ FMIS÷ (១) ត្រូវពង្រឹង និងចូលរួមសហការជាមួយក្រុមការងារ FMWG លើការដោះស្រាយបញ្ហាប្រឈមនានាក្នុងការប្រើប្រាស់ប្រព័ន្ធ, (២) ត្រូវប្រើប្រាស់ប្រព័ន្ធ FMIS តែមួយ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយពុំត្រូវអភិវឌ្ឍប្រព័ន្ធផ្សេងៗ ដែលនាំឱ្យពិបាកក្នុងការគ្រប់គ្រងប្រព័ន្ធ និងនាំឱ្យកើនឡើងថ្លៃចំណាយខ្ពស់ ដែលនឹងក្លាយជាបន្ទុកសម្រាប់ថវិកាជាតិ,និង (៣) ត្រូវចូលរួមការអនុវត្តផែនការពង្រីកប្រព័ន្ធ FMIS ជំហានទី៣ ឆ្នាំ២០២១-២០២៥ ប្រកបដោយបុរេសកម្ម សកម្ម និងអន្តរសកម្ម។**

## ២.៣.២ លទ្ធផលបឋមនៃការត្រួតពិនិត្យចំណាយសាធារណៈ

១០០. អ.គ.ហ. សហការជាមួយធនាគារពិភពលោកសិក្សាលើការត្រួតពិនិត្យចំណាយសាធារណៈ (PER) ដោយជ្រើសរើសប្រធានបទ Macro-fiscal performance, ប្រព័ន្ធថវិកានៃរដ្ឋបាលខេត្តព្រះសីហនុ រួមទាំងក្រុង-ស្រុក និងឃុំ-សង្កាត់, ប្រព័ន្ធថវិកានៃក្រសួងសុខាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

១០១. សម្រាប់របាយការណ៍ទាំងបួននេះនឹងចាប់ផ្តើមចាប់ពីត្រីមាសទី១ ឆ្នាំ២០២២ រហូតដល់ឆ្នាំ២០២៣។ ជាជំហានដំបូង ធនាគារពិភពលោកបានរៀបចំសេចក្តីព្រាងបទបង្ហាញបឋមជូនក្រុមការបច្ចេកទេស អ.គ.ហ. ដើម្បីពិនិត្យលើរបកគំហើញ និងការងារបន្ត ដើម្បីឈានទៅបញ្ចប់របាយការណ៍។

---

[20] ចំណុចនេះ លេខាធិការដ្ឋាន FMWG បានបញ្ជាក់បន្ថែមថា ក្រុមការងារគ្រប់គ្រងគម្រោង FMIS តែងរៀបចំកម្មវិធីជួបអ្នកប្រើប្រាស់ដើម្បីស្តាប់វឌ្ឍនភាព និងបញ្ហាប្រឈមរបស់អ្នកប្រើប្រាស់រៀងរាល់ចុងឆ្នាំដើម្បីប្រមូលធាតុចូលសម្រាប់ដោះស្រាយ។ ក្រុមការងារ មានការខកខានក្នុងការរៀបចំអំឡុងពេលមានការផ្ទុះការរាលដាលនៃវិបត្តិជំងឺកូវីដ-១៩ ប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ក្រុមការងារតែងតែទាក់ទងដោះស្រាយបញ្ហាប្រឈមជូនអ្នកប្រើប្រាស់ជាប្រចាំថ្ងៃផងដែរ។

## ក. លទ្ធផលបឋមនៃការវាយតម្លៃចំណាយសាធារណៈ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១០២. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវបានត្រួតពិនិត្យចំណាយសាធារណៈនៅឆ្នាំ២០១៨ ដោយធនាគារពិភពលោក ដែលរកឃើញនូវចំណុចគន្លឹះរួមមាន÷ការចំណាយក្នុងវិស័យកសិកម្មគឺស្ថិតក្នុងកម្រិតសមតុល្យល្អ (well balance), ការវិនិយោគនៅមានកម្រិតលើការសិក្សាស្រាវជ្រាវផ្នែកកសិកម្ម និងការគ្រប់គ្រងដីធ្លី, និងកង្វះព័ត៌មានសមិទ្ធកម្មសម្រាប់អនុវត្តថវិកាកម្មវិធី។

១០៣. ការសិក្សាឆ្នាំ២០២២ នឹងផ្តោតលើប្រសិទ្ធភាពប្រព័ន្ធថវិកានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្នុងចំណោមក្រសួងបី ស្ថិតក្នុងវិស័យកសិកម្ម ក្នុងនោះក្រសួងអភិវឌ្ឍន៍ជនបទ (MRD), ក្រសួងធនធានទឹក និងឧតុនិយម (MORWAM) និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បង្ហាញថា ថវិកានៅឆ្នាំ២០២០ របស់ MRD មានចំណែក ៣១%, MORWAM មានចំណែក ៤៦% និង MAFF មានចំណែក ២៣%។

ដ្យាក្រាមទី 9 ÷ ថវិកាវិស័យកសិកម្ម




១០៤. សម្រាប់ថវិកាឆ្នាំ២០២១ របស់ MAFF បៀវត្សបានរួមចំណែកប្រមាណ ៤៦% នៃចំណាយសរុបបន្ទាប់មកសេវាប្រមាណ ២៤%, ទំនិញប្រមាណ ១៣% និងផ្សេងទៀតប្រមាណ ១៧% ហើយថវិកានៅថ្នាក់កណ្តាលប្រមាណ ៦៥% និងមូលដ្ឋានប្រមាណ ៣៥%។

ដ្យាក្រាមទី 10 ÷ ការចំណាយថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច (% ចំណាយសរុប)



១០៥. លទ្ធផលបឋមជារួមបានបង្ហាញថា មានចំណុចចំនួន ៥ ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវការពង្រឹងបន្ថែមក្នុងនោះរួមមាន៖ ការពង្រឹងការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រថវិកាជាមួយថវិកាប្រចាំឆ្នាំ, ការពង្រឹងការចូលរួមក្នុងការកំណត់អាទិភាពថវិកាវិនិយោគដោយការសម្របសម្រួលកាន់តែទូលាយក្នុងវិស័យពាក់ព័ន្ធនឹងគម្រោង វិនិយោគហិរញ្ញប្បទានពីប្រភពខាងក្រៅ, ការធ្វើសាមញ្ញកម្ម និងទំនើបកម្មម៉ាទ្រីសសមិទ្ធកម្ម, ការពង្រឹងការធានាចំណាយ និងផែនការសម្រាប់កិច្ចលទ្ធកម្មឱ្យទាន់ពេលវេលា, និងការពង្រឹងក្របខណ្ឌត្រួតពិនិត្យ។

ដ្យាក្រាមទី 11 ៖ អនុសាសន៍កែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅ MAFF




## ខ. លទ្ធផលបឋមនៃការវាយតម្លៃចំណាយសាធារណៈ នៃខេត្តព្រះសីហនុ

១០៦. កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដែលកម្មវិធីជាតិទី១ ឆ្នាំ២០១០-២០១៩ និងកម្មវិធីជាតិទី២ ឆ្នាំ២០២១-២០៣០។ ជាមួយគ្នានេះ, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ដែលមានទិសដៅពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីជាបណ្តើរៗ ដើម្បីឈានដល់ការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាដោយធានាឱ្យបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាពិសេសគោលបំណងគោលនយោបាយរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវតម្រឹមជាមួយនឹងគោលនយោបាយជាតិ និងស្របតាមរចនាសម្ព័ន្ធគ្រប់គ្រងនៃរដ្ឋបាល ដែលកំណត់តួនាទី សិទ្ធិអំណាច និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ការសិក្សាលើប្រព័ន្ធវាយតម្លៃប្រសិទ្ធភាពប្រព័ន្ធថវិកាថ្នាក់ក្រោមជាតិនៅខេត្តព្រះសីហនុ គឺផ្តោតលើរដ្ឋបាលទាំងបីកម្រិត រួមមាន រដ្ឋបាលខេត្ត, ក្រុង ស្រុក និងឃុំ សង្កាត់។

❖ <u>រដ្ឋបាលខេត្តព្រះសីហនុ</u>

១០៧. ផ្អែកលើទិន្នន័យថវិកាឆ្នាំ២០១៨-២០២០ បង្ហាញថាការគ្រោងចំណូល និងចំណាយថវិកាធៀបនឹងការអនុវត្តមានគម្លាត ដែលក្រុមការងារនឹងបន្តសិក្សាបន្ថែមលើករណីនេះ។

១០៨. លទ្ធផលបឋមនៃការវាយតម្លៃបានបង្ហាញថានៅរដ្ឋបាលខេត្ត ÷ សមត្ថភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាប្រចាំឆ្នាំនៅមានកម្រិត, មានគម្លាតខ្ពស់រវាងការអនុវត្តថវិកា និងផែនការ (ការព្យាករចំណូលទាបធៀបនឹងការអនុវត្ត និងសំណើបន្ថែមឥណទានថវិកាមានកម្រិតខ្ពស់), សំណើសម្រាប់ការបន្ថែមឥណទានថវិកាមានភាពយឺតយ៉ាវ, ដំណើការធានាចំណាយ និងកិច្ចលទ្ធកម្មត្រូវការពេលវេលាយូរ, និងដំណើរការរៀបចំការទទួលទំនិញ និងការទូទាត់ត្រូវការរយៈពេលយូរ (ជាពិសេសគម្រោងដែលលើសពីតានថវិកា)។

តារាងទី 6 ÷ ការគ្រោង និងអនុវត្តថវិកាឆ្នាំ២០១៨-២០២០

| Items/year | | 2018 | | | 2019 | | | 2020 | | |
|---|---|---|---|---|---|---|---|---|---|---|
| | | Plan | Actual | % | Plan | Actual | % | Plan | Actual | % |
| Revenue | **Total** | **36,173** | **138,819** | **384%** | **48,153** | **193,148** | **401%** | **135,021** | **149,293** | **111%** |
| | Tax | 31,600 | 111,790 | **354%** | 42,700 | **160,149** | 375% | 120,727 | 114,924 | **95%** |
| | Non-tax | 473 | 437 | 92% | 453 | 574 | 127% | 9,044 | 12,586 | 139% |
| | Transfer | 4,100 | 26,593 | **649%** | 5,000 | **32,425** | 648% | 5,250 | 21,784 | **415%** |
| Expenditure | **Total** | **36,173** | **134,819** | **373%** | **44,313** | **75,557** | **171%** | **117,867** | **87,836** | **75%** |
| | Ch60 | 2,533 | 2,627 | 104% | 2,711 | 3,371 | 124% | 3,291 | 2,941 | 89% |
| | Ch61 | 26,638 | 50,984 | **191%** | 32,359 | 63,446 | **196%** | 92,282 | 63,782 | 69% |
| | Ch64 | 2,733 | 2,808 | 103% | 3,077 | 3,219 | 105% | 10,684 | 10,849 | 102% |
| | Ch62 | 415 | 1,312 | **316%** | 700 | 1,054 | **151%** | 1,400 | 3,539 | **253%** |
| | Ch65 | 1,625 | 75,266 | 4632% | 1,708 | 2,070 | 121% | - | 1,431 | |
| | Ch69 | 1,809 | - | 0% | 2,408 | - | 0% | 6,310 | - | 0% |
| | Ch21 | 420 | 1,822 | **434%** | 1,350 | 2,398 | **178%** | 3,900 | 5,295 | **136%** |

❖ **រដ្ឋបាលក្រុង ស្រុក**

១០៩. ការផ្ទេរមុខងារចំនួន ៥៥ មុខងារ ទៅរដ្ឋបាលក្រុង ស្រុក ប៉ុន្តែរដ្ឋបាលក្រុង ស្រុក ទទួលបានថវិកាតិចបំផុត និងមិនមានការផ្ទេរថវិកាទៅតាមមុខងារទាំង ៥៥។

ដ្យាក្រាមទី 12 ÷ ការវិភាជថវិកាដល់រដ្ឋបាលក្រុង ស្រុកតាមចំណាត់ថ្នាក់សេដ្ឋកិច្ច




❖ **រដ្ឋបាលឃុំ សង្កាត់**

១១០. សមត្ថភាពមន្ត្រីបច្ចេកទេសនៅមានកម្រិតដែលនាំឱ្យមានការពន្យារពេលក្នុងការរៀបចំឯកសារគម្រោង និងបញ្ហាមួយទៀតគឺពាក់ព័ន្ធនឹងតម្លាភាព និងដំណើការកិច្ចលទ្ធកម្ម។

ដ្យាក្រាមទី 13 ÷ ការវិភាជថវិកាដល់រដ្ឋបាលឃុំ សង្កាត់តាមចំណាត់ថ្នាក់សេដ្ឋកិច្ច




១១១. ទោះជាយ៉ាងនេះក្តី ខាងលើនេះ ជាលទ្ធផលបឋមប៉ុណ្ណោះ ធនាគារពិភពលោកនឹងសហការបន្ថែមទៀតជាមួយ អ.គ.ហ. ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលខេត្តព្រះសីហនុ ដើម្បីពិភាក្សា និងធ្វើសុពលភាពបន្ថែមទៅលើរបកគំហើញខាងលើនេះ។ របាយការណ៍បន្ទាប់ពីមានការពិគ្រោះយល់បន្ថែមជាមួយភាគី ដែលមានការពាក់ព័ន្ធនឹងត្រូវរាយការណ៍លម្អិតនៅក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២១ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ខាងមុខ។

## ២.៤ លទ្ធផលនៃការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

### ២.៤.១ លទ្ធផលនៃការវាយតម្លៃ PEFA ឆ្នាំ២០២១

១១២. ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈគឺត្រូវបានប្រើប្រាស់ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ដែលធ្លាប់ត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈចំនួនបីលើករួចមកហើយគឺនៅឆ្នាំ២០១០, ២០១៥ និងឆ្នាំ២០២១។

១១៣. បច្ច័យលើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ គឺធ្វើការប្រៀបធៀបលើលទ្ធផលទាំងបីលើក និងទាញការសន្និដ្ឋានលើលទ្ធផលវាយតម្លៃជាកម្រិតម៉ាក្រូ រួមមាន÷ (១) វិន័យថវិកា, (២) ប្រសិទ្ធភាពវិភាជន៍ថវិកា និង (៣) ស័ក្តិសិទ្ធភាពការផ្តល់សេវាសាធារណៈ។

១១៤. របកគំហើញការវាយតម្លៃ PEFA ឆ្នាំ២០២១ ដែលប្រើប្រាស់ក្របខណ្ឌ PEFA ឆ្នាំ២០១១ បង្ហាញថាមានការកែលម្អក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងពិន្ទុ នៃសូចនាករសមិទ្ធកម្ម (PIs) ចំនួន ១០ ក្នុងនោះរួមមាន÷ PI-2, PI-6, PI-7, PI-10, PI-13, PI-14, PI19, PI-21, PI-23 និង PI-25 រីឯ PI-3 ទទួលបានពិន្ទុទាបដោយសារមានគម្លាតខ្ពស់រវាងផែនការ និងលទ្ធផលប្រមូលចំណូលចាប់ពីឆ្នាំ២០១៧, ២០១៨ និង២០១៩។

១១៥. ផ្អែកលើលទ្ធផលនៃការវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិឆ្នាំ២០២១ (មានជាសេចក្តីព្រាង) បានឆ្លុះបញ្ចាំងថាវឌ្ឍនភាពនៃយុទ្ធសាស្ត្រគន្លឹះទាំង៥ កំពុងរួមចំណែក ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប៉ុន្តែចាំបាច់ត្រូវបន្តពង្រឹងបន្ថែម ជាពិសេស **(១) វិន័យថវិកា**÷ ផ្អែកលើការអនុវត្តចំណាយថវិកាបង្ហាញថាមានភាពកាន់តែមានល្អប្រសើរ ប៉ុន្តែចាំបាច់ត្រូវដោះស្រាយលើចំណាយ កកស្ទះ (ទាំងផ្នែកនិយមន័យ និងបំណុលមរតក) និងការអនុវត្តចំណូលថវិកាត្រូវបន្តពង្រឹងការព្យាករចំណូល, ពង្រឹងរដ្ឋបាលប្រមូលចំណូលជាពិសេសអនុលោមភាព និងការគ្រប់គ្រងហានិភ័យ, ការតាមដានលើគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ,**(២) ប្រសិទ្ធភាពវិភាជន៍ថវិកា**÷ ថវិកាប្រចាំឆ្នាំត្រូវបានរៀបចំស្របតាមប្រតិទិនថវិកា ប៉ុន្តែចាំបាច់ត្រូវបង្កើនគុណភាពឯកសារថវិកាបន្ថែមទៀត។ ការរៀបចំថវិការយៈពេលមធ្យម គឺស្ថិតក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ ដោយហេតុថា MTFF ពុំទាន់ត្រូវបានអនុវត្ត និងថវិការយៈពេលមធ្យមត្រូវបានអនុវត្តសាកល្បងចាប់ពីឆ្នាំ២០១៩ និង **(៣) ស័ក្តិសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ**÷ មិនទាន់អនុវត្តបានល្អនៅឡើយជាពិសេសកង្វះប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម, កិច្ចលទ្ធកម្មសាធារណៈនៅមិនទាន់មានការប្រកួតប្រជែង, ការផ្សព្វផ្សាយឯកសារថវិកាសម្រាប់ ក្រសួង-ស្ថាប័ន ផ្តល់សេវាសាធារណៈនៅមានកម្រិត និងតម្លាភាពថវិកានៅមានកម្រិត។ ជាមួយគ្នានេះការពង្រឹងមុខងារសវនកម្មផ្ទៃក្នុងនឹងជួយលើកកម្ពស់ប្រព័ន្ធត្រួតពិនិត្យ (Internal control system) ដើម្បីធានាប្រសិទ្ធភាពចំណាយថវិកា និងសមិទ្ធកម្ម។

ដ្យាក្រាមទី 14÷ ការងារគន្លឹះត្រូវពង្រឹងបន្ថែមតាមវដ្តថវិកា ដោយធៀបនឹងស្តង់ដា PEFA




## ២.៤.២ លទ្ធផលបឋមនៃការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលរាជធានីភ្នំពេញ

១១៦. ក្របខណ្ឌ PEFA គឺជាឧបករណ៍សម្រាប់វាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសមួយ ដែលអាចត្រូវបានប្រើសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។ ខណៈពេលដែលផ្តោតលើយុត្តាធិការរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រដ្ឋបាលរាជធានីភ្នំពេញ (PPCA), ការវាយតម្លៃ PEFA នេះក៏កំណត់ចំណុចខ្លាំង និងចំណុចខ្សោយនៃប្រព័ន្ធ PFM សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) ជាទូទៅ។

របាយការណ៍នេះបង្ហាញពីការវាយតម្លៃជាបរិមាណតាមសសរស្តម្ភ PEFA ទាំងប្រាំពីរដូចខាងក្រោម÷

- សសរស្តម្ភ SNG÷ ទំនាក់ទំនងថវិកាអន្តររដ្ឋបាល
- សសរស្តម្ភទី១÷ ភាពជឿទុកចិត្តនៃថវិកា
- សសរស្តម្ភទី២÷ តម្លាភាពនៃហិរញ្ញវត្ថុសាធារណៈ
- សសរស្តម្ភទី៣÷ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងបំណុល
- សសរស្តម្ភទី៤÷ យុទ្ធសាស្ត្រសារពើពន្ធផ្អែកលើគោលនយោបាយ និងថវិកា
- សសរស្តម្ភទី៥÷ ការព្យាករ និងការគ្រប់គ្រងក្នុងការអនុវត្តថវិកា
- សសរស្តម្ភទី៦÷ គណនេយ្យ និងរបាយការណ៍
- សសរស្តម្ភទី៧÷ ការពិនិត្យពិនិស្ស័យ និងសវនកម្មផ្ទៃក្រៅ។

១១៧. ការវាយតម្លៃពិនិត្យមើលសូចនាករ PEFA (PIs) ចំនួន ៣៤ និងសមាសធាតុនៃការអនុវត្ត ១០១ ដោយមានសូចនាករបន្ថែមចំនួន ៣ ដើម្បីពិនិត្យមើលការផ្ទេរប្រាក់ពីរដ្ឋាភិបាលថ្នាក់កណ្តាល ដែលហៅថាទំនាក់ទំនងថវិកាអន្តររដ្ឋាភិបាល និងការពិគ្រោះយោបល់ជាសាធារណៈ។ ការវាយតម្លៃនេះក៏ផ្តល់នូវរបាយការណ៍ការអនុវត្តរួមបញ្ចូលគ្នាដោយសង្ខេបដែលវិភាគ លទ្ធផលនៅទូទាំងសូចនាករទាំងអស់ ដើម្បីសង្ខេបពីផលប៉ះពាល់សម្រាប់

ការអនុវត្តធៀបនឹងលទ្ធផលថវិកាស្នូលចំនួន ៣ រួមមាន÷ វិន័យថវិកា, ប្រសិទ្ធភាពវិភាជន៍ធនធាន និង ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

**ក.សនិដ្ឋានកម្មនិងគោលបំណង**

១១៨. ពេលវេលាសម្រាប់ការវាយតម្លៃ PEFA នេះ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលកំណត់គោលដៅរដ្ឋបាលរាជធានីភ្នំពេញ ក៏មកដល់ចំណុចសំខាន់សម្រាប់របៀបវារៈការកែទម្រង់ PFM ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ពិសេសជាងនេះទៅទៀត នៅថ្នាក់ជាតិ PFMRP ដែលមានមូលដ្ឋានលើដំណាក់កាលនេះ បច្ចុប្បន្នស្ថិតនៅក្នុងឆ្នាំចុងក្រោយដែលបានអនុវត្តសម្រាប់ដំណាក់កាលទី៣ ដោយបន្តរយៈពេលពីរឆ្នាំ ជាមួយនឹងការងារកំពុងរៀបចំរួចហើយលើការបង្កើត CAP4 ដែលរំពឹងថានឹងគ្របដណ្តប់ចាប់ពីឆ្នាំ២០២៣-២០២៧។ ការរកឃើញពីការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិនៃ PPCA រួមជាមួយនឹងការអនុវត្ត PEFA ថ្នាក់ជាតិ គឺជាការរួមចំណែកដ៏សំខាន់ចំពោះការបង្កើតគោលបំណង CAP4 នៅទូទាំងជួរនៃគោលបំណងកម្រិតសមាសភាគ PFM រួមទាំងអ្នកដែលទាក់ទងនឹងការរៀបចំថវិកា, ប្រតិបត្តិការថវិកា និងរបាយការណ៍ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និងការគ្រប់គ្រងការវិនិយោគសាធារណៈ ក៏ដូចជាសម្រាប់គោលបំណង CAP4 ជាពិសេសផ្តោតលើការគ្រប់គ្រងហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ និងបញ្ហាវិមជ្ឈការហិរញ្ញវត្ថុ។

១១៩. ដូចដែលបានកត់សម្គាល់ខាងលើ ការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិនេះផ្តោតលើការអនុវត្ត PFM, ប្រព័ន្ធ និងដំណើរការរបស់ PPCA។ ការសម្រេចចិត្តដើម្បីកំណត់គោលដៅជាពិសេស PPCA ឆ្លុះបញ្ចាំងពីការពិចារណាសំខាន់ពីរ។ **ទីមួយ** រាជធានីភ្នំពេញ មិនត្រឹមតែជារាជធានី ដែលមានចំនួនប្រជាជនច្រើនជាងគេប៉ុណ្ណោះទេ ប៉ុន្តែក៏មានស្ថានភាពលេចធ្លោមួយផងដែរ ទាក់ទងនឹងសេដ្ឋកិច្ច សកម្មភាពអាជីវកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ដូច្នេះហើយ ការជ្រើសរើសរាជធានីភ្នំពេញជាចំណុចផ្តោតតែមួយសម្រាប់ការវាយតម្លៃការអនុវត្ត PEFA ថ្នាក់ក្រោមជាតិ នេះអនុញ្ញាតឱ្យចាប់យកសមាមាត្រដ៏ធំនៃសកម្មភាពហិរញ្ញវត្ថុសាធារណៈថ្នាក់ក្រោមជាតិសរុបរួមទាំងចំណូល និងចំណាយ។ **ទីពីរ** រាជធានីភ្នំពេញមានឋានៈពិសេសមួយនៅក្នុងវិសាលភាពនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការគ្រប់គ្រងហិរញ្ញវត្ថុមានលក្ខណៈខុសប្លែកមួយចំនួន បើធៀបជាមួយរដ្ឋបាលខេត្តផ្សេងទៀត។

១២០. របាយការណ៍នេះបង្ហាញពីការរកឃើញសំខាន់ៗ នៃការវាយតម្លៃដំបូង នៃប្រព័ន្ធ PFM នៅក្នុង PPCA ដែលអនុវត្តវិធីសាស្ត្រ PEFA។ លទ្ធផលនៃការវាយតម្លៃនឹងត្រូវបានប្រើជាធាតុបញ្ចូលសម្រាប់ការរៀបចំ CAP4 ឆ្នាំ២០២៣-២០២៧។ ជាទូទៅ ការវាយតម្លៃនេះជួយរាជរដ្ឋាភិបាលកម្ពុជា ឱ្យយល់កាន់តែច្បាស់អំពីធាតុសំខាន់ៗ នៃប្រព័ន្ធ PFM ទាំងមូល។

១២១. លទ្ធផលនៃការវាយតម្លៃនេះមិនអាចអនុវត្តសម្រាប់រដ្ឋបាលខេត្តផ្សេងទៀតបានទេ ដោយសារលក្ខណៈពិសេសរបស់រាជធានី។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលនេះក្លាយជាមូលដ្ឋានសម្រាប់ការវាយតម្លៃបន្ទាប់ ក៏ដូចជាការកែលម្អប្រព័ន្ធ PFM ផងដែរ។

១២២. ការគ្របដណ្តប់នៃការវាយតម្លៃ÷ ការវាយតម្លៃនេះគ្របដណ្តប់លើ PPCA លើមុខងារប្រត្តិបត្តិ, ទីចាត់ការ, អង្គភាពចំណាយ និងក្រុមប្រឹក្សា និងការផ្តល់សេវាសាធារណៈក្នុងសមត្ថកិច្ច និងសកម្មភាពទំនាក់ទំនងថ្នាក់ជាតិ។ ក្នុងដែនសមិទ្ធកិច្ចរបស់ PPCA គឺមិនមានគ្រឹះស្ថានសាធារណៈរដ្ឋបាល ឬសហគ្រាសសាធារណៈដែលស្ថិតក្រោម

ការគ្រប់គ្រងផ្ទាល់របស់ PPCA ទេ។ ការវាយតម្លៃប្រើប្រាស់ទិន្នន័យសម្រាប់រយៈពេល ៣ ឆ្នាំ (២០១៨, ២០១៩ និង២០២០) សម្រាប់សូចនាករជាច្រើន ហើយទន្ទឹមនឹងនេះក៏ត្រូវគិតគូរពីដំណើរការ និង/ឬទិន្នន័យសម្រាប់ឆ្នាំ ២០២១ តាមការទាមទារដោយសូចនាករការអនុវត្តជាក់លាក់។

### ខ.ភាពខ្លាំង និងភាពខ្សោយ

១២៣. ការរកឃើញចម្បងនៃការវាយតម្លៃគឺផ្តោតលើថាតើ PPCA មានប្រព័ន្ធសមស្របដើម្បីគាំទ្រការសម្រេចបាននូវលទ្ធផលថវិកាសំខាន់ៗចំនួនបីគឺវិន័យថវិកា ប្រសិទ្ធភាពវិភាជន៍ធនធាន និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានសម្រាប់ការផ្តល់សេវា។

១២៤. ជាលទ្ធផលនៃការវាយតម្លៃបង្ហាញថា សូចនាករចំនួន ៤ ក្នុងចំណោម ៣៤ ទទួលពិន្ទុ "A" ឬ "B" ដែលស្របទៅនឹងការអនុវត្តល្អ (Good practice) ជាអន្តរជាតិ; សូចនាករចំនួន ៦ ទទួលបានពិន្ទុ "C" ឬ "C+" ដែលស្ថិតក្នុងកម្រិតមូលដ្ឋាន ហើយសូចនាករចំនួន ១៨ ទទួលបានពិន្ទុ "D" ឬ "D+" ដែលបង្ហាញពីការអនុវត្ត ខ្សោយ។ ដោយ-ឡែក សូចនាករចំនួន ៣ គឺ "NA-Not Applicable" មានន័យថាពុំមានមុខងារនៅរដ្ឋបាលរាជធានីភ្នំពេញ (សម្រាប់សូចនាករ PI-13, PI-19 និង PI-31) និងសូចនាករចំនួន ៣ គឺ "NU-Not Use" មានន័យថាពុំត្រូវបានប្រើប្រាស់សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ (សម្រាប់សូចនាករ PI-15, PI-16 និង PI-30 ដូចដែលបានបង្ហាញនៅក្រោមដ្យាក្រាម ១៦ និងតារាងទី៧។

ដ្យាក្រាមទី 15 ÷ សង្ខេបពិន្ទុនៃប្រព័ន្ធ PFM នៃរដ្ឋបាលរាជធានីភ្នំពេញ




### ❖ ភាពខ្លាំង

១២៥. ប្រព័ន្ធ PFM របស់ PPCA ដែលនៅតែស្ថិតក្នុងដំណាក់កាលដំបូង នៃការអភិវឌ្ឍប្រាកដជាត្រូវការពេលវេលាបន្ថែមទៀតដើម្បីកែលម្អ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ PPCA ពឹងផ្អែកលើចំណូលប្រភពផ្ទាល់ខ្លួន និងការ-ចែករំលែកចំណូលពន្ធ និងការរៀបចំថវិកាប្រចាំឆ្នាំស្របតាមប្រតិទិនផ្ញើជូន កសហវ. ទាន់ពេលវេលា និងមាន

ធាតុសំខាន់ៗភាគច្រើន។ ប្រព័ន្ធ PFM ដែលមានប្រសិទ្ធភាព គឺទាមទារឱ្យមានការពង្រឹងស្ថាប័ន ក្របខណ្ឌបទប្បញ្ញត្តិ និងការអភិវឌ្ឍសមត្ថភាព។

❖ **ភាពខ្សោយ**

១២៦. ចំណុចខ្សោយនៃប្រព័ន្ធ PFM របស់ PPCA ត្រូវបានរកឃើញដូចជា (១) កង្វះខាតការសម្របសម្រួលសម្រាប់ការរៀបចំថវិកា (២) យន្តការត្រួតពិនិត្យ និងតុល្យភាពមានកម្រិតរវាងគណៈអភិបាល និងក្រុមប្រឹក្សា។ ក្រុមប្រឹក្សារាជធានីភ្នំពេញ (PPCC) គឺខ្វះការគាំទ្រផ្នែកបច្ចេកទេសដើម្បីពិនិត្យ និងវាយតម្លៃលើការចំណាយថវិការយៈពេលមធ្យម ផែនការថវិកាប្រចាំឆ្នាំ និងការអនុវត្ត ព្រមទាំងរបាយការណ៍សវនកម្ម (៣) កង្វះតម្លាភាព ដោយសារកង្វះការផ្សព្វផ្សាយឯកសារថវិកាដល់សាធារណជន និងការចូលរួមជាសាធារណៈក្នុងវដ្តថវិកា។ បញ្ហានេះអាចប៉ះពាល់មិនត្រឹមតែសាធារណជនទូទៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការរៀបចំផ្ទៃក្នុងរបស់រដ្ឋបាលរាជធានីភ្នំពេញដើម្បីធានាថាសកម្មភាព និងប្រតិបត្តិការរបស់រដ្ឋាភិបាលកំពុងប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌគោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាល ហើយជាកម្មវត្ថុនៃការគ្រប់គ្រងថវិកា និងការរៀបចំរបាយការណ៍ឱ្យបានគ្រប់គ្រាន់។ (៤) កង្វះការប្រើប្រាស់វិធីសាស្ត្រលទ្ធកម្មសាធារណៈប្រកួតប្រជែងជាសាធារណៈ។ វិធីសាស្ត្រប្រកួតប្រជែងនេះគឺដើម្បីធានាបាននូវតម្លៃនៃប្រាក់ (value for money), សន្សំសំចៃ និងគណនេយ្យភាព។ (៥) កង្វះនៃយន្តការតាមដាន និងវាយតម្លៃ និងការចាត់ចែង ផ្ទៃក្នុងដើម្បីធានា ថាផែនការផ្តល់សេវាសាធារណៈត្រូវបានកំណត់ដោយកម្មវិធី និងដំណើរការទៅមុខមួយជំហានទៅមុខ។ (៦) កង្វះជំនាញហិរញ្ញវត្ថុក្នុងការផ្តល់ជំនួយបច្ចេកទេសឱ្យត្រូវនឹងល្បឿននៃកំណែទម្រង់។ (៧) កង្វះខាតគុណភាព BSP និង PB តាមកម្មវិធី អនុកម្មវិធី លទ្ធផលក្នុងឆ្នាំ លទ្ធផលចុងក្រោយសូចនាករសមិទ្ធកម្មគន្លឹះ និងគោលដៅ និង (៨) ការប៉ាន់ប្រមាណការអនុវត្តថវិកាគឺនៅមានកម្រិត។ ចំណុចខ្សោយទាំងនេះបង្ហាញពីប្រព័ន្ធ PFM នៅមានកម្រិត ដើម្បីឱ្យការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនៃគោលនយោបាយ និងកម្មវិធី ការគ្រប់គ្រងថវិកា និងការគ្រប់គ្រងផ្ទៃក្នុង ដើម្បីធានាថាគោលនយោបាយ បទប្បញ្ញត្តិ និងច្បាប់ត្រូវបានអនុវត្តតាមក្នុងអំឡុងពេលដំណើរការនៃការអនុវត្តថវិកា។

**គ. បច្ច័យនៃលទ្ធផលចុងក្រោយថវិកា**

❖ **វិន័យថវិកា**

១២៧. សរុបមក វិន័យថវិកានៅតែជាបញ្ហាកង្វល់សម្រាប់ទាំងការចំណាយ និងការប្រមូលចំណូលដែលមិនមានភាពជាក់ស្តែង និងអនុវត្តដូចដែលបានអនុម័ត។ ការផ្ទេរពីកម្រិតខ្ពស់នៃរដ្ឋាភិបាល (HLG-1 ‘D’) និងវិធានថវិកា និងការត្រួតពិនិត្យស្ថានភាពថវិកា (HLG-2 ‘C+’)។ លទ្ធផលនៃការចំណាយបានបង្ហាញពីសមិទ្ធកម្មខ្សោយ (PI-1 ‘D’ និង PI-2 ‘D+’); ចំណាយកកស្ទះនៅតែប្រឈមនឹងការខ្វះខាតនៃនិយមន័យត្រឹមត្រូវសម្រាប់ចំណាយកកស្ទះដែលស្របតាមស្តង់ដាអន្តរជាតិ កង្វះដំណើរការត្រួតពិនិត្យការចំណាយប្រកបដោយប្រសិទ្ធភាព (PI-22 ‘D*’) និងកង្វះការត្រួតពិនិត្យនៅថ្នាក់ក្រោមជាតិ (PI-10 ‘D’)។

១២៨. លទ្ធផល នៃការអនុវត្តផែនការប្រមូលចំណូល (PI-3 ‘D’) បង្ហាញថាលទ្ធផល និងការគ្រោងគឺមានគម្លាតដ៏ធំដែលត្រូវការពង្រឹងការព្យាករណ៍ប្រាក់ចំណូល។ បញ្ហាជាមូលដ្ឋានមួយនៃប្រាក់ចំណូលពីទ្រព្យសម្បត្តិរដ្ឋគឺការកំណត់

ការចុះបញ្ជីទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងសារពើភ័ណ្ឌ ដោយសារកង្វះប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។ PPCA រៀបចំ និងត្រួតពិនិត្យថវិការបស់ខ្លួនដោយផ្អែកលើចំណាត់ថ្នាក់សេដ្ឋកិច្ចតែប៉ុណ្ណោះ។ ឯកសារថវិការួមមានការចាត់ថ្នាក់សេដ្ឋកិច្ច (PI-4 ‘D’) និងគុណភាពនៃការអនុវត្ត និងរចនាសម្ព័ន្ធនៃកម្មវិធីត្រូវកែលម្អបន្ថែមទៀត ដោយសារការរៀបចំ BSP របស់ PPCA មិនបានរួមបញ្ចូល នូវផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមទាំងការតម្រឹមផែនការរបស់ PPCA និងមន្ទីរជំនាញ។ BSP របស់ PPCA ក៏កំណត់យ៉ាងច្បាស់នូវលទ្ធផល និងលទ្ធផលដែលរំពឹងទុក (PI-8 ‘D’)។

១២៩. PIM នៅតែស្ថិតក្នុងដំណាក់កាលដំបូង (PI-11 ‘D+’) ហើយការគ្រប់គ្រងទ្រព្យសម្បត្តិត្រូវការការកែលម្អបន្ថែមទៀត (PI-12 ‘C+’)។ ការគ្រប់គ្រងផ្ទៃក្នុងលើការចំណាយមិនមែនប្រាក់បៀវត្សរ៍មានប្រសិទ្ធភាពមួយផ្នែក ប៉ុន្តែប្រសិទ្ធភាពនៃការគ្រប់គ្រងការចំណាយ និងការអនុលោមតាមវិធាន និងនីតិវិធីនៃការទូទាត់នៅតែអាចធ្វើឱ្យប្រសើរឡើង (PI-25 ‘C’)។

- ❖ យុទ្ធសាស្ត្រវិភាជន៍ធនធាន

១៣០. ចំណុចខ្វះខាតនៅតែកើតមានជាមួយនឹងកង្វះភាពគ្រប់ជ្រុងជ្រោយឯកសារថវិកា និងការធ្វើចំណាត់ថ្នាក់ (PI-5 ‘D’ និង PI-4 ‘D’) និងកង្វះព័ត៌មានដែលអាចទុកចិត្តបាន និងទាន់ពេលវេលាដែលបានផ្តល់ជូនលើការផ្ទេរទៅ PPCA, ខណ្ឌ និង សង្កាត់ដែលរៀបចំថវិកាផ្ទាល់ខ្លួន (PI-7 ‘C’)។ តម្លាភាពចំពោះសាធារណជនមានកម្រិតដោយសារកង្វះការផ្សព្វផ្សាយព័ត៌មានថវិកា (PI-9 ‘D’) និងការចូលរួមជាសាធារណៈនៅក្នុងវដ្តថវិកា (PI-9bis ‘D+’)។

១៣១. ពេលវេលាសម្រាប់ការរៀបចំ BSP គឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ PPCA ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការបង្រួបបង្រួម និងធ្វើឱ្យវាស្របតាម NSDP, ផែនការអភិវឌ្ឍ ៥ ឆ្នាំ, PIP, និង BSP របស់មន្ទីរជំនាញ។ លើសពីនេះទៀត គុណភាពនៃ BSP រួមទាំងរចនាសម្ព័ន្ធកម្មវិធី និង KPIs សម្រាប់លទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយគឺនៅតែជាចំណុចខ្សោយ ដោយសារតែការមិនត្រូវបានកំណត់ច្បាស់លាស់ និងផ្តល់គុណភាពល្អសម្រាប់ការវាស់វែងសមិទ្ធកម្ម (PI-14 ‘D’)។

១៣២. PPCC ពិនិត្យជាចម្បងលើព័ត៌មានលម្អិតនៃចំណូល និងការចំណាយរួមបញ្ចូលក្នុងសំណើថវិកា ប៉ុន្តែខ្វះ គោលការណ៍ពិភាក្សា និងការចំណាយថវិការយៈពេលមធ្យម (PI-18 ‘D+’ និង PI-31 ‘NA’) ។

- ❖ ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានសម្រាប់ផ្តល់សេវា

១៣៣. កម្រិតមធ្យមនៃការព្យាករនៅក្នុងមូលនិធិដែលមានសម្រាប់ PPCA កំឡុងពេលអនុវត្តថវិកា (PI-21.2 ‘B’) និងដល់ខណ្ឌ (PI-7.2 ‘C’) គាំទ្រការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព។ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មសម្រាប់ការផ្តល់សេវាត្រូវតែត្រូវបានបង្កើតឡើងសម្រាប់ PPCA (PI-8 ‘D’) និងភ្ជាប់ជាមួយការ អនុវត្តជាមូលដ្ឋាននៃការគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ (PI-12 ‘C+’)។ PPCC ពិនិត្យលើការចំណាយថវិការយៈពេលមធ្យម (PI-14 ‘D’) ដែលប្រឈមមុខនឹងបញ្ហាដោយសាររយៈពេលខ្លីបំផុតដែលត្រូវបានអនុញ្ញាតក្នុងការអនុវត្តសម្រាប់ដំណើរការនេះ និងជំនួយបច្ចេកទេសដើម្បីធានាឱ្យមានយន្តការត្រួតពិនិត្យ និងសមតុល្យ។

១៣៤. តម្លៃនៃកិច្ចសន្យាទាំងអស់ដែលទទួលបានតាមរយៈវិធីសាស្ត្រប្រកួតប្រជែងក្នុងឆ្នាំហិរញ្ញវត្ថុ ដែលបានបញ្ចប់ចុងក្រោយមានចំនួនតិចជាង ១០% នៃតម្លៃសរុបនៃកិច្ចសន្យាទាំងអស់ ដែលមានន័យថាភាគច្រើននៃលទ្ធកម្មត្រូវបានធ្វើឡើងដោយប្រើវិធីសាស្ត្រមិនប្រកួតប្រជែងប្រហែល ៩០% (PI-24 'D+')។ គួបផ្សំនឹងចំណាយកកស្ទះ (PI-22 'D*') ទំនងជាមិនបង្កើតតម្លៃល្អសម្រាប់ប្រាក់ (Value for money) លើការចំណាយជាតិទេ។

១៣៥. កង្វះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង (PI-23.4 'D', PI-25.2 'C' និង PI-25.3 'C' និង PI-26 'D') ទោះបីជាមានការត្រួតពិនិត្យទាន់ពេលវេលា និងពិនិត្យដោយស្ថាប័ននីតិប្បញ្ញត្តិក៏ដោយ (PI-31, វាយតម្លៃ 'NA') និងតម្លាភាពសាធារណៈ (PI-9 'D') គឺនៅមានកម្រិត ដែលមិនទាន់អាចធ្លុះបញ្ចាំងនូវប្រសិទ្ធភាពនៅមានកម្រិតក្នុងការប្រើប្រាស់ធនធានសាធារណៈ។

១៣៦. សរុបមក ការវាយតម្លៃ PEFA សម្រាប់ PPCA បង្ហាញថា មានតម្រូវការក្នុងការពង្រឹងការកែទម្រង់ PFM នៅក្នុង PPCA ដើម្បីបង្កើតជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសម្រាប់ការកែលម្អប្រព័ន្ធ PFM ដើម្បីឱ្យ PPCA រៀបចំផែនការប្រមូល និងប្រើប្រាស់ធនធានស្របតាមការចំណាយថវិការយៈពេលមធ្យម ក៏ដូចជាផែនការអភិវឌ្ឍរយៈពេល ៥ ឆ្នាំ។ ប្រសិទ្ធភាពនៃប្រព័ន្ធ PFM ដែលមានជាក់ស្តែងមានកម្រិតនៅឡើយ សមត្ថភាពសម្រាប់ការអនុវត្តក្របខណ្ឌគតិយុត្តនៅមានកម្រិត ហើយការត្រួតពិនិត្យសមិទ្ធកម្មត្រូវបានពង្រឹងគួរឱ្យកត់សម្គាល់។ ចំណុចខ្វះខាតត្រូវបានផ្សារភ្ជាប់ទៅនឹងភាពជឿទុកចិត្តនៃថវិកា ដែលនៅមានកម្រិតទាប ដែលជាឧបករណ៍មួយដើម្បីសម្រេចបាននូវគោលបំណងគោលនយោបាយកម្រិតខ្ពស់។

តារាងទី 7 ÷ ពិន្ទុតាមសូចនាករសមិទ្ធកម្ម PEFA ថ្នាក់ក្រោមជាតិ សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ

| សូចនាករ PFM | | វិធីសាស្ត្រដាក់ពិន្ទុ | ការវាយតម្លៃតាមសមាសធាតុ | | | | សរុបពិន្ទុ |
|---|---|---|---|---|---|---|---|
| | | | i. | ii. | iii. | iv. | |
| **សសរស្តម្ភ SNG ÷ ទំនាក់ទំនងថវិកាអន្តររដ្ឋាភិបាល** | | | | | | | |
| HLG-1 | ការផ្ទេរធនធានហិរញ្ញវត្ថុពីថ្នាក់ជាតិ | M2 | D | D | D | C | **D** |
| HLG-2 | វិធានហិរញ្ញវត្ថុសាធារណៈ និងការត្រួតពិនិត្យតាមដានស្ថានភាពហិរញ្ញវត្ថុសាធារណៈ | M1 | A | NA | C | | **C+** |
| **សសរស្តម្ភទី១: ភាពជឿទុកចិត្តនៃថវិកា** | | | | | | | |
| PI-1 | លទ្ធផលអនុវត្តចំណាយសរុប | | D | | | | **D** |
| PI-2 | លទ្ធផលអនុវត្តចំណាយតាមសមាសភាគ | M1 | NA | D | B | | **D+** |
| PI-3 | លទ្ធផលប្រមូលចំណូល | M2 | D | D | | | **D** |
| **សសរស្តម្ភទី២ ÷ តម្លាភាពនៃហិរញ្ញវត្ថុសាធារណៈ** | | | | | | | |
| PI-4 | ចំណាត់ថ្នាក់ថវិកា | | D | | | | **D** |
| PI-5 | ឯកសារថវិកា | | D | | | | **D** |

| សូចនាករ PFM | | វិធីសាស្ត្រដាក់ពិន្ទុ | ការវាយតម្លៃតាមសមាសធាតុ | | | | សរុបពិន្ទុ |
|---|---|---|---|---|---|---|---|
| | | | i. | ii. | iii. | iv. | |
| PI-6 | កិច្ចប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមិនកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុ | M2 | A | A | NA | | **A** |
| PI-7 | ការផ្ទេរធនធានទៅរដ្ឋបាលថ្នាក់ក្រោមជាតិ | M2 | C | C | | | **C** |
| PI-8 | ព័ត៌មានសមិទ្ធកម្មនៃការផ្តល់សេវាសាធារណៈ | M2 | D | D | D | D | **D** |
| PI-9 | លទ្ធភាពសាធារណជនទទួលបានព័ត៌មានហិរញ្ញ | | D | | | | **D** |
| PI-9bis | ការពិគ្រោះយោបល់ជាសាធារណៈ | M2 | D | C | D | | **D+** |
| **សសរស្តម្ភទី៣÷ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងបំណុល** | | | | | | | |
| PI-10 | ការរាយការណ៍ហានិភ័យហិរញ្ញវត្ថុសាធារណៈ | M2 | NA | D | NA | | **D** |
| PI-11 | ការគ្រប់គ្រងវិនិយោគសាធារណៈ | M2 | D | D | C | C | **D+** |
| PI-12 | ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ | M2 | C | C | B | | **C+** |
| PI-13 | ការគ្រប់គ្រងបំណុល | M2 | NA | NA | NA | | **NA** |
| **សសរស្តម្ភទី៤÷ យុទ្ធសាស្ត្រសារពើពន្ធផ្អែកលើគោលនយោបាយ និងថវិកា** | | | | | | | |
| PI-14 | យុទ្ធសាស្ត្រថវិការយៈពេលមធ្យម | M2 | C | D | D | D | **D** |
| PI-15 | យុទ្ធសាស្ត្រហិរញ្ញវត្ថុ | M2 | NU | NU | NU | | **NU** |
| PI-16 | ការរៀបចំថវិកាចំណាយរយៈពេលមធ្យម | M2 | NU | NU | NU | NU | **NU** |
| PI-17 | ដំណើរការរៀបចំថវិកា | M2 | A | D | D | | **C** |
| PI-18 | ការពិនិត្យពិនិស្ស័យថវិកាដោយស្ថាប័ននីតិប្បញ្ញត្តិ | M1 | C | D | A | A | **D+** |
| **សសរស្តម្ភទី៥÷ ការព្យាករ និងការគ្រប់គ្រងក្នុងការអនុវត្តថវិកា** | | | | | | | |
| PI-19 | រដ្ឋបាលចំណូលពន្ធ | M2 | NA | NA | NA | NA | **NA** |
| PI-20 | កិច្ចបញ្ជិកាចំណូល | M1 | A | A | NA | | **A** |
| PI-21 | ភាពអាចប៉ាន់ប្រមាណបាននៃការវិភាជធនធាន ក្នុងឆ្នាំ | M2 | A | B | D | A | **B** |
| PI-22 | ចំណាយកកស្ទះ | M1 | D* | D* | | | **D*** |
| PI-23 | ការគ្រប់គ្រងចំណាយបន្ទុកបុគ្គលិក | M1 | B | B | B | D | **D+** |
| PI-24 | ការគ្រប់គ្រងលទ្ធកម្មសាធារណៈ | M2 | A | D | D | D | **D+** |
| PI-25 | ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ចំណាយក្រៅ បន្ទុកបុគ្គលិក | M2 | C | C | C | | **C** |

| សូចនាករ PFM | | វិធីសាស្ត្រដាក់ពិន្ទុ | ការវាយតម្លៃតាមសមាសធាតុ | | | | សរុបពិន្ទុ |
|---|---|---|---|---|---|---|---|
| | | | i. | ii. | iii. | iv. | |
| PI-26 | សវនកម្មផ្ទៃក្នុង | M1 | D | NA | NA | NA | **D** |
| **សសរស្តម្ភទី៦: គណនេយ្យ និងរបាយការណ៍** | | | | | | | |
| PI-27 | សុក្រឹតភាពនៃទិន្នន័យហិរញ្ញវត្ថុ | M2 | NA | NA | NA | B | **B** |
| PI-28 | របាយការណ៍អនុវត្តថវិកាក្នុងឆ្នាំ | M1 | C | A | C | | **C+** |
| PI-29 | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | M1 | C | D | D | | **D+** |
| **សសរស្តម្ភទី៧: ការពិនិត្យពិនិស្ស័យ និងសវនកម្មផ្ទៃក្រៅ** | | | | | | | |
| PI-30 | សវនកម្មផ្ទៃក្រៅ | M1 | NU | NU | NU | NU | **NU** |
| PI-31 | ការពិនិត្យពិនិស្ស័យលើរបាយការណ៍សវនកម្ម ដោយស្ថាប័ននីតិបញ្ញត្តិ | M2 | NA | NA | NA | NA | **NA** |

## ៣. បញ្ហាប្រឈម និងវិធានការ

១៣៧. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បានគ្រោងបញ្ចប់ក្នុងឆ្នាំ២០២០ ប៉ុន្តែ ក្នុងគោលបំណងបញ្ចប់ការងារសេសសល់គ្រប់ផ្នែកនៃក្របខណ្ឌផែនការសកម្មភាពរួម គ.ហ.ស បានសម្រេចពន្យារពេលរយៈពេល ២ឆ្នាំ។ ក្នុងន័យនេះ, ផែនការសកម្មភាពរួម ដំណាក់កាលអន្តរកាល ត្រូវបានហៅកាត់ និងសាមញ្ញ គឺ ផែនការសកម្មភាពរួមបីបូកពីរ (CAP3+2) សម្រាប់អនុវត្តពីឆ្នាំ២០២១ ដល់ឆ្នាំ២០២២ ដើម្បីត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ "**គណនេយ្យភាពសមិទ្ធកម្ម**"។

១៣៨. ខាងក្រោមសង្ខេបនូវបញ្ហាប្រឈម និងវិធានការគន្លឹះៗ សម្រាប់ការអនុវត្តក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីបញ្ចប់នៅឆ្នាំ២០២២ ÷

| ស្ថានភាព | វិធានការ |
|---|---|
| ***ផ្នែកទី១ "ភាពជឿទុកចិត្តនៃថវិកា"*** | |
| ***ក. គោលនយោបាយពន្ធ*** | |
| ១. ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអាករពិសេសមានសភាពទ្រឹង។ | ▪ ស្នើអង្គភាពពាក់ព័ន្ធបន្តជំរុញការងាររៀបចំសេចក្តីព្រាងច្បាប់នេះ។ |
| ***ខ. ប្រសិទ្ធភាពគ្រប់គ្រងចំណាយថវិកា*** | |
| ២. ការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារនៅមិនទាន់អនុវត្តនៅគ្រប់ក្រសួង ស្ថាប័ន និងមិនទាន់មាន នីតិវិធីលម្អិតសម្រាប់អនុវត្ត។ ក្រសួង-ស្ថាប័នមួយចំនួនទៀតពុំទាន់មានឆន្ទៈក្នុងការដាក់ចេញជាសកម្មភាពសម្រាប់អនុវត្តសកម្មភាពនេះនៅឡើយ។ | ▪ ស្នើអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ រួមទាំងអង្គភាពពាក់ព័ន្ធ ពិនិត្យនិងសិក្សាលើរៀបចំនីតិវិធីលម្អិត និងជំរុញការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ។ |
| ៣. ក្រសួង-ស្ថាប័នមានការពិបាកក្នុងការអនុវត្តថវិកាប្រចាំឆ្នាំ ដោយសារ (១) កញ្ចប់ថវិកាត្រូវបានផ្ញើជូនក្រសួង-ស្ថាប័ន និងអង្គភាពថវិកាយឺត (២) នីតិវិធីហិរញ្ញវត្ថុថ្មី (នីតិវិធីចំណាយរដ្ឋ-ទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ , វិធាន និងនីតិវិធីចំណាយប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ, និងវិធាននិងនីតិវិធីចំណាយសម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាល កិច្ចប្រជុំ សិក្ខាសាលា និងសន្និសីទសម្រាប់រដ្ឋបាលថ្នាក់ជាតិ) និងរបៀបប្រើប្រាស់មុខងារលើប្រព័ន្ធ FMIS នៅពុំទាន់ផ្សព្វផ្សាយបានទូលំទូលាយ និង (៣) ការអនុវត្តការបិទបញ្ជីចុងឆ្នាំមានភាពតឹងរឹង។ កត្តាទាំងអស់នេះ បណ្តាលឱ្យការអនុវត្តចំណាយថវិកាមានភាពយឺតយ៉ាវ និងចំណាយឆ្លងឆ្នាំមួយចំនួនពុំត្រូវបានទូទាត់ ហើយការបូកសរុបឯកសារហិរញ្ញវត្ថុ និងរៀបចំកិច្ចបញ្ជិកាគណនេយ្យដោយអង្គភាពហិរញ្ញវត្ថុ ដែលជា សេនាធិការរបស់ | ▪ ស្នើអគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងអគ្គនាយកដ្ឋាន រតនាគារជាតិ ពិនិត្យឡើងវិញលើលិខិតបទដ្ឋានថ្មីព្រមទាំងជំរុញការផ្សព្វផ្សាយលិខិតបទដ្ឋានថ្មីៗ ជាពិសេសពាក់ព័ន្ធការអនុវត្តថវិកា ព្រមទាំងបន្តពង្រឹងការពិភាក្សា និងកំណត់បញ្ហាប្រឈមជាមួយក្រសួង-ស្ថាប័ន ដែលអនុវត្តលិខិតបទដ្ឋានថ្មី ដើម្បីធានាថាការអនុវត្តថវិកាមានភាពរលូន។ |

| | |
|---|---|
| អាណាប័កដើមខ្សែ គឺមានភាពស្មុគស្មាញ និងត្រូវការពេលវេលាច្រើន ដោយហេតុថា អង្គភាពហិរញ្ញវត្ថុត្រូវសម្រប-សម្រួលជាមួយអង្គភាពថវិកាជាច្រើន។ | |
| ***ផ្នែកទី២ "គណនេយ្យភាពហិរញ្ញវត្ថុ"*** | |
| ***គ. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*** | |
| ៤. ការកំណត់ទម្រង់របាយការណ៍ហិរញ្ញវត្ថុមួយសម្រាប់រដ្ឋបាលរាជធានី-ខេត្ត ដែលអាចផលិតចេញពីប្រព័ន្ធ FMIS ដើម្បីជៀសវាងការប្រើប្រាស់របាយការណ៍មានទម្រង់ច្រើន និងបន្ទុកដល់មន្ត្រីទទួលបន្ទុក ដែលប្រើប្រាស់ប្រព័ន្ធដោយដៃផង និងប្រព័ន្ធផងក្នុងផលិតរបាយការណ៍។ | ស្នើ FMWG សហការជាមួយអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលរាជធានី-ខេត្តសិក្សាលើតម្រូវការរបាយការណ៍ហិរញ្ញវត្ថុ។ |
| ៥. ការបន្តពង្រីកប្រព័ន្ធ FMIS នៅការដ្ឋានកាន់តែច្រើនបានបង្កើនបន្ទុកចំណាយ, ចំនួនមន្ត្រី និងបន្ទុកការងារ។ មុខងារប្រព័ន្ធត្រូវបានដាក់ឱ្យប្រើប្រាស់ ប៉ុន្តែពុំទាន់អនុវត្តពេញលេញនៅឡើយ។ ម្យ៉ាងទៀត អគ្គនាយកដ្ឋានជំនាញពុំបានចូលរួមពេញលេញលើការសិក្សានីតិវិធីអនុវត្តការងារសម្រាប់មុខងារថ្មីៗ ដែលកិច្ចការនេះត្រូវបានសិក្សា និងរៀបចំឡើងដោយលេខាធិការដ្ឋាន FMWG ដែលអាចនាំឱ្យពិបាកកំណត់នីតិវិធីអនុវត្តការងារច្បាស់លាស់, អនុវត្តដោយរលូន និងកែសម្រួលច្រើនលើក។ | គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃ កសហវ. ដឹកនាំកិច្ចប្រជុំពិនិត្យលើការអនុវត្តគម្រោង FMIS និងរំហូរនីតិវិធីអនុវត្តការងារថ្នាក់ជាតិ។ |
| ***គ. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ*** | |
| ៦. ក្រសួង-ស្ថាប័នមួយចំនួនពុំទាន់ចាប់ផ្តើមអនុវត្ត ប្រព័ន្ធ SARMIS និងបញ្ហាប្រឈមជាបច្ចេកទេសមួយចំនួន រួមមានការពិបាកពិនិត្យទិន្នន័យតាមការិយាល័យ, តារាងទិន្នន័យបានជម្រះ គ្មានជួរឈរបញ្ជាក់អត្តសញ្ញាណ និងមិនអាចកំណត់ទិន្នន័យជាក្រុម ក្នុងតារាងចុះបញ្ជី។ | ស្នើអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធបន្តជំរុញការប្រើប្រាស់ប្រព័ន្ធ SARMIS នៅតាមក្រសួង-ស្ថាប័ន និងកែលម្អប្រព័ន្ធ SARMIS បន្ថែមទៀត។ |
| ៧. អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋបានធ្វើប័ណ្ណកម្មសិទ្ធិរួចរាល់លើទីតាំងចំនួន ១៧ ៧៦៤ កន្លែង ស្មើនឹង ៦២% នៃទីតាំងសរុបចំនួន ២៨ ៥៦០ កន្លែង ចំណែកទីតាំងដែលគ្មានប័ណ្ណកម្មសិទ្ធិដីធ្លីទ្រព្យសម្បត្តិរដ្ឋចំនួន ៣៨% ស្មើនឹង ១០ ៧៩៦ កន្លែង។ | ស្នើអគ្គនាយកដ្ឋានសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធបន្តជំរុញការងារការរៀបចំប័ណ្ណកម្មសិទ្ធិដីធ្លីនៃទ្រព្យសម្បត្តិរដ្ឋ និងការរៀបចំផែនការគោលនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ |
| ***ផ្នែកទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"*** | |
| ***ឃ. ការកែទម្រង់វិមជ្ឈការហិរញ្ញវត្ថុនិងប្រព័ន្ធថវិកានៅថ្នាក់ក្រោមជាតិ*** | |

| | |
|---|---|
| ៨.រដ្ឋបាលថ្នាក់ក្រោមជាតិពិបាកក្នុងការកំណត់សូចនាករសមិទ្ធកម្មលទ្ធផលក្នុងផ្នាំនិងគោលដៅ/ លទ្ធផលចុងក្រោយ និងគោលដៅក្នុង BSP និងថវិកាកម្មវិធី រួមទាំងការរៀបចំរបាយការណ៍សមិទ្ធកម្ម។ | ស្នើអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិបន្តការបណ្តុះបណ្តាល និងរៀបចំគោលការណ៍ណែនាំលម្អិតលើការតាមដានត្រួតពិនិត្យសមិទ្ធកម្ម/ លទ្ធផល។ |
| ៩.ការអនុវត្តថវិកាកម្មវិធីថ្នាក់ក្រោមជាតិត្រូវបាននិងកំពុងអនុវត្តនៅរដ្ឋបាលរាជធានី-ខេត្ត ប៉ុន្តែតម្រូវឱ្យមានការសម្របសម្រួលជាច្រើនដើម្បីដោះស្រាយ បញ្ហាឈម។ | ស្នើអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិគួររៀបចំសិក្ខាសាលាស្តីពីការអនុវត្តថវិកាថវិកាកម្មវិធីជាប្រចាំឆ្នាំ។ |
| ***ផ្នែកទី៤ "ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់"*** | |
| ***ខ. លិខិតបទដ្ឋានគតិយុត្ត*** | |
| ១០.ការរៀបចំលិខិតបទដ្ឋានគោល (ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី, អនុក្រឹត្យលេខ៨១ និង៨២) ត្រូវបានពន្យារពេល។ | ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មីនឹងត្រូវបញ្ជូនទៅអង្គនីតិបញ្ញត្តិនៅត្រីមាសទី៤ ឆ្នាំ២០២២ រីឯអនុក្រឹត្យលេខ៨១ និង៨២ នៅត្រីមាសទី១ ឆ្នាំ២០២៣ ត្រូវបញ្ជូនទៅប្រមុខរាជរដ្ឋាភិបាល។ |
| ***ផ្សេងៗ*** | |
| ***ច. មន្ទីរ សហវ*** | |
| ១១.មន្ទីរ សហវ. រាជធានីខេត្ត បំពេញមុខងារជាអភិបាលហិរញ្ញវត្ថុនៅថ្នាក់មូលដ្ឋាន និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែមានការពិបាកក្នុងការបំពេញមុខងារលើការងារមួយចំនួនក្នុងនោះរួមមាន÷ (១) ពុំមានសិទ្ធិក្នុងការពិនិត្យរបាយការណ៍សម្រាប់ការបង់ចំណូលក្នុង NRMIS របស់មន្ទីរជំនាញ, (២) ការជំរុញឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋធ្វើប័ណ្ណកម្មសិទ្ធិដីធ្លី, (៣) ផែនការលទ្ធកម្មរបស់មន្ទីរជំនាញមានទំហំថវិកាតូចដែលពិបាកក្នុងការអនុវត្តនីតិវិធីលទ្ធកម្ម និង (៤) ការបូកសរុបរបាយការណ៍សមិទ្ធកម្មរបស់មន្ទីរជំនាញ គឺមិនទាន់អាចបូកសរុបបាន ដោយសារមន្ទីរជំនាញពុំបានផ្ញើជូនមន្ទីរ សហវ.។ | ស្នើ អ.គ.ហ. សហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទ កសហវ. ពិនិត្យ និងដោះស្រាលើបញ្ហាប្រឈមរបស់មន្ទីរ សហវ. ជាជំហាន។ |

## ៤. សន្និដ្ឋាន

១៣៩. របាយការណ៍ត្រួតពិនិត្យវឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២១ បានផ្តល់នូវការវាយតម្លៃគ្រប់ជ្រុងជ្រោយ ទាំងលើទិដ្ឋភាពនៃការអនុវត្ត ការវិភាគ និងវាយតម្លៃល្អិតល្អន់លើភាពខ្លាំង និងភាពខ្សោយនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ផ្អែកលើលទ្ធផលប្រចាំឆ្នាំ ២០២១ នេះ ការអនុវត្តផែនការសកម្មភាពគាំទ្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទទួលបានលទ្ធផលល្អប្រសើរ ដោយក្នុងនោះអង្គភាពក្រោមឱវាទ កសហវ. ជាង ១០០% អនុវត្តផែនការបានលើសពី ៨៥%, មន្ទីរ សហវ. រាជធានីខេត្ត ជាង ៨៨% អនុវត្តផែនការបានលើសពី ៨៥%, និងក្រសួង-ស្ថាប័ន ជាង ៧០% អនុវតផែនការបានលើសពី ៨៥% ស្របនឹងសមិទ្ធកម្មតាមអង្គភាពនៃ កសហវ.។ ម្យ៉ាងទៀត គុណភាពការរៀបចំ GDAP/MAP និងការរាយការណ៍មានគុណភាពប្រសើរជាងមុនផងដែរ ដែលងាយស្រួលរំលេច និងកំណត់ជារួមក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

១៤០. ទោះបីជាមានការវិវឌ្ឍគួរឱ្យកត់សម្គាល់ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក៏នៅមានការងារដែលត្រូវធ្វើបន្ត ដើម្បីសម្រេចឱ្យនូវដំណាក់កាលទី៣ “**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**” ដែលបានឆ្លុះបញ្ចាំងនៅគ្រប់ផ្នែកនៃផែនការសកម្មភាពរួម ដូចខាងក្រោម÷

១៤១. **ផ្នែកទី១÷** ការធ្វើពិពិធកម្មចំណូលថវិកាប្រកបដោយចីរភាព, ការរៀបចំច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងឯកសារគោល (Blueprint), ក្របខណ្ឌគោលនយោបាយស្តីការអភិវឌ្ឍមូលបត្ររដ្ឋ, ការកំណត់និយមន័យចំណាយកកស្ទះ, ភាពរលូននៃការអនុវត្តចំណាយថវិកាប្រចាំត្រីមាស និងការជំរុញរៀបចំគោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ PFMM

១៤២. **ផ្នែកទី២÷** ការជំរុញការប្រើប្រាស់ចំណាត់ថ្នាក់មុខងារក្នុងការរៀបចំ តាមដាន និងរៀបចំរបាយការណ៍, ការជំរុញកាត់បន្ថយនីតិវិធីការងារ និងពង្រឹងមុខងារប្រព័ន្ធ ដើម្បីឈានទៅការធ្វើស្វ័យប្រវត្តិកម្ម, ការឈានទៅការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ តាមប្រព័ន្ធ SARMIS និងធ្វើប័ណ្ណកម្មសិទ្ធិដីធ្លី, ការជំរុញគ្រឹះស្ថានសាធារណៈរដ្ឋបាលអនុវត្តនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុថ្មី។

១៤៣. **ផ្នែកទី៣÷** អភិវឌ្ឍប្រព័ន្ធថវិការយៈពេលមធ្យម, ការបង្កើនគុណភាព BSP និងបង្កើត និងបង្កើនអង្គភាពថវិកាព្រមទាំងការធ្វើសមាហរណកម្មថវិកាវិនិយោគ ទៅក្នុងកម្មវិធី។

១៤៤. **ផ្នែកទី៤÷** ការជំរុញការរៀបចំច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងអនុក្រឹត្យពាក់ព័ន្ធសម្រាប់ការអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មមានការពន្យារពេល និងការរៀបចំក្របខណ្ឌសម្រាប់អនុវត្ត និងត្រួតពិនិត្យថវិកាព័ត៌មានសមិទ្ធកម្ម,។

១៤៥. **ផ្នែកទី៥÷** ការកសាងសមត្ថភាពឱ្យស្របតាមល្បឿន នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការបង្កើតឱ្យក្របខណ្ឌរួមសម្រាប់ការងារកែទម្រង់បីបួកមួយ។

១៤៦. នីតិវិធីនៃការអនុវត្តថវិកាត្រូវបានកែលម្អច្រើន, ប៉ុន្តែនៅមិនទាន់អាចធានាបាននូវភាពឆាប់រហ័ស, ភាពត្រឹមត្រូវ និងភាពអាចប៉ាន់ប្រមាណបានតាមការរំពឹងទុកនៅឡើយ។ ការងារនេះមិនមែនជាការងារដាច់ដោយឡែក របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនោះទេ ប៉ុន្តែក៏ជាការងារផ្ទាល់របស់ក្រសួង-ស្ថាប័នផងដែរ។កសហវ. បានធ្វើការកែ-

សម្រួលមួយចំនួនហើយលើបញ្ហានេះ, ក៏ប៉ុន្តែក្រសួង ស្ថាប័នសាមី ក៏ត្រូវខិតខំកាត់បន្ថយនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីបង្កើនប្រសិទ្ធភាព និងតម្លាភាពផ្ទៃក្នុងរបស់ខ្លួនផងដែរ។ ភាពចាំបាច់ក្នុងការបន្ត ការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រ និងឆ្លើយតបទៅនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាពិសេសឆ្ពោះទៅប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម។

១៤៧. គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈធ្វើការវាយតម្លៃ និងសន្និដ្ឋានជារួមនៃការអនុវត្តគ្រប់ផ្នែក នៃផែនសកម្មភាពរួម ដំណាក់កាលទី ៣បូក២ ឆ្នាំ២០២១ ដូចខាងក្រោម÷

១៤៨. **ថវិកានៅតែមានភាពជឿទុកចិត្ត** គឺនៅតែរក្សាបានជាសារវន្តដោយរក្សាបាននូវភាពរឹងមាំង ការប្រមូលចំណូល, អនុបាតបំណុលសាធារណៈនៅមានកម្រិតទាប, លុបបំណាយកកស្ទះ និងការអនុវត្តថវិកាខិតទៅរកគោលដៅ។

១៤៩. **បុរេលក្ខខណ្ឌសំខាន់ៗនៃគណនេយ្យភាពហិរញ្ញវត្ថុ** ត្រូវបាន និងកំពុងកសាង និងបន្តពង្រឹងបន្ថែម ដើម្បីធានាគណនេយ្យភាព និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង តាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS, ការជំរុញការអនុវត្តនីតិវិធីការងារថ្មីតាមប្រព័ន្ធ និងបង្កើនកម្រិតស្វ័យប្រវត្តិកម្ម និងសុក្រឹតភាពនៃការផលិតរបាយការណ៍ និងភាពទាន់ពេលនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។ បន្ថែមពីនេះ ត្រូវបានពង្រឹង និងពង្រីកវិសាលភាព ទាំងក្នុងទិដ្ឋភាពនៃការអនុវត្តចំណាត់ថ្នាក់ថវិកា និងក្នុងទិដ្ឋភាពនៃការគ្របដណ្តប់លើស្ថាប័ន និងភ្នាក់ងារចំណាយរបស់រាជរដ្ឋាភិបាល ឱ្យស្របតាមស្តង់ដាអន្តរជាតិ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងថវិកា និងរំហូរសាច់ប្រាក់។

១៥០. **ក្របខណ្ឌថវិកាកម្មវិធី** ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្តទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាមួយការរៀបចំ និងអនុវត្តសាកល្បងក្របខណ្ឌថវិការយៈពេលមធ្យមដោយបញ្ចូលការកំណត់ពិតានចំណាយ និងបែងចែកធានធានថវិកាបម្រើឱ្យគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

១៥១. **បុរេលក្ខណៈសំខាន់ៗនៃគណនេយ្យភាពសមិទ្ធកម្ម** ត្រូវបាននិងកំពុងរៀបចំជាបណ្តើរ ប៉ុន្តែស្ថិតក្នុងដំណាក់កាលបឋមនៅឡើយ។ ក្នុងន័យនេះ បុរេលក្ខណៈសំខាន់ៗត្រូវបានកំណត់ និងបញ្ចូលក្នុងផែនការសកម្មភាព ដំណាក់កាលអន្តរកាលឆ្ពោះទៅដំណាក់កាលទី៤។

១៥២. **សមត្ថភាពមន្ត្រីនៃក្រសួង-ស្ថាប័នក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ត្រូវបានពង្រឹងជាបណ្តើរៗ និងកម្រិតនៃការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុមានការកើនឡើងជា លំដាប់។

១៥៣. ការវាយតម្លៃ PEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានផ្តល់ជាលទ្ធផលគោល/បន្ទាត់មូលដ្ឋាន (Baseline) អំពីស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ដើម្បីផ្តល់ជាធាតុចូលសម្រាប់រៀបចំក្របខណ្ឌផែនការសកម្មភាព តាមរយៈការកំណត់ការដ្ឋានអាទិភាព ដើម្បីដោះស្រាយជាដំណាក់កាលៗ ដើម្បីឈានទៅសម្រេចឱ្យបានចក្ខុវិស័យ និងបេសកកម្មនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគោលការណ៍ ០៣ រួមមាន បូរណភាពនៃការគោរពវិន័យថវិកា, ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ទាំងក្នុងផ្នែកប្រតិបត្តិការ, និងស័ក្តិសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ។ បន្ថែមពីនេះ, ការផ្តល់មតិយោបល់របស់ដៃគូអភិវឌ្ឍន៍ តាមរយៈការត្រួតពិនិត្យលើប្រសិទ្ធភាពប្រព័ន្ធ FMIS និងត្រួតពិនិត្យចំណាយសាធារណៈបានផ្តល់មូលដ្ឋាន សម្រាប់កែលម្អ

គុណប្រព័ន្ធ FMIS និងកំណត់ចំណុចបញ្ហាប្រឈម និងអនុសាសន៍កែលម្អការគ្រប់គ្រងថវិកានៅតាមក្រសួង-ស្ថាប័ន។

១៩៤. **ជារួម, ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព គឺមូលដ្ឋានគ្រឹះដ៏ចាំបាច់មិនអាចខ្វះបាន សម្រាប់ការជំរុញអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្រ ជាពិសេសតាមរយៈការធានានូវកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ដល់ប្រជាជន ព្រមទាំងរួមចំណែកសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា។**

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១ ÷ វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. ប្រចាំឆ្នាំ២០២១

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព<br>(គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២) | |
|---|---|---|---|---|---|
| I. | **វឌ្ឍនភាពសម្រេចបាន** | | | | |
| ០១ | សេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន | CUPPP | ត្រីមាសទី៤ ឆ្នាំ២០២១ | ប្រកាសឱ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២១។ | |
| ០២ | អនុក្រឹត្យស្តីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិអំណាចជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា | GDB | - | អនុក្រឹត្យ ត្រូវបានអនុម័តដោយប្រមុខរាជ-រដ្ឋាភិបាលនៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០២១។ | |
| ០៣ | ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌ PFMRP ដំណាក់កាលទី៤ | EFI | ត្រីមាសទី១ ឆ្នាំ២០២១ | ផែនការយុទ្ធសាស្ត្រត្រូវបានអនុម័តដ៏ខ្ពង់-ខ្ពស់ពី ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ តាមចំណារចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ២០២១ ហើយកំពុងស្ថិតក្នុងការរៀបចំទីតិវិធីបោះពុម្ព និងគ្រោងផ្សព្វផ្សាយនៅក្នុងត្រីមាសទី ១ ឆ្នាំ២០២២ ។ | |
| ០៤ | សន្ធានកម្មរវាង FMIS និងប្រព័ន្ធបៀវត្សរបស់ក្រសួងមុខងារសា-ធារណៈ | FMWG និង MCS | ត្រីមាសទី១ ឆ្នាំ២០២១ | បានដាក់ឱ្យដំណើការនៅ កសហវ. និងក្រសួងមុខងារសាធារណៈ នៅក្នុងខែឧសភា ឆ្នាំ២០២១ សម្រាប់ផ្តល់ជាគំរូ និងមូលដ្ឋានក្នុងការឈានទៅអនុវត្តនៅក្រសួង- ស្ថាប័នផ្សេងទៀត នៅដំណាក់កាលបន្ទាប់។ | |
| ០៥ | របាយការណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ថ្នាក់ជាតិ ឆ្នាំ២០២០ | GSC | ត្រីមាសទី២ ឆ្នាំ២០២១ | PEFA Check នៅថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ២០២២។ បានផ្សព្វផ្សាយនៅថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២១។ រៀបចំសិក្ខាសាលានៅថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០២២។ | |
| ០៦ | ផែនការសកម្មភាពសម្រាប់ជំរុញការបង្កើតអង្គភាពថវិកា | GDB | ត្រីមាសទី៤ ឆ្នាំ២០២១ | អគ្គនាយកដ្ឋានថវិកា បានរៀបចំផែនការសកម្មភាពសម្រាប់ ជំរុញការបង្កើតអង្គភាពថវិកា។ | |
| ០៧ | ការសិក្សាអំពីលទ្ធភាពបង្កើន អង្គភាពថវិកានៅរដ្ឋបាលរាជធានី-ខេត្ត និងរៀបចំជាផែនការសកម្មភាពជាក់លាក់ | GDSNAF | ត្រីមាសទី២ ឆ្នាំ២០២១ | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ បានរៀបចំរបាយការណ៍សិក្សាអំពីលទ្ធ-ភាពបង្កើនអង្គភាពថវិកានៅរដ្ឋបាល រាជធានី-ខេត្ត។ | |
| ០៨ | ផែនការធ្វើបណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋ | GDSP | ត្រីមាសទី២ ឆ្នាំ២០២១ | ផែនការសកម្មភាព ត្រូវបានធ្វើបច្ចុប្បន្នភាពបន្ថែម ក្នុងកម្រិតក្រុមការងារអន្តរក្រសួង។ | |
| II. | **វឌ្ឍនភាពបន្តតាមដាន** | | | | |
| **ក. ក្របខណ្ឌគតិយុត្ត** | | | | | |

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព (គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២) | |
|---|---|---|---|---|---|
| ១ | សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) | GDB | ត្រីមាសទី៤ ឆ្នាំ២០២២ | សេចក្តីព្រាងច្បាប់ គ្រោងបញ្ចប់កម្រិត កសហវ. និងបញ្ជូនទៅគណៈរដ្ឋមន្ត្រីនៅត្រីមាសទី៣ ឆ្នាំ២០២២ និងបញ្ជូនទៅអង្គនីតិប្បញ្ញត្តិនៅត្រីមាសទី៤ ឆ្នាំ២០២២។ | ● |
| ២ | សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | GDSPNTR | ត្រីមាសទី៤ ឆ្នាំ២០២២ | សេចក្តីព្រាងច្បាប់ បានដាក់ឆ្លងសិក្ខាសាលាពិគ្រោះយោបល់អន្តរក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍន៍, តំណាងសង្គមស៊ីវិល និងកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ កសហវ.។ ក្រុមការងារបានពិភាក្សា លើជំពូកទី១០ (ស្តីពីទោសប្បញ្ញត្តិ) ជាមួយក្រសួងយុត្តិធម៌ និងអង្គភាពប្រឆាំងអំពើពុករលួយ ចប់សព្វគ្រប់នាថ្ងៃទី ២៨ ខែមករា ២០២២។ ដំណាក់កាលបន្តនឹងដាក់ឆ្លងទៅគណៈកម្មាធិការគោល-នយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២។ | ● |
| ៣ | ក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ | GSC & GDICDM | ត្រីមាសទី៤ ឆ្នាំ២០២១ | ក្រុមការងារបច្ចេកទេសកំពុងបន្តរៀបចំសេចក្តីព្រាងក្របខណ្ឌគោលនយោបាយរួមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ២០២២-២០២៤។ | ▲ |
| ៤ | សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់-គ្រងសហគ្រាសសាធារណៈ | GDSP | ត្រីមាសទី ៤ ឆ្នាំ ២០២២ | សេចក្តីព្រាងច្បាប់ ត្រូវបានតាក់តែងជាទម្រង់ច្បាប់ និងខ្លឹមសារ រួចរាល់កម្រិតក្រុមការងារបច្ចេកទេស កសហវ.។ គ្រោងរៀបចំសិក្ខាសាលាពិគ្រោះយោបល់នាត្រីមាសទី១ ឆ្នាំ២០២២ និងគ្រោងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី នៅត្រីមាសទី៣ ឆ្នាំ២០២២។ ដោយសារត្រូវកសាងឯកសារយុទ្ធសាស្ត្រកែទម្រង់ សហគ្រាសសាធារណៈជាមុនសិន សម្រាប់ជាធាតុចូលបន្ថែមទៅលើសេចក្តីព្រាងច្បាប់នេះ។ | ● |
| ៥ | ការកែសម្រួលអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួត-ពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង | GDB | ត្រីមាសទី១ ឆ្នាំ២០២២ | បានបញ្ចប់ការពិភាក្សាត្រឹមកម្រិតអគ្គនាយកដ្ឋានថវិកា និងបានបញ្ជូនទៅជំនាញការបារាំងដើម្បីផ្តល់ធាតុចូល និងត្រៀមពិភាក្សា អន្តរអគ្គនាយកដ្ឋាន និងដាក់បញ្ចូលជាមួយសេចក្តីព្រាង កែសម្រួល | ● |

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព (គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២) | |
|---|---|---|---|---|---|
| | ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈ | | | អនុក្រឹត្យលេខ ៨២ អនក្រ.បក នៅត្រីមាសទី៣ ឆ្នាំ២០២២ នេះ។ | |
| ៦ | ការកែសម្រួលអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ | GDNT | ត្រីមាសទី១ ឆ្នាំ២០២២ | សេចក្តីព្រាងអនុក្រឹត្យលេខ ៨២ ត្រូវបានរៀបចំ និងត្រូវធ្វើបច្ចុប្បន្នភាពជាបណ្តើរៗ ដោយផ្អែកលើគោលការណ៍សម្រេចនៃក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ | ● |
| ៧ | គោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល | GSC | ត្រីមាសទី២ ឆ្នាំ២០២១ | ក្រុមការងារបច្ចេកទេស បាននិងកំពុងពិនិត្យ និងកែសម្រួលសេចក្តីព្រាងលើកទី៦ មុនដាក់ឆ្លងសិក្ខាសាលាពិគ្រោះយោបល់។ | ▲ |
| ៨ | សេចក្តីព្រាងប្រកាសគោលការណ៍ និងនីតិវិធីសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារចំពោះចំណូលពីសេវាសាធារណៈ: ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម និងក្នុងលក្ខខណ្ឌនៃការចែករំលែកចំណូលពីសេវាធារណៈនិងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ | GDSPNTR<br>GSC | ត្រីមាសទី៤ ឆ្នាំ២០២១ | បានបញ្ចប់សេចក្តីព្រាងប្រកាស និងដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័ន ទាំងកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំនៅខែកុម្ភៈ ឆ្នាំ២០២២។ សេចក្តីព្រាងប្រកាសនេះ គ្រោងគោរពជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ពិនិត្យ និងអនុម័ត នៅដើមត្រីមាសទី២ ឆ្នាំ២០២២។ បញ្ជាក់÷ បានដំឡើងគតិយុត្តភាពពីសេចក្តីព្រាងប្រកាសទៅជាសេចក្តីព្រាងអនុក្រឹត្យក្រោមចំណងជើងសេចក្តីព្រាង "អនុក្រឹត្យស្តីពីគោល- ការណ៍និងនីតិវិធីបន្ថែមសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារ និងការចែករំលែកចំណូលមិនមែនសារពើពន្ធ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ | ▲ |
| ៩ | ការរៀបចំសារាចររបស់រាជរដ្ឋាភិបាលសម្រាប់ជំរុញក្រសួង-ស្ថាប័ន ជាពិសេសក្រសួង-ស្ថាប័នស្ថិតក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចឱ្យធ្វើការផ្សព្វផ្សាយ ឬរៀបចំវេទិកាសាធារណៈ អំពីថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នសាមី ជូនសាធារណជន | GDB | ត្រីមាសទី៤ ឆ្នាំ២០២១ | សេចក្តីណែនាំអំពីការរៀបចំវេទិកាសាធារណៈ និងសៀវភៅថវិកាពលរដ្ឋ ដើម្បីផ្សព្វផ្សាយអំពីកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងនីមួយៗ ជូនដល់សាធារណជន និង ដៃគូរពាក់ព័ន្ធ ត្រូវបានសម្រេចដាក់ឱ្យអនុវត្តដោយជ្រើសរើសក្រសួងចំនួន ៤ រួមមាន÷ (១)-ក្រសួងអប់រំ យុវជន និងកីឡា (២)-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ | ▲ |

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព (គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២) | |
|---|---|---|---|---|---|
| | | | | សម្បទា (៣)- ក្រសួងធនធានទឹក និងឧតុ-និយម និង (៤)- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្ត តាមរយៈលិខិតលេខ ១៩៤៨ សហវ-អថ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០២២ ចាប់ពីឆ្នាំ ២០២២។ | |
| **ខ. យុទ្ធសាស្ត្រ** | | | | | |
| ១០ | សេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១ | ACAR | ត្រីមាសទី២ ឆ្នាំ២០២១ | សេចក្តីព្រាងចុងក្រោយយុទ្ធសាស្ត្រទទួលបានការឯកភាពជាគោលការណ៍ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលពីថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០២១។ អ.គ.ហ. សហការជាមួយនិយ័ត-ករគណនេយ្យនិងសវនកម្ម បាន និងកំពុងកែសម្រួលបន្ថែមដើម្បីគោរពជូនប្រមុខរាជរដ្ឋា-ភិបាល អនុម័ត។ | ▲ |
| ១១ | ឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃការងារកែទម្រង់ ៣ បូក ១ | GSC, NCDD, PAR & CLJR | ត្រីមាសទី៤ ឆ្នាំ២០២១ | សេចក្តីព្រាងឯកសារទស្សនាទាន ត្រូវបានរៀបចំ និងត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំកម្រិតអន្តរការដ្ឋានកែទម្រង់៣ បូក ១ ចំនួន ៣ លើក និងគម្រោងវិបស្សនា ត្រូវបានរៀបចំ។ | ▲ |
| ១២ | ចក្ខុវិស័យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | GSMEF | ត្រីមាសទី៤ ឆ្នាំ២០២១ | សេចក្តីព្រាងចក្ខុវិស័យ ត្រូវបានរៀបចំរួចរាល់ និងបានដាក់ឆ្លងកម្រិតថ្នាក់-ដឹកនាំ។ គ្រោងប្រជុំឆ្លងជាមួយ ឯកឧត្តមអគ្គបណ្ឌិត-សភាចារ្យ នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ខាងមុខ។ | ▲ |
| ១៣ | ផែនការមេសម្រាប់គ្រប់គ្រងទ្រព្យ-សម្បត្តិរដ្ឋរយៈពេលមធ្យមនិងវែង | GDSP | ត្រីមាសទី៤ ឆ្នាំ២០២២ | ក្រុមការងារសិក្សា និងរៀបចំឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានបង្កើតនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ ហើយបានរៀបចំមាតិកាគោលនិងខ្លឹមសារព្រាងខ្លះៗនៃជំពូកនីមួយៗ។ | ● |

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព (គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២) | |
|---|---|---|---|---|---|
| ១៤ | ឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ | GDSP | ត្រីមាសទី៤ ឆ្នាំ២០២១ | បានពិនិត្យឯកសារគោលដោយសម្រួលខ្លឹមសារពីភាសាអង់គ្លេស ទៅភាសាខ្មែរឱ្យត្រឹមត្រូវតាមពាក្យ និងទិដ្ឋភាពបច្ចេកទេស ដើម្បីដាក់ជូនក្រុមការងារកម្រិតអន្តរ-អគ្គនាយកដ្ឋាន នៃ កសហវ. ពិនិត្យកែសម្រួលចុងក្រោយ។ បានរៀបចំប្រជុំកែសម្រួលសេចក្តីព្រាងលើកទី៣ ដោយក្រុមការងារ.កសហវ. នាថ្ងៃទី២១ មីនា ២០២២។ | ▲ |
| **គ. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន** | | | | | |
| ១៥ | សន្ទានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធ EFMS របស់ក្រសួងអប់រំ យុវជន និងកីឡា | MoEYS&F MWG | ត្រីមាសទី១ ឆ្នាំ២០២២ | ក្រសួងអប់រំ យុវជន និងកីឡា កំពុងធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍបន្ថែមមុខងារការទិញ និងមុខងារត្រូវសង លើប្រព័ន្ធ EFMS ជំនាន់ទី ៣ ថ្មី ដែលគ្រោងនឹងបញ្ចប់ និងដាក់ឱ្យប្រើប្រាស់នៅខែមេសា ឆ្នាំ២០២២។ ជាមួយគ្នានេះ ក្រុមការងារ FMIS កំពុងផ្តល់កិច្ចសហការក្នុងការផ្តល់ធាតុចូល និងតម្រូវការនានាជូនក្រុមការងារ MoEYS ដើម្បីសិក្សាលម្អិតអំពីតម្រូវការព័ត៌មាននៅតាមដំណាក់កាលនៃការអភិវឌ្ឍប្រព័ន្ធ EFMS ទៅតាមមុខងារ នីមួយៗក្នុងការធ្វើសន្ទានកម្មរវាងប្រព័ន្ធទាំង២។ ឆ្នាំ២០២២ នេះ នឹងគ្រោងធ្វើសន្ទានកម្មតែមួយមុខងារការទិញ និងឆ្នាំ២០២៣ មុខងារត្រូវសង។ | ● |
| **ឃ. យន្តការ** | | | | | |
| ១៦ | ការពិនិត្យនិងសិក្សារៀបចំការបែង-ចែកមុខងាររបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ចតាមក្រសួង-ស្ថាប័ន អនុលោមតាមអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ | GI&GDIA | ត្រីមាសទី៤ ឆ្នាំ២០២១ | បានតាមដានការអនុវត្តអនុក្រឹត្យលេខ ១៦៨ អនក្រ.បក នៅតាមបណ្តាក្រសួង-ស្ថាប័នចំនួន ១២។ ជាជំហានបន្ទាប់ អគ្គាធិការដ្ឋាននឹងរៀបចំក្របខ័ណ្ឌនិងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូលក្រោមជំនួយបច្ចេកទេសពី AFD។ | ▲ |

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព (គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២) | |
|---|---|---|---|---|---|
| ១៧ | របាយការណ៍ PEFA ថ្នាក់ក្រោម-ជាតិ ឆ្នាំ២០២០ | GSC | ត្រីមាសទី២ ឆ្នាំ២០២១ | បានបញ្ចប់ការកែសម្រួលសេចក្ដីព្រាងទី១ ដោយបានពិនិត្យនិងកែសម្រួលតាមមតិ-យោបល់របស់ក្រុមការងារ PEFA, លេខាធិ-ការដ្ឋាន PEFA និងដៃគូអភិវឌ្ឍន៍។ ជាការងារបន្ទាប់ អ.គ.ហ. នឹងរៀបចំសិក្ខា-សាលាពិគ្រោះយោបល់លើសេចក្ដីព្រាងនេះនៅចុងត្រីមាសទី១ ឆ្នាំ២០២២។ | ▲ |
| ១៨ | ក្របខណ្ឌរួម ផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ | GSC | ត្រីមាសទី៤ ឆ្នាំ២០២១ | ក្រុមជំនាញការ ស្ថិតនៅក្នុងដំណាក់កាលគ្រោងបញ្ចប់ការធ្វើសុពលភាពទៅលើរបាយការណ៍សិក្សាអំពីជំហានចំណាយនីមួយៗ ដើម្បីអាចពិភាក្សាបឋមទាក់ទងនឹងរបកគំហើញនាពេលខាងមុខ។ | ▲ |
| ១៩ | កម្មវិធីសិក្សាភ្ជាប់វិញ្ញាបនបត្រ (Certificate Program) ដោយផ្សារភ្ជាប់មុខតំណែងឱ្យបានគ្រប់ជ្រុងជ្រោយ | EFI | ត្រីមាសទី៤ ឆ្នាំ២០២១ | សេចក្ដីព្រាងប្រកាសអន្តរក្រសួង ស្ដីពីគុណ-វុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានពិគ្រោះយោបល់ និង រៀបចំកម្រិត វសហ។ ទន្ទឹមនឹងនេះ កម្មវិធីសិក្សា Certificate Program កំពុងរៀបចំស្របតាមផែនការយុទ្ធសាស្ត្រកសាង និងអភិវឌ្ឍសមត្ថភាពដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី៤ និង អាចអនុវត្តបានក្នុងឆ្នាំ ២០២៣ ខាងមុខ។ | ▲ |
| ២០ | ការវាយតម្លៃលើបច្ច័យនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM Impact Assessment) | GSC | ត្រីមាសទី៤ ឆ្នាំ ២០២១ | សេចក្ដីព្រាងរបាយការណ៍បឋមនៃការវាយតម្លៃនេះ កំពុងរៀបចំ និងបន្តកែសម្រួលដើម្បីត្រៀមជួបប្រជុំជាមួយក្រុមការងារ បច្ចេកទេស។ | ▲ |
| ២១ | ពិនិត្យ និងធ្វើបច្ចុប្បន្នភាពសមាស-ភាពគណៈកម្មាធិការ, គណៈកម្មា-ការ និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | GSC | ត្រីមាសទី៤ ឆ្នាំ ២០២១ | បានរៀបចំសេចក្ដីព្រាងសេចក្ដីសម្រេច និង កំពុងពិនិត្យធ្វើបច្ចុប្បន្នភាពសមាសភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគ្រោងគោរពស្នើសុំឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ពិនិត្យ និងសម្រេចលើសមាសភាពនៅត្រីមាសទី ២ ឆ្នាំ២០២២ នេះ។ | ▲ |
| ២២ | ការបង្កើតក្រុមការងារអន្តរអគ្គ-នាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច | GSMEF | ត្រីមាសទី១ ឆ្នាំ ២០២២ | បានបែងចែកក្រុមការងារដើម្បីសិក្សាទៅលើក្របខណ្ឌគតិយុត្តដែលមានស្រាប់ និង | ● |

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព (គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២) | |
|---|---|---|---|---|---|
| | និងហិរញ្ញវត្ថុ សិក្សា និងវាយតម្លៃអំពីមុខងាររបស់មន្ទីរ សហវ. និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | | | រៀបចំបំពេញបន្ថែមនូវចំណុចដែលចែងមិនច្បាស់លាស់ ដើម្បីរៀបចំជាសេចក្តីព្រាងគោលការណ៍ថ្មី។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋាន កសហវ. បានរៀបចំជាសេចក្តីព្រាងគោលការណ៍ណែនាំ។ | |
| ២៣ | មូលនិធិ PFMRP គ្រប់ជ្រុងជ្រោយ | GSC | ត្រីមាសទី៣ ឆ្នាំ២០២១ | បានរៀបចំរបាយការណ៍សិក្សាលម្អិតអំពីការអនុវត្តមូលនិធិ PFMRP ដំណាក់កាលទី ១ និងការឈានទៅអនុវត្ត ដំណាក់កាលទី២ និងបានទទួលការឯកភាពជាគោលការណ៍ពីឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២២។ | ▲ |
| ២៤ | ការវាយតម្លៃការអនុវត្តក្របខណ្ឌថវិកាទូទាំងប្រទេស (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) | GSC | ត្រីមាសទី២ ឆ្នាំ ២០២២ | របាយការណ៍វាយតម្លៃបឋម ត្រូវបានដាក់ឆ្លងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃ កសហវ. នៅថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២២។ របកគំហើញនៃរបាយការណ៍ នឹងត្រូវដាក់បញ្ចូលក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៤។ | ● |
| ២៥ | ការវាយតម្លៃរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ក្របខណ្ឌ TADAT | GSC | ត្រីមាសទី៤ ឆ្នាំ ២០២១ | ការវាយតម្លៃ TADAT ត្រូវបានបញ្ចប់ដោយជោគជ័យ បន្ទាប់ពីលទ្ធផលនិងខ្លឹមសាររបាយការណ៍នៃការវាយតម្លៃ ត្រូវបានធ្វើសុពលភាពដោយលេខាធិការដ្ឋាន TADAT និងគណៈកម្មការវាយតម្លៃ TADAT។ អគហបានគោរពរាយការណ៍ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ។ | ▲ |
| ២៦ | ការរៀបចំសៀវភៅថវិកាពលរដ្ឋ (Citizen Budget) និងវេទិកាផ្សព្វផ្សាយថវិកាកម្មវិធីជូនសាធារណជន របស់ក្រសួងអាទិភាព ចំនួន ០៤ ដែលក្រសួងចំនួន ០២ ស្ថិតក្នុងវិស័យសេដ្ឋកិច្ច និងក្រសួងចំនួន ០២ ទៀតស្ថិតក្នុងវិស័យសង្គមកិច្ច | GDB& GSC | ចាប់ផ្តើមពីឆ្នាំ ២០២២ | សេចក្តីណែនាំអំពីការរៀបចំវេទិកាសាធារណៈ និងសៀវភៅថវិកាពលរដ្ឋ ដើម្បីផ្សព្វផ្សាយអំពីកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងនីមួយៗ ជូនដល់សាធារណជន និង ដៃគូពាក់ព័ន្ធ ត្រូវបានសម្រេចដាក់ឱ្យអនុវត្តដោយការជ្រើសរើសក្រសួងចំនួន ៤ រួមមាន÷ (១)- ក្រសួងអប់រំ យុវជន និងកីឡា (២)- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (៣)- ក្រសួងធនធានទឹក និងឧតុ- | ● |

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព (គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២) | |
|---|---|---|---|---|---|
| | | | | និយមនិង(៤)- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្ត តាមរយៈលិខិតលេខ ១៩៤៨ សហវ-អថ ចុះថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០២២។ | |
| ២៧ | ជំរុញក្រសួង- ស្ថាប័នអាទិភាព ចំនួន ០៥-០៧ រៀបចំ FMM របស់ក្រសួង- ស្ថាប័នសាមី | GSC | ២០២២ | កាលពីខែមករា ឆ្នាំ២០២២, អ.គ.ហ.បាន រៀបចំកិច្ចប្រជុំជាមួយក្រសួង- ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមរៀបចំ FMM។ ក្នុងនោះ ក្រសួង- ស្ថាប័នចំនួន ១២ បានដាក់ផែនការសកម្មភាពរៀបចំ FMM តាមយន្តការ MAP និង GDAP សម្រាប់ឆ្នាំ២០២២។ | ● |
| III. វឌ្ឍនភាពបន្តតាមដាន | | | | | |
| ក. ក្របខណ្ឌគតិយុត្ត | | | | | |
| ០១ | ការប្រើប្រាស់ធាតុចូលដែលទទួលបានពីរបាយការណ៍វាយតម្លៃការអនុវត្តប្រព័ន្ធ FMIS និងការវាយតម្លៃចំណាយសាធារណៈ បញ្ចូលក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4)។ | GSC | ២០២២ | - | - |
| ០២ | ការកំណត់វិធានការគន្លឹះជំរុញល្បឿនការងារកែទម្រង់ (Reform Triggers) ឆ្នាំ២០២២ | GSC | ២០២២ | - | - |
| ០៣ | ការពិនិត្យលើការផ្ទេរមុខងារចំនួន ៥៥ មុខងារ ទៅរដ្ឋបាលក្រុង ស្រុក និងថវិកាឱ្យស្របតាមមុខងារទាំង ៥៥ | GDSNAF | ២០២២ | - | - |
| ០៤ | ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអាករពិសេស | LCs, GDT, GDCE | - | - | - |
| ០៥ | ការពិនិត្យលើការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ នៅតាមក្រសួង- ស្ថាប័ន | GDB, GDNT | ២០២២ | - | - |

| ល.រ | ការសម្រេចរបស់ គ.ហ.ស. | អង្គភាពទទួលបន្ទុក | គោលដៅបញ្ចប់ | វឌ្ឍនភាព (គិតត្រឹមថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២) | |
|---|---|---|---|---|---|
| ០៦ | ការជំរុញក្រសួង-ស្ថាប័នក្នុងការអនុវត្ត SARMIS ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | GDSPNR | ២០២២ | - | - |
| ០៧ | ការជំរុញការរៀបចំបណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋ និងផែនការមេសម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ | GDSPNR | ២០២២ | - | - |

## ឧបសម្ព័ន្ធទី២៖ តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់អង្គភាពក្រោមឱវាទ កសហវ. ប្រចាំឆ្នាំ២០២១

| ល.រ. | អង្គភាពក្រោមឱវាទ កសហវ. | ថវិកាឆ្នាំ២០២១ (គិតជាពាន់រៀល) | | | | # សកម្មភាព សម្រេចបាន | ពិន្ទុភាគរយ ប្រចាំឆ្នាំ២០២១ |
|---|---|---|---|---|---|---|---|
| | | ថវិកាអនុវត្ត PFMRP | ឧបត្ថម្ភលើក ទឹកចិត្ត PFM | ឧបត្ថម្ភលើកទឹក-ចិត្តក្រៅ PFM | ថវិកាសរុប | | |
| 1 | អគ្គនាយកដ្ឋានគោលនយោបាយ | 506,489 | 495,535 | - | 1,002,024 | 19/22 | 93% |
| 2 | អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | 32,514 | - | - | 32,514 | 12/13 | 96% |
| 3 | អគ្គនាយកដ្ឋានពន្ធដារ | 407,671 | - | - | 407,671 | 21/29 | 97% |
| 4 | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | 155,702 | - | - | 155,702 | 6/14 | 92% |
| 5 | អគ្គនាយកដ្ឋានថវិកា | 316,107 | 427,637 | 189,708 | 933,452 | 56/59 | 98% |
| 6 | អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | 262,933 | 328,822 | - | 591,755 | 29/40 | 92% |
| 7 | អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | - | 155,542 | - | 155,542 | 17/17 | 100% |
| 8 | អគ្គនាយកដ្ឋានរតនាគារជាតិ | 509,475 | 266,122 | 490,000 | 1,265,597 | 24/26 | 98% |
| 9 | អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | 50,372 | 98,519 | - | 148,891 | 4/10 | 87% |
| 10 | អគ្គលេខាធិការដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 368,800 | 396,834 | 1,454,107 | 2,219,741 | 30/36 | 98% |
| 11 | អគ្គាធិការដ្ឋាន | - | 136,937 | - | 136,937 | 16/20 | 94% |
| 12 | អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | 238,067 | 274,233 | 73,520 | 585,820 | 13/16 | 92% |
| 13 | វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | 77,722 | 177,593 | 188,210 | 443,525 | 10/13 | 99% |
| 14 | ក្រុមការងារ FMIS | 15,869,275 | 1,382,884 | - | 17,252,159 | 15/21 | 97% |
| 15 | ក្រុមប្រឹក្សានីតិកម្ម | 42,629 | 550,806 | - | 593,435 | 9/9 | 100% |
| 16 | និយ័តករគណនេយ្យនិងសវនកម្ម | 13,556 | 35,431 | 264,134 | 313,121 | 6/8 | 88% |

| ល.រ. | អង្គភាពក្រោមឱវាទ កសហវ. | ថវិកាឆ្នាំ២០២១ (គិតជាពាន់រៀល) | | | | # សកម្មភាព សម្រេចបាន | ពិន្ទុភាគរយ ប្រចាំឆ្នាំ២០២១ |
|---|---|---|---|---|---|---|---|
| | | ថវិកាអនុវត្ត PFMRP | ឧបត្ថម្ភលើកទឹកចិត្ត PFM | ឧបត្ថម្ភលើកទឹក-ចិត្តក្រៅ PFM | ថវិកាសរុប | | |
| 17 | អង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជនថ្នាក់កណ្តាល | - | 183,296 | - | 183,296 | 2/5 | 89% |
| **សរុបរួម** | | **18,851,312** | **4,910,191** | **2,659,679** | **26,421,182** | **-** | **-** |

# ឧបសម្ព័ន្ធទី៣÷ តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់មន្ទីរ សហវ. រាជធានី-ខេត្ត ប្រចាំឆ្នាំ២០២១

| ល.រ. | អង្គភាពក្រោមឱវាទ កសហវ. | ថវិកាឆ្នាំ២០២១ (គិតជាពាន់រៀល) | | | | # សកម្មភាព សម្រេចបាន | ពិន្ទុភាគរយ ប្រចាំឆ្នាំ២០២១ |
|---|---|---|---|---|---|---|---|
| | | ថវិកាអនុវត្ត PFMRP | ឧបត្ថម្ភលើក-ទឹកចិត្ត PFM | ឧបត្ថម្ភលើក ទឹក-ចិត្តក្រៅ PFM | ថវិកាសរុប | | |
| ១ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ | 6,777 | 12,608 | - | 19,385 | 9/11 | 98% |
| ២ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបាត់ដំបង | 9,887 | 12,608 | - | 22,495 | 7/10 | 96% |
| ៣ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ចាម | 6,776 | 12,608 | - | 19,384 | 6/10 | 89% |
| ៤ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ឆ្នាំង | 11,033 | 12,608 | - | 23,641 | 8/10 | 97% |
| ៥ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ស្ពឺ | 6,777 | 12,608 | - | 19,385 | 10/11 | 89% |
| ៦ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពង់ធំ | 7,776 | 12,608 | - | 20,384 | 11/11 | 100% |
| ៧ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកំពត | 6,777 | 12,608 | - | 19,385 | 10/11 | 97% |
| ៨ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកណ្តាល | 6,777 | 12,608 | - | 19,385 | 10/11 | 89% |
| ៩ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកោះកុង | 6,776 | 12,608 | - | 19,384 | 9/11 | 85% |
| ១០ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តក្រចេះ | 7,276 | 12,608 | - | 19,884 | 9/10 | 87% |
| ១១ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តមណ្ឌលគិរី | 14,173 | 12,608 | - | 26,781 | 9/11 | 95% |
| ១២ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីភ្នំពេញ | 20,330 | 12,608 | - | 32,938 | 10/10 | 100% |
| ១៣ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រះវិហារ | 6,776 | 12,608 | - | 19,384 | 9/11 | 78% |
| ១៤ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រៃវែង | 5,162 | 12,608 | - | 17,770 | 11/11 | 100% |
| ១៥ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តពោធិ៍សាត់ | 5,162 | 12,608 | - | 17,770 | 8/10 | 98% |
| ១៦ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តរតនគិរី | 6,776 | 12,608 | - | 19,384 | 9/11 | 76% |
| ១៧ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តសៀមរាប | 6,776 | 12,608 | - | 19,384 | 8/11 | 78% |

| ល.រ. | អង្គភាពក្រោមឱវាទ កសហវ. | ថវិកាឆ្នាំ២០២១ (គិតជាពាន់រៀល) | | | | # សកម្មភាព សម្រេចបាន | ពិន្ទុភាគរយ ប្រចាំឆ្នាំ២០២១ |
|---|---|---|---|---|---|---|---|
| | | ថវិកាអនុវត្ត PFMRP | ឧបត្ថម្ភលើក-ទឹកចិត្ត PFM | ឧបត្ថម្ភលើកទឹក-ចិត្តក្រៅ PFM | ថវិកាសរុប | | |
| ១៨ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តព្រះសីហនុ | 18,764 | 12,608 | - | 31,372 | 10/10 | 100% |
| ១៩ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តស្ទឹងត្រែង | 6,776 | 12,608 | - | 19,384 | 10/11 | 98% |
| ២០ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តស្វាយរៀង | 6,776 | 12,608 | - | 19,384 | 9/11 | 81% |
| ២១ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តតាកែវ | 12,262 | 12,608 | - | 24,870 | 9/10 | 99% |
| ២២ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តឧត្តរមានជ័យ | 6,776 | 12,608 | - | 19,384 | 10/11 | 96% |
| ២៣ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកែប | 8,519 | 12,608 | - | 21,127 | 9/11 | 98% |
| ២៤ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តប៉ៃលិន | 6,776 | 12,608 | - | 19,384 | 11/11 | 100% |
| ២៥ | មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តត្បូងឃ្មុំ | 5,163 | 12,608 | - | 17,771 | 9/10 | 91% |
| សរុបរួម | | **213,599** | **315,210** | **-** | **528,809** | **-** | **-** |

# ឧបសម្ព័ន្ធទី៤៖ តារាងអនុវត្តថវិកា និងសមិទ្ធកម្ម របស់ក្រសួង-ស្ថាប័ន ប្រចាំឆ្នាំ២០២១

| ល.រ | ក្រសួង-ស្ថាប័ន | ថវិកាឆ្នាំ២០២១ (គិតជាពាន់រៀល) | | | #សកម្មភាពសម្រេចបាន | ពិន្ទុភាគរយ ប្រចាំឆ្នាំ២០២១ |
|---|---|---|---|---|---|---|
| | | ថវិកាអនុវត្ត PFMRP | ប្រាក់ឧបត្ថម្ភ លើកទឹកចិត្ត PFM | ថវិកាសរុប | | |
| **ស្ថាប័នសេវាសេដ្ឋកិច្ច** | | | | | | |
| ១ | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | 101,837 | 71,700 | 173,537 | 11/30 | 81% |
| ២ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | - | 70,800 | 70,800 | 29/32 | 95% |
| ៣ | ក្រសួងរ៉ែ និងថាមពល | 65,570 | 70,800 | 136,370 | 37/44 | 95% |
| ៤ | ក្រសួងពាណិជ្ជកម្ម | - | 70,800 | 70,800 | 19/30 | 84% |
| ៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | - | 69,300 | 69,300 | 18/32 | 79% |
| ៦ | ក្រសួងអភិវឌ្ឍន៍ជនបទ | 55,636 | 70,800 | 126,436 | 15/17 | 94% |
| ៧ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | | 70,800 | 70,800 | 22/29 | 94% |
| ៨ | ក្រសួងសាធារណការនិងដឹកជញ្ជូន | 130,907 | 61,800 | 192,707 | 25/35 | 82% |
| ៩ | ក្រសួងទេសចរណ៍ | - | 70,800 | 70,800 | 26/36 | 83% |
| ១០ | ក្រសួងធនធានទឹកនិងឧតុនិយម | - | 70,800 | 70,800 | 21/28 | 87% |
| ១១ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | - | 70,800 | 70,800 | 20/31 | 82% |
| **ស្ថាប័នសេវាហិរញ្ញវត្ថុ កាបរទេស និងសេវាសាធារណៈ** | | | | | | |
| ១ | ទីស្តីការគណៈរដ្ឋមន្ត្រី | - | 58,800 | 58,800 | 13/19 | 93% |
| ២ | ក្រសួងមុខងារសាធារណៈ | - | 72,600 | 72,600 | 28/39 | 94% |
| ៣ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | - | 70,800 | 70,800 | 29/30 | 98% |

| | | | | | | |
|---|---|---|---|---|---|---|
| ៤ | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | 38,564 | 64,800 | 103,364 | 19/22 | 90% |
| ៥ | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | 48,225 | 70,800 | 119,025 | 25/25 | 100% |
| ៦ | ក្រសួងព័ត៌មាន | - | 58,800 | 58,800 | 13/21 | 86% |
| ៧ | ក្រសួងផែនការ | 152,812 | 70,800 | 223,612 | 33/35 | 96% |
| ៨ | គណៈកម្មការមូលបត្រកម្ពុជា | 28,922 | 58,950 | 87,872 | 16/17 | 99% |
*៣. ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌ PFMRP ដំណាក់កាលទី៤*

*៤. សន្ធានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធបៀវត្សរបស់ក្រសួងមុខងារសាធារណៈ*

*៥. របាយការណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ថ្នាក់ជាតិ ឆ្នាំ២០២១*

*៦. ផែនការសកម្មភាពសម្រាប់ជំរុញការបង្កើតអង្គភាពថវិកា*

*៧. ការសិក្សាអំពីលទ្ធភាពបង្កើនអង្គភាពថវិកានៅរដ្ឋបាលរាជធានី-ខេត្ត និងរៀបចំជាផែនការសកម្មភាពជាក់លាក់*

*៨. ផែនការធ្វើបណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋ*

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

**១. សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)** [GDB ; ត.មទ ឆ្នាំ២០២២ ដាក់ជូនស្ថាប័ននីតិបញ្ញត្តិ] ●

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) គ្រោងបញ្ចប់កម្រិត កសហវ. និងបញ្ជូនទៅគណៈរដ្ឋមន្ត្រី នៅត្រីមាសទី៣ ឆ្នាំ២០២២ និងបញ្ជូនទៅអង្គនីតិបញ្ញត្តិ នៅត្រីមាសទី ៤ ឆ្នាំ២០២២ ។

**២. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ** [GDSPNR; ត.ម៤, ២០២២] ●

សេចក្តីព្រាងច្បាប់ បានដាក់ឆ្លងសិក្ខាសាលាពិគ្រោះយោបល់អន្តរក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍន៍, តំណាងសង្គមស៊ីវិល និងកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ កសហវ. ។ ក្រុមការងារបានពិភាក្សាលើជំពូកទី១០ (ស្តីពីទោសប្បញ្ញត្តិ) ជាមួយក្រសួងយុត្តិធម៌ និងអង្គភាពប្រឆាំងអំពើពុករលួយ ចប់សព្វគ្រប់នាថ្ងៃទី ២៨ ខែមករា ២០២២ ។ ដំណាក់កាលបន្តនឹងដាក់ឆ្លងទៅគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**៣. ក្របខណ្ឌគោលនយោបាយស្តីការអភិវឌ្ឍមូលបត្ររដ្ឋ** [GSC & GDICDM; ត.ម៤, ២០២១] ▲

ក្រុមការងារបច្ចេកទេសកំពុងបន្តរៀបចំសេចក្តីព្រាងក្របខណ្ឌគោលនយោបាយរួមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២២-២០២៨ ។

**៤. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ** [GDSPNR; ត.ម៤, ២០២២ បញ្ជូនទៅស្ថាប័ននីតិបញ្ញត្តិ] ●

សេចក្តីព្រាងច្បាប់ ត្រូវបានតាក់តែងជាទម្រង់ច្បាប់ និងខ្លឹមសាររួចរាល់កម្រិតក្រុមការងារបច្ចេកទេស កសហវ.។ គ្រោងរៀបចំសិក្ខាសាលាពិគ្រោះយោបល់នាត្រីមាសទី១ ឆ្នាំ២០២២ និងគ្រោងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី នៅ ត.ម.៣ ឆ្នាំ២០២២។



## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

**៥. ការកែសម្រួលអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥** [GDB; ត.ម១, ២០២២] ●

បានបញ្ចប់ការពិភាក្សាត្រឹមកម្រិតអគ្គនាយកដ្ឋានថវិកា និងបានបញ្ជូនទៅជំនាញការបារាំងដើម្បីផ្តល់ធាតុចូល និងត្រៀមពិភាក្សាអន្តរអគ្គនាយកដ្ឋាន និងដាក់បញ្ចូលជាមួយសេចក្តីព្រាងកែសម្រួលអនុក្រឹត្យលេខ ៨២ អនក្រ.បក នៅត្រីមាសទី២ ឆ្នាំ២០២២នេះ ។

**៦. ការកែសម្រួលអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥** [GDNT; ត.ម១, ២០២២] ●

សេចក្តីព្រាងអនុក្រឹត្យលេខ ៨២ ត្រូវបានរៀបចំ និងត្រូវធ្វើបច្ចុប្បន្នភាពជាបណ្តើរៗ ដោយផ្អែកលើគោលការណ៍សម្រេចនៃក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

**៧. គោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល** [GSC; ត.ម២, ២០២១] ▲

ក្រុមការងារបច្ចេកទេស បាននិងកំពុងពិនិត្យ និងកែសម្រួលសេចក្តីព្រាងលើកទី៦ នៃគោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមុនដាក់សិក្ខាសាលាពិគ្រោះយោបល់ ។

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

ក្របខណ្ឌគតិយុត្ត

៨. សេចក្តីព្រាងប្រកាសគោលការណ៍ និងនីតិវិធីសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារចំពោះចំណូលពីសេវាសាធារណៈ ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម និងក្នុងលក្ខខណ្ឌនៃការចែករំលែកចំណូលពីសេវាធារណៈ និងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ [GSC & GDSPNR; ត.ម.៤, ២០២១] ▲

បានបញ្ចប់សេចក្តីព្រាងប្រកាសគោល និងដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័ន ទាំងកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំនៅខែកុម្ភៈ ឆ្នាំ២០២២ ។ សេចក្តីព្រាងប្រកាសគោលនេះ គ្រោងគោរពជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ពិនិត្យ និងអនុម័ត នៅខែមីនា ឆ្នាំ២០២២ ។

៩. សារាចររបស់រាជរដ្ឋាភិបាលសម្រាប់ជំរុញក្រសួង-ស្ថាប័នជាពិសេសក្រសួង-ស្ថាប័នស្ថិតក្នុងវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ចឱ្យធ្វើ ▲ ការផ្សព្វផ្សាយ ឬរៀបចំវេទិកាសាធារណៈ អំពីថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នសាមីជូនសាធារណជន [GDB; ត.ម.៤, ២០២១]

សារាចរណែនាំស្តីពីការជំរុញក្រសួង-ស្ថាប័ន ក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ឱ្យធ្វើការផ្សព្វផ្សាយ ឬរៀបចំវេទិការសាធារណៈអំពីថវិកាប្រចាំឆ្នាំរបស់ក្រសួងសាមីជូនសាធារណជនកំពុងដំណើរការស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពីថ្នាក់ដឹកនាំ កសហវ. ។

9

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

យុទ្ធសាស្ត្រ

១០. សេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១ [ACAR ; ត.ម២,២០២១] ▲

សេចក្តីព្រាងចុងក្រោយយុទ្ធសាស្ត្រទទួលបានការឯកភាពជាគោលការណ៍ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលពីថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០២១ ។ អ.គ.ហ. សហការជាមួយនិយ័តករគណនេយ្យនិងសវនកម្ម បាននិងកំពុងកែសម្រួលបន្ថែមដើម្បីគោរពជូនប្រមុខរាជរដ្ឋាភិបាល អនុម័ត ។

១១. ឯកសារទស្សនាទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃការងារកែទម្រង់ ៣ បូក ១ [GSC, NCDD, PAR និង CLJR ; ត.ម៤,២០២១] ▲

សេចក្តីព្រាងឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ បី បូក មួយ ត្រូវបានរៀបចំ និងត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំកម្រិតអន្តរការដ្ឋានកែទម្រង់៣ បូក ១ ចំនួន ៣លើក និងគម្រោងវិបស្សនា ត្រូវបានរៀបចំ ។

១២. ចក្ខុវិស័យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ [GSMEF; ត.ម៤, ២០២១] ▲

សេចក្តីព្រាងចក្ខុវិស័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានរៀបចំរួចរាល់ និងបានដាក់ឆ្លងកម្រិតថ្នាក់ដឹកនាំ ។ គ្រោងដាក់ឆ្លងវិបស្សនាក្រសួងនាថ្ងៃទី ២២-២៣ ខែមីនា ឆ្នាំ២០២២ ខាងមុខ ។

១៣. ផែនការមេសម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរយៈពេលមធ្យមនិងវែង [GDSPNR; ត.ម.៤, ២០២២] ●

ក្រុមការងារសិក្សានិងរៀបចំឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋត្រូវបានបង្កើតនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ និងបានរៀបចំមាតិកាគោល ។

១៤. ឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ [GDSPNR; ត.ម.៤, ២០២១] ▲

បានពិនិត្យឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដោយសម្រួលខ្លឹមសារពីភាសាអង់គ្លេស ទៅភាសាខ្មែរឱ្យត្រឹមត្រូវតាមពាក្យ និងទិដ្ឋភាពបច្ចេកទេស ដើម្បីដាក់ជូនក្រុមការងារកម្រិតអន្តរអគ្គនាយកដ្ឋាន.កសហវ. ពិនិត្យកែសម្រួលចុងក្រោយ ។

10

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

### ១៥. សន្ធានកម្មរវាងប្រព័ន្ធ FMIS និង ប្រព័ន្ធ EFMS របស់ក្រសួងអប់រំ យុវជន និងកីឡា [MoEYS & FMWG ; ត.ម១, ២០២២] ○

ក្រសួងអប់រំ យុវជន និងកីឡា កំពុងធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍបន្ថែមមុខងារការទិញ និងមុខងារត្រូវសង លើប្រព័ន្ធ EFMS ជំនាន់ទី ៣ ថ្មី ដែលគ្រោងនឹងបញ្ចប់ និងដាក់ឱ្យប្រើប្រាស់នៅខែមេសា ឆ្នាំ២០២២ ។ ជាមួយគ្នានេះ ក្រុមការងារ FMIS កំពុងផ្តល់កិច្ចសហការក្នុងការផ្តល់ធាតុចូល និងតម្រូវការនានាជូនក្រុមការងារ MoEYS ដើម្បីសិក្សាលម្អិតអំពីតម្រូវការព័ត៌មាននៅតាមដំណាក់កាលនៃការអភិវឌ្ឍប្រព័ន្ធ EFMS ទៅតាមមុខងារនីមួយៗក្នុងការធ្វើសន្ធានកម្មរវាងប្រព័ន្ធទាំង២ ។ ឆ្នាំ២០២២នេះ នឹងគ្រោងធ្វើសន្ធានកម្មតែមួយមុខងារការទិញ និងឆ្នាំ២០២៣ មុខងារត្រូវសង ។



## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

យន្តការ

### ១៦. ការពិនិត្យនិងសិក្សារៀបចំការបែងចែកមុខងាររបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ចតាមក្រសួង-ស្ថាប័ន អនុលោមតាមអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ [GI&GDIA ; ត.ម៤, ២០២១] ▲

បានតាមដានការអនុវត្តអនុក្រឹត្យលេខ១៦៨ អនក្រ.បក នៅតាមបណ្តាក្រសួង-ស្ថាប័នចំនួន ១២ ។ ជាជំហានបន្ទាប់ អគ្គាធិការដ្ឋាននឹងរៀបចំក្របខ័ណ្ឌនិងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូលក្រោមជំនួយបច្ចេកទេសពី AFD ។

### ១៧. របាយការណ៍ PEFA ថ្នាក់ក្រោមជាតិ ឆ្នាំ២០២០ [GSC ; ត.ម២, ២០២១] ▲

បានបញ្ចប់ការកែសម្រួលសេចក្តីព្រាងទី១ ដោយបានពិនិត្យនិងកែសម្រួលតាមមតិយោបល់របស់ក្រុមការងារ PEFA, លេខាធិការដ្ឋាន PEFA និងដៃគូអភិវឌ្ឍន៍ ។ ជាការងារបន្ទាប់ អ.គ.ហ. នឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងនេះនៅត្រីមាសទី១ ឆ្នាំ២០២២ ។

### ១៨. ក្របខណ្ឌរួម ផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ [GSC; តម៤, ២០២១] ▲

ក្រុមជំនាញការ ស្ថិតនៅក្នុងដំណាក់កាលគ្រោងបញ្ចប់ការធ្វើសុពលភាពទៅលើរបាយការណ៍សិក្សាអំពីជំហានចំណាយនីមួយៗ ដើម្បីអាចពិភាក្សាបឋមទាក់ទងនឹងរបកគំហើញនាពេលខាងមុខ។

### ១៩. កម្មវិធីសិក្សាភ្ជាប់វិញ្ញាបនបត្រ (Certificate Program) ដោយផ្សារភ្ជាប់មុខតំណែងឱ្យបានគ្រប់ជ្រុងជ្រោយ [EFI; ត.ម៤,២០២១] ▲

ឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និងទទួលបានការណែនាំពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ នៅថ្ងៃទី៥ ខែមករា ឆ្នាំ ២០២២ ។ តាមចំណារដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ, ឯកសារទស្សនាទាន ត្រូវបានបន្តនីតិវិធីដាក់ឆ្លងកិច្ចប្រជុំជាមួយក្រុម-ការងារកែទម្រង់ពាប្ញក១នៃ អ.គ.ហ ដើម្បីពិនិត្យ និង ផ្តល់យោបល់បន្ថែម ដើម្បីរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួង ។

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

២០. ការវាយតម្លៃលើបច្ច័យនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM Impact Assessment) [GSC; ត.ម៤, ២០២១]▲

សេចក្តីព្រាងរបាយការណ៍បឋមនៃការវាយតម្លៃនេះកំពុងរៀបចំ និងបន្តកែសម្រួល ដើម្បីត្រៀមជួបប្រជុំជាមួយក្រុមការងារបច្ចេកទេស ។

២១. ពិនិត្យ និងធ្វើបច្ចុប្បន្នភាពសមាសភាពគណៈកម្មាធិការ, គណៈកម្មការ និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ [GSC; ត.ម៤, ២០២១] ▲

បានរៀបចំសេចក្តីព្រាងសេចក្តីសម្រេច និង កំពុងពិនិត្យធ្វើបច្ចុប្បន្នភាពសមាសភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គ្រោងគោរពស្នើសុំ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ពិនិត្យ និងសម្រេចលើសមាសភាពនៅដើមខែមេសា ឆ្នាំ២០២២ នេះ ។

២២. ការបង្កើតក្រុមការងារអន្តរអគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សិក្សា និងវាយតម្លៃអំពីមុខងាររបស់មន្ទីរ សហវ. និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ [GSMEF; តម១, ២០២២] ●

បានបែងចែកក្រុមការងារដើម្បីសិក្សាទៅលើក្របខណ្ឌគតិយុត្តដែលមានស្រា ប់និងរៀបចំបំពេញបន្ថែមនូវចំណុចដែលចែងមិនច្បាស់លាស់ ដើម្បីរៀបចំ ជាសេចក្តីព្រាងគោលការណ៍ថ្មី ។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋាន កសហវ. បានរៀបចំជាសេចក្តីព្រាងគោលការណ៍ណែនាំ ។

២៣. មូលនិធិ PFMRP គ្រប់ជ្រុងជ្រោយ [GSC; ត.ម៣, ២០២១] ▲

បានរៀបចំរបាយការណ៍សិក្សាលម្អិតអំពីការអនុវត្តមូលនិធិ PFMRP ដំណាក់កាលទី១ និងការឈានទៅអនុវត្ត ដំណាក់កាលទី២ និងកំពុងរៀបចំគោរពស្នើសុំ ការពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ។



## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

២៤. ការវាយតម្លៃការអនុវត្តក្របខណ្ឌថវិកាទូទាំងប្រទេស (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) [GSC; តម២, ២០២២] ●

អ.គ.ហ. សហការជាមួយធនាគារពិភពលោក ដោយគ្រោងនឹងមានជាលទ្ធផលរាយការណ៍ជូនថ្នាក់ដឹកនាំក្នុងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារ កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងដៃគូអភិវឌ្ឍន៍ ក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២១ នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ។

២៥. ការវាយតម្លៃរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ក្របខណ្ឌ TADAT [GSC; តម៤, ២០២១] ▲

របាយការណ៍វាយតម្លៃរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ក្របខណ្ឌ TADAT ត្រូវបានរៀបចំ និងផ្តល់សុពលភាពដោយលេខាធិការដ្ឋាន TADAT។ អ.គ.ហ. កំពុងស្នើសុំគោលការណ៍ដើម្បីរាយការណ៍លទ្ធផលនៃការវាយតម្លៃនេះជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

២៦. ការរៀបចំសៀវភៅថវិកាពលរដ្ឋ (Citizen Budget) និងវេទិកាផ្សព្វផ្សាយថវិកាកម្មវិធីជូនសាធារណជន របស់ក្រសួងអាទិភាព ចំនួន ០៤ ដែលក្រសួងចំនួន ០២ ស្ថិតក្នុងវិស័យសេដ្ឋកិច្ច និងក្រសួងចំនួន ០២ ទៀតស្ថិតក្នុងវិស័យសង្គមកិច្ច [GDB & GSC, ចាប់ផ្តើមពី២០២២] ●

សេចក្តីព្រាងឯកសារទស្សនាទានសម្រាប់ជាមូលដ្ឋានលើការរៀបចំ និងផ្សព្វផ្សាយសៀវភៅថវិកា ដែលរួមបញ្ចូលទាំង មាតិកាសង្ខេបគំរូសម្រាប់ការរៀបចំ សៀវភៅថវិកាពលរដ្ឋរបស់ក្រសួងទាំង ៤ រួមមាន÷ (១). ក្រសួងអប់រំ យុវជន និងកីឡា (២). ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (៣). ក្រសួងអភិវឌ្ឍន៍ជនបទ (៤). ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

២៧. ជំរុញក្រសួង-ស្ថាប័នអាទិភាពចំនួន ០៥-០៧ រៀបចំ FMM របស់ក្រសួង-ស្ថាប័នសាមី [GSC, ២០២២] ●

កាលពីខែមករា ឆ្នាំ២០២២, អ.គ.ហ. បានរៀបចំកិច្ចប្រជុំជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមរៀបចំ FMM ។ ក្នុង នោះ ក្រសួង-ស្ថាប័នចំនួន ១២ បានដាក់ផែនការសកម្មភាពរៀបចំ FMM តាមយន្តការ MAP និង GDAP សម្រាប់ឆ្នាំ២០២២។

# ២.២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម

- *វឌ្ឍនភាពតាមផ្នែកទាំង ៥ នៃផែនការសកម្មភាពរួម*
- *វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ.*
- *វឌ្ឍនភាព (%) តាមមន្ទីរ សហវ. រាជធានី ខេត្ត*
- *វឌ្ឍនភាព (%) តាមក្រសួង-ស្ថាប័ន*



## ផ្នែកទី១÷ បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា — សូចនាករសមិទ្ធកម្មគន្លឹះទាំង៦

**មិនមាន**




**១០៤,៤៩ %**
*(ទំហំ ២២ ១៥៥ ប៊ីលានរៀល)*

**៩៥,៣៦%** *(ធៀបច្បាប់ថវិកា)*
**៩៨,៧៩%** *(ធៀបឥណទានក្រោយវិចារណកម្ម)*
*(ទំហំអនុវត្តថវិកា ២៦ ១៥២ ប៊ីលានរៀល)*

- ❖ **ការប្រមូលចំណូលថវិកាថ្នាក់ជាតិ**
  - គយ និងរដ្ឋាករ÷ ៩៦,២៦%
  - ពន្ធដារ÷ ១១៥,១៤ %
  - ចំណូលមិនមែនសារពើពន្ធ ÷ ៧៨,៧៧%
- ❖ **ការប្រមូលចំណូលថវិកាថរដ្ឋបាលថ្នាក់-ក្រោមជាតិ (រដ្ឋបាលរាជធានី-ខេត្ត)**
  - ចំណូលសារពើពន្ធ÷ ១៦៨,៣%
  - ចំណូលមិនមែនសារពើពន្ធ÷១០១,៣%

**១២២** *គណនី*

*បៀវត្ស* **៩៦,០៦%**
*ទំនិញ-សេវា* **៩៥,១៨%** *(ធៀបច្បាប់)*, **១០៦,៦១%** *(ធៀបឥណទានក្រោយវិចារណកម្ម)*
*មូលធន* **៩២,២៤%**
*ផ្សេងៗ÷* **៩៩,៥៦%**
*បន្ទុកហិរញ្ញវត្ថុ ៨០,៧៩%, អត្ថប្រយោជន៍សង្គម ១៦៣,៨៨%, ឧបត្ថម្ភធន ៥៧,៥៨%, និង ពន្ធនិងអាករ ១៦៨,៨០%*

**-២,៦៨** *ពិន្ទុភាគរយ នៃ ផ.ស.ស.*

*ទំហំ ផ.ស.ស ឆ្នាំ២០២១= ១១៦ ៧១១ ប៊ីលានរៀល (ប្រភព÷ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ) ។*
*ចំណូលចរន្តធៀបនឹង ផ.ស.ស. ÷ ឆ្នាំ២០២០ = ២១,៦២% នៃ ផ.ស.ស, ឆ្នាំ២០២១ = ១៨,៥៧% នៃ ផ.ស.ស ។*



*ប្រភព÷អគ្គនាយកដ្ឋានរតនាគារជាតិ* *ទិន្នន័យចំណូល-ចំណាយគិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ (ទិន្នន័យបណ្ដោះអាសន្ន) ។*

## ផ្នែកទី១៖ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា — វឌ្ឍនភាព

១ ៩០% ផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា

- ចំនួនក្រសួង ស្ថាប័ន, ចំនួនសហគ្រាសសាធារណៈនិងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងចំនួនអង្គភាពថវិកា លើសពី ៩០% បានផ្ញើផែនការលទ្ធកម្មប្រចាំឆ្នាំមក កសហវ. និងត្រូវបានអនុម័តទាន់ពេលវេលា ។

២ យ៉ាងតិច ៦០% នៃអង្គភាពថវិកាផ្តល់របាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ (គិតក្នុងឆ្នាំ២០២០)

- អង្គភាពថវិកាបានផ្ញើរបាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ. មានសរុបចំនួន ៣៩១ អង្គភាព ស្មើនឹង ៦១,១៨% ។

៣ ការបន្តអនុវត្តជំហានទី១ នៃការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈ

- នៅឆ្នាំ២០១៩ ជំហានទី១ ត្រូវបានដាក់ឱ្យអនុវត្តដោយបានបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈ របស់ស្ថាប័នអនុវត្តលទ្ធកម្ម ។
- ជំហានទី ២ នឹងត្រូវចាប់ផ្តើមនៅឆ្នាំ២០២២ ។

៤ យ៉ាងតិច ៦០% នៃទំហំទឹកប្រាក់ប្រគល់កិច្ចសន្យាសរុប ប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែង (គិតក្នុងឆ្នាំ២០២០)

- ទំហំទឹកប្រាក់កិច្ចសន្យាសរុបប្រចាំឆ្នាំប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងលទ្ធកម្មមានចំនួន ៦០,៦២% ។



## ផ្នែកទី១៖ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា — សន្និដ្ឋាន

ភាពជឿទុកចិត្តនៃថវិកា គឺរក្សាបាននូវភាពរឹងមាំ ដែលឆ្លុះបញ្ចាំងអំពីភាពធននៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលបានកសាងកន្លងមក ។ ទោះបីជាយ៉ាងនេះក្តី ការធ្វើស្ថាបនីយកម្មយន្តការប្រមូល និងការគ្រប់គ្រងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ នៅមានលទ្ធភាពកែលម្អបន្ថែមទៀត ។ ចំពោះប្រសិទ្ធភាពចំណាយថវិកា ត្រូវពង្រឹងលើបៀវត្ស, ទំនិញ/សេវា និងវិនិយោគតាមរយៈការរៀបចំ និងអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដូចមានកំណត់ក្នុងយុទ្ធសាស្ត្រគន្លឹះទាំង៤ (BSRS, SBSRS, PPSRS & PIMSRS) ។ ផ្អែកលើមូលដ្ឋាននេះ, ថវិកាឆ្នាំ២០២១ បានបំពេញជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលអាចជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យទាំងក្នុង និងក្រៅប្រទេស ដើម្បីប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គមសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជន ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ នៅក្រោយពេលមានភាពធូរស្បើយពីវិបត្តិជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីធានាសុខសន្តិភាព ស្ថិរភាពសង្គម និងចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជា ជាមួយនឹងការបន្តលើកស្ទួយសុខុមាលភាពរបស់ប្រជាជន ។

## ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ — វឌ្ឍនភាព

| | |
|---|---|
| ១ នីតិវិធីធានាចំណាយ និងទូទាត់ចំណាយផ្សេងៗ កម្រិត ១ និងកម្រិត ២ ត្រូវបានដាក់ឱ្យអនុវត្តផ្លូវការ នៅ កសហវ. និង ៧ ក្រសួង ផ្សេងទៀត | • នីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS លើការទូទាត់ចំណាយបៀវត្ស និងចំណាយទូទាត់ត្រង់ ដែលមានហានិភ័យកម្រិត១ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅក្រសួងស្ថាប័នចំនួន ២៧ ។ |
| ២ មុខងារថ្មីពីរ (មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញ) ត្រូវបានដាក់ឱ្យសាកល្បងនៅ កសហវ. និងក្រសួងព័ត៌មាន | • **<u>មុខងាររៀបចំផែនការថវិកា</u>** ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងនៅ កសហវ. និង ក្រសួងកិច្ចការនារី និង **<u>មុខងារលទ្ធកម្មពេញលេញ</u>** ត្រូវបានដាក់ឲ្យប្រើប្រាស់សាកល្បងនៅ កសហវ. ក្រសួងកិច្ចការនារី និង ក្រសួងព័ត៌មាន ។ |
| ៣ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មី ២ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS និងរដ្ឋបាលរាជធានី ខេត្ត ទាំង ២៥ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS សម្រាប់ត្រៀមប្រើប្រាស់នៅឆ្នាំ ២០២២ | • អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីចំនួន ២ ត្រូវបានដាក់ឲ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ ។ រដ្ឋបាលរាជធានី ខេត្តចំនួន ២៥ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីចំនួន ១០ ត្រូវបានដាក់ដំឡើង FMIS សម្រាប់ត្រៀមប្រើប្រាស់ជាផ្លូវការនៅដើមឆ្នាំ ២០២២ ។ |
| ៤ ការបិទបញ្ជីគណនេយ្យក្នុងរយៈពេល ពី ៦ ខែ ទៅ ៩ខែ | • ការបិទបញ្ជីគណនេយ្យត្រូវប្រើរយៈពេល ៩ ខែ ។ |



## ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ — វឌ្ឍនភាព (ត...)

| | |
|---|---|
| ៥ កម្រិតអនុលោមភាព នៃ របាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដា IPSAS Cash Basis | • សមាសធាតុសំខាន់មួយចំនួនត្រូវបានកែលម្អដោយបានលាតត្រដាងកាន់តែលម្អិតនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុដោយបានដាក់បង្ហាញព័ត៌មានអំពីសាច់ប្រាក់កម្ចីដែលមិនទាន់ប្រើប្រាស់និងព័ត៌មានអំពីអង្គភាពថវិកាដែលរាយការណ៍ ។ |
| ៦ របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៩ ត្រូវបានរៀបចំរួចរាល់ក្នុងត្រីមាសទី ២ ឆ្នាំ២០២១ | • របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៩ ត្រូវបានរៀបចំរួចរាល់ក្នុងអំឡុងត្រីមាសទី ២ ឆ្នាំ២០២១ ។ |
| ៧ របាយការណ៍បូកសរុបទ្រព្យសម្បត្តិរដ្ឋ កម្រិតក្រសួង - ស្ថាប័ន, មន្ទីរអង្គភាពជំនាញថ្នាក់មូលដ្ឋាន និង រដ្ឋបាលថ្នាក់ក្រោមជាតិ | • គិតត្រឹម ២០ ខែមករា ២០២១ ការរៀបចំតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ (២០២០) ដោយទទួលបាន ៨៩% នៃអង្គភាពប្រើប្រាស់សរុប ៣០៣៦ អង្គភាព ។ |
| ៨ សូចនាករបំណុលគន្លឹះទាំង ៥ បានត្រូវបន្តរក្សាក្រោមពិតានដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ | • សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិតានដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ។ |

## ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ — វឌ្ឍនភាព (ត...)

| | |
|---|---|
| **៩** ការវិភាគហានិភ័យបំណុល និងហានិភ័យកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវបានរៀបចំដាក់បញ្ចូលនៅក្នុងរបាយការណ៍ដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុល | • បានរៀនចំរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានខ្លឹមសារហានិភ័យបំណុលសាធារណៈ ប្រចាត្រីមាសទី១, ត្រីមាសទី២, និងត្រីមាសទី៣ ឆ្នាំ២០២១ ព្រមទាំងផ្សព្វផ្សាយលើគេហទំព័រផ្លូវការ ។ |
| **១០** លក្ខណវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបាយការណ៍សិក្សាអំពីវិធីសាស្ត្រវាយតម្លៃគ្រឹះស្ថានសាធារណៈកម្រិត កសហវ. | • បានរៀបចំរបាយការណ៍សិក្សាលើការកំណត់លក្ខណៈវិនិច្ឆ័យអប្បរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈ ។ |
| **១១** សេចក្តីព្រាងច្បាប់ស្តីពីសហគ្រាសសាធារណៈ ត្រូវបានរៀបចំដាក់ឆ្លងថ្នាក់ដឹកនាំ កសហវ. | • សេចក្តីព្រាងច្បាប់ ត្រូវបានតាក់តែងជាទម្រង់ច្បាប់ និងខ្លឹមសាររួចរាល់កម្រិតក្រុមការងារបច្ចេកទេស កសហវ.។ គ្រោងរៀបចំសិក្ខាសាលាពិគ្រោះយោបល់នាត្រីមាសទី ១ និងគ្រោងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី នៅ ត.ម.៣ ឆ្នាំ២០២២។ |
| **១១** ចំនួនបណ្ណកម្មសិទ្ធិមិនទាន់បានចុះបញ្ជី (ដីធ្លី) សរុប ត្រូវបានរៀបចំដោយក្រុមការងារអន្តរក្រសួង និងផែនការសកម្មភាពត្រូវបានរៀបចំ | • ទីតាំងដែលពុំទាន់បានធ្វើបណ្ណកម្មសិទ្ធិមានចំនួន ១០ ៧៩៦ កន្លែង ស្មើនឹង ៣៨% នៃទីតាំងសរុប នឹងត្រូវបន្តជំរុញធ្វើប័ណ្ណកម្មសិទ្ធិឱ្យអស់ក្នុងឆ្នាំ២០២៣ ។ |



## ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ — សន្ទិដ្ឋាន

ប្រព័ន្ធ FMIS ជាប្រព័ន្ធស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ ហើយត្រូវបានពង្រីក និងដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័ន ។ ទន្ទឹមនឹងវឌ្ឍនភាពនេះ គួរមានការគិតគូរអំពីវិសាលភាពនៃការប្រើប្រាស់មុខងារថ្មីចំនួន២ និងការសិក្សាឱ្យបានស៊ីជម្រៅបន្ថែមទៀតអំពីហានិភ័យនៃការដាក់ឱ្យអនុវត្តនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS (Business Process Streamlining) ។ ក្នុងន័យនេះ, ក្រុមការងារគ្រប់គ្រងគម្រោង FMIS គួរបន្តពិនិត្យ និងជំរុញការងារអាទិភាពនេះ ដើម្បីឱ្យការអនុវត្តស្របទៅនឹងទិសដៅប្រព័ន្ធថវិកា ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ។

## ផ្នែកទី៣÷ ការពង្រឹងប្រសិទ្ធភាពនៃផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ — វឌ្ឍនភាព

| | |
|---|---|
| ១ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ | • សេចក្តីព្រាង MTFF ២០២១-២០២៣ ត្រូវបានដាក់ជូនថ្នាក់ដឹកនាំ កសហវ ប៉ុន្តែដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩,ថ្នាក់ដឹកនាំ កសហវ. បានសម្រេចពន្យារពេលក្នុងការដាក់ឱ្យអនុវត្ត ហើយជាទិសដៅនឹងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២២ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៣-២០២៥ និងគម្រោងថវិកាឆ្នាំ២០២៣ ។ |
| ២ សេចក្តីព្រាងក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) កំណត់ពិតានថវិកាពហុឆ្នាំ ត្រូវបានដាក់ឱ្យដាក់ឱ្យអនុវត្ត | • ការរៀបចំឯកសារ MTBF ដោយមានពិតានតាមវិស័យតាម ក្រសួង- ស្ថាប័ន ត្រូវបានអនុម័តដោយប្រមុខរាជរដ្ឋាភិបាល។ |
| ៣ សេចក្តីព្រាងបឋមនៃក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ | • សេចក្តីព្រាង MTBF របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំរួចរាល់ និងត្រៀមគោរពជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ។ |
| ៤ ការរៀបចំយន្តការគ្រប់គ្រងវដ្តគម្រោងវិនិយោគសាធារណៈ | • គោលការណ៍ណែនាំចំនួន៣ ត្រូវបានអនុម័ត រួមមាន (១) គោលការណ៍ណែនាំលម្អិតស្តីពីវដ្តនៃគម្រោងវិនិយោគសាធារណៈ, (២) គោលការណ៍និងនីតិវិធីគ្រប់គ្រងយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធលទ្ធភាព និងរៀបចំគម្រោង និង (៣) គោលការណ៍ណែនាំសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ។ |
| ៥ ការញែកបន្ទុកបុគ្គលិកបានតាមកម្មវិធីនីមួយៗឆ្នាំ N+1 | • ឯកសារទស្សនាទានស្តីពីការញែកបន្ទុកបុគ្គលិក ត្រូវបានរៀបចំ ។ |

23

## ផ្នែកទី៣÷ ការពង្រឹងប្រសិទ្ធភាពនៃផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ — វឌ្ឍនភាព(ត...)

| | |
|---|---|
| ៦ គម្លាតរវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ (N+1) | • ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ២០២១ មានគម្លាត ៩,៨% ។ |
| ៧ បន្ថែមចំនួន ៣ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិថែមទៀត និងបន្ថែម ១០ អង្គភាពថវិកា នៅតាមក្រសួង- ស្ថាប័ន | • នៅឆ្នាំ២០២១ អង្គភាពថវិកាមានចំនួនសរុប ៩២៦ ដែលក្នុងនោះរដ្ឋបាលកណ្តាលមានចំនួន ៣២៣ (កើនឡើង១២) និងថ្នាក់-មូលដ្ឋាន (មន្ទីរជំនាញរាជធានី ខេត្ត)ចំនួន ៦០៣ ។ សម្រាប់ថ្នាក់កណ្តាល អង្គភាពថវិកាចំនួន ៣២៣ ក្នុងនោះ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិមានចំនួន ៨៣ (ឆ្នាំ២០២០ មានចំនួន ៦១) និងមិនទាន់ផ្ទេរសិទ្ធិ ២៤០ (ឆ្នាំ២០២០ មានចំនួន ២៥០) និងសម្រាប់ថ្នាក់មូលដ្ឋានគ្រប់អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិចំនួន ៦០៣ (ឆ្នាំ២០២០ មានចំនួន ៦០៣)។ |
| ៨ តម្រឹមផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់-ក្រោមជាតិ រវាងរាជធានី-ខេត្ត ជាមួយនឹងថវិកាមន្ទីរជំនាញ | • តម្រឹមផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិ រវាងរាជធានី ខេត្ត ជាមួយនឹងថវិកាមន្ទីរជំនាញ រាជធានី-ខេត្ត ។ ប៉ុន្តែគុណភាព និងភាពទាន់ពេល ចាំបាច់ត្រូវពង្រឹងបន្ថែម ។ |
| ៩ ការធ្វើប្រតិភូកម្មសិទ្ធិអំណាចនៃការធ្វើនិយ័តថវិកាជូនរដ្ឋបាលថ្នាក់ក្រោមជាតិ | • រដ្ឋបាលរាជធានី ខេត្ត ទទួលបានឆន្ទានុសិទ្ធក្នុងការធ្វើនិយ័តថវិកាតាមរយៈប្រកាសស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ |

24

## ផ្នែកទី៣៖ ការពង្រឹងប្រសិទ្ធភាពនៃផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ — សន្និដ្ឋាន

ក្របខណ្ឌថវិការយៈពេលមធ្យមត្រូវបានរៀបចំ និងអនុវត្តសាកល្បង និង ឯកសារ MTFF នឹងត្រូវដាក់កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០២២ សម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២៣-២០២៥ និងថវិកាប្រចាំឆ្នាំ២០២៣ ដែលនឹងបង្កលក្ខណៈងាយស្រួលដល់ក្រសួង-ស្ថាប័ន ក្នុងការរៀបចំថវិកា ដោយមានកំណត់ថវិកាទាំងវិស័យ និងក្រសួង-ស្ថាប័ន ពិសេសការធ្វើសមាហរណកម្មថវិកាចរន្ត និងវិនិយោគ រួមទាំងពេលវេលាអនុលោមតាមប្រតិទិននៃការរៀបចំថវិកា ។ ដោយឡែក ក្រសួង-ស្ថាប័នមួយចំនួនក៏នៅរក្សាការ-គ្រប់គ្រងថវិកាតាមបែបប្រមូលផ្តុំនៅឡើយ ដោយអនុញ្ញាតឱ្យមានអង្គភាពថវិកាចំនួនតិចតួច ដែលមានន័យថាថវិកាផ្តល់ដល់អង្គភាពអនុវត្តផ្ទាល់ ក៏មានតិចតួចផងដែរ ។ ក្នុងន័យនេះ ការបង្កើនចំនួនអង្គភាពថវិកា និងអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិជាការងារសំខាន់ ដែលចាំបាច់ត្រូវជំរុញ និងពង្រឹងសមត្ថភាពបន្ថែម ។



## ផ្នែកទី៤៖ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម — វឌ្ឍនភាព

| | | |
|---|---|---|
| ១ | សាកល្បងរៀបចំផែនការសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ ២០២១ | • ពុំមានវឌ្ឍនភាព ប៉ុន្តែ អគ្គនាយកដ្ឋានថវិកាបានរៀបចំទម្រង់កិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំរវាង កសហវ. និងក្រសួង ស្ថាប័នសម្រាប់អនុវត្តឆ្នាំ២០២២។ |
| ២ | សេចក្តីព្រាងអនុក្រឹត្យលេខ ៨១ និងសេចក្តីព្រាងអនុក្រឹត្យលេខ ៨២ ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ | • **<u>សេចក្តីព្រាងអនុក្រឹត្យលេខ ៨១</u>** បានបញ្ចប់ការពិភាក្សាត្រឹមកម្រិតអគ្គនាយកដ្ឋាន និងបានបញ្ជូនទៅជំនាញការបារាំងដើម្បីផ្តល់ធាតុចូល និងត្រៀមពិភាក្សាអន្តរអគ្គនាយកដ្ឋាន និងដាក់បញ្ចូលជាមួយសេចក្តីព្រាងកែសម្រួលអនុក្រឹត្យលេខ ៨២ អនក្រ.បក នៅត្រីមាសទី២ ឆ្នាំ២០២២នេះ ។ **<u>សេចក្តីព្រាងអនុក្រឹត្យលេខ ៨២</u>** ត្រូវបានរៀបចំ និងត្រូវធ្វើបច្ចុប្បន្នភាពជាបណ្តើរៗ ដោយផ្អែកលើគោលការណ៍សម្រេចនៃក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។ |
| ៣ | ប្រកាសស្តីពីយន្តការតាមដាន និងត្រួតពិនិត្យការអនុវត្តថវិកា | • កសហវ. បានចេញប្រកាសលេខ ១១៣ សហវ.ប្រក ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម ។ |
| ៤ | គ្រប់ក្រសួង-ស្ថាប័នមានយន្តការគ្រប់គ្រងការអនុវត្តថវិកាតាមក្របខណ្ឌគ្រប់គ្រងសមិទ្ធកម្ម និងមានយន្តការគ្រប់គ្រងសមិទ្ធកម្ម | • ពុំមានវឌ្ឍនភាព ។ |

## ផ្នែកទី៤÷ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម — វឌ្ឍនភាព (ត...)

| | |
|---|---|
| ៥ ការរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ស្របតាមប្រព័ន្ធថវិកាសមិទ្ធកម្ម | • កសហវ. បានរៀបចំឯកសារប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង, បានកែសម្រួលបញ្ចប់សេចក្តីព្រាងអនុក្រឹត្យថ្មី ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង និងចេញប្រកាសស្តីពីគោលការណ៍ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន ។ |
| ៦ សវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន ត្រូវបានអនុវត្ត នៅគ្រប់ក្រសួង-ស្ថាប័ន | • អនុវត្តសវនកម្មសមិទ្ធកម្មសាកល្បងជាករណីសិក្សាជូនក្រសួង ចំនួន ៦ និងអនុវត្តសវនកម្មបច្ចេកវិទ្យាព័ត៌មាន សាកល្បងជាករណីសិក្សាជូនក្រសួង ចំនួន ៤ ។ |
| ៧ មានរបាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៥ ត្រូវបានរៀបចំដោយអាជ្ញាធរសវនកម្មជាតិ និងបញ្ជូនទៅអង្គនីតិបញ្ញត្តិ | • មានរបាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៥ ត្រូវបានរៀបចំដោយអាជ្ញាធរសវនកម្មជាតិ និងបញ្ជូនទៅអង្គនីតិបញ្ញត្តិ ។ |
| ៧ ការលើកកម្ពស់តម្លាភាពថវិកា | • កសហវ. បានរៀបចំវេទិកាសាធារណៈ ស្តីពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌថវិកាប្រចាំឆ្នាំ និងផ្សព្វផ្សាយឯកសារថវិកាផ្សេងទៀត ។ |

27

## ផ្នែកទី៤÷ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម — សន្និដ្ឋាន

ជារួម ការឈានទៅអនុវត្តដំណាក់កាលទី៤ នឹងត្រូវត្រៀមខ្លួនរួចរាល់សម្រាប់ដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០២៣ តទៅ តាមរយៈការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី), ការរៀបចំអនុក្រឹត្យលេខ ៨១ និង ៨២ (ថ្មី) ព្រមទាំងការរៀបចំក្របខណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម ដែលរំពឹងថាត្រូវបញ្ចប់ក្នុងឆ្នាំ ២០២២ ។ ទន្ទឹមនេះ, មុខងារសវនកម្មផ្ទៃក្នុង (ជាពិសេសការធ្វើសវនកម្មសមិទ្ធកម្ម) និងអធិការកិច្ច នៅគ្រប់ក្រសួង-ស្ថាប័នត្រូវពង្រឹងបន្ថែមជាបណ្តើរៗ ដើម្បីធានាថាក្រសួង-ស្ថាប័នមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរឹងមាំ ស្របពេលរាជរដ្ឋាភិបាលបាននិងកំពុងធ្វើវិមជ្ឈការហិរញ្ញវត្ថុដល់ក្រសួង-ស្ថាប័ន ។

28

## ផ្នែកទី៥ ៖ការគាំទ្រកម្មវិធីកែទម្រង់ និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ — វឌ្ឍនភាព

| | |
|---|---|
| ១ របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ (GDAP/PDAP/MAP) ត្រូវបានផ្តល់ជូន អ.គ.ហ. ស្របតាមសារាចរ ០៩ សរ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០១៥ (ត្រឹមដំណាច់ខែមករា នៃឆ្នាំបន្ទាប់) ។ | • ក្រសួង-ស្ថាប័ន មានចំនួន ៣៩/៤១ ស្មើនឹង ៩៥% ។<br>• អង្គភាពក្រោមឱវាទ កសហវ. មានចំនួន ១៧/១៧ ស្មើនឹង ១០០% ។<br>• មន្ទីរ សហវ. រាជធានី-ខេត្ត មានចំនួន ២៥/២៥ ស្មើនឹង ១០០% ។ |
| ២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខណ្ឌ PFMRP ដំណាក់កាលទី ត្រូវបានអនុម័ត និង កម្មវិធីវិញ្ញាបនបត្រ (Certificate Program) ត្រូវបានរៀបចំ | • ផែនការយុទ្ធសាស្ត្រ ទទួលបានអនុម័តពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** នៅថ្ងៃទី ៤ ខែ តុលា ឆ្នាំ២០២១ ។ ឯកសារទស្សនាទានស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និងទទួលបានការណែនាំពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** នៅថ្ងៃទី៥ ខែមករា ឆ្នាំ ២០២២ ។ |
| ៣ លក្ខខណ្ឌយោងតួនាទីភារកិច្ចនៃសមាជិកក្រុមការងារកែទម្រង់ PFM អង្គភាពក្រោមឱវា កសហវ. និងគ្រប់ក្រសួង ស្ថាប័ន ត្រូវបានសម្រួចនិងតម្រឹមតាមគោលបំណង/ សកម្មភាពគន្លឹះក្នុងម៉ាទ្រីសនៃផែនការ GDAP/MAP ឆ្នាំ ២០២១ | • អង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័នបានធ្វើបច្ចុប្បន្នភាព និងកែលម្អជាប្រចាំនូវលក្ខខណ្ឌយោងការដោយតម្រឹមជាមួយគោលបំណង/ សកម្មភាពគន្លឹះក្នុង GDAP/MAP តាមរយៈយន្តការនៃការផ្តល់ប្រាក់ឧបត្ថម្ភក្រោម PFMRP ។ |
| ៤ ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព នៃកម្មវិធីកែទម្រង់ត្រូវបានរៀបចំ និងអនុវត្ត (ជំហានបឋមអនុវត្តផ្ទៃក្នុង អ.គ.ហ. ) | • ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព នៃកម្មវិធីកែទម្រង់ជំហានទី ១ ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅផ្ទៃក្នុង អ.គ.ហ. ។ |

29

## ផ្នែកទី៥៖ការគាំទ្រកម្មវិធីកែទម្រង់ និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ — វឌ្ឍនភាព(ត...)

| | |
|---|---|
| ៥ ក្របខណ្ឌលើកទឹកចិត្តផ្សារភ្ជាប់សមិទ្ធកម្មត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២១ | • បច្ចុប្បន្ន ការលើកទឹកចិត្ត ត្រូវបានធ្វើឡើងតាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប៉ុន្តែពុំទាន់បានផ្សារភ្ជាប់ពេញលេញជាមួយសមិទ្ធកម្មនៅឡើយ ។ |
| ៦ កិច្ចប្រជុំកម្មវិធីកែទម្រង់ ៣ ប្លុក ១ ត្រូវបានរៀបចំប្រចាំត្រីមាស និងយ៉ាងតិច ៩០% នៃផែនការសកម្មភាពត្រូវបានអនុវត្ត | • ពុំមានវឌ្ឍនភាព ដោយរង់ចាំការដឹកនាំប្រជុំរបស់លេខាធិការដ្ឋាន គជអប ។<br>• សម្រាប់ផែនការសកម្មភាព ត្រូវបានអាក់ខានដោយត្រូវផ្តោតលើការរៀបចំឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ ប្លុក ១ ។ |
| ៧ ឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ ប្លុក ១ | • សេចក្តីព្រាងឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ បី ប្លុក មួយ ត្រូវបានរៀបចំ និងត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំកម្រិតអន្តរការដ្ឋានកែទម្រង់៣ ប្លុក ១ ចំនួន ៣លើក និងគម្រោងវិបស្សនា ត្រូវបានរៀបចំ។ |
| ៨ គោលការណ៍ណែនាំ ស្តីពីការពិពណ៌នាមុខតំណែងត្រូវបានដាក់ឱ្យអនុវត្ត | • បានបញ្ចប់ការរៀបចំសេចក្តីព្រាងលើកទី២ នៃឯកសារណែនាំស្តីពីការរៀបចំការពិពណ៌នាមុខតំណែង និងបានបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តឯកសារណែនាំស្តីពីការរៀបចំការពិពណ៌នាមុខតំណែងក្នុងកម្រិតអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ ។ |

30

## ផ្នែកទី៥÷ការគាំទ្រកម្មវិធីកែទម្រង់ និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ — សន្និដ្ឋាន

ការអនុវត្តផ្នែកទី៥នេះ រងផលប៉ះពាល់តិចតួចចំពោះការរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងសិក្ខាសាលាផ្សព្វផ្សាយ ដោយសារក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២១, តួអង្គដែលមានការពាក់ព័ន្ធបានផ្លាស់ប្តូរវិធីសាស្រ្តនៃការបណ្តុះបណ្តាល ឬសិក្ខាសាលាតាមរយៈប្រព័ន្ធអនឡាញ ។ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមអង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័ន បានខិតខំអនុវត្តតាមផែនការ និងបានផ្ញើរបាយការណ៍សមិទ្ធកម្មមក អ.គ.ហ. ទាន់ពេលវេលា បើទោះជាមានភាពយឺតយ៉ាវសម្រាប់ក្រសួង-ស្ថាប័នមួយចំនួនក្តី ។ ដើម្បីជំរុញចលនការ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គប្បីអនុវត្តវិធានការបន្ថែមរួមមាន ការបន្តពង្រឹងយន្តការអនុវត្ត និងបុរេសកម្មបំពេញតួនាទីភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ ដែលបានកំណត់ក្នុងលក្ខខណ្ឌយោងការងារ និងបន្តពង្រឹងយន្តការសម្របសម្រួល តាមដាន និងរាយការណ៍នៃការអនុវត្តផែនការសកម្មភាព ដូចមានកំណត់ក្នុង GDAP, C/PDAP, &MAP ។



## ➢ វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ. ប្រចាំត្រីមាសទី៤ ឆ្នាំ២០២១



## ➢ វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ. ប្រចាំឆ្នាំ២០២១






## ➢ សមិទ្ធកម្មសង្ខេបតាមមន្ទីរ សហវ. រាជធានី ខេត្ត

**វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់មន្ទីរ សហវ. រាជធានី-ខេត្ត ប្រចាំឆ្នាំ២០២១**




| | ១១.២.១. សៀវភៅបន្ទុក | ១១.២.២. ការអនុវត្តប្រកាសស្ដីពីការផ្ដល់សេវាសាធារណៈនៅមន្ទីរ-អង្គភាពជំនាញ | ២៣.១.១. បណ្ណកម្មសិទ្ធិអចលនទ្រព្យ ក្រោម កសហវ. នៅថ្នាក់មូលដ្ឋាន | ២៣.១.២. បណ្ណកម្មសិទ្ធិអចលនទ្រព្យនៃមន្ទីរ-អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ២៣.១.៣. តារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២០របស់មន្ទីរ-អង្គភាពជំនាញ | ២៣.១.៤. តារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
|---|---|---|---|---|---|---|
| គោលដៅប្រចាំឆ្នាំ | 451 | 345 | 16 | 153 | 813 | 1253 |
| វឌ្ឍនភាពប្រចាំឆ្នាំ | 449 | 316 | 9 | 134 | 803 | 1121 |
| % ធៀបប្រចាំឆ្នាំ | 100% | 92% | 56% | 88% | 99% | 89% |

## ➢ វឌ្ឍនភាព (%) តាមមន្ទីរ សហវ. រាជធានី ខេត្ត ប្រចាំត្រីមាសទី ៤ ឆ្នាំ២០២១






## ➢ វឌ្ឍនភាព (%) តាមមន្ទីរ សហវ. រាជធានី ខេត្ត ប្រចាំឆ្នាំ២០២១



## ➢ វឌ្ឍនភាព (%) តាមក្រសួង-ស្ថាប័ន ប្រចាំត្រីមាសទី ៤ ឆ្នាំ២០២១

វឌ្ឍនភាពជាភាគរយ(%) ប្រចាំត្រីមាសទី ៤ របស់ក្រសួង-ស្ថាប័ន






## ➢ វឌ្ឍនភាព (%) តាមក្រសួង-ស្ថាប័ន ប្រចាំឆ្នាំ២០២១

ការអនុវត្តថវិកា និងវឌ្ឍនភាពជាភាគរយ(%) ប្រចាំឆ្នាំ២០២១ របស់ក្រសួង-ស្ថាប័ន




■ ការអនុវត្តថវិកា ■ ប្រាក់ឧបត្ថម្ភលើកទឹកចិត្ត **%** ថវិកា (អនុវត្ត+ ឧបត្ថម្ភ) ធៀបនឹងថវិកា LMs សរុប **N/N, %** ចំនួនសកម្មភាព និងពិន្ទុសិទ្ធកម្ម

## ៣.ចំណាយលើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៤-២០២១




*សម្គាល់÷ ចំណាយរបស់ក្រុមការងារ FMIS, អង្គភាពក្រោមឱវាទ កសហវ. ក្រសួង-ស្ថាប័ន និងមន្ទីរ សហវ. បូកបញ្ចូលចំណាយលើទំនិញ, ទីប្រឹក្សា, បណ្ដុះបណ្ដាល/សិក្ខាសាលា, និងប្រតិបត្តិការ ។*



## ៣.ចំណាយលើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៤-២០២១




គិតជាលានរៀល/ លានដុល្លាសហរដ្ឋអាមេរិក

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS

❖ ការពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS

**ជំហានទី១ (២០១៣-២០១៦)**

- ៨ អគ្គនាយកដ្ឋានគន្លឹះ នៃ កសហវ.
- ២៥ រតនាគាររាជធានី-ខេត្ត

**៣៣ ការដ្ឋាន និងអ្នកប្រើប្រាស់ ចំនួន ៥០០ នាក់*

**ជំហានទី២ (២០១៧-២០២០)**

- ៣៧ ក្រសួង-ស្ថាប័ន
- ២៥ មន្ទីរ សហវ. រាជធានី-ខេត្ត
- ២៥ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ

**៨៧ ការដ្ឋាន និងអ្នកប្រើប្រាស់ ចំនួន ១ ១៦២ នាក់*

**ជំហានទី៣ (២០២១-២០២៥)**

- ២៥ រដ្ឋបាលរាជធានី-ខេត្ត
- ២៧ រដ្ឋបាលក្រុង, ១៤ រដ្ឋបាលខណ្ឌ, និង ២ រដ្ឋបាលស្រុក
- ៥០ មន្ទីរជំនាញ រាជធានី-ខេត្ត (២ក្រសួង-ស្ថាប័ន)
- ២០ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ

** ១៣៨ ការដ្ឋាន និងអ្នកប្រើប្រាស់ចំនួន ១ ៧០០ នាក់*

41

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS (ត...)

- ការប្រើប្រាស់ web-based application សម្រាប់កុំព្យូទ័រផ្សេង ដើម្បីអាចប្រើប្រាស់ប្រព័ន្ធ FMIS បាន ។
- ការរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំអំពីលំហូរនៃការអនុវត្តនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS នៅតាមដំណាក់កាលត្រួតពិនិត្យនីមួយៗ (pendency of payment at various control points)។ អាចរៀបចំជា Dashboard សម្រាប់ថ្នាក់ដឹកនាំដើម្បីតាមដានអំពីលំហូរនៃការទូទាត់ ។
- ការផ្តួចផ្តើមឱ្យមានការប្រើប្រាស់ហត្ថលេខាអេឡិចត្រូនិក ។
- ការពង្រឹងតួនាទីសវនកម្ម ដែលដើរតួសំខាន់ក្នុងការវាយតម្លៃមុខងារ និងដំណើការប្រព័ន្ធ ។

- ក្នុងជំហានទី៣, ប្រព័ន្ធ FMIS នឹងត្រូវពង្រីកការដ្ឋានបន្ថែមរហូតដល់ ១៣៨ និងបន្ថែមអ្នកប្រើប្រាស់ចំនួន១ ៧០០ នាក់, ដូចនេះការតេស្តមាត្រដ្ឋានប្រព័ន្ធ គឺជាការចាំបាច់ដើម្បីបញ្ជាក់អំពីសមត្ថភាពប្រព័ន្ធ, ដំណើរការប្រព័ន្ធ និង database ដែលអាចទ្រទ្រង់សម្រាប់ផែនការនាពេលខាងមុខ ។

**ការកែលម្អប្រព័ន្ធ**

**ការអភិវឌ្ឍប្រព័ន្ធ**

**ការធ្វើមាត្រដ្ឋានប្រព័ន្ធ (System Scalability)**

**ការធ្វើសន្ធានកម្មប្រព័ន្ធ**

- ការធ្វើសន្ធានកម្មរវាងប្រព័ន្ធ DMFAS និង ប្រព័ន្ធ FMIS នៅមិនទាន់ពេញលេញ ។
- មិនទាន់ធ្វើសន្ធានកម្មរវាងប្រព័ន្ធ FMIS និង ប្រព័ន្ធ EFMS
- ការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធផ្សេងទៀត ជាអាទិ៍ PIMS របស់ GDP និង PPMS របស់ GDICDM ។
- ការពង្រឹងការធ្វើសន្ធានកម្មជាមួយធនាគារជាតិ និងធនាគារពាណិជ្ជផ្សេងទៀត ដើម្បីពង្រឹងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក និងការផ្ទៀងផ្ទាត់របាយការណ៍ដោយស្វ័យប្រវត្តិ (Automatic reconciliation)

42

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS (ត...)

- មុខងារសម្រាប់អនុវត្តថវិកាក្នុងប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់ ប៉ុន្តែនៅមានការប្រើប្រាស់ដោយដៃ នៅឡើយ ។
- ប្លង់គណនេយ្យ (CoA) មិនត្រូវបានកំណត់សម្រាប់អង្គភាពដែលស្ថិតក្នុងកម្រិតទាបបំផុត (Lowest level units) នៃក្រសួង-ស្ថាប័ន ។ ករណីនេះ តម្រូវឱ្យអង្គភាពទាំងនោះ អនុវត្តថវិកាដោយប្រើប្រាស់ដោយដៃ និងក្នុងករណីខ្លះត្រូវបង្កើតប្រព័ន្ធសម្រាប់ប្រើប្រាស់ផ្ទៃក្នុង ដូចជា EFMS របស់ ក្រសួងអប់រំ យុវជន និងកីឡា ជាដើម ។




- ក្រសួង-ស្ថាប័ន នៅពុំអាចប្រើប្រាស់ប្រព័ន្ធសម្រាប់រៀបចំរបាយការណ៍ និងគ្រប់គ្រងថវិកាផ្ទៃក្នុង ។
- ចំណាយហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ពុំទាន់បានកត់ត្រាចូលប្រព័ន្ធ FMIS ។
- មុខងារលទ្ធកម្មពុំមានវិសាលភាពដល់លទ្ធកម្មចំណាយវិនិយោគ គឺត្រឹមចំណាយចរន្ត ។
- មុខងាររៀបចំផែនការថវិកា នឹងត្រូវប្រើប្រាស់សម្រាប់បញ្ចូលសំណើថវិកា (Budget Request Collation) ដោយពុំទាន់ប្រើប្រាស់សម្រាប់រៀបចំថវិកា, ការស្នើ និងការចរចាដែលកិច្ចការទាំងនេះ នៅតែដំណើរការដោយដៃនៅឡើយ ។

43

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS (ត...)

❖ ការរៀបចំអភិបាលកិច្ច និងការគ្រប់គ្រងការផ្លាស់ប្ដូរ

- គម្រោង FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់ស្របតាមផែនការដែលបានកំណត់ ប៉ុន្តែពុំមានការពិគ្រោះយោបល់ជាផ្លូវការ ឬជាទៀងទាត់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមគន្លឹះៗ ។
- អង្គភាពជំនាញចាំបាច់ត្រូវចូលរួមពេញលេញជាមួយលេខាធិការដ្ឋាន FMWG ដើម្បីធានាថាការអនុវត្តសម្រេចតាមគោលដៅរំពឹងទុកដែលបានដាក់ចេញក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។




- ពង្រឹងការរៀបចំផែនការ និងការតាមដានគម្រោងFMIS ។
- ពង្រឹងការតាមដានអនុសាសន៍នៃរបាយការណ៍ទីប្រឹក្សា (Advisory Report), និងរបាយការណ៍សវនកម្មលើប្រព័ន្ធ FMIS ។
- ការយល់ដឹងអំពីតម្រូវការនៃការតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS (Business Process) នៅមានកម្រិត ។ ដំណើរការ (Process) ត្រូវបានរៀបចំឡើងវិញបន្ទាប់ពីដាក់ឱ្យប្រើប្រាស់មុខងារនៃប្រព័ន្ធ FMIS ។
- ការយល់ដឹងអំពីតម្រូវការ និង អត្ថប្រយោជន៍ នៃការប្រើប្រាស់ប្រព័ន្ធ FMIS នៅមានកម្រិត ។
- គួរបង្កើតជាវេទិកាពិភាក្សាលើការប្រើប្រាស់ប្រព័ន្ធ FMIS ជាប្រចាំ ដោយមានការចូលរួមពីអ្នកប្រើប្រាស់ ។ 44

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS (ត...)

ជារួម ផែនការពង្រីកប្រព័ន្ធ FMIS ជំហានទី១ និងជំហានទី២ ទទួលបានជោគជ័យ ។ មុខងារនៃប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់ ប៉ុន្តែពុំទាន់ត្រូវបានអនុវត្តពេញលេញនៅឡើយ ជាពិសេសការទាញអត្ថប្រយោជន៍ជាអតិបរមាពីប្រព័ន្ធ FMIS ។ ក្នុងន័យនេះ គួរផ្តោតលើការពង្រឹងការអនុវត្តឱ្យបានពេញលេញនូវមុខងារនៃប្រព័ន្ធ FMIS, ការតម្រង់ទិសនីតិវិធីអនុវត្តការងារ, ការផលិតរបាយការណ៍, ការធ្វើសន្ធានកម្មជាមួយប្រព័ន្ធផ្សេងៗ, និងការពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងការផ្លាស់ប្តូរ, មុននឹងពង្រីកការដ្ឋានប្រព័ន្ធ FMIS បន្ថែមទៀត ។



## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃចំណាយសាធារណៈ

❖ ***ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ***

- តម្រឹមរចនាសម្ព័ន្ធកម្មវិធី
- ធ្វើសមាហរណកម្មចំណាយវិនិយោគក្នុងស្រុក និងប្រភពខាងក្រៅ ទៅក្នុង BSP
- តម្រឹម BSP ជាមួយ MTFF

- ធ្វើបច្ចុប្បន្នភាពតួនាទី និងភារកិច្ចសវនកម្មផ្ទៃក្នុង
- បង្កើត រៀបចំផែនទីបង្ហាញផ្លូវ និងអនុវត្តក្របខណ្ឌត្រួតពិនិត្យផ្ទៃក្នុង
- ផ្សព្វផ្សាយរបាយការណ៍សវនកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ពង្រឹងតួនាទីក្រសួង-ស្ថាប័នក្នុងការធ្វើការសិក្សាសមិទ្ធិលទ្ធភាព ។
- ពង្រឹងការសម្របសម្រួលឱ្យទូលាយក្នុងវិស័យ ពាក់ព័ន្ធនឹងគម្រោងវិនិយោគហិរញ្ញប្បទានពីប្រភពខាងក្រៅ ។




- មិនបូកបញ្ចូលធាតុចូលជាម៉ាទ្រីស (ឧ. សិក្ខាសាលា)
- ផ្តោតលើលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ
- កាត់បន្ថយសូចនាករ មកនៅត្រឹម ៥ ទៅ ១០ ដែលជាសូនាករគន្លឹះ
- ធ្វើសមាហរណកម្មម៉ាទ្រីសសមិទ្ធកម្មទៅក្នុងសំណើថវិកា
- សមិទ្ធកម្ម (តាមរយៈ BSP) គួរត្រូវបានផ្តោតក្នុងការចរចាថវិកា
- រៀបចំម៉ាទ្រីសសមិទ្ធកម្ម ភ្ជាប់ជាមួយនឹងការកសាងសមត្ថភាព ។

- គិតគូរលើការផ្តល់ឆន្ទានុសិទ្ធក្នុងការធ្វើនិយ័តថវិការវាងសមាសធាតុចំណាយមួយចំនួន
- ពង្រឹងការធានាចំណាយ និងផែនការសម្រាប់កិច្ចលទ្ធកម្មឱ្យទាន់ពេលវេលា

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃចំណាយសាធារណៈ

❖ ***រដ្ឋបាលខេត្តព្រះសីហនុ***

- ការពន្យារពេលក្នុងការរៀបចំឯកសារគម្រោង ដោយសារពុំមានមន្ត្រីបច្ចេកទេសគ្រប់គ្រាន់ ។
- តម្លាភាព និងបញ្ហាប្រឈម ក្នុងដំណើរការកិច្ចលទ្ធកម្ម ។




- ការផ្ទេរមុខងារចំនួន ៥៥ មុខងារ ទៅរដ្ឋបាលក្រុង ស្រុក ។ ប៉ុន្តែ រដ្ឋបាលក្រុង ស្រុក ទទួលបានថវិកាតិចបំផុត និងមិនមានការផ្ទេរថវិកា ទៅតាមមុខងារទាំង ៥៥ ។

- សមត្ថភាព និងបញ្ហាប្រឈមនៃការរៀបចំ BSP និង ថវិកាប្រចាំឆ្នាំ
- គម្លាតខ្ពស់រវាងការអនុវត្តថវិកា និងផែនការ(ការព្យាករចំណូលទាបធៀបនឹងការអនុវត្ត និង សំណើបន្ថែមឥណទានថវិកាមានកម្រិតខ្ពស់ ។
- សំណើសម្រាប់ការបន្ថែមឥណទានថវិកាមានភាពយឺតយ៉ាវ ។
- ដំណើការធានាចំណាយ និងកិច្ចលទ្ធកម្មត្រូវការពេលវេលាយូរ (ជាពិសេសគម្រោងដែលលើសពិតានថវិកា) ។
- ដំណើរការរៀបចំការទទួលទំនិញ និងការទូទាត់ត្រូវការរយៈពេលយូរ (ជាពិសេសគម្រោងដែលលើសពិតានថវិកា) ។



## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

- ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រើប្រាស់ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ដែលធ្លាប់បានប្រើប្រាស់សម្រាប់ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈចំនួនបីលើករួចមកហើយគឺនៅឆ្នាំ២០១០, ២០១៥ និងឆ្នាំ២០២១ ។
- បច្ច័យលើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ គឺធ្វើការប្រៀបធៀបលើលទ្ធផលទាំងបីលើក និងទាញការសន្និដ្ឋានលើលទ្ធផលវាយតម្លៃជាកម្រិតម៉ាក្រូ ក្នុងនោះរួមមាន÷ **(១) វិន័យថវិកា, (២) ប្រសិទ្ធភាពវិភាជន៍ថវិកា និង (៣) ស័ក្តិសិទ្ធភាពការផ្តល់សេវាសាធារណៈ** ។
- របកគំហើយពីការវាយតម្លៃ PEFA ឆ្នាំ២០២១ ដែលប្រើប្រាស់ក្របខណ្ឌ PEFA ឆ្នាំ២០១១ បង្ហាញថាមានការកែលម្អក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងពិន្ទុនៃសូចនាករសមិទ្ធកម្ម (PIs) ចំនួន ១០ ក្នុងនោះរួមមាន÷ PI-2, PI-6, PI-7, PI-10, PI-13, PI-14, PI19, PI-21, PI-23 និង PI-25 រីឯ PI-3 ទទួលបានពិន្ទុទាបដោយសារមានគម្លាតខ្ពស់រវាងផែនការនិងលទ្ធផលប្រមូលចំណូលចាប់ពីឆ្នាំ២០១៧, ២០១៨ និង២០១៩ ។ អ.គ.ហ. បាននិងកំពុងរៀបចំក្របខណ្ឌវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន (កំពុងស្ថិតសេចក្តីព្រាង) និងសាកល្បងវាយតម្លៃឆ្នាំ២០២២នេះ ។

# ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

**បំរែបំរួលពិន្ទុ PEFA ឆ្នាំ២០១០, ២០១៥, ២០២១**






# ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

- ***វិន័យថវិកា÷*** ផ្នែកការអនុវត្តចំណាយថវិកាបង្ហាញថាមានភាពកាន់តែមានល្អប្រសើរ ប៉ុន្តែចាំបាច់ត្រូវដោះស្រាយលើចំណាយកកស្ទះ (ទាំងផ្នែកនិយមន័យ និងបំណុលចាស់) និងការអនុវត្តចំណូលថវិកាត្រូវបន្តពង្រឹងការព្យាករចំណូល, ពង្រឹងរដ្ឋបាលប្រមូលចំណូលជាពិសេសអនុលោមភាព និងការគ្រប់គ្រងហានិភ័យ, ការតាមដានលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ។
- ***ប្រសិទ្ធភាពវិភាជន៍ថវិកា÷*** ថវិកាប្រចាំឆ្នាំត្រូវបានរៀបចំស្របតាមប្រតិទិនថវិកា ប៉ុន្តែចាំបាច់ត្រូវបង្កើនគុណភាពឯកសារថវិកាបន្ថែមទៀត ។ ការរៀបចំថវិការយៈពេលមធ្យមគឺស្ថិតក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ ដោយហេតុថាក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យមពុំទាន់ត្រូវបានអនុវត្ត និងថវិការយៈពេលមធ្យមត្រូវបានអនុវត្តសាកល្បងចាប់ពីឆ្នាំ២០១៩ ។
- ***ស័ក្តិសិទ្ធភាពការផ្តល់សេវាសាធារណៈ÷*** មិនទាន់អនុវត្តបានល្អនៅឡើយ ជាពិសេសកង្វះប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម, កិច្ចលទ្ធកម្មសាធារណៈគឺការប្រកួតប្រជែងនៅមានកម្រិត, និងតម្លាភាពថវិកាក៏នៅមានកម្រិត ផងដែរ ។

## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

*ការងារគន្លឹះត្រូវពង្រឹងបន្ថែមតាមវដ្តថវិកា ដោយធៀបនឹងស្តង់ដា PEFA*

**ចំណុចគន្លឹះត្រូវពង្រឹងបន្ថែមតាមវដ្តថវិកា**

**រៀបចំផែនការ**

- ការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រតាមវិស័យទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រតាមវិស័យ និងធនធាន ។

**រៀបចំថវិកា**

- សមាហរណកម្មថវិកាចរន្ត និងមូលធន
- ថវិការយៈពេលមធ្យម
- គុណភាព BSP និង PB (រចនាសម្ព័ន្ធកម្មវិធី និងសូចនាករ)
- ការប្រើប្រាស់ចំណាត់ថ្នាក់មុខងារ
- ការផ្សារភ្ជាប់រវាងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងផែនការយុទ្ធសាស្ត្រថវិកា ។

**អនុវត្តថវិកា**

- ចំណាយកកស្ទះ និងបំណុលពន្ធ
- ការប្រើប្រាស់វិធីសាស្ត្រកិច្ចលទ្ធកម្ម រួមទាំងតម្លាភាព
- ការវិភាគ និងវាយតម្លៃហានិភ័យពន្ធ
- ការអនុវត្តមុខងារអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករ
- ភាពទាន់ពេលវេលានៃការផលិតរបាយការណ៍ហិរញ្ញវត្ថុ
- សមាហរណកម្មប្រព័ន្ធបៀវត្ស និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ។

**ត្រួតពិនិត្យ និងវាយតម្លៃ**

- ការវាយតម្លៃសមិទ្ធកម្មនៅតាមក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល
- ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម
- សវនកម្មលើសមិទ្ធកម្មស្ថិតក្នុងដំណាក់កាលចាប់ផ្តើម
- សវនកម្មលើបៀវត្ស
- មុខងារសវនកម្ម និងអធិការកិច្ច
- គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ ។

**ពិនិត្យពិនិស្ស័យថវិកា**

- ជំនួយបច្ចេកទេសដើម្បីពិនិត្យលើសេចក្តីព្រាង ច្បាប់ថវិកា និងរបាយការណ៍សវនកម្ម
- យន្តការតាមដានអនុសាសន៍សវនកម្មផ្ទៃក្រៅ ។

51

## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិ

**ពិន្ទុវាយតម្លៃសូចនាករ PEFA ថ្នាក់ក្រោមជាតិ សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ**




| ពិន្ទុ | ចំនួនសូចនាករ |
|---|---|
| A | 2 |
| B+ | 0 |
| B | 2 |
| C+ | 3 |
| C | 3 |
| D+ | 7 |
| D | 11 |

52

## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលបឋមនៃការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិ

***ការងារគន្លឹះត្រូវពង្រឹងបន្ថែមតាមវដ្តថវិកា ដោយធៀបនឹងស្តង់ដា PEFA***




- បង្កើនគុណភាព និងភាពទាន់ពេលវេលានៃការរៀបចំផែនការយុទ្ធសាស្រ្តថវិកា
- ការដាក់ឱ្យអនុវត្តថវិការយៈពេលមធ្យម (MTBF)

- គុណភាពថវិកាកម្មវិធី (រចនាសម្ព័ន្ធកម្មវិធី, លទ្ធផលចុងក្រោយ និងលទ្ធផលចុងក្រោយ (សូចនាករ និងគោលដៅ)
- ការប្រើប្រាស់ចំណាត់ថ្នាក់មុខងារ
- ការគ្រប់គ្រងវិនិយោគសាធារណៈ
- បង្កើនតម្លាភាពថវិកា និងការចូលរួមពីសាធារណជន

- ចំណាយកកស្ទះ
- ការប្រើប្រាស់វិធីសាស្រ្តកិច្ចលទ្ធកម្ម រួមទាំងតម្លាភាព
- ការអនុវត្តមុខងារអគ្គីបាលហិរញ្ញវត្ថុ និងគណនេយ្យករ
- ភាពទាន់ពេលវេលានៃការផលិតរបាយការណ៍ហិរញ្ញវត្ថុ

- ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម
- សវនកម្មលើបៀវត្ស
- មុខងារសវនកម្ម

- ពង្រឹងមុខងារប្រតិគុល្យភាព
- ពង្រឹងការត្រួតពិនិត្យវដ្តថវិកា



## ៦. បញ្ហាប្រឈម និងសំណើដំណោះស្រាយ

| ល.រ | បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|---|
| ***ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា*** | | |
| ០១ | ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអាករពិសេស នៅមិនទាន់មានវឌ្ឍនភាព ។ | ស្នើអង្គភាពពាក់ព័ន្ធជំរុញការងាររៀបចំសេចក្តីព្រាងច្បាប់នេះ ។ (GDAP) |
| ០២ | ការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារនៅមិនទាន់មាននីតិវិធីលម្អិត ហើយមានក្រសួង- ស្ថាប័នមួយចំនួនតូចប៉ុណ្ណោះបាននិងកំពុងអនុវត្ត ។ ក្រសួង- ស្ថាប័នមួយចំនួនទៀតពុំទាន់មានឆន្ទៈក្នុងការដាក់ចេញជាសកម្មភាពសម្រាប់អនុវត្តសកម្មភាពនេះនៅឡើយ។ | ស្នើអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ រួមទាំងអង្គភាពពាក់ព័ន្ធពិនិត្យ និងសិក្សាលើរៀបចំនីតិវិធីលម្អិត និងជំរុញការអនុវត្តនៅតាមក្រសួង- ស្ថាប័ន ។ (MAP) |

## ៦. បញ្ហាប្រឈម និងសំណើដំណោះស្រាយ (ត...)

| ល.រ | បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|---|
| *ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា* | | |
| ០៣ | ក្រសួង-ស្ថាប័នមានការពិបាកក្នុងការអនុវត្តថវិកាប្រចាំឆ្នាំ ដោយសារ (១) កញ្ចប់ថវិកាត្រូវបានផ្ញើជូនក្រសួង-ស្ថាប័ន និងអង្គភាពថវិកាយឺតយ៉ាវ (២) នីតិវិធីហិរញ្ញវត្ថុថ្មី (នីតិចំណាយរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) និងរបៀបប្រើប្រាស់មុខងារលើប្រព័ន្ធ FMIS នៅពុំទាន់ផ្សព្វផ្សាយបានទូលំទូលាយ និង (៣) ការអនុវត្តការបិទបញ្ជីចុងឆ្នាំមានភាពតឹងរឹង ។ កត្តាទាំងអស់នេះ បណ្តាលឱ្យការអនុវត្តចំណាយថវិកាមានភាពយឺតយ៉ាវ និងចំណាយឆ្លងឆ្នាំមួយចំនួនពុំត្រូវបានទូទាត់ ហើយការប្រូកសុបឯកសារហិរញ្ញវត្ថុ និងរៀបចំកិច្ចបញ្ជិកាគណនេយ្យដោយអង្គភាពហិរញ្ញវត្ថុ ដែលជាសេនាធិការរបស់អាណាប័កដើមខ្សែ គឺមានភាពស្មុគស្មាញ និងត្រូវការពេលវេលាច្រើន ដោយហេតុថាអង្គភាពហិរញ្ញវត្ថុត្រូវសម្របសម្រួលជាមួយអង្គភាពថវិកាជាច្រើន ។ | ស្នើអគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក្រោមជាតិ និងអគ្គ-នាយកដ្ឋានរតនាគារជាតិ ពិនិត្យឡើងវិញលើការនីតិចំណាយរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងការផ្សព្វផ្សាយលិខិតបទដ្ឋានថ្មីៗ ជាពិសេសពាក់ព័ន្ធការអនុវត្តថវិកា ព្រមទាំងបន្តពង្រឹងការពិភាក្សា និងកំណត់បញ្ហាប្រឈមជាមួយក្រសួង ស្ថាប័ន ដែលអនុវត្តលិខិតបទដ្ឋានថ្មី ដើម្បីឱ្យការអនុវត្តថវិកាកាន់តែមានភាពរលូន ។<br>(សិក្ខាសាលា PB) |



## ៦. បញ្ហាប្រឈម និងសំណើដំណោះស្រាយ (ត...)

| ល.រ | បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|---|
| *ផ្នែកទី២÷ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ* | | |
| ០៤ | ការកំណត់ទម្រង់របាយការណ៍ហិរញ្ញវត្ថុរួមសម្រាប់រដ្ឋបាលរាជធានី-ខេត្ត ដែលអាចផលិតចេញពី FMIS ដើម្បីជៀសវាងការប្រើប្រាស់របាយការណ៍មានទម្រង់ច្រើន និងបង្កើនបន្ទុកដល់មន្ត្រីទទួលបន្ទុក ដែលប្រើប្រាស់ដោយដៃផង និងប្រព័ន្ធផងក្នុងការផលិតរបាយការណ៍ផង ។ | ស្នើ FMWG សហការជាមួយអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ និងរដ្ឋបាលរាជធានី-ខេត្តសិក្សាលើតម្រូវការរបាយការណ៍ហិរញ្ញវត្ថុ ។<br>(SNA PB Workshop) |
| ០៥ | ការបន្តពង្រីកប្រព័ន្ធ FMIS នៅការដ្ឋានកាន់តែច្រើនបានបង្កើនបន្ទុកចំណាយ, ចំនួនមន្ត្រី និងបន្ទុកការងារ ។ មុខងារប្រព័ន្ធត្រូវបានដាក់ឱ្យប្រើប្រាស់ ប៉ុន្តែពុំទាន់អនុវត្តពេញលេញនៅឡើយ ។ ម្យ៉ាងទៀត អគ្គនាយកដ្ឋានជំនាញពុំបានចូលរួមពេញលេញលើការសិក្សានីតិវិធីអនុវត្តការងារសម្រាប់មុខងារថ្មីៗ ដែលកិច្ចការនេះត្រូវបានសិក្សា និងរៀបចំឡើងដោយលេខាធិការដ្ឋាន FMWG ដែលអាចនាំឱ្យពិបាកកំណត់នីតិវិធីអនុវត្តការងារច្បាស់លាស់, អនុវត្តដោយរលូន និងកែសម្រួលច្រើនលើក ។ | តើគួរផ្តោតលើការពង្រឹងការអនុវត្តឱ្យបានពេញលេញនូវមុខងារនៃប្រព័ន្ធ FMIS, ការកែសម្រួលនិតិវិធីអនុវត្តការងារ, ការផលិតរបាយការណ៍, ការធ្វើសន្ទានកម្មជាមួយប្រព័ន្ធផ្សេងៗ, ការពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងការផ្លាស់ប្តូរ ដែរឬទេ? |

## ៦. បញ្ហាប្រឈម និងសំណើដំណោះស្រាយ (ត...)

| ល.រ. | បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|---|
| ០៦ | ក្រសួង-ស្ថាប័នមួយចំនួនពុំទាន់ចាប់ផ្តើមអនុវត្ត SARMIS និងបញ្ហាប្រឈមជាបច្ចេកទេសមួយចំនួន រួមមាន ការពិបាកពិនិត្យទិន្នន័យតាមការិយាល័យ, តារាងទិន្នន័យបានជម្រះ គ្មានជួរឈរបញ្ជាក់អំពីអត្តសញ្ញាណ និងមិនអាចកំណត់ទិន្នន័យជាក្រុមក្នុងតារាងចុះបញ្ជី ។ | ស្នើអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធបន្តជំរុញការប្រើប្រាស់ SARMIS នៅតាមក្រសួង-ស្ថាប័ន និងកែលម្អ SARMIS បន្ថែមទៀត ។ (MAP) |
| ០៧ | អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋបានធ្វើបណ្ណកម្មសិទ្ធិរួចរាល់លើទីតាំងចំនួន ១៧ ៧៦៤ កន្លែង ស្មើនឹង ៦២% នៃទីតាំងសរុបចំនួន ២៨ ៥៦០ កន្លែង ចំណែកទីតាំងដែលគ្មានបណ្ណកម្មសិទ្ធិដីធ្លីទ្រព្យសម្បត្តិរដ្ឋចំនួន ៣៨% ស្មើនឹង ១០ ៧៩៦ កន្លែង ។ ការរៀបចំបណ្ណកម្មសិទ្ធិនេះ នៅតែមានបញ្ហានៅតាមបណ្តារាជធានី-ខេត្តមួយចំនួន ដែលត្រូវដោះស្រាយ និងពន្លឿនការរៀបចំបណ្ណកម្មសិទ្ធិបន្ថែមទៀត ។ | ស្នើអគ្គនាយកដ្ឋានសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធបន្តជំរុញការងារការរៀបចំបណ្ណកម្មសិទ្ធិដីធ្លីនៃទ្រព្យសម្បត្តិរដ្ឋ និងការរៀបចំផែនការគោលនៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។ (GDAP) |

57

## ៦. បញ្ហាប្រឈម និងសំណើដំណោះស្រាយ (ត...)

| ល.រ | បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|---|
| ***ផ្នែកទី៣ ÷ ការពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ*** | | |
| ០៨ | រដ្ឋបាលថ្នាក់ក្រោមជាតិពិបាកក្នុងការកំណត់សូចនាករសមិទ្ធកម្មលទ្ធផលក្នុងឆ្នាំ និងគោលដៅ/លទ្ធផលចុងក្រោយនិងគោលដៅក្នុង BSP និងថវិកាកម្មវិធី រួមទាំងការរៀបចំរបាយការណ៍សមិទ្ធកម្ម ។ | ស្នើអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិបន្តការបណ្តុះបណ្តាល និងរៀបចំគោលការណ៍ណែនាំលម្អិតលើការតាមដានសមិទ្ធកម្ម/លទ្ធផល ។ (SNA PB Workshop) |
| ០៩ | ការអនុវត្តថវិកាកម្មវិធីថ្នាក់ក្រោមជាតិត្រូវបាននិងកំពុងអនុវត្តនៅរដ្ឋបាលរាជធានីខេត្ត ប៉ុន្តែតម្រូវឱ្យមានការសម្របសម្រួលជាច្រើនដើម្បីដោះស្រាយបញ្ហាឈម ។ | ស្នើអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិគួរចាប់ផ្តើមរៀបចំសិក្ខាសាលាស្តីពីការអនុវត្តថវិកាថវិកាកម្មវិធីជាប្រចាំឆ្នាំ ។(SNA PB Workshop) |
| ***ផ្នែកទី៤ ÷ ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម*** | | |
| ១០ | ការរៀបចំលិខិតបទដ្ឋានគោល (ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មី, អនុក្រឹត្យលេខ៨១ និង៨២) កំពុងតែមានវឌ្ឍនភាព ។ ក្នុងករណី មិនបានបញ្ចប់ក្នុងឆ្នាំ២០២២ អាចនឹងមានបច្ច័យដល់ការបញ្ចប់ការត្រៀមខ្លួនសម្រាប់ឈានទៅអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម ។ | ស្នើជំរុញការរៀបចំលិខិតបទដ្ឋានគោលនេះ ដោយបញ្ចប់ក្នុងឆ្នាំ២០២២ ។ (GDAP) |

58

## ៦. បញ្ហាប្រឈម និងសំណើដំណោះស្រាយ (ត...)

| ល.រ | បញ្ហាប្រឈម | សំណើដំណោះស្រាយ |
|---|---|---|
| *បញ្ហាប្រឈមរបស់មន្ទីរ សហវ. រាជធានី ខេត្ត* | | |
| ១១ | មន្ទីរ សហវ. រាជធានីខេត្ត បំពេញមុខងារជាអភិបាលហិរញ្ញវត្ថុនៅថ្នាក់មូលដ្ឋាន និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប៉ុន្តែមានការពិបាកក្នុងការបំពេញមុខងារលើការងារមួយចំនួន ក្នុងនោះរួមមាន÷ (១) ពុំមានសិទ្ធិក្នុងការពិនិត្យរបាយការណ៍សម្រាប់ការបង់ចំណូលក្នុង NRMIS របស់មន្ទីរជំនាញ, (២) ការជំរុញឱ្យអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋធ្វើបណ្ណកម្មសិទ្ធិដីធ្លី, (៣) ផែនការលទ្ធកម្មរបស់មន្ទីរជំនាញមានទំហំថវិកា ដែលពុំអាចអនុវត្តនីតិលទ្ធកម្មបាន និង (៤) ការប្រមូលសរុបរបាយការណ៍សមិទ្ធកម្មរបស់មន្ទីរជំនាញ មិនទាន់បាន ដោយសារមន្ទីរជំនាញពុំបានផ្ញើជូន មន្ទីរ សហវ. ។ | ស្នើ អ.គ.ហ. សហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទ កសហវ. ពិនិត្យ និងដោះស្រាយលើបញ្ហាប្រឈមរបស់មន្ទីរ សហវ. ជាជំហាន ។ (កិច្ចប្រជុំពិភាក្សាលើរបាយការណ៍ជាមួយមន្ទីរ សហវ) |



## ៧. សេចក្តីសន្និដ្ឋាន

ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យតាមដានវឌ្ឍនភាពប្រចាំឆ្នាំ២០២១, សកម្មភាពជាច្រើនសម្រេចបានតាមគោលដៅ និងសកម្មភាពមួយចំនួនកំពុងមានវឌ្ឍនភាព ហើយសកម្មភាពគន្លឹះពាក់ព័ន្ធនឹងការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ ត្រូវបាននិងកំពុងរៀបចំជាបណ្តើរៗផងដែរ ។ គុណភាពនៃការរៀបចំ GDAP/PDAP/MAP និងរបាយការណ៍មានភាពប្រសើរជាងមុន ។ អង្គភាពក្រោមឱវាទ កសហវ. ១០០% អនុវត្តផែនការបានលើសពី ៨៥%, មន្ទីរ សហវ. រាជធានីខេត្ត ជាង ៩០% អនុវត្តផែនការបានលើសពី ៨៥%, និងក្រសួង-ស្ថាប័ន ជាង ៧០% អនុវត្តផែនការបានលើសពី ៨៥% ។

បើទោះជាស្ថិតក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩, សកម្មភាពកែទម្រង់នៅតែមានចលនការគួរឱ្យកត់សម្គាល់ ដែលនេះបានបង្ហាញអំពីឆន្ទៈ និងការចូលរួមពីគ្រប់ភាគីដែលមានការពាក់ព័ន្ធក្នុងការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ឱ្យកាន់តែរឹងមាំ និងធននឹងវិបត្តិ ។

## ៧. សេចក្តីសន្និដ្ឋាន (ត...)

- **ថវិកានៅតែមានភាពជឿទុកចិត្ត** ដែលបានក្លាយជាកម្លាំងចលករក្នុងការទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ច បើទោះបីជាមានផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ប៉ុន្តែត្រូវពង្រឹងពិពិធកម្មចំណូល និងពង្រឹងប្រសិទ្ធភាពអនុវត្តចំណាយ ។
- **បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពហិរញ្ញវត្ថុ** ត្រូវបានកសាង និងពង្រឹងបន្ថែម ដើម្បីធានាគណនេយ្យភាព និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងក្នុងគោលដៅប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងតម្លាភាព ។
- **ក្របខណ្ឌថវិកាកម្មវិធី** ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្តទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។
- **បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពសមិទ្ធកម្ម** ត្រូវបាននិងកំពុងរៀបចំជាបណ្តើរៗ ដែលស្ថិតក្នុងដំណាក់កាលឈានទៅបញ្ចប់ដើម្បីត្រៀមខ្លួនសម្រាប់ដំណាក់កាលទី៤ ។
- **សមត្ថភាពមន្ត្រីនៃក្រសួង-ស្ថាប័នក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ត្រូវបានពង្រឹងជាបណ្តើរៗ និងកម្រិតនៃការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានការកើនឡើង ប៉ុន្តែត្រូវជំរុញបន្ថែមទៀតសម្រាប់ការអនុវត្តដំណាក់កាលទី៤ ដែលជាដំណាក់កាលកាន់តែសំខាន់ ។



## ៧. សេចក្តីសន្និដ្ឋាន (ត...)

ការវាយតម្លៃ PEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានផ្តល់ជាលទ្ធផលគោល/បន្ទាត់មូលដ្ឋាន (Baseline) អំពីស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ដើម្បីផ្តល់ជាធាតុចូលសម្រាប់រៀបចំក្របខណ្ឌផែនការសកម្មភាព តាមរយៈការកំណត់ការដ្ឋានអាទិភាព ដើម្បីដោះស្រាយជាដំណាក់កាលៗ ។ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺចាំបាច់ត្រូវពង្រឹងជាប្រចាំ និងកសាងសមាសធាតុ សំខាន់ៗបន្ថែមទៀត ដើម្បីឆ្លើយតបបានទៅនឹងបរិការណ៍នៃជំងឺកូវីដ-១៩ និងវិបត្តិផ្សេងៗដែលអាចកើតមានជាយថាហេតុ ដើម្បីតម្រង់ឆ្ពោះទៅរកគណនេយ្យភាពសមិទ្ធកម្ម ។

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព គឺមូលដ្ឋានគ្រឹះដ៏ចាំបាច់មិនអាចខ្វះបាន សម្រាប់ការជំរុញអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្រ ជាពិសេសតាមរយៈការធានានូវកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ដល់ប្រជាជនព្រមទាំងរួមចំណែកសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ។

# អភិក្រមការងារ ៤ ប្រការ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១. អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និងគោរពក្រមសីលធម៌វិជ្ជាជីវៈ
២. អនុវត្តការងារជាក្រុម
៣. អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និងគោលការណ៍ប្រសិទ្ធភាពថវិកា
៤. មិនត្រូវមើលរំលងកំហុសខ្លួនឯង

## សូមអរគុណ!

## ឧបសម្ព័ន្ធទី ៧ ÷ បទបង្ហាញស្ដីពីរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ PFMRP និងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១ សម្រាប់កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២១ (ភាសាខ្មែរ)

### កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២១
### ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ បូក២

# របាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១

"កែលម្អប្រព័ន្ធ ក្របខណ្ឌគតិយុត្ត យន្តការស្ថាប័ន និងធនធានមនុស្ស"

ថ្ងៃពុធ ៦រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
ប្រព័ន្ធវីដេអូអនឡាញ, ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០២២



# មាតិកា

១. សេចក្តីផ្តើម

២. វឌ្ឍនភាពប្រចាំឆ្នាំ២០២១

៣. ចំណាយលើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៤-២០២១

៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃប្រព័ន្ធ FMIS និងការវាយតម្លៃចំណាយសាធារណៈ

៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៦. សន្និដ្ឋាន

## ១. សេចក្តីផ្តើម – សាវតារ និងគោលបំណង

- សារាចរលេខ ០៩ សរ របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ ការតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។
- របាយការណ៍ត្រួតពិនិត្យនិងវាយតម្លៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១ គឺមានភាពគ្រប់ជ្រុងជ្រោយ តាមរយៈការបង្កើនការចូលរួមផ្តល់ជាធាតុចូលពីគ្រប់ភាគីដែលមានការពាក់ព័ន្ធរួមមាន អង្គភាពក្រោមឱវាទ កសហវ. រួមទាំងមន្ទីរ សហវ. រាជធានី-ខេត្ត, ក្រសួង-ស្ថាប័ន រដ្ឋបាលរាជធានី-ខេត្ត, និងដៃគូអភិវឌ្ឍន៍ ។
- របាយការណ៍នេះ នឹងក្លាយជាធាតុចូលដ៏មានសារៈសំខាន់សម្រាប់រៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៤ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។



## ១. សេចក្តីផ្តើម – វិធីសាស្ត្ររៀបចំរបាយការណ៍



# ២. វឌ្ឍនភាពប្រចាំឆ្នាំ២០២១

២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស.

២.២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម



## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពសម្រេចបាន

**ការសម្រេចរបស់ គ.ហ.ស. សរុប មានចំនួន ៣៥ វិធានការ ក្នុងនោះ សម្រេចបាន ៨ វិធានការ ។**

*១. ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន*

*២. អនុក្រឹត្យស្តីពីការបង្កើនចំនួនអង្គភាពថវិកា និងការប្រគល់សិទ្ធិអំណាចជាអាណាប័កផ្ទេរសិទ្ធិជូនអង្គភាពថវិកា*

*៣. ផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌ PFMRP ដំណាក់កាលទី៤*

*៤. សន្ធានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធបៀវត្សរបស់ក្រសួងមុខងារសាធារណៈ*

*៥. របាយការណ៍វាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ ថ្នាក់ជាតិ ឆ្នាំ២០២១*

*៦. ផែនការសកម្មភាពសម្រាប់ជំរុញការបង្កើតអង្គភាពថវិកា*

*៧. ការសិក្សាអំពីលទ្ធភាពបង្កើនអង្គភាពថវិកានៅរដ្ឋបាលរាជធានី-ខេត្ត និងរៀបចំជាផែនការសកម្មភាពជាក់លាក់*

*៨. ផែនការធ្វើបណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋ*

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

**១. សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី)** [GDB ; ត.ម៤ ឆ្នាំ២០២២ ដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិ]

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) គ្រោងបញ្ចប់កម្រិត កសហវ. និងបញ្ជូនទៅគណៈរដ្ឋមន្ត្រី នៅត្រីមាសទី៣ ឆ្នាំ២០២២ និងបញ្ជូនទៅអង្គនីតិប្បញ្ញត្តិ នៅត្រីមាសទី ៤ ឆ្នាំ២០២២ ។

**២. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ** [GDSPNR; ត.ម៤, ២០២២]

សេចក្តីព្រាងច្បាប់ បានដាក់ឆ្លងសិក្ខាសាលាពិគ្រោះយោបល់អន្តរក្រសួង-ស្ថាប័ន, ដៃគូអភិវឌ្ឍន៍, តំណាងសង្គមស៊ីវិល និងកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំ កសហវ. ។ ក្រុមការងារបានពិភាក្សាលើជំពូកទី១០ (ស្តីពីទោសប្បញ្ញត្តិ) ជាមួយក្រសួងយុត្តិធម៌ និងអង្គភាពប្រឆាំងអំពើពុករលួយ ចប់សព្វគ្រប់នាថ្ងៃទី ២៨ ខែមករា ២០២២ ។ ដំណាក់កាលបន្តនឹងដាក់ឆ្លងទៅគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២ ។

**៣. ក្របខណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ** [GSC & GDICDM; ត.ម៤, ២០២១]

ក្រុមការងារបច្ចេកទេសកំពុងបន្តរៀបចំសេចក្តីព្រាងក្របខណ្ឌគោលនយោបាយរួមស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២២-២០២៨ ។

**៤. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសហគ្រាសសាធារណៈ** [GDSPNR; ត.ម៤, ២០២២ បញ្ជូនទៅស្ថាប័ននីតិប្បញ្ញត្តិ]

សេចក្តីព្រាងច្បាប់ ត្រូវបានតាក់តែងជាទម្រង់ច្បាប់ និងខ្លឹមសាររួចរាល់កម្រិតក្រុមការងារបច្ចេកទេស កសហវ. ។ គ្រោងរៀបចំសិក្ខាសាលាពិគ្រោះយោបល់នាត្រីមាសទី១ ឆ្នាំ២០២២ និងគ្រោងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី នៅត្រីមាសទី៣ ឆ្នាំ២០២២ ។ ដោយសារត្រូវកសាងឯកសារយុទ្ធសាស្ត្រកែទម្រង់សហគ្រាសសាធារណៈជាមុនសិន សម្រាប់ជាធាតុចូលបន្ថែមទៅលើសេចក្តីព្រាងច្បាប់នេះ។



## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

**៥. ការកែសម្រួលអនុក្រឹត្យលេខ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥** [GDB; ត.ម១, ២០២២]

បានបញ្ចប់ការពិភាក្សាត្រឹមកម្រិតអគ្គនាយកដ្ឋានថវិកា និងបានបញ្ជូនទៅជំនាញការបារាំងដើម្បីផ្តល់ធាតុចូល និងត្រៀមពិភាក្សាអន្តរអគ្គនាយកដ្ឋាន និងដាក់បញ្ចូលជាមួយសេចក្តីព្រាងកែសម្រួលអនុក្រឹត្យលេខ ៨២ អនក្រ.បក នៅត្រីមាសទី៣ ឆ្នាំ២០២២ នេះ ។

**៦. ការកែសម្រួលអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥** [GDNT; ត.ម១, ២០២២]

សេចក្តីព្រាងអនុក្រឹត្យលេខ ៨២ ត្រូវបានរៀបចំ និងត្រូវធ្វើបច្ចុប្បន្នភាពជាបណ្តើរៗ ដោយផ្អែកលើគោលការណ៍សម្រេចនៃក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។

**៧. គោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល** [GSC; ត.ម២, ២០២១]

ក្រុមការងារបច្ចេកទេស បាននិងកំពុងពិនិត្យ និងកែសម្រួលសេចក្តីព្រាងលើកទី៦ មុនដាក់ឆ្លងសិក្ខាសាលាពិគ្រោះយោបល់ ។

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

ក្របខណ្ឌគតិយុត្ត

៨. សេចក្តីព្រាងប្រកាសស្តីពីគោលការណ៍ និងនីតិវិធីសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ក្នុងលក្ខខណ្ឌនៃការផ្ទេរមុខងារចំពោះចំណូលពីសេវាសាធារណៈ ចំណូលពីការផាកពិន័យនិងការដាក់ទណ្ឌកម្ម និងក្នុងលក្ខខណ្ឌនៃការចែករំលែកចំណូលពីសេវាធារណៈ និងចំណូលពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ពីរដ្ឋបាលថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ [GSC & GDSPNR; ត.ម.៤, ២០២១] ▲

បានបញ្ចប់សេចក្តីព្រាងប្រកាស និងដាក់ឆ្លងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង-ស្ថាប័ន ទាំងកម្រិតបច្ចេកទេស និងកម្រិតថ្នាក់ដឹកនាំនៅខែកុម្ភៈ ឆ្នាំ ២០២២ ។ សេចក្តីព្រាងប្រកាសនេះ គ្រោងគោរពជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ពិនិត្យ និងអនុម័ត នៅដើមត្រីមាសទី២ ឆ្នាំ២០២២ ។

៩. សារាចររបស់រាជរដ្ឋាភិបាលសម្រាប់ជំរុញក្រសួង-ស្ថាប័នជាពិសេសក្រសួង-ស្ថាប័នស្ថិតក្នុងវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ចឱ្យធ្វើការផ្សព្វផ្សាយ ឬរៀបចំវេទិកាសាធារណៈ អំពីថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នសាមីជូនសាធារណជន [GDB; ត.ម.៤, ២០២១] ▲

សេចក្តីណែនាំអំពីការរៀបចំវេទិកាសាធារណៈ និងសៀវភៅថវិកាពលរដ្ឋ ដើម្បីផ្សព្វផ្សាយអំពីកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួង នីមួយៗ ជូនដល់សាធារណជន និង ដៃគូរពាក់ព័ន្ធ ត្រូវបានសម្រេចដាក់ឱ្យអនុវត្ត ដោយជ្រើសរើសក្រសួងចំនួន ៤ រួមមាន÷ (១)-ក្រសួងអប់រំ យុវជន និងកីឡា (២)-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (៣)-ក្រសួងធនធានទឹក និងឧតុនិយម និង (៤)- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តតាមរយៈលិខិតលេខ ១៩៤៨ សហវ-អថ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០២២ ចាប់ពីឆ្នាំ ២០២២ ។



## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

យុទ្ធសាស្ត្រ

១០. សេចក្តីព្រាងយុទ្ធសាស្ត្រស្តីពីការអនុវត្តស្តង់ដាគណនេយ្យសាធារណៈមូលដ្ឋានបង្គរនៅកម្ពុជា ២០២១-២០៣១ [ACAR ; ត.ម២,២០២១] ▲

សេចក្តីព្រាងចុងក្រោយយុទ្ធសាស្ត្រទទួលបានការឯកភាពជាគោលការណ៍ក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលពីថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០២១ ។ អ.គ.ហ. សហការជាមួយនិយ័តករគណនេយ្យនិងសវនកម្ម បាននិងកំពុងកែសម្រួលបន្ថែមដើម្បីគោរពជូនប្រមុខរាជរដ្ឋាភិបាល អនុម័ត ។

១១. ឯកសារទស្សនាទានស្តីពីចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃការងារកែទម្រង់ ៣ បូក ១ [GSC, NCDD, PAR និង CLJR ; ត.ម៤,២០២១] ▲

សេចក្តីព្រាងឯកសារទស្សនាទាន ត្រូវបានរៀបចំ និងត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំកម្រិតអន្តរការដ្ឋានកែទម្រង់៣ បូក ១ ចំនួន ៣លើក និងគម្រោងវិបស្សនា ត្រូវបានរៀបចំ ។

១២. ចក្ខុវិស័យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ [GSMEF; ត.ម៤, ២០២១] ▲

សេចក្តីព្រាងចក្ខុវិស័យ ត្រូវបានរៀបចំរួចរាល់ និងបានដាក់ឆ្លងកម្រិតថ្នាក់ដឹកនាំ ។ គ្រោងប្រជុំឆ្លងជាមួយ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ នាថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ខាងមុខ។

១៣. ផែនការមេសម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរយៈពេលមធ្យម និងវែង [GDSPNR; ត.ម.៤, ២០២២] ●

ក្រុមការងារសិក្សានិងរៀបចំឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានបង្កើតនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១ ហើយបានរៀបចំមាតិកាគោល និងខ្លឹមសារព្រាងខ្លះៗនៃជំពូកនីមួយៗ។

១៤. ឯកសារគោល (Blueprint) ស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ [GDSPNR; ត.ម.៤, ២០២១] ▲

បានពិនិត្យឯកសារគោលដោយសម្រួលខ្លឹមសារពីភាសាអង់គ្លេស ទៅភាសាខ្មែរឱ្យត្រឹមត្រូវតាមពាក្យ និងទិដ្ឋភាពបច្ចេកទេស ដើម្បីដាក់ជូនក្រុមការងារកម្រិតអន្តរអគ្គនាយកដ្ឋាន.កសហវ. ពិនិត្យកែសម្រួលចុងក្រោយ ។ បានរៀបចំប្រជុំកែសម្រួលសេចក្តីព្រាងលើកទី៣ ដោយក្រុមការងារ.កសហវ. នាថ្ងៃទី២១ មីនា ២០២២។


10

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

ប្រព័ន្ធ បច្ចេកវិទ្យា ព័ត៌មាន

**១៥. សន្ធានកម្មរវាងប្រព័ន្ធ FMIS និង ប្រព័ន្ធ EFMS របស់ក្រសួងអប់រំ យុវជន និងកីឡា [MoEYS & FMWG ; ត.ម១, ២០២២]**

ក្រសួងអប់រំ យុវជន និងកីឡា កំពុងធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍបន្ថែមមុខងារការទិញ និងមុខងារត្រូវសង លើប្រព័ន្ធ EFMS ជំនាន់ទី ៣ ថ្មី ដែលគ្រោងនឹងបញ្ចប់ និងដាក់ឱ្យប្រើប្រាស់នៅខែមេសា ឆ្នាំ២០២២ ។ ជាមួយគ្នានេះ ក្រុមការងារ FMIS កំពុងផ្តល់កិច្ចសហការក្នុងការផ្តល់ធាតុចូល និងតម្រូវការនានាជូនក្រុមការងារ MoEYS ដើម្បីសិក្សាលម្អិតអំពីតម្រូវការព័ត៌មាននៅតាមដំណាក់កាលនៃការអភិវឌ្ឍប្រព័ន្ធ EFMS ទៅតាមមុខងារនីមួយៗក្នុងការធ្វើសន្ធានកម្មរវាងប្រព័ន្ធទាំង២ ។ ឆ្នាំ២០២២ នេះ នឹងគ្រោងធ្វើសន្ធានកម្មតែមួយមុខងារការទិញ និងឆ្នាំ២០២៣ មុខងារត្រូវសង ។



## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

យន្តការ

**១៦. ការពិនិត្យនិងសិក្សារៀបចំការបែងចែកមុខងាររបស់សវនកម្មផ្ទៃក្នុងនិងអធិការកិច្ចតាមក្រសួង-ស្ថាប័ន អនុលោមតាមអនុក្រឹត្យលេខ ១៦៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០ [GI&GDIA ; ត.ម៤, ២០២១]**

បានតាមដានការអនុវត្តអនុក្រឹត្យលេខ១៦៨ អនក្រ.បក នៅតាមបណ្តាក្រសួង-ស្ថាប័នចំនួន ១២ ។ ជាជំហានបន្ទាប់ អគ្គាធិការដ្ឋាននឹងរៀបចំក្របខ័ណ្ឌនិងវិធាននៃប្រព័ន្ធសវនកម្មផ្ទៃក្នុង និងអធិការកិច្ចក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូលក្រោមជំនួយបច្ចេកទេសពី AFD ។

**១៧. របាយការណ៍ PEFA ថ្នាក់ក្រោមជាតិ ឆ្នាំ២០២០ [GSC ; ត.ម២, ២០២១]**

បានបញ្ចប់ការកែសម្រួលសេចក្តីព្រាងទី១ ដោយបានពិនិត្យនិងកែសម្រួលតាមមតិយោបល់របស់ក្រុមការងារ PEFA, លេខាធិការដ្ឋាន PEFA និងដៃគូអភិវឌ្ឍន៍ ។ ជាការងារបន្ទាប់ អ.គ.ហ. នឹងរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងនេះនៅចុងត្រីមាសទី១ ឆ្នាំ២០២២ ។

**១៨. ក្របខណ្ឌរួម ផែនទីបង្ហាញផ្លូវ និងផែនការសកម្មភាពសម្រាប់ដោះស្រាយចំណាយកកស្ទះ [GSC; តម៤, ២០២១]**

ក្រុមជំនាញការ ស្ថិតនៅក្នុងដំណាក់កាលគ្រោងបញ្ចប់ការធ្វើសុពលភាពទៅលើរបាយការណ៍សិក្សាអំពីជំហានចំណាយនីមួយៗ ដើម្បីអាចពិភាក្សាបឋមទាក់ទងនឹងរបកគំហើញនាពេលខាងមុខ។

**១៩. កម្មវិធីសិក្សាភ្ជាប់វិញ្ញាបនបត្រ (Certificate Program) ដោយផ្សារភ្ជាប់មុខតំណែងឱ្យបានគ្រប់ជ្រុងជ្រោយ [EFI; ត.ម៤,២០២១]**

សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានពិគ្រោះយោបល់ និង រៀបចំកម្រិត វសហ ។ ទន្ទឹមនឹងនេះ កម្មវិធីសិក្សា Certificate Program កំពុងរៀបចំស្របតាមផែនការយុទ្ធសាស្ត្រកសាង និង អភិវឌ្ឍសមត្ថភាពដំណាក់កាល ៣ បូក ២ និង ដំណាក់កាលទី៤ និងអាចអនុវត្តបានក្នុងឆ្នាំ ២០២៣ ខាងមុខ ។

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

**២០. ការវាយតម្លៃលើបច្ច័យនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM Impact Assessment) [GSC; ត.មទ, ២០២១]▲**

សេចក្តីព្រាងរបាយការណ៍បឋមនៃការវាយតម្លៃនេះ កំពុងរៀបចំ និងបន្តកែសម្រួល ដើម្បីត្រៀមជួបប្រជុំជាមួយក្រុមការងារបច្ចេកទេស ។

**២១. ពិនិត្យ និងធ្វើបច្ចុប្បន្នភាពសមាសភាពគណៈកម្មាធិការ, គណៈកម្មការ និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ [GSC; ត.មទ, ២០២១] ▲**

បានរៀបចំសេចក្តីព្រាងសេចក្តីសម្រេច និង កំពុងពិនិត្យធ្វើបច្ចុប្បន្នភាពសមាសភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គ្រោងគោរពស្នើសុំ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ពិនិត្យ និងសម្រេចលើសមាសភាពនៅខែមេសា ឆ្នាំ២០២២ នេះ ។

**២២. ការបង្កើតក្រុមការងារអន្តរអគ្គនាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សិក្សា និងវាយតម្លៃអំពីមុខងាររបស់មន្ទីរ សហវ. និង លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ [GSMEF; តម១, ២០២២] ●**

បានបែងចែកក្រុមការងារដើម្បីសិក្សាទៅលើក្របខណ្ឌគតិយុត្តដែលមានស្រាប់ និងរៀបចំបំពេញបន្ថែមនូវចំណុចដែលចែងមិនច្បាស់លាស់ ដើម្បីរៀបចំជាសេចក្តីព្រាងគោលការណ៍ថ្មី ។ បច្ចុប្បន្ន អគ្គលេខាធិការដ្ឋាន កសហវ. បានរៀបចំជាសេចក្តីព្រាងគោលការណ៍ណែនាំ ។

**២៣. មូលនិធិ PFMRP គ្រប់ជ្រុងជ្រោយ [GSC; ត.មព,២០២១] ▲**

បានរៀបចំរបាយការណ៍សិក្សាលម្អិតអំពីការអនុវត្តមូលនិធិ PFMRP ដំណាក់កាលទី១ និងការឈានទៅអនុវត្ត ដំណាក់កាលទី២ និងបានទទួលការឯកភាពជាគោលការណ៍ពី ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ នៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២២ ។

13

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. – វឌ្ឍនភាពបន្តតាមដាន

**២៤. ការវាយតម្លៃការអនុវត្តក្របខណ្ឌថវិកាទូទាំងប្រទេស (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) [GSC; តម២, ២០២២] ●**

របាយការណ៍វាយតម្លៃបឋម ត្រូវបានដាក់ឆ្លងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃ កសហវ នៅថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២២ ។ របកគំហើញនៃរបាយការណ៍ នឹងត្រូវដាក់បញ្ចូលក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៤ ។

**២៥. ការវាយតម្លៃរដ្ឋបាលសារពើពន្ធដោយប្រើប្រាស់ក្របខណ្ឌ TADAT [GSC; តម៤, ២០២១] ▲**

ការវាយតម្លៃ TADAT ត្រូវបានបញ្ចប់ដោយជោគជ័យ បន្ទាប់ពីលទ្ធផលនិងខ្លឹមសាររបាយការណ៍នៃការវាយតម្លៃ ត្រូវបានធ្វើសុពលភាពដោយលេខាធិការដ្ឋាន TADAT និងគណៈកម្មការវាយតម្លៃ TADAT ។ អគហ បានគោរពរាយការណ៍ជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ។

**២៦. ការរៀបចំសៀវភៅថវិកាពលរដ្ឋ (Citizen Budget) និងវេទិកាផ្សព្វផ្សាយថវិកាកម្មវិធីជូនសាធារណជន របស់ក្រសួងអាទិភាពចំនួន ០៤ ដែលក្រសួងចំនួន ០២ ស្ថិតក្នុងវិស័យសេដ្ឋកិច្ច និងក្រសួងចំនួន ០២ ទៀតស្ថិតក្នុងវិស័យសង្គមកិច្ច [GDB & GSC, ២០២២] ●**

សេចក្តីណែនាំអំពីការរៀបចំវេទិកាសាធារណៈ និងសៀវភៅថវិកាពលរដ្ឋ ដើម្បីផ្សព្វផ្សាយអំពីកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួង នីមួយៗ ជូនដល់សាធារណជន និងដៃគូរពាក់ព័ន្ធ ត្រូវបានសម្រេចដាក់ឱ្យអនុវត្ត ដោយការជ្រើសរើសក្រសួងចំនួន ៤ រួមមាន÷(១)-ក្រសួងអប់រំ យុវជន និងកីឡា (២)-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (៣)-ក្រសួងធនធានទឹក និងឧតុនិយម និង (៤)- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្ត តាមរយៈលិខិតលេខ ១៩៤៨ សហវ-អថ ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០២២ ។

**២៧. ជំរុញក្រសួង-ស្ថាប័នអាទិភាពចំនួន ០៥-០៧ រៀបចំ FMM របស់ក្រសួង-ស្ថាប័នសាមី [GSC, ២០២២] ●**

កាលពីខែមករា ឆ្នាំ២០២២, អ.គ.ហ. បានរៀបចំកិច្ចប្រជុំជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីលើកកម្ពស់ការយល់ដឹង និងការចូលរួមរៀបចំ FMM ។ ក្នុងនោះ ក្រសួង-ស្ថាប័នចំនួន ១២ បានដាក់ផែនការសកម្មភាពរៀបចំ FMM តាមយន្តការ MAP និង GDAP សម្រាប់ឆ្នាំ២០២២។

14

## ២.១. វឌ្ឍនភាពនៃការអនុវត្តការសម្រេចរបស់ គ.ហ.ស. –វិធានការបន្ថែម

១. ការប្រើប្រាស់ធាតុចូលដែលទទួលបានពីរបាយការណ៍វាយតម្លៃការអនុវត្តប្រព័ន្ធ FMIS (សហការវាយតម្លៃដោយមូលនិធិរូបិយវត្ថុអន្តរជាតិ) និង ការវាយតម្លៃចំណាយសាធារណៈ (សហការវាយតម្លៃដោយធនាគារពិភពលោក) បញ្ចូលក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4)

២. ការកំណត់វិធានការគន្លឹះជំរុញល្បឿនការងារកែទម្រង់ (Reform Triggers) ឆ្នាំ២០២២-២០២៣

៣. ការពិនិត្យលើការផ្ទេរមុខងារចំនួន ៥៥ មុខងារ ទៅរដ្ឋបាលក្រុង ស្រុក និងថវិកាឱ្យស្របតាមមុខងារទាំង ៥៥

៤. ការរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីអាករពិសេស

៥. ការពិនិត្យលើការបើកប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារ នៅតាមក្រសួង-ស្ថាប័ន

៦. ការជំរុញការអនុវត្ត SARMIS ទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

៧. ការជំរុញការរៀបចំបណ្ណកម្មសិទ្ធិដីធ្លីរបស់រដ្ឋ និងផែនការមេសម្រាប់គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ រយៈពេលមធ្យម និងវែង ។



## ២.២. វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរួម

- *វឌ្ឍនភាពតាមផ្នែកទាំង ៥ នៃផែនការសកម្មភាពរួម*
- *វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ.*
- *វឌ្ឍនភាព (%) តាមមន្ទីរ សហវ. រាជធានី-ខេត្ត*
- *វឌ្ឍនភាព (%) តាមក្រសួង-ស្ថាប័ន*

## ផ្នែកទី១÷ បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា — សូចនាករសមិទ្ធកម្មគន្លឹះទាំង៦




**មិនមាន**

**១០៤,៤៩ %**

*(ទំហំ ២២ ១៥៥ ប៊ីលានរៀល)*

**៩៥,៣៦%** *(ធៀបច្បាប់ថវិកា)*

**៩៨,៧៩%** *(ធៀបឥណទានក្រោយវិចារណកម្ម)*

*(ទំហំអនុវត្តថវិកា ២៦ ១៥២ ប៊ីលានរៀល)*

- ❖ **ការប្រមូលចំណូលថវិកាថ្នាក់ជាតិ**
  - គយ និងរដ្ឋាករ÷ ៩៦,២៦%
  - ពន្ធដារ÷ ១១៥,១៤ %
  - ចំណូលមិនមែនសារពើពន្ធ ÷ ៧៨,៧៧%
- ❖ **ការប្រមូលចំណូលថវិការដ្ឋបាលថ្នាក់-ក្រោមជាតិ (រដ្ឋបាលរាជធានី-ខេត្ត)**
  - ចំណូលសារពើពន្ធ÷ ១៦៨,៣%
  - ចំណូលមិនមែនសារពើពន្ធ÷១០១,៣%

**១២២** *គណនី*

*បៀវត្ស* **៩៦,០៦%**

*ទំនិញ-សេវា* **៩៥,១៨%** *(ធៀបច្បាប់),* **១០៦,៦១%** *(ធៀបឥណទានក្រោយវិចារណកម្ម)*

**-២,៦៨** *ពិន្ទុភាគរយ នៃ ផ.ស.ស.*

*មូលធន* **៩២,២៤%**

*ផ្សេងៗ÷* **៩៩,៥៦%**
*បន្ទុកហិរញ្ញវត្ថុ ៨០,៧៩%, អត្ថប្រយោជន៍សង្គម ១៦៣,៨៨%, ឧបត្ថម្ភធន ៥៧,៥៨%, និង ពិន្ទុនិងអាករ ១៦៨,៨០%*

*ទំហំ ផ.ស.ស ឆ្នាំ២០២១= ១១៦ ៧១១ ប៊ីលានរៀល (ប្រភព÷ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសារណៈ) ។*
*ចំណូលចរន្តធៀបនឹង ផ.ស.ស. ÷ ឆ្នាំ២០២០ = ២១,៦២% នៃ ផ.ស.ស, ឆ្នាំ២០២១ = ១៨,៥៧% នៃ ផ.ស.ស ។*

17

*ប្រភព÷អគ្គនាយកដ្ឋានរតនាគារជាតិ* *ទិន្នន័យចំណូល-ចំណាយគិតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ (ទិន្នន័យបណ្ដោះអាសន្ន) ។*

## ផ្នែកទី១÷ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា — វឌ្ឍនភាព

**១** ៩០% ផែនការលទ្ធកម្មប្រចាំឆ្នាំត្រូវបានអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកា

- ចំនួនក្រសួង ស្ថាប័ន, ចំនួនសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងចំនួនអង្គភាពថវិកា លើសពី ៩០% បានផ្ញើផែនការលទ្ធកម្មប្រចាំឆ្នាំមក កសហវ. និងត្រូវបានអនុម័តទាន់ពេលវេលា ។

**២** យ៉ាងតិច ៦០% នៃអង្គភាពថវិកាផ្ដល់របាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ. (គិតក្នុងឆ្នាំ២០២០)

- អង្គភាពថវិកាបានផ្ញើរបាយការណ៍កិច្ចលទ្ធកម្មទាន់ពេលវេលា មក កសហវ. មានសរុបចំនួន ៣៩១ អង្គភាព ស្មើនឹង ៦១,១៨% ។

**៣** ការបន្តអនុវត្តជំហានទី១ នៃការបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈ

- នៅឆ្នាំ២០១៩ ជំហានទី១ ត្រូវបានដាក់ឱ្យអនុវត្តដោយបានបង្កើនកម្រិតទឹកប្រាក់សិទ្ធិសម្រេចកិច្ចលទ្ធកម្មសាធារណៈ របស់ស្ថាប័នអនុវត្តលទ្ធកម្ម ។

**៤** យ៉ាងតិច ៦០% នៃទំហំទឹកប្រាក់ប្រគល់កិច្ចសន្យាសរុប ប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែង (គិតក្នុងឆ្នាំ២០២០)

- ទំហំទឹកប្រាក់កិច្ចសន្យាសរុបប្រចាំឆ្នាំប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងលទ្ធកម្មមានចំនួន ៦០,៦២% ។

18

## ផ្នែកទី១៖ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា — សន្និដ្ឋាន

ភាពជឿទុកចិត្តនៃថវិកា គឺរក្សាបាននូវភាពរឹងមាំ ដែលឆ្លុះបញ្ចាំងអំពីភាពធននៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលបានកសាងកន្លងមក ។ ទោះបីជាយ៉ាងនេះក្តី ការធ្វើស្ថាបនីយកម្មយន្តការប្រមូល និងការគ្រប់គ្រងការចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ នៅមានលទ្ធភាពកែលម្អបន្ថែមទៀត ។ ចំពោះប្រសិទ្ធភាពចំណាយថវិកា ត្រូវពង្រឹងលើបៀវត្ស, ទំនិញ/សេវា និងវិនិយោគតាមរយៈការរៀបចំ និងអនុវត្តលិខិតបទដ្ឋានគតិយុត្ត ដូចមានកំណត់ក្នុងយុទ្ធសាស្ត្រគន្លឹះទាំង៤ (BSRS, SBSRS, PPSRS & PIMSRS) ។ ផ្អែកលើមូលដ្ឋានេះ, ថវិកាឆ្នាំ២០២១ បានបំពេញជាឧបករណ៍ដ៏មានប្រសិទ្ធភាពដែលអាចជួយឱ្យរាជរដ្ឋាភិបាលឆ្លើយតបទៅនឹងបញ្ហាប្រឈម និងហានិភ័យទាំងក្នុង និងក្រៅប្រទេស ដើម្បីប្រយុទ្ធការពារអាយុជីវិតប្រជាជន រក្សាលំនឹងសង្គមសេដ្ឋកិច្ច និងជីវភាពរបស់ប្រជាជន ព្រមជាមួយនឹងការតម្រង់ធនធានឆ្ពោះទៅស្តារ និងជំរុញកំណើនសេដ្ឋកិច្ចឡើងវិញ នៅក្រោយពេលមានភាពធូរស្បើយពីវិបត្តិជំងឺកូវីដ-១៩ តាមគន្លងប្រក្រតីថ្មី ដើម្បីធានាសុខសន្តិភាព ស្ថិរភាពសង្គម និងចីរភាពនៃកំណើនសេដ្ឋកិច្ច ព្រមទាំងភាពប្រកួតប្រជែងរបស់កម្ពុជា ជាមួយនឹងការបន្តលើកស្ទួយសុខុមាលភាពរបស់ប្រជាជន ។



## ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ — វឌ្ឍនភាព

| | |
|---|---|
| ១ នីតិវិធីធានាចំណាយ និងទូទាត់ចំណាយផ្សេងៗ កម្រិត ១ និងកម្រិត ២ ត្រូវបានដាក់ឱ្យអនុវត្តផ្លូវការនៅ កសហវ. និង ៧ ក្រសួង ផ្សេងទៀត | • នីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS លើការទូទាត់ចំណាយបៀវត្ស និងចំណាយទូទាត់ត្រង់ដែលមានហានិភ័យកម្រិត១ ត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការនៅក្រសួងស្ថាប័នចំនួន ២៧ ។ |
| ២ មុខងារថ្មីពីរ (មុខងាររៀបចំផែនការថវិកា និងមុខងារលទ្ធកម្មពេញលេញ) ត្រូវបានដាក់ឱ្យសាកល្បងនៅ កសហវ. និងក្រសួងព័ត៌មាន | • **<u>មុខងាររៀបចំផែនការថវិកា</u>** ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងនៅ កសហវ. និង ក្រសួងកិច្ចការនារី និង **<u>មុខងារលទ្ធកម្មពេញលេញ</u>** ត្រូវបានដាក់ឱ្យប្រើប្រាស់សាកល្បងនៅ កសហវ. ក្រសួងកិច្ចការនារី និង ក្រសួងព័ត៌មាន ។ |
| ៣ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មី ២ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS និងរដ្ឋបាលរាជធានី-ខេត្ត ទាំង ២៥ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS សម្រាប់ត្រៀមប្រើប្រាស់នៅឆ្នាំ២០២២ | • អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីចំនួន ២ ត្រូវបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ FMIS ជាផ្លូវការ ។ រដ្ឋបាលរាជធានី-ខេត្តចំនួន ២៥ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិបន្ថែមថ្មីចំនួន ១០ ត្រូវបានដាក់ដំឡើងប្រព័ន្ធ FMIS សម្រាប់ត្រៀមប្រើប្រាស់ជាផ្លូវការនៅដើមឆ្នាំ ២០២២ ។ |
| ៤ ការបិទបញ្ជីគណនេយ្យក្នុងរយៈពេល ពី ៦ ខែ ទៅ ៩ខែ | • ការបិទបញ្ជីគណនេយ្យត្រូវប្រើរយៈពេល ៩ ខែ ។ |

## ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ — វឌ្ឍនភាព (ត...)

| | |
|---|---|
| ៥ កម្រិតអនុលោមភាព នៃ របាយការណ៍ហិរញ្ញវត្ថុតាមស្តង់ដា IPSAS Cash Basis | • សមាសធាតុសំខាន់មួយចំនួនត្រូវបានកែលម្អដោយបានលាតត្រដាងកាន់តែលម្អិតនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុដោយបានដាក់បង្ហាញព័ត៌មានអំពីសាច់ប្រាក់កម្ចីដែលមិនទាន់ប្រើប្រាស់និងព័ត៌មានអំពីអង្គភាពថវិកាដែលរាយការណ៍ ។ |
| ៦ របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៩ ត្រូវបានរៀបចំរួចរាល់ក្នុងត្រីមាសទី ២ ឆ្នាំ២០២១ | • របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០១៩ ត្រូវបានរៀបចំរួចរាល់ក្នុងអំឡុងត្រីមាសទី ២ ឆ្នាំ២០២១ ។ |
| ៧ របាយការណ៍បូកសរុបទ្រព្យសម្បត្តិរដ្ឋ កម្រិតក្រសួង - ស្ថាប័ន, មន្ទីរអង្គភាពជំនាញថ្នាក់មូលដ្ឋាន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | • គិតត្រឹមថ្ងៃទី ២០ ខែមករា ២០២១ ការរៀបចំតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ (២០២០) ដោយទទួលបាន ៨៩% នៃអង្គភាពប្រើប្រាស់សរុប ៣ ០៣៦ អង្គភាព ។ |
| ៨ សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិតានដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់-គ្រងបំណុលសាធារណៈ | • សូចនាករបំណុលគន្លឹះទាំង ៥ ត្រូវបានបន្តរក្សាក្រោមពិតានដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ។ |



## ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ — វឌ្ឍនភាព (ត...)

| | |
|---|---|
| ៩ ការវិភាគហានិភ័យបំណុល និងហានិភ័យកាតព្វកិច្ចបំណុលជាយថាហេតុ ត្រូវបានរៀបចំដាក់បញ្ចូលនៅក្នុងរបាយការណ៍ដាក់ជូនគណៈកម្មាធិការគ្រប់គ្រងបំណុល | • បានរៀបចំរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងបំណុលសាធារណៈ មានខ្លឹមសារហានិភ័យបំណុលសាធារណៈ ប្រចាំត្រីមាសទី១, ត្រីមាសទី២, និងត្រីមាសទី៣ ឆ្នាំ២០២១ ព្រមទាំងផ្សព្វផ្សាយលើគេហទំព័រផ្លូវការ ។ |
| ១០ លក្ខណវិនិច្ឆ័យអប្បបរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងរបាយការណ៍សិក្សាអំពីវិធីសាស្ត្រវាយតម្លៃគ្រឹះស្ថានសាធារណៈ កម្រិត កសហវ. | • បានរៀបចំរបាយការណ៍សិក្សាលើការកំណត់លក្ខណៈវិនិច្ឆ័យអប្បរមានៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់គ្រឹះស្ថានសាធារណៈ ។ |
| ១១ សេចក្តីព្រាងច្បាប់ស្តីពីសហគ្រាសសាធារណៈ ត្រូវបានរៀបចំដាក់ឆ្លងថ្នាក់ដឹកនាំ កសហវ. | • សេចក្តីព្រាងច្បាប់ ត្រូវបានតាក់តែងជាទម្រង់ច្បាប់ និងខ្លឹមសាររួចរាល់កម្រិតក្រុមការងារបច្ចេកទេស កសហវ.។ គ្រោងរៀបចំសិក្ខាសាលាពិគ្រោះយោបល់នាត្រីមាសទី ១ និងគ្រោងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី នៅត្រីមាសទី៣ ឆ្នាំ២០២២ ។ |
| ១១ ចំនួនបណ្ណកម្មសិទ្ធិមិនទាន់បានចុះបញ្ជី (ដីធ្លី) សរុប ត្រូវបានរៀបចំដោយក្រុមការងារអន្តរក្រសួង និងផែនការសកម្មភាពត្រូវបានរៀបចំ | • ទីតាំងដែលពុំទាន់បានធ្វើបណ្ណកម្មសិទ្ធិមានចំនួន ១០ ៧៩៦ កន្លែង ស្មើនឹង ៣៨% នៃទីតាំងសរុប នឹងត្រូវបន្តជំរុញធ្វើបណ្ណកម្មសិទ្ធិឱ្យអស់ក្នុងឆ្នាំ២០២៣ ។ |

## ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ — សន្និដ្ឋាន

ប្រព័ន្ធ FMIS ជាប្រព័ន្ធស្នូលនៃគណនេយ្យភាពហិរញ្ញវត្ថុ ហើយត្រូវបានពង្រីក និងដាក់ឱ្យអនុវត្តគ្រប់ក្រសួង-ស្ថាប័ន ។ ទន្ទឹមនឹងវឌ្ឍនភាពនេះ គួរមានការគិតគូរអំពីវិសាលភាពនៃការប្រើប្រាស់មុខងារថ្មីចំនួន២ និងការសិក្សាឱ្យបានស៊ីជម្រៅបន្ថែមទៀតអំពីហានិភ័យនៃការដាក់ឱ្យអនុវត្តនីតិវិធីអនុវត្តការងារថ្មីតាមប្រព័ន្ធ FMIS (Business Process Streamlining) ។ ក្នុងន័យនេះ, ក្រុមការងារគ្រប់គ្រងគម្រោង FMIS គួរបន្តពិនិត្យ និងជំរុញការងារអាទិភាពនេះ ដើម្បីឱ្យការអនុវត្តស្របទៅនឹងទិសដៅប្រព័ន្ធថវិកា ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ ។



## ផ្នែកទី៣៖ ការពង្រឹងប្រសិទ្ធភាពនៃផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ — វឌ្ឍនភាព

| | |
|---|---|
| ១ ក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ | • សេចក្តីព្រាងឯកសារ MTFF ត្រូវបានពន្យារពេលក្នុងការអនុវត្ត ដោយជំនួសមកវិញក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣។ |
| ២ សេចក្តីព្រាងក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) កំណត់ពិតានថវិកាពហុឆ្នាំ ត្រូវបានដាក់ឱ្យអនុវត្ត | • ការរៀបចំឯកសារ MTBF ដោយមានពិតានតាមវិស័យ និងតាមក្រសួង-ស្ថាប័ន ត្រូវបានអនុម័តដោយប្រមុខរាជរដ្ឋាភិបាល ។ |
| ៣ សេចក្តីព្រាងបឋមនៃក្របខណ្ឌថវិការយៈពេលមធ្យម (MTBF) របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ | • សេចក្តីព្រាង MTBF របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំរួចរាល់ និងត្រៀមគោរពជូនឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់ ។ |
| ៤ ការរៀបចំយន្តការគ្រប់គ្រងវដ្តគម្រោងវិនិយោគសាធារណៈ | • គោលការណ៍ណែនាំចំនួន៣ ត្រូវបានអនុម័ត រួមមាន (១) គោលការណ៍ណែនាំលម្អិតស្តីពីវដ្តនៃគម្រោងវិនិយោគសាធារណៈ, (២) គោលការណ៍និងនីតិវិធីគ្រប់គ្រងយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់សិក្សាសមិទ្ធិលទ្ធភាព និងរៀបចំគម្រោង និង (៣) គោលការណ៍ណែនាំសម្រាប់ការរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល។ |
| ៥ ការញែកបន្ទុកបុគ្គលិកបានតាមកម្មវិធីនីមួយៗឆ្នាំ N+1 | • ឯកសារទស្សនាទានស្តីពីការញែកបន្ទុកបុគ្គលិក ត្រូវបានរៀបចំ ។ |

## ផ្នែកទី៣៖ ការពង្រឹងប្រសិទ្ធភាពនៃផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ — វឌ្ឍនភាព(ត...)

| | | |
|---|---|---|
| ៦ | គម្លាតរវាងផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ (N+1) | • ផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ២០២១ មានគម្លាត ៩,៨% ។ |
| ៧ | បន្ថែមចំនួន ៣ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិថែមទៀត និងបន្ថែម ១០ អង្គភាពថវិកា នៅតាមក្រសួង-ស្ថាប័ន | • នៅឆ្នាំ២០២១ អង្គភាពថវិកាមានចំនួនសរុប ៩២៦ ដែលក្នុងនោះរដ្ឋបាលកណ្តាលមានចំនួន ៣២៣ (កើនឡើង១២) និងថ្នាក់-មូលដ្ឋាន (មន្ទីរជំនាញរាជធានី ខេត្ត)ចំនួន ៦០៣ ។ សម្រាប់ថ្នាក់កណ្តាល អង្គភាពថវិកាចំនួន ៣២៣ ក្នុងនោះ អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិមានចំនួន ៨៣ (ឆ្នាំ២០២០ មានចំនួន ៦១) និងមិនទាន់ផ្ទេរសិទ្ធិ ២៤០ (ឆ្នាំ២០២០ មានចំនួន ២៥០) និងសម្រាប់ថ្នាក់មូលដ្ឋានគ្រប់អង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិចំនួន ៦០៣ (ឆ្នាំ២០២០ មានចំនួន ៦០៣)។ |
| ៨ | តម្រឹមផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់-ក្រោមជាតិ រវាងរាជធានី-ខេត្ត ជាមួយនឹងថវិកាមន្ទីរជំនាញ | • បានតម្រឹមផែនការយុទ្ធសាស្ត្រថវិការដ្ឋបាលថ្នាក់ក្រោមជាតិ រវាងរាជធានី ខេត្ត ជាមួយនឹងថវិកាមន្ទីរជំនាញ រាជធានី-ខេត្ត ។ ប៉ុន្តែគុណភាព និងភាពទាន់ពេល ចាំបាច់ត្រូវពង្រឹងបន្ថែម ។ |
| ៩ | ការធ្វើប្រតិភូកម្មសិទ្ធិអំណាចនៃការធ្វើនិយ័តថវិកាជូនរដ្ឋបាលថ្នាក់ក្រោមជាតិ | • រដ្ឋបាលរាជធានី ខេត្ត ទទួលបានឆន្ទានុសិទ្ធក្នុងការធ្វើនិយ័តថវិកាតាមរយៈប្រកាសស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។ |

25

## ផ្នែកទី៣៖ ការពង្រឹងប្រសិទ្ធភាពនៃផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ — សន្និដ្ឋាន

ក្របខណ្ឌថវិការយៈពេលមធ្យមត្រូវបានរៀបចំ និងអនុវត្តសាកល្បង និងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣ នឹងត្រូវរៀបចំសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២៣-២០២៥ និងថវិកាប្រចាំឆ្នាំ២០២៣ ។ កិច្ចការនេះ នឹងបង្កលក្ខណៈងាយស្រួលដល់ក្រសួង-ស្ថាប័នក្នុងការរៀបចំថវិកា ដោយមានកំណត់ថវិកាទាំងវិស័យ និងក្រសួង-ស្ថាប័ន ពិសេសការធ្វើសមាហរណកម្មថវិកាចរន្តនិងវិនិយោគ រួមទាំងពេលវេលាអនុលោមតាមប្រតិទិននៃការរៀបចំថវិកា ។ ដោយឡែក ក្រសួង-ស្ថាប័នមួយចំនួនក៏នៅរក្សាការគ្រប់គ្រងថវិកាតាមបែបប្រមូលផ្តុំនៅឡើយ ដោយអនុញ្ញាតឱ្យមានអង្គភាពថវិកាចំនួនតិចតួច ដែលមានន័យថា ថវិកាផ្តល់ដល់អង្គភាពអនុវត្តផ្ទាល់ ក៏មានតិចតួចផងដែរ ។ ក្នុងន័យនេះ ការបង្កើនចំនួនអង្គភាពថវិកា និងអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិជាការងារសំខាន់ ដែលចាំបាច់ត្រូវជំរុញ និងពង្រឹងសមត្ថភាពបន្ថែម ។

26

## ផ្នែកទី៤÷ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម — វឌ្ឍនភាព

| | |
|---|---|
| ១ សាកល្បងរៀបចំផែនការសមិទ្ធកម្មគន្លឹះប្រចាំឆ្នាំ ២០២១ | • ពុំមានវឌ្ឍនភាព ប៉ុន្តែបានរៀបចំទម្រង់កិច្ចព្រមព្រៀងលើលទ្ធផលក្នុងឆ្នាំរវាង កសហវ. និង ក្រសួង ស្ថាប័នសម្រាប់អនុវត្តឆ្នាំ២០២២ ។ |
| ២ សេចក្តីព្រាងអនុក្រឹត្យលេខ ៨១ និងសេចក្តីព្រាង អនុក្រឹត្យលេខ ៨២ ដាក់ជូនថ្នាក់ដឹកនាំពិនិត្យ | • **<u>សេចក្តីព្រាងអនុក្រឹត្យលេខ ៨១</u>** បានបញ្ចប់ការពិភាក្សាត្រឹមកម្រិតអគ្គនាយកដ្ឋាន និងបានបញ្ជូនទៅជំនាញការបារាំង ដើម្បីផ្តល់ធាតុចូល និងត្រៀមពិភាក្សាអន្តរអគ្គនាយកដ្ឋាន និងដាក់បញ្ចូលជាមួយសេចក្តីព្រាងកែសម្រួលអនុក្រឹត្យលេខ ៨២ អនក្រ.បក នៅត្រីមាសទី៣ ឆ្នាំ២០២២នេះ ។ **<u>សេចក្តីព្រាងអនុក្រឹត្យលេខ ៨២</u>** ត្រូវបានរៀបចំ និងត្រូវធ្វើបច្ចុប្បន្នភាពជាបណ្តើរៗ ដោយផ្អែកលើគោលការណ៍សម្រេចនៃក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ។ |
| ៣ ប្រកាសស្តីពីយន្តការតាមដាន និងត្រួតពិនិត្យការអនុវត្តថវិកា | • កសហវ. បានចេញប្រកាសលេខ ១១៣ សហវ.ប្រក ស្តីពីការដាក់ឱ្យប្រើប្រាស់គោលការណ៍ណែនាំស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម ។ |
| ៤ គ្រប់ក្រសួង-ស្ថាប័នមានយន្តការគ្រប់គ្រងការអនុវត្តថវិកាតាមក្របខណ្ឌគ្រប់គ្រងសមិទ្ធកម្ម និងមានយន្តការគ្រប់គ្រងសមិទ្ធកម្ម | • ពុំមានវឌ្ឍនភាព ។ |



## ផ្នែកទី៤÷ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម — វឌ្ឍនភាព (ត...)

| | |
|---|---|
| ៥ ការរៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ស្របតាមប្រព័ន្ធថវិកាសមិទ្ធកម្ម | • កសហវ. បានរៀបចំឯកសារប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង, បានកែសម្រួលបញ្ចប់សេចក្តីព្រាងអនុក្រឹត្យថ្មី ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង និងចេញប្រកាសស្តីពីគោលការណ៍ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងបច្ចេកវិទ្យាព័ត៌មាន ។ |
| ៦ សវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន ត្រូវបានអនុវត្ត នៅគ្រប់ក្រសួង-ស្ថាប័ន | • អនុវត្តសវនកម្មសមិទ្ធកម្មសាកល្បងជាករណីសិក្សាជូនក្រសួង ចំនួន ៦ និងអនុវត្តសវនកម្មបច្ចេកវិទ្យាព័ត៌មាន សាកល្បងជាករណីសិក្សាជូនក្រសួង ចំនួន ៤ ។ |
| ៧ របាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៥ ត្រូវបានរៀបចំដោយអាជ្ញាធរសវនកម្មជាតិ និងបញ្ជូនទៅអង្គនីតិបញ្ញត្តិ | • របាយការណ៍សវនកម្មសមិទ្ធកម្មចំនួន ៥ ត្រូវបានរៀបចំដោយអាជ្ញាធរសវនកម្មជាតិ និងបានបញ្ជូនទៅអង្គនីតិបញ្ញត្តិ ។ |
| ៧ ការលើកកម្ពស់តម្លាភាពថវិកា | • កសហវ. បានរៀបចំវេទិកាសាធារណៈ ស្តីពីក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខណ្ឌថវិកាប្រចាំឆ្នាំ និងផ្សព្វផ្សាយឯកសារថវិកាផ្សេងទៀត ។ |

## ផ្នែកទី៤÷ការបញ្ចប់ការត្រៀមខ្លួនឆ្ពោះទៅគណនេយ្យភាពសមិទ្ធកម្ម — សន្និដ្ឋាន

ជារួម ការឈានទៅអនុវត្តដំណាក់កាលទី៤ នឹងត្រូវត្រៀមខ្លួនរួចរាល់សម្រាប់ដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០២៣ តទៅ តាមរយៈការរៀបចំច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី), ការរៀបចំអនុក្រឹត្យលេខ ៨១ និង ៨២ (ថ្មី) ព្រមទាំងការរៀបចំក្របខណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម ដែលរំពឹងថាត្រូវបញ្ចប់ក្នុងឆ្នាំ ២០២២ ។ ទន្ទឹមនេះ, មុខងារសវនកម្មផ្ទៃក្នុង (ជាពិសេសការធ្វើសវនកម្មសមិទ្ធកម្ម) និងអធិការកិច្ច នៅគ្រប់ក្រសួង-ស្ថាប័នត្រូវពង្រឹងបន្ថែមជាបណ្ដើរៗ ដើម្បីធានាថាក្រសួង-ស្ថាប័នមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរឹងមាំ ស្របពេលរាជរដ្ឋាភិបាលបាននិងកំពុងធ្វើវិមជ្ឈការហិរញ្ញវត្ថុដល់ក្រសួង-ស្ថាប័ន ។

29

## ផ្នែកទី៥ ÷ការគាំទ្រកម្មវិធីកែទម្រង់ និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ — វឌ្ឍនភាព

| | |
|---|---|
| ១ របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ (GDAP/PDAP/MAP) ត្រូវបានផ្ដល់ជូន អ.គ.ហ. ស្របតាមសារាចរ ០៩ សរ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០១៥ (ត្រឹមដំណាច់ខែមករា នៃឆ្នាំបន្ទាប់) ។ | •ក្រសួង-ស្ថាប័ន មានចំនួន ៣៩/៤១ ស្មើនឹង ៩៥% ។<br>•អង្គភាពក្រោមឱវាទ កសហវ. មានចំនួន ១៧/១៧ ស្មើនឹង ១០០% ។<br>•មន្ទីរ សហវ. រាជធានី-ខេត្ត មានចំនួន ២៥/២៥ ស្មើនឹង ១០០% ។ |
| ២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពក្នុងក្របខណ្ឌ PFMRP ដំណាក់កាលទី ត្រូវបានអនុម័ត និង កម្មវិធីវិញ្ញាបនបត្រ (Certificate Program) ត្រូវបានរៀបចំ | •ផែនការយុទ្ធសាស្ត្រ ទទួលបានការអនុម័តពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** នៅថ្ងៃទី ០៤ ខែ តុលា ឆ្នាំ២០២១ ។ ឯកសារទស្សនាទានស្ដីពីគុណវុឌ្ឍិមន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និងទទួលបានការណែនាំពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** នៅថ្ងៃទី០៥ ខែមករា ឆ្នាំ ២០២២ ។ |
| ៣ លក្ខខណ្ឌយោងតួនាទីភារកិច្ចនៃសមាជិកក្រុមការងារកែទម្រង់ PFM អង្គភាពក្រោមឱវា កសហវ. និងគ្រប់ក្រសួង ស្ថាប័ន ត្រូវបានសម្រួចនិងតម្រឹមតាមគោលបំណង/សកម្មភាពគន្លឹះក្នុងម៉ាទ្រីសនៃផែនការ GDAP/MAP ឆ្នាំ ២០២១ | •អង្គភាពក្រោមឱវាទ កសហវ. និងក្រសួង-ស្ថាប័នបានធ្វើបច្ចុប្បន្នភាព និងកែលម្អជាប្រចាំនូវលក្ខខណ្ឌយោងការងារដោយតម្រឹមជាមួយគោលបំណង/សកម្មភាពគន្លឹះក្នុង GDAP/MAP តាមរយៈយន្តការនៃការផ្ដល់ប្រាក់ឧបត្ថម្ភក្រោម PFMRP ។ |
| ៤ ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព នៃកម្មវិធីកែទម្រង់ត្រូវបានរៀបចំ និងអនុវត្ត (ជំហានបឋមអនុវត្តផ្ទៃក្នុង អ.គ.ហ. ) | • ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាព នៃកម្មវិធីកែទម្រង់ជំហានទី ១ ត្រូវបានដាក់ឱ្យអនុវត្តសាកល្បងនៅផ្ទៃក្នុង អ.គ.ហ. ។ |

30

## ផ្នែកទី៥÷ការគាំទ្រកម្មវិធីកែទម្រង់ និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ — វឌ្ឍនភាព(ត...)

| | |
|---|---|
| ៥ ក្របខណ្ឌលើកទឹកចិត្តផ្សារភ្ជាប់សមិទ្ធកម្មត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២១ | • បច្ចុប្បន្ន ការលើកទឹកចិត្ត ត្រូវបានធ្វើឡើងតាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភលើកទឹកចិត្តក្រោម PFMRP ប៉ុន្តែពុំទាន់បានផ្សារភ្ជាប់ពេញលេញជាមួយសមិទ្ធកម្មនៅឡើយ ។ |
| ៦ កិច្ចប្រជុំកម្មវិធីកែទម្រង់ ៣ បូក ១ ត្រូវបានរៀបចំប្រចាំត្រីមាស និងយ៉ាងតិច ៩០% នៃផែនការសកម្មភាពត្រូវបានអនុវត្ត | • ពុំមានវឌ្ឍនភាព លើការរៀបចំកិច្ចប្រជុំ (ការរៀបចំជាលក្ខណៈវិលជុំ) ។<br>• សម្រាប់ផែនការសកម្មភាព ត្រូវបានអាក់ខានដោយត្រូវផ្តោតលើការរៀបចំឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១ ។ |
| ៧ ឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ ៣ បូក ១ | • សេចក្តីព្រាងឯកសារទស្សនាទានស្តីពីចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ បី បូក មួយ ត្រូវបានរៀបចំ និងត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំកម្រិតអន្តរការដ្ឋានកែទម្រង់៣ បូក ១ ចំនួន ៣លើក និងគម្រោងវីបស្សនា ត្រូវបានរៀបចំ ។ |
| ៨ គោលការណ៍ណែនាំស្តីពីការពិពណ៌នាមុខតំណែងត្រូវបានដាក់ឱ្យអនុវត្ត | • បានបញ្ចប់ការរៀបចំសេចក្តីព្រាងលើកទី២ នៃឯកសារណែនាំស្តីពីការរៀបចំការពិព័ណ៌នាមុខ-តំណែង និងបានបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការដាក់ឱ្យអនុវត្តឯកសារណែនាំស្តីពីការរៀបចំការពិព័ណ៌នាមុខតំណែង ក្នុងកម្រិតអគ្គនាយកដ្ឋាន ។ |



## ផ្នែកទី៥÷ការគាំទ្រកម្មវិធីកែទម្រង់ និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ — សន្និដ្ឋាន

ការអនុវត្តផ្នែកទី៥នេះ រងផលប៉ះពាល់តិចតួចចំពោះការរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងសិក្ខាសាលាផ្សព្វផ្សាយ ដោយសារក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២១, តួអង្គដែលមានការពាក់ព័ន្ធបានផ្លាស់ប្តូរវិធីសាស្ត្រនៃការបណ្តុះបណ្តាល ឬសិក្ខាសាលាតាមរយៈប្រព័ន្ធអនឡាញ ។ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមអង្គភាពក្រោមឱវាទ កសហវ. រួមទាំងមន្ទីរនិងក្រសួង-ស្ថាប័ន បានខិតខំអនុវត្តតាមផែនការ និងបានផ្ញើរបាយការណ៍សមិទ្ធកម្មមក អ.គ.ហ. ទាន់ពេលវេលា បើទោះជាមានភាពយឺតយ៉ាវសម្រាប់ក្រសួង-ស្ថាប័នមួយចំនួនក្តី ។ ដើម្បីជំរុញចលនការ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គប្បីអនុវត្តវិធានការបន្ថែមរួមមាន ការបន្តពង្រឹងយន្តការអនុវត្ត និងបុរេសកម្មក្នុងការបំពេញតួនាទីភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ ដែលបានកំណត់ក្នុងលក្ខខណ្ឌយោងការងារ និងបន្តពង្រឹងយន្តការសម្របសម្រួល តាមដាន និងរាយការណ៍ការអនុវត្តផែនការសកម្មភាព ដូចមានកំណត់ក្នុង GDAP, C/PDAP, &MAP ។

## ➢ វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ. ប្រចាំត្រីមាសទី៤ ឆ្នាំ២០២១






## ➢ វឌ្ឍនភាព (%) តាមអង្គភាពក្រោមឱវាទ កសហវ. ប្រចាំឆ្នាំ២០២១



## ➤ សមិទ្ធកម្មសរុបតាមមន្ទីរ សហវ. រាជធានី ខេត្ត

វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់មន្ទីរ សហវ. រាជធានី-ខេត្ត ប្រចាំឆ្នាំ២០២១




| | ១១.២.១.សៀវភៅបន្ទុក | ១១.២.២.ការអនុវត្តប្រកាសស្ដីពីការផ្ដល់សេវាសាធារណៈនៅមន្ទីរ-អង្គភាពជំនាញ | ២៣.១.១.បណ្ណកម្មសិទ្ធិអចលនទ្រព្យ ក្រោម កសហវ. នៅថ្នាក់មូលដ្ឋាន | ២៣.១.២.បណ្ណកម្មសិទ្ធិអចលនទ្រព្យនៃមន្ទីរ-អង្គភាពជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ | ២៣.១.៣.តារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ២០២០របស់មន្ទីរ-អង្គភាពជំនាញ | ២៣.១.៤.តារាងប្រៀបធៀបការកើនឡើង/ថយចុះនៃទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ |
|---|---|---|---|---|---|---|
| គោលដៅប្រចាំឆ្នាំ | 451 | 345 | 16 | 153 | 813 | 1253 |
| វឌ្ឍនភាពប្រចាំឆ្នាំ | 449 | 316 | 9 | 134 | 803 | 1121 |
| % ធៀបប្រចាំឆ្នាំ | 100% | 92% | 56% | 88% | 99% | 89% |



## ➤ វឌ្ឍនភាព (%) តាមមន្ទីរ សហវ. រាជធានី ខេត្ត ប្រចាំត្រីមាសទី ៤ ឆ្នាំ២០២១

វឌ្ឍនភាពជាភាគរយ (%) ប្រចាំត្រីមាសទី ៤ របស់មន្ទីរ សហវ. រាជធានី-ខេត្ត



## ➢ វឌ្ឍនភាព (%) តាមមន្ទីរ សហវ. រាជធានី ខេត្ត ប្រចាំឆ្នាំ២០២១




37

## ➢ វឌ្ឍនភាព (%) តាមក្រសួង-ស្ថាប័ន ប្រចាំត្រីមាសទី ៤ ឆ្នាំ២០២១




38

## ➢ វឌ្ឍនភាព (%) តាមក្រសួង-ស្ថាប័ន ប្រចាំឆ្នាំ២០២១

ការអនុវត្តថវិកា និងវឌ្ឍនភាពជាភាគរយ (%) ប្រចាំឆ្នាំ២០២១ របស់ក្រសួង-ស្ថាប័ន






## ៣.ចំណាយលើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៤-២០២១

ចំណាយលើការអនុវត្ត PFMRP ឆ្នាំ២០០៤-២០២១




*សម្គាល់÷ ចំណាយរបស់ក្រុមការងារ FMIS, អង្គភាពក្រោមឱវាទ កសហវ, ក្រសួង-ស្ថាប័ន និងមន្ទីរ សហវ, បូកបញ្ចូលចំណាយលើទិនិញ, ទីប្រឹក្សា, បណ្តុះបណ្តាល/សិក្ខាសាលា, និងប្រតិបត្តិការ ។*
*ប្រភពហិរញ្ញប្បទាន÷ រដ្ឋាភិបាល, CF, PHRD Grant, IDA&MDTF (ធនាគារពិភពលោក), UNICEF, សហភាពអឺរ៉ុប, និងធនាគារអភិវឌ្ឍន៍អាស៊ី*

## ៣.ចំណាយលើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០០៤-២០២១




*ប្រភពហិរញ្ញប្បទាន÷ រដ្ឋាភិបាល, CF, PHRD Grant, IDA&MDTF (ធនាគារពិភពលោក), UNICEF, សហភាពអឺរ៉ុប, និងធនាគារអភិវឌ្ឍន៍អាស៊ី.*

41

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS

❖ ការពង្រីកការប្រើប្រាស់ប្រព័ន្ធ FMIS

**ជំហានទី១** (២០១៣-២០១៦)
- ៨ អគ្គនាយកដ្ឋានគន្លឹះ នៃ កសហវ.
- ២៥ រតនាគាររាជធានី-ខេត្ត

**៣៣ ការដ្ឋាន និងអ្នកប្រើប្រាស់ ចំនួន ៥០០ នាក់*

**ជំហានទី២** (២០១៧-២០២០)
- ៣៧ ក្រសួង-ស្ថាប័ន
- ២៥ មន្ទីរ សហវ. រាជធានី-ខេត្ត
- ២៥ អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិ

**៨៧ ការដ្ឋាន និងអ្នកប្រើប្រាស់ ចំនួន ១ ១៦២ នាក់*

**ជំហានទី៣** (២០២១-២០២៥)
- ២៥ រដ្ឋបាលរាជធានី-ខេត្ត (២០២២)
- គ្រឹះស្ថានសាធារណៈរដ្ឋបាល ១៥ (២០២៣)
- គ្រឹះស្ថានសាធារណៈរដ្ឋបាលសេសសល់ (២០២៤)
- មុខងារថ្មីៗ នៅគ្រប់ការដ្ឋានជំហានមុនៗ
- រដ្ឋបាលក្រុង ខណ្ឌ និង ស្រុក ចំនួន ៤៣ (២០២៤)
- មន្ទីរជំនាញនៅរាជធានី-ខេត្តរបស់ក្រសួងចំនួន ២ (២០២៥)

** គ្រោង ១៤៨ ការដ្ឋាន និងអ្នកប្រើប្រាស់ចំនួន ១ ៩០០ នាក់*

(មិនរាប់បញ្ចូលការដ្ឋាន FMIS Portal V1)

*កំណត់សម្គាល់÷ ព័ត៌មានអំពីការពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ទទួលបាការធ្វើបច្ចុប្បន្នភាពបន្ថែមពីលេខាធិការដ្ឋាន FMWG ។*

42

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS (ត...)

- ការផ្តួចផ្តើមឱ្យមានការប្រើប្រាស់ហត្ថលេខាអេឡិចត្រូនិក ។
- ការពង្រឹងតួនាទីសវនកម្ម ដែលដើរតួសំខាន់ក្នុងការវាយតម្លៃមុខងារ និងដំណើរការប្រព័ន្ធ ។




- ក្នុងជំហានទី៣, ប្រព័ន្ធ FMIS នឹងត្រូវពង្រីកការដ្ឋានបន្ថែមរហូតដល់ ១៤៨ និងបន្ថែមអ្នកប្រើប្រាស់ចំនួន១ ៩០០ នាក់, ដូចនេះការតេស្តមាត្រដ្ឋានប្រព័ន្ធ គឺជាការចាំបាច់ ។ ការរៀបចំមុខងារប្រព័ន្ធ (Module architecture) និងកិច្ចលទ្ធកម្ម Sever អាចពិនិត្យ ឱ្យស្របតាមការពង្រីកប្រព័ន្ធ ។

- ការធ្វើសន្ទានកម្មរវាងប្រព័ន្ធ DMFAS និង ប្រព័ន្ធ FMIS នៅមិនទាន់ពេញលេញ ។
- មិនទាន់ធ្វើសន្ទានកម្មរវាងប្រព័ន្ធ FMIS និង ប្រព័ន្ធ EFMS
- ការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធផ្សេងទៀត ជាអាទិ៍ PIP-BDMS របស់ GDP និង PPMS របស់ GDICDM ។
- ការពង្រឹងការធ្វើសន្ទានកម្មជាមួយធនាគារជាតិ និងធនាគារពាណិជ្ជផ្សេងទៀត ដើម្បីពង្រឹងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក និងការផ្ទៀងផ្ទាត់របាយការណ៍ដោយស្វ័យប្រវត្តិ (Automatic reconciliation)

43

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS (ត...)

- មុខងារសម្រាប់អនុវត្តថវិកាក្នុងប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់ ប៉ុន្តែនៅមានការប្រើប្រាស់ដោយដៃ នៅឡើយ ។
- ដោយសារភាពមានកម្រិតនៃប្លង់គណនេយ្យ (CoA), ការវិភាជលម្អិតថវិកា (budget sub-allocation) តម្រូវឱ្យក្រសួង- ស្ថាប័នបង្កើតប្រព័ន្ធដើម្បីបំពេញបន្ថែម ។




- មុខងារលទ្ធកម្មពុំមានវិសាលភាពដល់លទ្ធកម្មចំណាយវិនិយោគ គឺត្រឹមចំណាយចរន្ត ។

- ក្រសួង- ស្ថាប័ន ពុំអាចប្រើប្រាស់ប្រព័ន្ធសម្រាប់គ្រប់គ្រងថវិកាផ្ទៃក្នុង និងតាមដានអង្គភាពអនុវត្តថវិកានៅកម្រិតទាប (lover-level budget entities) ដោយសារភាពមានកម្រិតនៃប្លង់គណនេយ្យ (COA)។
- ចំណាយហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ពុំទាន់បានកត់ត្រាចូលប្រព័ន្ធ FMIS ។

- មុខងាររៀបចំផែនការថវិកា នឹងត្រូវប្រើប្រាស់សម្រាប់បញ្ចូលសំណើថវិកា (Budget Request Collation) ដោយពុំទាន់ប្រើប្រាស់សម្រាប់រៀបចំថវិកា, ការស្នើ និងការចរចាដែលកិច្ចការទាំងនេះ នៅតែដំណើរការដោយដៃនៅឡើយ ។

44

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS (ត...)

❖ **ការរៀបចំអភិបាលកិច្ច និងការគ្រប់គ្រងការផ្លាស់ប្តូរ**

- គម្រោង FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់ស្របតាមផែនការដែលបានកំណត់ ប៉ុន្តែពុំមានការពិគ្រោះយោបល់ជាផ្លូវការ ឬជាទៀងទាត់អំពីវឌ្ឍនភាព និង បញ្ហាប្រឈមគន្លឹះៗ ។
- ការដឹកនាំក្នុងកិច្ចប្រតិបត្តិការ (Operational leadership) និងការចូលរួម របស់អង្គភាពជំនាញ នៅក្នុង FMWG អាចពង្រឹងបន្ថែម ។




- ពង្រឹងការរៀបចំផែនការ និងការតាមដាន គម្រោង FMIS ។
- ពង្រឹងការតាមដានអនុសាសន៍នៃរបាយ-ការណ៍ទីប្រឹក្សា (Advisory Report), និង របាយការណ៍សវនកម្មលើប្រព័ន្ធ FMIS ។

- ការយល់ដឹងអំពីតម្រូវការនៃការតម្រង់ទិសនីតិវិធីអនុវត្តការងារ តាមប្រព័ន្ធ FMIS (Business Process) នៅមានកម្រិត ។ ដំណើរការ (Process) ត្រូវបានរៀបចំឡើងវិញបន្ទាប់ពីដាក់ឱ្យ ប្រើប្រាស់មុខងារនៃប្រព័ន្ធ FMIS ។
- គួរបង្កើតជាវេទិកាពិភាក្សាលើការប្រើប្រាស់ប្រព័ន្ធ FMIS ជាប្រចាំ ដោយមានការចូលរួមពីអ្នកប្រើប្រាស់ ។

45

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធ FMIS (ត...)

ជារួម ផែនការពង្រីកប្រព័ន្ធ FMIS ជំហានទី១ និងជំហានទី២ ទទួលបានជោគជ័យ ។ មុខងារនៃប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យប្រើប្រាស់ ប៉ុន្តែពុំទាន់ត្រូវបានអនុវត្តពេញលេញនៅឡើយ ជាពិសេសការទាញអត្ថប្រយោជន៍ជាអតិបរមាពីប្រព័ន្ធ FMIS ។ ក្នុងន័យនេះ គួរផ្តោតលើការពង្រឹងការអនុវត្តឱ្យបានពេញលេញនូវមុខងារនៃប្រព័ន្ធ FMIS, ការតម្រង់ទិសនីតិវិធីអនុវត្តការងារ, ការផលិតរបាយការណ៍, ការធ្វើសន្ទានកម្មជាមួយប្រព័ន្ធផ្សេងៗ, និងការពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងការផ្លាស់ប្តូរ, មុននឹងពង្រីកការដ្ឋានប្រព័ន្ធ FMIS បន្ថែមទៀត ។

46

## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃចំណាយសាធារណៈ

❖ ***ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ***

- តម្រឹមរចនាសម្ព័ន្ធកម្មវិធី
- ធ្វើសមាហរណកម្មចំណាយវិនិយោគក្នុងស្រុក និងប្រភពខាងក្រៅ ទៅក្នុង BSP
- តម្រឹម BSP ជាមួយ MTFF

- ធ្វើបច្ចុប្បន្នភាពតួនាទី និងភារកិច្ចសវនកម្មផ្ទៃក្នុង
- បង្កើត រៀបចំផែនទីបង្ហាញផ្លូវ និងអនុវត្តក្របខណ្ឌត្រួតពិនិត្យផ្ទៃក្នុង
- ផ្សព្វផ្សាយរបាយការណ៍សវនកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ពង្រឹងតួនាទីក្រសួង- ស្ថាប័នក្នុងការធ្វើការសិក្សាសមិទ្ធិលទ្ធភាព ។
- ពង្រឹងការសម្របសម្រួលឱ្យទូលាយក្នុងវិស័យ ពាក់ព័ន្ធនឹងគម្រោងវិនិយោគហិរញ្ញប្បទានពីប្រភពខាងក្រៅ ។




- មិនប្តូរបញ្ចូលធាតុចូលជាម៉ាទ្រីស (ឧ. សិក្ខាសាលា)
- ផ្តោតលើលទ្ធផលក្នុងឆ្នាំ និងលទ្ធផលចុងក្រោយ
- កាត់បន្ថយសូចនាករ មកនៅត្រឹម ៥ ទៅ ១០ ដែលជាសូនាករគន្លឹះ
- ធ្វើសមាហរណកម្មម៉ាទ្រីសសមិទ្ធកម្មទៅក្នុងសំណើថវិកា
- សមិទ្ធកម្ម (តាមរយៈ BSP) គួរត្រូវបានផ្តោតក្នុងការចរចាថវិកា
- រៀបចំម៉ាទ្រីសសមិទ្ធកម្ម ភ្ជាប់ជាមួយនឹងការកសាងសមត្ថភាព ។

- គិតគូរលើការផ្តល់ឆន្ទានុសិទ្ធិក្នុងការធ្វើនិយ័តថវិការវាងសមាសធាតុចំណាយមួយចំនួន
- ពង្រឹងការធានាចំណាយ និងផែនការសម្រាប់កិច្ចលទ្ធកម្មឱ្យទាន់ពេលវេលា



## ៤. យោបល់ដៃគូអភិវឌ្ឍន៍ – លទ្ធផលបឋមនៃការវាយតម្លៃចំណាយសាធារណៈ

❖ ***រដ្ឋបាលខេត្តព្រះសីហនុ***

- ការពន្យារពេលក្នុងការរៀបចំឯកសារគម្រោង ដោយសារពុំមានមន្ត្រីបច្ចេកទេសគ្រប់គ្រាន់ ។
- តម្លាភាព និងបញ្ហាប្រឈម ក្នុងដំណើការកិច្ចលទ្ធកម្ម ។

- ការផ្ទេរមុខងារចំនួន ៥៥ មុខងារ ទៅរដ្ឋបាលក្រុង ស្រុក ។ ប៉ុន្តែ រដ្ឋបាលក្រុង ស្រុក ទទួលបានថវិកាតិច និងមិនមានការផ្ទេរថវិកាទៅតាមមុខងារទាំង ៥៥ ។




- សមត្ថភាព និងបញ្ហាប្រឈមនៃការរៀបចំ BSP និង ថវិកាប្រចាំឆ្នាំ ។
- គម្លាតខ្ពស់រវាងការអនុវត្តថវិកា និងផែនការ (ការព្យាករចំណូលទាបធៀបនឹងការអនុវត្ត និង សំណើបន្ថែមឥណទានថវិកាមានកម្រិតខ្ពស់) ។
- សំណើសម្រាប់ការបន្ថែមឥណទានថវិកាមានភាពយឺតយ៉ាវ ។
- ដំណើការធានាចំណាយ និងកិច្ចលទ្ធកម្មត្រូវការពេលវេលាយូរ ។
- ដំណើរការរៀបចំការទទួលទំនិញ និងការទូទាត់ត្រូវការរយៈពេលយូរ ។

## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

- ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រើប្រាស់ក្របខណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ដែលធ្លាប់បានប្រើប្រាស់សម្រាប់ការវាយតម្លៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈចំនួនបីលើករួចមកហើយគឺនៅឆ្នាំ២០១០, ២០១៥ និងឆ្នាំ២០២១ ។
- បច្ច័យលើប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនេះ គឺធ្វើការប្រៀបធៀបលើលទ្ធផលទាំងបីលើក និងទាញការសន្និដ្ឋានលើលទ្ធផលវាយតម្លៃជាកម្រិតម៉ាក្រូ ក្នុងនោះរួមមាន÷ (១) វិន័យថវិកា, (២) ប្រសិទ្ធភាពវិភាជន៍ថវិកា និង (៣) ស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ។
- របកគំហើញពីការវាយតម្លៃ PEFA ឆ្នាំ២០២១ ដែលប្រើប្រាស់ក្របខណ្ឌ PEFA ឆ្នាំ២០១១ បង្ហាញថាមានការកែលម្អក្នុងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងពិន្ទុនៃសូចនាករសមិទ្ធកម្ម (PIs) ចំនួន ១០ ក្នុងនោះរួមមាន÷ PI-2, PI-6, PI-7, PI-10, PI-13, PI-14, PI19, PI-21, PI-23 និង PI-25 រីឯ PI-3 ទទួលបានពិន្ទុទាបដោយសារមានគម្លាតខ្ពស់រវាងផែនការនិងលទ្ធផលប្រមូលចំណូលចាប់ពីឆ្នាំ២០១៧, ២០១៨ និង២០១៩ ។ អ.គ.ហ.បាននិងកំពុងរៀបចំក្របខណ្ឌវាយតម្លៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន (កំពុងស្ថិតសេចក្តីព្រាង) និងសាកល្បងវាយតម្លៃឆ្នាំ២០២២នេះ ។

49

## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

**បំរែបំរួលពិន្ទុ PEFA ឆ្នាំ២០១០, ២០១៥, ២០២១**




50

## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០២១ | បម្រែបម្រួល |
|---|---|---|---|---|---|
| ១ | លទ្ធផលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ÷ ភាពជឿទុកចិត្តនៃថវិកា | | | | |
| PI-1 | ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | B | A | A | មិនមាន |
| PI-2 | សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | D | D+ | B+ | ↑ |
| PI-3 | ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | A | A | D | ↓ |
| PI-4 | សន្និធិបំណុលកកស្ទះ និងការត្រួតពិនិត្យតាមដានចំណាយកកស្ទះ | C+ | D+ | D+ | មិនមាន |
| ២ | ការងារត្រួតស៊ីគ្នាសំខាន់ៗ ÷ ភាពគ្រប់ជ្រុងជ្រោយ និងតម្លាភាពនៃថវិកា | | | | |
| PI-5 | ចំណាត់ថ្នាក់ថវិកា | C | C | C | មិនមាន |
| PI-6 | ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | B | C | B | ↑ |
| PI-7 | ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ | C | C | B | ↑ |
| PI-8 | តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល(ថ្នាក់ជាតិនិងក្រោមជាតិ) | C+ | B | B | មិនមាន |
| PI-9 | ការត្រួតពិនិត្យហានិភ័យថវិកា ពីអង្គភាពសាធារណៈដទៃទៀត ក្រៅពីក្រសួង-ស្ថាប័នរដ្ឋ | C+ | C+ | C+ | មិនមាន |
| PI-10 | លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ | C | D | C | ↑ |

51

## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០២១ | បម្រែបម្រួល |
|---|---|---|---|---|---|
| ៣ | វដ្តថវិកា | | | | |
| ៣.១ | ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | | | | |
| PI-11 | កាលានុក្រម និងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ | A | A | A | មិនមាន |
| PI-12 | ទស្សនៈវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកាគោលនយោបាយចំណាយ និងការរៀបចំថវិកា | B | C+ | C+ | មិនមាន |
| ៣.២ | ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា | | | | |
| PI-13 | តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និងបំណុលពន្ធរបស់អ្នកជាប់ពន្ធ | B | C+ | B | ↑ |
| PI-14 | ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធនិងការវាយតម្លៃពន្ធ | C | D+ | C+ | ↑ |
| PI-15 | ប្រសិទ្ធភាពនៃការប្រមូលពន្ធ | D+ | D+ | NA | មិនអាចប្រៀបធៀប |
| PI-16 | ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ | C+ | C+ | C+ | មិនមាន |
| PI-17 | ការកត់ត្រា និងការគ្រប់គ្រងសមតុល្យសាច់ប្រាក់, បំណុល និងការធានា | C+ | C+ | C+ | មិនមាន |
| PI-18 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស | D+ | D+ | D+ | មិនមាន |
| PI-19 | តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម | NA | D | C+ | ↑ |
| PI-20 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស | C | C | C | មិនមាន |
| PI-21 | ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង | D+ | C | C+ | ↑ |

52

## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

| ល.រ | សូចនាករ | ពិន្ទុ ឆ្នាំ២០១០ | ពិន្ទុ ឆ្នាំ២០១៥ | ពិន្ទុ ឆ្នាំ២០២១ | បម្រែបម្រួល |
|---|---|---|---|---|---|
| ៣ | វដ្តថវិកា (ត...) | | | | |
| ៣.៣ | **គណនេយ្យ, ការកត់ត្រា និងរបាយការណ៍** | | | | |
| PI-22 | ភាពទាន់ពេល និងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី | C | C | C | មិនមាន |
| PI-23 | អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា | C | D | B | ↑ |
| PI-24 | គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ | C+ | C+ | C+ | មិនមាន |
| PI-25 | គុណភាព និងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | D+ | D+ | C+ | ↑ |
| ៣.៤ | **ការត្រួតពិនិត្យ និងសវនកម្មខាងក្រៅ** | | | | |
| PI-26 | វិសាលភាព ចរិតលក្ខណៈ និងការតាមដានបន្តនៃសវនកម្មពីខាងក្រៅ | D+ | NR | NA | មិនអាចប្រៀបធៀប |
| PI-27 | ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិបញ្ញត្តិ | NU | C+ | C+ | មិនមាន |
| PI-28 | ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មពីខាងក្រៅ ដោយអង្គនីតិបញ្ញត្តិ | NU | B | B | មិនមាន |
| ៤ | **ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍** | | | ពុំវាយតម្លៃ | |



## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

- ***វិន័យថវិកា៖*** ផ្នែកការអនុវត្តចំណាយថវិកាបង្ហាញថាមានភាពកាន់តែមានល្អប្រសើរ ប៉ុន្តែចាំបាច់ត្រូវដោះស្រាយលើចំណាយកកស្ទះ (ទាំងផ្នែកនិយមន័យ និងបំណុលចាស់) និងការអនុវត្តចំណូលថវិកាត្រូវបន្តពង្រឹងការព្យាករចំណូល, ពង្រឹងរដ្ឋបាលប្រមូលចំណូលជាពិសេសអនុលោមភាព និងការគ្រប់គ្រងហានិភ័យ, ការតាមដានលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅតាមគ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ។
- ***ប្រសិទ្ធភាពវិភាជន៍ថវិកា៖*** ថវិកាប្រចាំឆ្នាំត្រូវបានរៀបចំស្របតាមប្រតិទិនថវិកា ប៉ុន្តែចាំបាច់ត្រូវបង្កើនគុណភាពឯកសារថវិកាបន្ថែមទៀត ។ ការរៀបចំថវិការយៈពេលមធ្យមគឺស្ថិតក្នុងដំណាក់កាលចាប់ផ្តើមនៅឡើយ ដោយហេតុថាក្របខណ្ឌហិរញ្ញវត្ថុរយៈពេលមធ្យមពុំទាន់ត្រូវបានអនុវត្ត និងថវិការយៈពេលមធ្យមត្រូវបានអនុវត្តសាកល្បងចាប់ពីឆ្នាំ២០១៩ ។
- ***ស័ក្តិសិទ្ធភាពការផ្តល់សេវាសាធារណៈ៖*** មិនទាន់អនុវត្តបានល្អនៅឡើយ ជាពិសេសកង្វះប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម, កិច្ចលទ្ធកម្មសាធារណៈគឺការប្រកួតប្រជែងនៅមានកម្រិត, និងតម្លាភាពថវិកាក៏នៅមានកម្រិត ផងដែរ ។

## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ជាតិ

**ចំណុចគន្លឹះ ត្រូវពង្រឹងបន្ថែម តាមវដ្តថវិកា**

**រៀបចំផែនការ**

- ការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រតាមវិស័យទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- ការផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រតាមវិស័យ និងធនធាន ។

**រៀបចំថវិកា**

- សមាហរណកម្មថវិកាចរន្ត និងមូលធន
- ថវិការយៈពេលមធ្យម
- គុណភាព BSP និង PB (រចនាសម្ព័ន្ធកម្មវិធី និងសូចនាករ)
- ការប្រើប្រាស់ចំណាត់ថ្នាក់មុខងារ
- ការផ្សារភ្ជាប់រវាងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងផែនការយុទ្ធសាស្ត្រថវិកា ។

**អនុវត្តថវិកា**

- ចំណាយកកស្ទះ និងបំណុលពន្ធ
- ការប្រើប្រាស់វិធីសាស្ត្រកិច្ចលទ្ធកម្ម រួមទាំងតម្លាភាព
- ការវិភាគ និងវាយតម្លៃហានិភ័យពន្ធ
- ការអនុវត្តមុខងារអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករ
- ភាពទាន់ពេលវេលានៃការផលិតរបាយការណ៍ហិរញ្ញវត្ថុ
- សមាហរណកម្មប្រព័ន្ធបៀវត្ស និងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ។

**ត្រួតពិនិត្យ និងវាយតម្លៃ**

- ការវាយតម្លៃសមិទ្ធកម្មនៅតាមក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល
- ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្ម
- សវនកម្មលើសមិទ្ធកម្មស្ថិតក្នុងដំណាក់កាលចាប់ផ្ដើម
- សវនកម្មលើបៀវត្ស
- មុខងារសវនកម្ម និងអធិការកិច្ច
- គ្រឹះស្ថានសាធារណៈ និងសហគ្រាសសាធារណៈ ។

**ពិនិត្យពិនិស្ស័យថវិកា**

- ជំនួយបច្ចេកទេសដើម្បីពិនិត្យលើសេចក្ដីព្រាងច្បាប់ថវិកា និងរបាយការណ៍សវនកម្ម
- យន្តការតាមដានអនុសាសន៍សវនកម្មផ្ទៃក្រៅ ។

55

## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលនៃការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិ

**ពិន្ទុវាយតម្លៃសូចនាករ PEFA ថ្នាក់ក្រោមជាតិ សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ**




| ពិន្ទុ | ចំនួនសូចនាករ |
|---|---|
| A | 2 |
| B+ | 0 |
| B | 2 |
| C+ | 3 |
| C | 3 |
| D+ | 7 |
| D | 11 |

56

## ៥. បច្ច័យលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ– លទ្ធផលបឋមនៃការវាយតម្លៃ PEFA ថ្នាក់ក្រោមជាតិ

- បង្កើនគុណភាព និងភាពទាន់ពេលវេលានៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា
- ការដាក់ឱ្យអនុវត្តថវិការយៈពេលមធ្យម (MTBF)

- ពង្រឹងមុខងារប្រតិភូលភាព
- ពង្រឹងការត្រួតពិនិត្យរដ្ឋថវិកា




- គុណភាពថវិកាកម្មវិធី (រចនាសម្ព័ន្ធកម្មវិធី, លទ្ធផលចុងក្រោយ និងលទ្ធផលចុងក្រោយ (សូចនាករ និងគោលដៅ)
- ការប្រើប្រាស់ចំណាត់ថ្នាក់មុខងារ
- ការគ្រប់គ្រងវិនិយោគសាធារណៈ
- បង្កើនតម្លាភាពថវិកា និងការចូលរួមពីសាធារណជន

- ប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធកម្ម
- សវនកម្មលើបៀវត្ស
- មុខងារសវនកម្ម

- ចំណាយកកស្ទះ
- ការប្រើប្រាស់វិធីសាស្ត្រកិច្ចលទ្ធកម្ម រួមទាំងតម្លាភាព
- ការអនុវត្តមុខងារអភិបាលហិរញ្ញវត្ថុ និងគណនេយ្យករ
- ភាពទាន់ពេលវេលានៃការផលិតរបាយការណ៍ហិរញ្ញវត្ថុ



## ៦. សេចក្តីសន្និដ្ឋាន

ផ្អែកលើលទ្ធផលនៃការត្រួតពិនិត្យតាមដានវឌ្ឍនភាពប្រចាំឆ្នាំ២០២១, សកម្មភាពជាច្រើនសម្រេចបានតាមគោលដៅ និងសកម្មភាពមួយចំនួនកំពុងមានវឌ្ឍនភាព ហើយសកម្មភាពគន្លឹះពាក់ព័ន្ធនឹងការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ ត្រូវបាននិងកំពុងរៀបចំជាបណ្តើរៗផងដែរ ។ គុណភាពនៃការរៀបចំ GDAP/PDAP/MAP និងរបាយការណ៍មានភាពប្រសើរជាងមុន ។ អង្គភាពក្រោមឱវាទកសហវ. ១០០% អនុវត្តផែនការបានលើសពី ៨៥%, មន្ទីរ សហវ. រាជធានីខេត្ត ជាង ៩០% អនុវត្តផែនការបានលើសពី ៨៥%, និងក្រសួង-ស្ថាប័ន ជាង ៧០% អនុវត្តផែនការបានលើសពី ៨៥% ។

បើទោះជាស្ថិតក្នុងបរិការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩, សកម្មភាពកែទម្រង់នៅតែមានចលនការគួរឱ្យកត់សម្គាល់ ដែលនេះបានបង្ហាញអំពីឆន្ទៈ និងការចូលរួមពីគ្រប់ភាគីដែលមានការពាក់ព័ន្ធក្នុងការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ឱ្យកាន់តែរឹងមាំ និងធននឹងវិបត្តិ ។

## ៦. សេចក្តីសន្និដ្ឋាន (ត...)

- **ថវិកានៅតែមានភាពជឿទុកចិត្ត** ដែលបានក្លាយជាកម្លាំងចលករក្នុងការទ្រទ្រង់ និងជំរុញកំណើនសេដ្ឋកិច្ច បើទោះបីជាមានផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ ។ ប៉ុន្តែត្រូវពង្រឹងពិពិធកម្មចំណូល និងពង្រឹងប្រសិទ្ធភាពអនុវត្តចំណាយ ។
- **បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពហិរញ្ញវត្ថុ** ត្រូវបានកសាង និងពង្រឹងបន្ថែម ដើម្បីធានាគណនេយ្យភាព និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងក្នុងគោលដៅប្រើប្រាស់ធនធានហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងតម្លាភាព ។
- **ក្របខណ្ឌថវិកាកម្មវិធី** ត្រូវបានរៀបចំ ពង្រឹង និងពង្រីកការអនុវត្តទាំងនៅរដ្ឋបាលថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលជាឧបករណ៍សំខាន់សម្រាប់ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ។
- **បុរេលក្ខណៈសំខាន់ៗ នៃគណនេយ្យភាពសមិទ្ធកម្ម** ត្រូវបាននិងកំពុងរៀបចំជាបណ្តើរៗ ដែលស្ថិតក្នុងដំណាក់កាលឈានទៅបញ្ចប់ដើម្បីត្រៀមខ្លួនសម្រាប់ដំណាក់កាលទី៤ ។
- **សមត្ថភាពមន្ត្រីនៃក្រសួង-ស្ថាប័នក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ត្រូវបានពង្រឹងជាបណ្តើរៗ និងកម្រិតនៃការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានការកើនឡើង ប៉ុន្តែត្រូវជំរុញបន្ថែមទៀតសម្រាប់ការអនុវត្តដំណាក់កាលទី៤ ដែលជាដំណាក់កាលកាន់តែសំខាន់ ។



## ៦. សេចក្តីសន្និដ្ឋាន (ត...)

ការវាយតម្លៃ PEFA ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បានផ្តល់ជាលទ្ធផលគោល/បន្ទាត់មូលដ្ឋាន (Baseline) អំពីស្ថានភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ដើម្បីផ្តល់ជាធាតុចូលសម្រាប់រៀបចំក្របខណ្ឌផែនការសកម្មភាព តាមរយៈការកំណត់ការដ្ឋានអាទិភាព ដើម្បីដោះស្រាយជាដំណាក់កាលៗ ។ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺចាំបាច់ត្រូវពង្រឹងជាប្រចាំ និងកសាងសមាសធាតុ សំខាន់ៗបន្ថែមទៀត ដើម្បីឆ្លើយតបបានទៅនឹងបរិការណ៍នៃជំងឺកូវីដ-១៩ និងវិបត្តិផ្សេងៗដែលអាចកើតមានជាយថាហេតុ ដើម្បីតម្រង់ឆ្ពោះទៅរកគណនេយ្យភាពសមិទ្ធកម្ម ។

ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព គឺមូលដ្ឋានគ្រឹះដ៏ចាំបាច់មិនអាចខ្វះបាន សម្រាប់ការជំរុញអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្រ ជាពិសេសតាមរយៈការធានានូវកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន និងបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ដល់ប្រជាជនព្រមទាំងរួមចំណែកសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា ។

# អភិក្រមការងារ ៤ ប្រការ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

១. អនុវត្តការងារប្រកបដោយវិជ្ជាជីវៈ និងគោរពក្រមសីលធម៌វិជ្ជាជីវៈ
២. អនុវត្តការងារជាក្រុម
៣. អនុវត្តការងារដោយប្រកាន់ខ្ជាប់ស្មារតីបុរេសកម្ម និងគោលការណ៍ប្រសិទ្ធភាពថវិកា
៤. មិនត្រូវមើលរំលងកំហុសខ្លួនឯង

**សូមអរគុណ!**

# ឧបសម្ព័ន្ធទី ៨ ៖ ការឆ្លើយតបទៅនឹងមតិយោបល់របស់ដៃគូអភិវឌ្ឍន៍លើរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ PFMRP និងរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១ (ភាសាខ្មែរ)

| ល.រ | មតិយោបល់ |
|---|---|
| **ក. មតិយោបល់ទូទៅ** | |
| ០១ | **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍៖**<br>ដៃគូអភិវឌ្ឍន៍អបអរសាទររាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះវឌ្ឍនភាពប្រកដោយចីរភាពលើគ្រប់ទិដ្ឋភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្ដេជ្ញាគាំទ្រការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ |
| | ◆ **ការឆ្លើយតបរបស់ អ.គ.ហ. លើវឌ្ឍនភាពប្រកបដោយចីរភាពលើគ្រប់ទិដ្ឋភាពនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការប្ដេជ្ញាគាំទ្រការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។**<br>រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានផ្ដល់អាទិភាព និងចាត់ទុកភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឆ្អឹងខ្នងនៃការអនុវត្តរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាឱ្យសម្រេចបានប្រកបដោយជោគជ័យ និងចីរភាព។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយរឹងមាំ នឹងឈានទៅសម្រេចបាននូវលទ្ធផលចុងក្រោយទាំង៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន (១) បូរណភាពនៃការគោរពវិន័យថវិកា, (២) ប្រសិទ្ធភាពនៃថវិកា ទាំងក្នុងផ្នែកវិភាជន៍ ទាំងក្នុងផ្នែកប្រតិបត្តិការ និង (៣) ស័ក្តិសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ។ សមិទ្ធផលសម្រេចបានក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈលើទិដ្ឋភាពទាំងបួន រួមមាន ការកែលម្អប្រព័ន្ធ, ក្របខណ្ឌគតិយុត្ត, យន្តការស្ថាប័ន និងការកសាងសមត្ថភាព បានឆ្លុះបញ្ចាំងអំពីការចូលរួមចំណែកគាំទ្រ និងអនុវត្តពីគ្រប់តួអង្គពាក់ព័ន្ធ ព្រមទាំងឆ្លុះបញ្ចាំងអំពីកិច្ចសហប្រតិបត្តិការជាមួយបណ្ដាដៃគូអភិវឌ្ឍន៍។<br>ជាមួយគ្នានេះ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងពិនិត្យធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារថ្មីតាម FMIS, ផែនការសកម្មភាពសម្រាប់អនុវត្ត (១) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥, (២) យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥, (៣) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥, និង (៤) យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ ក្នុងគោលបំណងតម្រង់ទិសការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤។ |

| | |
|---|---|
| | ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អ.គ.ហ. សូមថ្លែងអំណរគុណដល់ដៃគូអភិវឌ្ឍន៍ ដែលផ្តល់ការគាំទ្រទាំងជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសក្នុងការអនុវត្តកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីដំណាក់កាលទី១ រហូតមកដល់បច្ចុប្បន្ន។ |
| ០២ | **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷**<br><br>ដៃគូអភិវឌ្ឍន៍កត់សម្គាល់ឃើញថា ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) ក្នុងឆ្នាំ២០២១ បាននាំឱ្យសម្រេចបាននូវលទ្ធផលគន្លឹះៗរួមមាន ÷ ការគ្រប់គ្រងបាននូវសភាពការណ៍នៃការរីករាលដាលជំងឺកូវីដ-១៩, ការគាំទ្រដល់ប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះ តាមរយៈកម្មវិធីគាំពារសង្គម ក៏ដូចជាគាំទ្រអាជីវកម្ម និងសហគ្រាសធុនតូចនិងមធ្យម។ (១) ការពួនផ្តុំចំណាយសាធារណៈដើម្បីជំរុញការផ្តល់ធនធានសម្រាប់ឆ្លើយតបទៅនឹងវិបត្តិនៃជំងឺកូវីដ-១៩, (២) ការពង្រឹងការកៀរគរចំណូលក្នុងឆ្នាំ២០២១, និង (៣) ការអនុម័តក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការគ្រប់គ្រង និងធ្វើឱ្យមានសភាពធូរស្បើយយ៉ាងឆាប់រហ័សពីវិបត្តិនៃជំងឺកូវីដ-១៩។ |
| | **២.១) ការឆ្លើយតបរបស់អគ្គនាយកដ្ឋានថវិកាអំពី (i) ការពួនផ្តុំចំណាយសាធារណៈដើម្បីជំរុញការផ្តល់ធនធានសម្រាប់ឆ្លើយតបទៅនឹងវិបត្តិនៃជំងឺកូវីដ-១៩។**<br><br>នៅឆ្នាំ២០២១ រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចពន្យារពេលដំឡើងប្រាក់បៀវត្សរ៍មន្ត្រីរាជការ និងអនុញ្ញាតឱ្យជ្រើសរើសមន្ត្រីរាជការថ្មី សម្រាប់តែវិស័យសុខាភិបាលតែមួយប៉ុណ្ណោះ។ តាមរយៈវិធានការនេះ ថវិកាប្រមាណ ២០០ លានដុល្លារអាមេរិកត្រូវបានសន្សំទុក ដែលបានជួយដល់គោលនយោបាយអន្តរាគមន៍ហិរញ្ញប្បទាន ដើម្បីគាំទ្រវិស័យសុខាភិបាល សង្គម និងសេដ្ឋកិច្ចក្នុងអំឡុងពេលមានការរីករាលដាលនៃជំងឺកូវីដ-១៩។<br><br>អនុវត្តតាមវិធីសាស្ត្រស្រដៀងគ្នានេះ ការវិភាជត្រូវបានចាត់ចែងឱ្យកាន់តែមានប្រសិទ្ធភាពសម្រាប់ ចំណាយមិនមែនជាប្រាក់បៀវត្ស ដោយអនុវត្តវិធានការដូចជា (១) គ្មានការវិភាជសម្រាប់ចំណាយដែលមិនចាំបាច់ (២) ការវិភាជមានភាពតឹងរឹងសម្រាប់ចំណាយដែលមានភាពចាំបាច់តិចតួច (៣) បន្តវិភាជសម្រាប់ចំណាយចាំបាច់, (៤) ប្តេជ្ញាវិភាជបន្ថែមទៀតចំពោះចំណាយចាំបាច់បំផុត។ លើសពីនេះ ការផ្តោតសំខាន់គឺលើវិស័យអាទិភាព ទាក់ទិននឹងសកម្មភាព និងកម្មវិធី (Program) របស់ក្រសួង-ស្ថាប័ននានា ក្នុងក្របខណ្ឌនៃការរក្សាតុល្យភាពកម្រិតជីវភាពប្រជាពលរដ្ឋ កត្តាសង្គម និងសេដ្ឋកិច្ចក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩។<br><br>ជាមួយគ្នានេះ ផ្អែកលើការសម្រេចរបស់រាជរដ្ឋាភិបាល, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវសារាចរដែលរួមបញ្ចូលវិធានការវិចារណកម្មចំណាយថវិកា នៅអំឡុងពេលអនុវត្តច្បាប់ថវិកាក្នុងឆ្នាំ២០២១ ទាំងចំណាយចរន្ត និងចំណាយមូលធន នៅកម្រិតថ្នាក់ជាតិ។ វិធានការនេះ ជួយឱ្យរាជរដ្ឋាភិបាលសន្សំថវិកា |

| | |
|---|---|
| | ប្រមាណ ៩៨ លានដុល្លាអាមេរិក ដើម្បីដោះស្រាយនូវផលប៉ះពាល់ជាអវិជ្ជមានលើសង្គមសេដ្ឋកិច្ចដែលបណ្តាលមកពីការបិទខ្ទប់ដើម្បីប្រយុទ្ធប្រឆាំងនឹងការរីករាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍ ២០ កុម្ភៈ ២០២១។ |
| | **២.២) ការឆ្លើយតបរបស់អគ្គនាយកដ្ឋានគោលនយោបាយអំពី (ii) ការពង្រឹងការកៀរគរចំណូលក្នុងឆ្នាំ ២០២១, និង (iii) ការអនុម័តក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣**<br>ជាលទ្ធផលនៃ "ការផ្ទុះរីករាលដាលជំងឺកូវីដ-១៩ ២០ កុម្ភៈ" រួមជាមួយនឹងការអនុវត្តវិធានការបន្ធូរបន្ថយពន្ធ សម្រាប់ធុរកិច្ចដែលរងផលប៉ះពាល់, ចំណូលចរន្តក្នុងឆ្នាំ២០២១ បានទទួលរងសម្ពាធបន្ថែមទៀតដោយធ្លាក់ចុះ -៥,៣% (ទិន្នន័យពីប្រព័ន្ធ FMIS គិតត្រឹមថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ២០២២)។ ជាមួយគ្នានេះ តម្រូវការចំណាយសាធារណៈបានបន្តកើនឡើង ដោយសារវិធានការជាច្រើនត្រូវបានដាក់ចេញ ដើម្បីគ្រប់គ្រងការរីក-រាលដាល និងដើម្បីជំរុញការងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក។<br>រាជរដ្ឋាភិបាលបានមើលឃើញអំពីសារៈសំខាន់ ក្នុងការជំរុញការកៀរគរចំណូលសម្រាប់រយៈពេលមធ្យមខាងមុខ។ ដូចនេះ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ក្នុងគោលបំណង ធ្វើទំនើបកម្មរដ្ឋបាលពន្ធ, ធ្វើវិចារណកម្មគោលនយោបាយពន្ធ និងកសាងមូលដ្ឋានសម្រាប់ការកែ-ទម្រង់ប្រព័ន្ធពន្ធទាំងមូល។ បច្ចុប្បន្ន រាជរដ្ឋាភិបាលបានធ្វើការសិក្សាអំពីប្រភេទពន្ធនានា រួមមាន គោល-នយោបាយអាករពិសេស, ពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល និងការកែទម្រង់ប្រព័ន្ធពន្ធ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូររចនា-សម្ព័ន្ធសង្គមសេដ្ឋកិច្ចជាតិ និងសេចក្តីត្រូវការសម្រាប់ការអភិវឌ្ឍ។<br>បន្ថែមពីនេះ ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣ នឹងត្រូវប្រើប្រាស់ជាផែនទីបង្ហាញផ្លូវសម្រាប់គាំទ្រការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជា ជាមួយនឹងវិធានការជាក់លាក់ ដោយផ្តោតការយកចិត្តទុកដាក់លើ ការស្តារកំណើន, ការកែទម្រង់, និងការកសាងភាពធន់។ ទោះជាយ៉ាងនេះក្តី យន្តការហិរញ្ញប្បទាន គឺជាសមាសធាតុ មួយក្នុងចំណោមសមាសធាតុសំខាន់ជាច្រើន នៃក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនេះ ដើម្បីគាំទ្រការអនុវត្ត ខណៈត្រូវធានាឱ្យបាននូវចីរភាពហិរញ្ញវត្ថុផងដែរ។ រាជរដ្ឋាភិបាល នឹងបន្តប្រើប្រាស់ធនធានឱ្យអស់ពីសក្តានុពល ដោយធ្វើអាទិភាវូបនីយកម្មចំណាយ ដើម្បីគាំទ្រគោលដៅជាអាទិភាព ខណៈបង្កើតយន្តការហិរញ្ញប្បទានបន្ថែមដូចជាការបង្កើតទីផ្សារមូលបត្ររដ្ឋ និងយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ជាដើម។ |
| ០៣ | **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍ ÷**<br>ដៃគូអភិវឌ្ឍន៍កត់សម្គាល់ឃើញថា ខណៈដែលបរិមាណនៃចំណាយសាធារណៈត្រូវបានជំរុញកាន់តែច្រើនស្របជាមួយនឹងការកើនឡើងលំហថវិកា (មុនមានការរីករាលដាលនៃជំងឺកូវីដ-១៩), គុណភាពនៃចំណាយសាធារណៈ នៅមានបញ្ហាប្រឈម។ ក្នុងន័យនេះ ការកែទម្រង់បន្ថែមទៀត គួរផ្តោតការយកចិត្តទុកដាក់លើការកែលម្អទិដ្ឋភាពនេះ ដើម្បីឆ្ពោះទៅអនុវត្តគណនេយ្យភាពចំពោះសមិទ្ធកម្ម។ |
| | ❖ **ការឆ្លើយតបរបស់អគ្គនាយកដ្ឋានថវិកាទៅលើគុណភាពនៃចំណាយសាធារណៈ** |

ដើម្បីគ្រប់គ្រងចំណាយសាធារណៈ និងក្នុងអំឡុងពេលនៃការរៀបចំថវិកាប្រចាំឆ្នាំ រាជរដ្ឋាភិបាលបានផ្តោតលើការលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជថវិកាដល់ក្រសួង-ស្ថាប័ននានា ដោយខិតខំកែលម្អការវិភាជថវិកាឱ្យកាន់តែចំគោលដៅ និងភាពចាំបាច់ ព្រមទាំងការបង្កើនការឆ្លើយតបរបស់ថវិកាទៅនឹងគោលនយោបាយអាទិភាពតាម វិស័យ។

គុណភាពចំណាយសាធារណៈ ត្រូវបានកែលម្អគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារការត្រួតពិនិត្យយ៉ាងម៉ត់ចត់អំឡុងពេលចរចាថវិកា និងតាមជំហានចំណាយនីមួយៗ។ មុខសញ្ញាចំណាយត្រូវបានកំណត់នៅក្នុងការចរចាថវិកា អំពីចំណាយប្រចាំ មិនប្រចាំ ឬជាមុខសញ្ញាចំណាយមិនចាំបាច់។ សំណើចំណាយថវិកាសម្រាប់ការអនុវត្ត ត្រូវបានត្រួតពិនិត្យជាមួយផែនការ និងការសម្រេចនៅអំឡុងពេលចរចា ថវិកា។ ក្នុងករណីមានការប្រែប្រួល នឹងត្រូវធ្វើការផ្ទៀងផ្ទាត់ និងស្នើសុំការពន្យល់បន្ថែម។ ជារួម ការកែលម្អប្រសិទ្ធភាពនៃការអនុវត្តថវិកា គឺត្រូវបន្តយកចិត្តទុកដាក់។ បច្ចុប្បន្ន ថវិកាត្រូវបានគ្រប់គ្រងផ្ទាល់ដោយអង្គភាពថវិកា, ហើយវិធានការវិចារណកម្មថវិកាត្រូវបានដាក់ចេញជាបន្តបន្ទាប់ដើម្បីបង្កើន "**តម្លៃនៃលុយ**" សម្រាប់ចំណាយចរន្តនិងចំណាយមូលធន។ បន្ថែមពីនេះ គម្រោងហេដ្ឋារចនាសម្ព័ន្ធហិរញ្ញប្បទានដោយចំណាយមូលធនក្នុងស្រុកត្រូវបានគ្រប់គ្រងតាមរយៈគណៈកម្មាធិការអន្តរក្រសួង ដែលជាភស្តុតាងបញ្ជាក់អំពីប្រសិទ្ធភាពខ្ពស់ទាំងក្នុង ការរៀបចំ និងការអនុវត្ត។

◆ **ការផ្តល់មតិបន្ថែមរបស់ អ ទៅលើគុណភាពនៃចំណាយសាធារណៈ .ហ.គ.**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងដាក់ចេញជាវិធានការគន្លឹះៗ ដើម្បីបង្កើនគុណភាពចំណាយ ថវិកា ក្នុងនោះរួមមានដូចខាងក្រោម÷

១) ជាទិសដៅ, FMIS នឹងត្រូវប្រើប្រាស់ជាឧបករណ៍សម្រាប់ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

២) រៀបចំច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ដែលនឹងត្រូវរៀបចំបញ្ចប់សេចក្តីព្រាងនៅខែមីនា និងដាក់ជូនស្ថាប័ននីតិប្បញ្ញត្តិនៅត្រីមាសទី៤ ឆ្នាំ២០២២ នេះ។ ច្បាប់នេះគឺជាគន្លឹះនៃការកែទម្រង់គ្រប់សមាសធាតុនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ និងគណនេយ្យភាពសមិទ្ធកម្ម។

០៤ **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷**

ក្នុងរយៈពេលមធ្យម, សម្ពាធហិរញ្ញវត្ថុសម្រាប់រាជរដ្ឋាភិបាល ទំនងជានៅតែស្ថិតក្នុងកម្រិតខ្ពស់ ហើយតម្រូវការក្នុងការធ្វើអាទិភាពូបនីយកម្ម, ការពង្រឹង និងការអនុវត្តការងារកែទម្រង់គន្លឹះៗ នឹងកាន់តែមានភាពបន្ទាន់។ របាយការណ៍ប្រចាំឆ្នាំ បានបង្ហាញអំពីកិច្ចការដែលត្រូវកែទម្រង់កាន់តែស៊ីជម្រៅបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ។

**៤.១) ការឆ្លើយតបរបស់ អ.គ.ហ. លើកិច្ចការដែលត្រូវធ្វើការកែទម្រង់បន្ថែមឱ្យកាន់តែស៊ីជម្រៅ។**

ចំពោះសំពាធហិរញ្ញវត្ថុបច្ចុប្បន្ន, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងផ្តោតជាសំខាន់លើការពង្រីកលំហថវិកា និងការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងចំណាយសាធារណៈ បន្ថែមទៀត។

ចំពោះផ្នែកចំណូល ដូចបានដាក់ចេញក្នុងយុទ្ធសាស្ត្រគៀរចំណូល ២០១៩-២០២៣, រាជរដ្ឋាភិបាល នឹងអនុវត្តក្របខណ្ឌគោលនយោបាយពន្ធ រួមទាំងពន្ធលើប្រាក់ចំណេញមូលធន និងពន្ធលើប្រាក់ចំណូលរូបវន្ត បុគ្គល។ បន្ថែមពីនេះ រាជរដ្ឋាភិបាលកំពុងធ្វើការសិក្សាលើប្រព័ន្ធពន្ធឡើងវិញ ហើយដោយមានការគាំទ្របច្ចេកទេស ពីក្រុមការងារធនាគារពិភពលោក, លទ្ធផលនៃការសិក្សានេះនឹងអាចសម្រេចបានត្រឹមដំណាច់ឆ្នាំ២០២២ ព្រមទាំង ក្លាយជាធាតុចូលដ៏សំខាន់សម្រាប់តម្រឹមគោលនយោបាយ និងរដ្ឋបាលពន្ធកម្ពុជា នាឆ្នាំខាងមុខ។ បច្ចុប្បន្ន អគ្គនាយកដ្ឋានគោលនយោបាយ និងអគ្គនាយកដ្ឋានពន្ធដារកំពុងសហការរៀបចំក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌប្រតិបត្តិគោលនយោបាយ ក្នុងការត្រៀមដាក់ឱ្យអនុវត្តពន្ធថ្មីទាំងនេះ។

ដោយឡែក សម្រាប់ចំណូលមិនមែនសារពើពន្ធ គឺរងការប៉ះទង្គិចយ៉ាងខ្លាំងពីវិបត្តិនៃជំងឺកូវីដ-១៩។ ជាការសន្និដ្ឋាន កំណើនចំណូលមិនមែនសារពើពន្ធមិនទាន់អាចវិលទៅរកកម្រិត ដែលសម្រេចបានមុនពេល មានវិបត្តិកូវីដ-១៩ នៅឡើយ។ យ៉ាងណាមិញ សម្រាប់ការដ្ឋានកែទម្រង់នេះ ការយកចិត្តទុកដាក់ត្រូវបានផ្តល់ លើការកែលម្អប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការគ្រប់គ្រង តាមរយៈការដាក់ឱ្យអនុវត្តប្រព័ន្ធ NRMIS និង ប្រព័ន្ធ SARMIS។ បន្ថែមពីនេះ ឯកសារគោលស្តីពីការកែទម្រង់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធត្រូវ បានរៀបចំជាសេចក្តីព្រាង ទន្ទឹមនឹងសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ កំពុងត្រូវ បានពិគ្រោះយោបល់ និងត្រៀមដាក់ឆ្លងគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំង គណៈរដ្ឋមន្ត្រីនៅក្នុងឆ្នាំ២០២២ នេះ។

សម្រាប់ផ្នែកចំណាយ កិច្ចខិតខំកែទម្រង់ត្រូវតម្រង់ឆ្ពោះទៅពង្រឹងវឌ្ឍនភាពនៃការដាក់ឱ្យដំណើរការមុខ ងារ នានានៃ FMIS ដោយការតម្រង់ទិសនីតិវិធីថ្មី (Business Process Streamlining) និងការដកចេញនូវ ដំណើរការ ប្រតិបត្តិការហិរញ្ញវត្ថុចំណាយក្រៅប្រព័ន្ធ ព្រមទាំងពង្រឹងការអនុវត្តយុទ្ធសាស្ត្រស្នូលនានា ក្នុង នោះរួមមាន÷ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០១៨-២០២៥, យុទ្ធសាស្ត្រស្តីពីការកែទម្រង់ ប្រព័ន្ធគ្រប់គ្រងការវិ-និយោគសាធារណៈ ២០១៩-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាល ថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥ និងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥។

### ៤.២.) ការឆ្លើយតបរបស់អគ្គនាយកដ្ឋានថវិកាទៅលើវិធានការរយៈពេលមធ្យមសម្រាប់សម្ពាធហិរញ្ញវត្ថុ។

ឱនភាពថវិការយៈពេលមធ្យមត្រូវបានព្យាករថានឹងកើនឡើង បើធៀបនឹងតួលេខកន្លងមក ដោយសារ តែកំណើនចំណូលយឺត បើធៀបទៅនឹងកំណើនឆាប់រហ័សមុនការរីករាលដាលនៃជំងឺកូវីដ-១៩ និងតម្រូវការ ចំណាយច្រើនឡើង សម្រាប់ផែនការស្តារឡើងវិញ ដើម្បីសម្រេចបាននូវអាទិភាពគោលនយោបាយសំខាន់ៗ របស់រាជរដ្ឋាភិបាល។ ការណ៍នេះ បង្ហាញថារបៀបវារៈគោលនយោបាយហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល នឹងត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើយុទ្ធសាស្ត្រគៀរចំណូល និងក្របខណ្ឌចំណាយគ្រប់ជ្រុង-ជ្រោយ ដើម្បីធានាបាននូវចីរភាពថវិកា។ បញ្ហាប្រឈមទាំងនេះរួមមាន ÷

i) អន្តរកាលឆ្ពោះទៅប្រទេសមានចំណូលមធ្យម នាំមកនូវការថមថយជំនួយហិរញ្ញប្បទាន និងកម្ចីសម្បទានខ្ពស់។ ដៃគូអភិវឌ្ឍន៍ តម្រូវឱ្យរាជរដ្ឋាភិបាល បង្កើនការរួមចំណែកជាសាច់ប្រាក់ និងបន្តគាំទ្រគម្រោង និងកម្មវិធីជាក់លាក់មួយចំនួន។ រាជរដ្ឋាភិបាលក៏នឹងទទួលខុសត្រូវផងដែរចំពោះកម្មវិធីសំខាន់ៗក្នុងចំណោមកម្មវិធីសំខាន់ៗផ្សេងទៀតដែលបានបញ្ចប់ដោយហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ដូច្នេះមានការកើនឡើងកាតព្វកិច្ចសេវាបំណុលពីគម្រោងនានា។

ii) កាតព្វកិច្ចទូទាត់សម្រាប់គម្រោងធំៗ ពហុឆ្នាំ ទាំងការចំណាយចរន្ត និងមូលធន។ និង

iii) ការកើនឡើងនៃចំណាយបៀវត្ស ដែលដាក់សម្ពាធលើចំណាយចាំបាច់មិនមែនបៀវត្ស និងចំណាយវិនិយោគចាំបាច់។

០៥ **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷**

ដៃគូអភិវឌ្ឍន៍ស្វាគមន៍ចំពោះវឌ្ឍនភាពនៃការរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៤ (CAP4)។ ដៃគូអភិវឌ្ឍន៍រីករាយចូលរួមកិច្ចពិគ្រោះយោបល់សម្រាប់ការរៀបចំ CAP4។

- **ការឆ្លើយតបរបស់ អ.គ.ហ. លើការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងដំណើរការពិគ្រោះយោបល់សម្រាប់ការរៀបចំ CAP4។**

អ.គ.ហ. ចាប់ផ្តើមរៀបចំ CAP4 ក្នុងខែកុម្ភៈ ឆ្នាំ២០២២ ដែលគ្រោងបញ្ចប់ត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០២២ ហើយប្រើប្រាស់ CAP4 សម្រាប់រៀបចំផែនការសកម្មភាពលម្អិត GDAP, MAP and PDAP ឱ្យបានត្រឹមដំណាច់ឆ្នាំ២០២២។ ការរៀបចំ CAP4 ត្រូវបានប្រព្រឹត្តទៅជា ៣ ជំហាន (ទី១) ការពិនិត្យលើរបៀបវារៈកែទម្រង់ ដែលនៅសេសសល់, (ទី២) ការពិភាក្សាលើក្របខណ្ឌ និងសមាសធាតុ CAP4, និង (ទី៣) ការស្នើសុំការពិនិត្យនិងអនុសាសន៍ណែនាំលើសេចក្តីព្រាង CAP4 ពីគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

គិតមកត្រឹមពេលនេះ ក្រុមការងាររៀបចំ CAP4 បានពិនិត្យការដ្ឋានកែទម្រង់សំខាន់ៗ និងបានរៀបចំជាសេចក្តីព្រាងក្របខណ្ឌ CAP4 រួចរាល់។ ក្របខណ្ឌនេះត្រូវបានដាក់ពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ក្នុងកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ហើយធាតុចូលរបស់ដៃគូអភិវឌ្ឍន៍ ពិសេសតាមរយៈការរៀបចំ ទស្សនាទាន (Policy Note) របស់ដៃគូអភិវឌ្ឍន៍ ត្រូវបានឆ្លុះបញ្ចាំងក្នុងខ្លឹមសារក្របខណ្ឌ CAP4 កែសម្រួល ចុងក្រោយ ។

អ.គ.ហ. ស្វាគមន៍ចំពោះការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងដំណើរការរៀបចំ CAP4។

## ខ. មតិយោបល់ជាក់លាក់

០៦ **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷**

ដៃគូអភិវឌ្ឍន៍កោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងលើការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (ថ្មី) ក្នុងការឯកភាពលើគ្រប់មាត្រានៅកម្រិតបច្ចេកទេសត្រឹមចុងខែមីនា ឆ្នាំ២០២២ និងការប្តេជ្ញាផ្ញើសេចក្តីព្រាងច្បាប់ជូនស្ថាប័ននីតិបញ្ញត្តិអនុម័តត្រឹមចុងឆ្នាំ២០២២។

- **ការឆ្លើយតបរបស់អគ្គនាយកដ្ឋានថវិកាលើការប្តេជ្ញាផ្ញើសេចក្តីព្រាងច្បាប់ជូនស្ថាប័ននីតិបញ្ញត្តិអនុម័តត្រឹមចុងឆ្នាំ២០២២។**

គណៈកម្មាធិការដឹកនាំការរៀបចំច្បាប់ថ្មីនេះនឹងបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ នៅចុងខែមីនា។ កិច្ចពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍, ក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធផ្សេងទៀតនឹងត្រូវធ្វើឡើងមុនដាក់ជូនថ្នាក់ដឹកនាំកំពូលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ថ្នាក់ដឹកនាំកំពូលនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងផ្តល់នូវការត្រួតពិនិត្យចុងក្រោយនៅត្រីមាសទី២។ ការដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រីនឹងធ្វើឡើងនៅត្រីមាសទី៣។ នៅត្រីមាសទី៤ រដ្ឋសភានឹងទទួលបានសេចក្តីព្រាងច្បាប់នេះ។

០៧ **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷**

ដៃគូអភិវឌ្ឍន៍រំលឹកអំពីការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបៃតង (Greening PFM reforming) នៅពេលដែលអាចអនុវត្តបានដើម្បីគាំទ្រគោលនយោបាយវេតយិតភាពអាកាសធាតុ (climate-sensitive policies) ឬអាចអនុវត្តក្នុង CAP4។

- **ការឆ្លើយតបរបស់ អទៅលើការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបៃតង .ហ.គ.។**

ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអាចជាឧបករណ៍មួយសម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ដោយហេតុថាបញ្ហាប្រែប្រួលអាកាសធាតុនិងការគាំពារបរិស្ថានគឺជាគោលនយោបាយអាទិភាពក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, ការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឱ្យមានលក្ខណៈឆ្លើយតបសម្រាប់អនុវត្តគោលនយោបាយទាំងនេះ គឺពិតជាកិច្ចការសំខាន់។

គិតមកត្រឹមពេលនេះ, អ.គ.ហ បានកត់សម្គាល់ថា តាមរយៈកិច្ចសហការរវាងអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃក្រសួងបរិស្ថាន, បញ្ហាប្រែប្រួលអាកាសធាតុ និងការគាំពារបរិស្ថានត្រូវបានរំលេចជាគោលនយោបាយអាទិភាពក្នុងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងថវិកាកម្មវិធី។ ក្រសួង-ស្ថាប័នត្រូវបានជំរុញឱ្យបញ្ជ្រាបអាទិភាពគោលនយោបាយនេះទៅក្នុងកម្មវិធី និងគម្រោងអភិវឌ្ឍន៍នៃផែនការថវិការបស់ក្រសួង-ស្ថាប័នសាមី។

ជាទិសដៅបន្ត, អ.គ.ហ នឹងសហការជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រំលេចការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានលក្ខណៈឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ និងការគាំពារបរិស្ថាន (green PFM) ទៅក្នុងនីតិវិធីស្តង់ដាប្រតិបត្តិរួម (SOP) និងឯកសារណែនាំស្តីពីការគ្រប់គ្រងវិនិយោគសាធារណៈ និងការគ្រប់គ្រងលទ្ធកម្មសាធារណៈ ព្រមទាំងការដ្ឋានផ្សេងៗទៀត តាមការចាំបាច់។

## គ. សំណើបញ្ជាក់បន្ថែម

| | |
|---|---|
| ០៨ | **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷**<br>ដៃគូអភិវឌ្ឍន៍ស្នើព័ត៌មានបន្ថែមអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការបន្តពង្រឹងការកៀរគរចំណូលក្នុងស្រុក នាពេលអនាគត ជាពិសេសទាក់ទិននឹងគោលនយោបាយពន្ធ និងរដ្ឋបាលពន្ធ។ ការរំពឹងទុកក្នុងការផ្លាស់ប្ដូរមូលដ្ឋានផសស នាពេលខាងមុខ (rebasing of GDP) នឹងកាត់បន្ថយចំណែកនៃចំណូលរបស់កម្ពុជា លុះត្រាតែរាជរដ្ឋាភិបាលចាត់វិធានការចាំបាច់នានា ក្នុងការពង្រីកមូលដ្ឋាននៃការប្រមូលពន្ធ កែលម្អគោលនយោបាយពន្ធ និងធ្វើទំនើបកម្មរដ្ឋបាលពន្ធ។ |
| | ❖ **ការឆ្លើយតបរបស់អគ្គនាយកដ្ឋានគោលនយោបាយអំពីកិច្ចខិតខំប្រឹងប្រែងក្នុងការបន្តពង្រឹងការកៀរគរចំណូល ក្នុងស្រុក នាពេលខាងមុខ ជាពិសេសទាក់ទិននឹងគោលនយោបាយពន្ធ និងរដ្ឋបាលពន្ធ។**<br>យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ (RMS-II) នៅតែជាយុទ្ធសាស្ត្រគន្លឹះសម្រាប់ពង្រឹងការប្រមូលចំណូលក្នុងស្រុក, រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការអនុវត្តយុទ្ធសាស្ត្រនេះ ជាពិសេសការធ្វើទំនើបកម្មរដ្ឋបាលប្រមូលចំណូល និងការរៀបចំគោលនយោបាយពន្ធសំខាន់ៗ។ RMS-II នឹងបន្តផ្តោតការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស, ការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រង ឱ្យស្របនឹងបរិការណ៍នៃការអភិវឌ្ឍន៍, ការពង្រឹងប្រសិទ្ធភាពសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ, ការត្រួតពិនិត្យ និងដាក់ឱ្យអនុវត្តវិធានការគោលនយោបាយថ្មីដើម្បីដោះស្រាយបញ្ហាប្រឈម, ការបន្តធ្វើវិចារណកម្មគោលនយោបាយពន្ធ និងមិនមែនពន្ធដើម្បីធានាសង្គតិភាពជាមួយគោលដៅកែទម្រង់ និងគោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាល ជាពិសេសការកំណត់ និងការផ្សារភ្ជាប់វិធានការជាយុទ្ធសាស្ត្រជាមួយសូចនាករសមិទ្ធកម្មគន្លឹះ ក្នុងគោលបំណងត្រួតពិនិត្យតាមដាន និងវាយតម្លៃ។ ជាក់ស្តែង យោងតាម RMS-II, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិងកំពុងរៀបចំគោលនយោបាយអាករពិសេស, ក្របខណ្ឌគោលនយោបាយសម្រាប់ត្រៀមលក្ខណៈអនុវត្តពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល។ល។ ជាមួយគ្នានេះ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងធ្វើការវាយតម្លៃពាក់កណ្ដាលអាណត្តិលើការអនុវត្ត RMS-II ដើម្បីតាមដាន និងវាយតម្លៃវឌ្ឍនភាព, កំណត់បញ្ហាប្រឈម និងស្នើកែសម្រួល ឬវិធានការ ដើម្បីធានាក្នុងការសម្រេចបានគោលដៅតាមការកំណត់។<br>បន្ថែមពីលើនេះ ការអនុម័ត និងអនុវត្តច្បាប់វិនិយោគថ្មី, វិធានការកែលម្អបរិយាកាសធុរកិច្ច, លើកកម្ពស់សហគ្រាសធុនតូចនិងមធ្យម, វិធានការលើកកម្ពស់ការស្តារសេដ្ឋកិច្ចឡើងវិញ ក៏ដូចជាការលើកទឹកចិត្តផ្សេងៗ ជាពិសេសវិធានការដែលប្រទាក់ក្រឡាគ្នា និង ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣ នឹងជួយជំរុញការវិនិយោគ និងទាក់ទាញធុរកិច្ច ដែលនឹងពង្រីកមូលដ្ឋានសម្រាប់ការប្រមូលចំណូល។ |
| ០៩ | **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷**<br>ដៃគូអភិវឌ្ឍន៍ស្នើព័ត៌មានបន្ថែមអំពីស្ថានភាពនៃការអនុម័តនីតិវិធីគ្រប់គ្រងប្រតិបត្តិការសម្រាប់រៀបចំ និងគ្រប់គ្រងគម្រោង PPP (SOP) សម្រាប់ការអនុវត្តច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន (ត្រូវបានអនុម័តកាលពីឆ្នាំ២០២១)។ |

❖ **ការឆ្លើយតបរបស់អគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋនិងឯកជនលើស្ថានភាពនៃការអនុម័តនីតិវិធីគ្រប់គ្រងប្រតិបត្តិការសម្រាប់រៀបចំ និងគ្រប់គ្រងគម្រោង PPP (SOP)។**

នីតិវិធីគ្រប់គ្រងប្រតិបត្តិការសម្រាប់រៀបចំ និងគ្រប់គ្រងគម្រោង **PPP (SOP)** ត្រូវបានចាប់ផ្តើមរៀបចំឡើងស្របពេលជាមួយនឹងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ទោះជាយ៉ាងនេះក្តី, ច្បាប់នេះត្រូវបានអនុម័ត និងដាក់ឱ្យអនុវត្តនៅត្រីមាសទី៤ ឆ្នាំ២០២១ ប៉ុន្តែការរៀបចំ SOP នៅមានភាពយឺតយ៉ាងជាងការគ្រោងទុក ដោយសារមូលហេតុសំខាន់ៗមួយចំនួន រួមមាន ÷ ផលប៉ះពាល់នៃវិបត្តិជំងឺកូវីដ-១៩ និងភាពស្មុគស្មាញផ្នែកបច្ចេកទេសនៃ SOP។ ទោះជាមានបញ្ហាប្រឈមទាំងនោះក៏ដោយ, ការរៀបចំ SOP កំពុងមានវឌ្ឍនភាព។ SOP នេះ មានបីភាគ (ភាគទី ១÷ គោលនយោបាយ និងនីតិវិធី, ភាគទី ២ ÷ គោលការណ៍ណែនាំ, និងភាគទី ៣ ÷ នីតិវិធីលទ្ធកម្ម)។ មកដល់ពេលនេះ, គោលការណ៍ណែនាំមួយចំនួនត្រូវបានដាក់ពិភាក្សា រួចហើយជាមួយភាគីពាក់ព័ន្ធ ហើយអង្គភាពគ្រោងស្នើសុំអនុម័ត និងដាក់ឱ្យអនុវត្ត SOP នេះ នៅត្រីមាសទី ២ ឆ្នាំ២០២២។

១០ **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷**

ដៃគូអភិវឌ្ឍន៍កត់សម្គាល់ឃើញថាអំឡុងពេលកិច្ចការកែទម្រង់ដែលបានត្រូវដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០២១ មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ប៉ុន្តែនៅមានតម្រូវការពង្រឹងបន្ថែម។ ក្នុងន័យនេះ, ដៃគូអភិវឌ្ឍន៍ស្នើព័ត៌មានបន្ថែមដូចខាងក្រោម÷

i) ផែនការសម្រាប់អនុវត្តក្របខណ្ឌផែនការរយៈពេលមធ្យម និងការអនុវត្តក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម )MTFF) និងក្របខណ្ឌថវិការយៈពេលមធ្យម )MTBF)។

ii) កិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនការប្រើប្រាស់នីតិវិធីប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្មសាធារណៈ។

**១០.១) ការឆ្លើយតបរបស់អគ្គនាយកដ្ឋានគោលនយោបាយអំពីក្របខណ្ឌផែនការរយៈពេលមធ្យម និងការអនុវត្តក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF)។**

ក្រុមការងារបច្ចេកទេសបានរៀបចំសេចក្តីព្រាង **MTFF** ឆ្នាំ២០២៣-២០២៥ រួចរាល់។ ប៉ុន្តែ ដោយសារភាពមិនប្រាកដប្រជាដែលកើតឡើងពីសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលនាំមកនូវផលប៉ះពាល់ជាសកល ព្រមទាំងការផ្លាស់ប្តូរឆ្នាំគោលនៃការគណនា ផសស របស់រាជរដ្ឋាភិបាល ចាប់ពីឆ្នាំ ២០២៣ ដែលនឹងនាំមកនូវការផ្លាស់ប្តូរជាបច្ចេកទេសមួយចំនួន និងនាំមកនូវការពិភាក្សាជាគោលនយោបាយច្រើន, ថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចពន្យាពេលអនុវត្ត **MTFF** ឆ្នាំ ២០២៣-២០២៥។ ដូច្នេះ ការអនុវត្ត **MTFF** ជាផ្លូវការលើកដំបូងនឹងធ្វើនៅឆ្នាំ ២០២៣ ដែលជាក្របខណ្ឌសម្រាប់ឆ្នាំ ២០២៤-២០២៦។

**១០.២) ការឆ្លើយតបរបស់អគ្គនាយកដ្ឋានថវិកាអំពីក្របខណ្ឌថវិការយៈពេលមធ្យម។**

បច្ចុប្បន្ន ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២២ ត្រូវបានរៀបចំ និងអនុម័ត។ ដោយផ្អែកលើយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា (BSRS) ២០១៨-

២០២៥ ក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) គឺជាមូលដ្ឋានសម្រាប់រៀបចំក្របខណ្ឌថវិការយៈពេលមធ្យម (MTBF)។ ដើម្បីបញ្ចប់ការងារនេះជាបណ្តើរៗ និងពង្រឹងសមត្ថភាពសម្រាប់ការរៀបចំ MTBF អគ្គនាយកដ្ឋានថវិកាបានបញ្ចូលការងារនេះទៅក្នុងផែនការយុទ្ធសាស្ត្រថវិកា (BSP) ដោយកំណត់ពិដានចំណាយ និងបន្តបញ្ចូលចំណាយចរន្ត និងចំណាយមូលធនទៅតាមគោលដៅប្រចាំឆ្នាំដែលត្រូវបានអនុម័ត។

វឌ្ឍនភាពជាវិជ្ជមាននៃការរៀបចំឯកសារ MTBF នឹងរួមបញ្ចូលចំណាយពិតានមូលដ្ឋាន និងស្របតាមទិសដៅគោលនយោបាយសំខាន់ៗមួយចំនួនរបស់ក្រសួង-ស្ថាប័ន ដែលរួមបញ្ចូលពីឯកសារ MTFF ផ្សារភ្ជាប់ទៅយុទ្ធសាស្ត្រដែលបានដាក់ចេញនាពេលថ្មីៗ និងអាទិភាពសំខាន់ៗសម្រាប់រយៈពេលមធ្យម ដើម្បីធានាថាមិនឃ្លាតចាកពីគោលបំណងរួមនៃគោលនយោបាយជាតិ។ បន្ថែមពីលើនេះ, ការដាក់ចំណាយពិតានមូលដ្ឋានសម្រាប់ក្រសួង-ស្ថាប័ន នឹងជួយសម្រួលដល់ក្រសួង-ស្ថាប័ន មានផែនការច្បាស់លាស់ទៅតាមកម្មវិធី/គម្រោងពហុឆ្នាំ ជាមួយនឹងថវិកាហិរញ្ញប្បទានដោយជាតិ និងថវិកាហិរញ្ញវត្ថុដោយបរទេស។

### ១០.៣) ការឆ្លើយតបរបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ និងអគ្គនាយកដ្ឋានថវិកា (នាយកដ្ឋានវិនិយោគ) អំពីនីតិវិធីប្រកួតប្រជែងក្នុងកិច្ចលទ្ធកម្មសាធារណៈ។

❖ **អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ÷**

កិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងប្រសិទ្ធភាពនៃវិធីសាស្ត្រលទ្ធកម្មប្រកួតប្រជែងមានដូចខាងក្រោម÷

- បន្តត្រួតពិនិត្យលើការអនុវត្តផែនការលទ្ធកម្មប្រចាំឆ្នាំដែលបានអនុម័ត
- ពិនិត្យឱ្យបានហ្មត់ចត់នូវសំណើគោលការណ៍សម្រាប់ការប្រើប្រាស់វិធីសាស្ត្រកិច្ចលទ្ធកម្មជាជម្រើស (កិច្ចសន្យាផ្ទាល់)
- ជំរុញការដេញថ្លៃប្រកួតប្រជែងសម្រាប់គម្រោងចំណាយវិនិយោគ។

❖ **អគ្គនាយកដ្ឋានថវិកា ÷(នាយកដ្ឋានវិនិយោគ)**

ពាក់ព័ន្ធនឹងបញ្ហានេះ អគ្គនាយកដ្ឋានថវិកានឹងបន្តអនុវត្តកិច្ចការសំខាន់ៗ ដូចខាងក្រោម÷

១. ការបង្កើតមូលនិធិ/ថវិកាសម្រាប់ការសិក្សាគម្រោង នឹងកែលម្អប្រសិទ្ធភាពនៃការរៀបចំផែនការវិនិយោគសាធារណៈ, ការសិក្សាគម្រោង, ការវាយតម្លៃ និងការជ្រើសរើស, ការរៀបចំឯកសារវិស្វកម្ម (drawings) និងលក្ខខណ្ឌបច្ចេកទេស (technical specifications) ក៏ដូចជាចៀសវាងការកែសម្រួលគម្រោងជាញឹក-ញាប់ដែលនឹងមានបច្ច័យដល់ស័ក្តិសិទ្ធភាពនៃការអនុវត្តគម្រោង។ ការណ៍នេះ នឹងជំរុញប្រសិទ្ធភាពនៃការអនុវត្តគម្រោងដេញថ្លៃប្រកួតប្រជែងដែលជាមូលដ្ឋានគ្រឹះឆ្ពោះទៅបង្កើនគម្រោងដេញថ្លៃប្រកួតប្រជែងហិរញ្ញ-ប្បទាន ដោយថវិកាជាតិ។

២. ការបង្កើតក្របខណ្ឌរួមសម្រាប់កំណត់ឱ្យច្បាស់លាស់អំពីតួនាទីនិងមុខងារនៃអង្គភាពចំណុះក្រសួង-ស្ថាប័នជាពិសេសអង្គភាពវិស្វកម្ម នឹងត្រូវរៀបចំ និងស្នើសុំការអនុម័តពីប្រមុខរាជរដ្ឋាភិបាល។ ក្របខណ្ឌ

នេះ នឹងក្លាយជាមូលដ្ឋានគតិយុត្តដែលមានសារៈសំខាន់ដើម្បីការពារ និងកាត់បន្ថយការបង្កើតអង្គភាពវិស្វកម្មដែលបាននិងកំពុងអនុវត្តគម្រោងដោយប្រើប្រាស់វិធីសាស្ត្រលទ្ធកម្មដោយឡែក។

៣. អគ្គនាយកដ្ឋានថវិកា នឹងសហការយ៉ាងជិតស្និត និងបន្តជំរុញក្រសួង-ស្ថាប័នតាមរយៈយន្តការគណៈកម្មាធិការអន្តរក្រសួងដើម្បីអនុវត្តគម្រោងដេញថ្លៃប្រកួតប្រជែងហិរញ្ញប្បទានដោយថវិកាជាតិ ក៏ដូចជាពង្រឹងប្រសិទ្ធភាពនៃការសិក្សាគម្រោង, ការរៀបចំ និងការតាមដាន។

៤. អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ សហការគ្នារៀបចំផែនការសកម្មភាពសម្រាប់សិក្សាសមិទ្ធិលទ្ធភាពនៃការបង្កើនគម្រោងដេញថ្លៃ ដោយប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែងចំពោះគម្រោងដែលហិរញ្ញប្បទានដោយថវិកាជាតិ។

## គ. សំណើ

**១១ មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷**

ដៃគូអភិវឌ្ឍន៍រីករាយចំពោះការបង្កើនការយកចិត្តទុកដាក់លើការកែលម្អប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈប្រព័ន្ធនានា ជាអាទិ៍ ប្រព័ន្ធ FMIS, ប្រព័ន្ធ SARMIS, និងប្រព័ន្ធ NRMIS។ ដៃគូអភិវឌ្ឍន៍លើកទឹកចិត្តរាជរដ្ឋាភិបាល បន្តកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើត និងធ្វើស្ថាប័នីយកម្មប្រព័ន្ធទាំងនេះ ជាពិសេស ប្រព័ន្ធ FMIS។ ដៃគូអភិវឌ្ឍន៍កោតសរសើរចំពោះការបន្តតម្រង់ទិសនីតិវិធីថ្មី (Business process streamlining តាមប្រព័ន្ធ FMIS ដើម្បីធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពហិរញ្ញវត្ថុ, ការដកចេញនូវដំណើរការ (outdated process) ដែលលែងចាំបាច់, ការបន្តធ្វើសន្ទានកម្មរវាងប្រព័ន្ធ FMIS និងប្រព័ន្ធផ្សេងៗ និងការបញ្ចូលនូវចំណាយវិនិយោគ ដើម្បីធានាភាពគ្រប់ជ្រុងជ្រោយនៃការកត់ត្រាទិន្នន័យ។

### ១១.១) ការឆ្លើយតបរបស់ក្រុមការងារ FMIS លើប្រព័ន្ធ FMIS

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានឯកភាពលើការតម្រង់ទិសនីតិវិធីថ្មីតាមប្រព័ន្ធFMIS ទាំងស្រុង ហើយដកចេញនូវដំណើរការប្រតិបត្តិការហិរញ្ញវត្ថុចំណាយដែលនៅក្រៅប្រព័ន្ធ FMIS។ ចាប់ផ្តើមពីត្រីមាសទី៣ ឆ្នាំ២០២២ តទៅ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន (បូករួមទាំងអង្គភាពអាណាប័កផ្ទេរសិទ្ធិ) នឹងត្រូវដាក់ឱ្យអនុវត្តសាកល្បងសម្រាប់ការធ្វើស្វ័យប្រវត្តិកម្មពេញលេញលើចំណាយចរន្តក្នុងប្រព័ន្ធ **FMIS** ស្របពេលដែលក្រសួង-ស្ថាប័ន ៨ ផ្សេងទៀត អនុវត្តពេញលេញនូវដំណើរការចំណាយដែលមិនមែនជាការធានាចំណាយ (non-commitment expenditure)។ ជាមួយនឹងការប្តេជ្ញាខ្ពស់ និងផែនការប្រកបដោយមហិច្ឆិតា, ការធ្វើស្វ័យប្រវត្តិកម្មពេញលេញនូវដំណើរការចំណាយចរន្តនឹងត្រូវអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន (រួមទាំងអង្គភាពថវិកា) ត្រឹមឆ្នាំ២០២៣។ ដំណើរការចំណាយវិនិយោគនឹងត្រូវតម្រង់ទិស និងអនុវត្តពេញលេញក្នុងប្រព័ន្ធ FMIS នៅឆ្នាំ២០២៤។

### ១១.២) ការឆ្លើយតបរបស់អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានរតនាគារជាតិអំពីប្រព័ន្ធ SARMIS និង ប្រព័ន្ធ NRMIS។

❖ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ(.ទ.ទ.អ) ÷

បន្ទាប់ពីប្រកាសដាក់ឱ្យអនុវត្តប្រព័ន្ធ SARMIS នៅថ្ងៃទី ០១ ខែមករា ឆ្នាំ២០២១, អគ្គនាយកដ្ឋានទ្រព្យ-សម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ បានរៀបចំវគ្គបណ្តុះបណ្តាលមួយចំនួន ជូនមន្ត្រីរាជការនៃក្រសួង-ស្ថាប័ន, រដ្ឋបាលរាជធានី-ខេត្ត, ក្រុង-ស្រុក-ខណ្ឌ, និងសហគ្រាសសាធារណៈ ចាប់ពីថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដល់ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០២២។ វគ្គបណ្តុះបណ្តាលសម្រាប់គាំទ្រការដាក់ឱ្យអនុវត្តប្រព័ន្ធ SARMIS នៅកម្រិតឃុំ-សង្កាត់ ត្រូវបានពិភាក្សាជាមួយ អ.គ.ហ.។ ក្នុងជំហានឆ្ពោះទៅមុខ ប្រព័ន្ធ SARMIS នឹងក្លាយជាប្រព័ន្ធអនឡាញដែលនឹងត្រូវធ្វើសន្ទានកម្មជាមួយប្រព័ន្ធ FMIS នៅឆ្នាំ២០២៥។

ប្រព័ន្ធ NRMIS ត្រូវបានដាក់ឱ្យអនុវត្តនៅក្រសួង-ស្ថាប័នចំនួន ២៣ រួមជាមួយនឹងមន្ទីរជំនាញ និងរដ្ឋបាលរាជធានី-ខេត្ត។ ប្រព័ន្ធ NRMIS ត្រូវបានធ្វើសន្ទានកម្មជាមួយប្រព័ន្ធ FMIS នៅខែមករា ឆ្នាំ២០២០។ ក្នុងឆ្នាំ២០២២, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ នឹងរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់ការអនុវត្តប្រព័ន្ធ NRMIS ជូនមន្ត្រីរាជការនៃរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ ដើម្បីត្រៀមខ្លួនសម្រាប់ការដាក់ឱ្យអនុវត្តនាពេលខាងមុខ។

❖ អគ្គនាយកដ្ឋានរតនាគារជាតិ÷ ប្រព័ន្ធ NRMIS។

អនុលោមតាមប្រកាសលេខ ៨៧៥ សហវ.ប្រក ចុះថ្ងៃទី២១ ខែ កក្កដា ឆ្នាំ២០១៦ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសដើម្បីសម្រួលនីតិវិធីកត់ត្រាចំណូលមិនមែនសារពើពន្ធ, ផែនការសកម្មភាពនៃប្រព័ន្ធ NRMIS ត្រូវបានរៀបចំឡើង និងដាក់ឱ្យអនុវត្តដូចខាងក្រោម÷

i) ឆ្នាំ ២០១៦-២០១៨

- ប្រកាសសមាសភាពសមាជិកក្រុមការងារ ក) ព.ម.NRMIS-WG)
- រៀបចំផែនការសកម្មភាព
- ទស្សនកិច្ចសិក្សានៅតាមបណ្តាក្រសួង-ស្ថាប័នមួយដែលគេបានប្រើប្រាស់ប្រព័ន្ធរួចហើយ
- នីតិវិធីអនុវត្តការងារ )BP)។

ii) ឆ្នាំ២០១៨-២០២០ ដំណាក់កាលទី១ រួមមាន ៣ ជំហាន

- NRMIS បានដាក់ឱ្យអនុវត្តនៅក្រសួង-ស្ថាប័ន ចំនួន ១៤ នៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៨
- NRMIS បានដាក់ឱ្យអនុវត្តនៅក្រសួង ស្ថាប័ន ចំនួន ៩ នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០១៨
- NRMIS បានដាក់ឱ្យអនុវត្តនៅមន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត ចំនួន ១៨ នៅថ្ងៃទី ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩។

iii) ឆ្នាំ២០២០-២០២២ រួមមាន ៣ ជំហាន

❖ ឆ្នាំ២០២០-២០២១, NRMIS នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ មាន ៣ ជំហាន

- NRMIS បានដាក់ឱ្យអនុវត្ត នៅរដ្ឋបាលរាជធានី-ខេត្ត នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១
- NRMIS ដាក់ឱ្យអនុវត្ត នៅរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ នៅឆ្នាំ២០២២

| | |
|---|---|
| | – NRMIS ដាក់ឱ្យអនុវត្ត នៅរដ្ឋបាលឃុំ-សង្កាត់ នៅឆ្នាំ២០២៣។<br>❖ ឆ្នាំ២០២០-២០២១ ការបង់ចំណូលតាមប្រព័ន្ធទូទាត់អេឡិចត្រូនិក ផ្សារភ្ជាប់ជាមួយប្រព័ន្ធ NRMIS (NRMIS-e-Payment) ចំនួន ២៣ ក្រសួង-ស្ថាប័ន រួមមាន ៣ ជំហាន និងមន្ទីរ អង្គភាពជំនាញក្រោមឱវាទ<br>– NRMIS-e-Payment បានដាក់ឱ្យអនុវត្តនៅក្រសួង-ស្ថាប័ន ចំនួន ៣ នៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០២០<br>– NRMIS-e-Payment បានដាក់ឱ្យអនុវត្តនៅក្រសួង-ស្ថាប័ន ចំនួន ១០ នៅថ្ងៃទី ២៧ ខែសីហា ឆ្នាំ ២០២១<br>– NRMIS-e-Payment បានដាក់ឱ្យអនុវត្តនៅក្រសួង-ស្ថាប័ន ចំនួន ១០ នៅថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០២២។<br>iv) ផែនការសកម្មភាពបន្ត ឆ្នាំ២០២៣-២០២៧ (CAP4)<br>– NRMIS ដាក់ឱ្យអនុវត្តនៅរដ្ឋបាលឃុំ-សង្កាត់ នៅឆ្នាំ២០២៣ (បន្ត(<br>– NRMIS ដាក់ឱ្យអនុវត្ត នៅក្រសួង-ស្ថាប័នចំនួន ១៥ និងមន្ទីរជំនាញ ចំនួន ៧ ដែលមិនទាន់បានប្រើប្រាស់ប្រព័ន្ធ NRMIS នៅឆ្នាំ២០២៤ ដោយសារក្រសួង-ស្ថាប័នទាំងនោះមិនមានចំណូលពីសេវាសារធារណៈ ប៉ុន្តែមានចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលផ្សេងៗ<br>– NMRIS-e-Payment ដាក់ឱ្យអនុវត្ត នៅក្រសួង-ស្ថាប័ន ចំនួន ១៥ និងមន្ទីរជំនាញ ចំនួន ៧, ដាក់ឱ្យអនុវត្តនៅរដ្ឋបាលរាជធានី-ខេត្ត, ដាក់ឱ្យអនុវត្តនៅរដ្ឋបាលក្រុង-ស្រុក-ខណ្ឌ, ដាក់ឱ្យអនុវត្តនៅរដ្ឋបាលឃុំ-សង្កាត់ឆ្នាំ ២០២៤-២០២៧។ |
| ១២ | **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷**<br>ដៃគូអភិវឌ្ឍន៍កត់សម្គាល់ឃើញថា កម្ពុជាបានប្តេជ្ញាអនុវត្តថវិកាព័តិមានសមិទ្ធកម្ម នៅជំហានបន្ទាប់។ នៅក្នុងជំហានបន្ទាប់នេះ ក្រសួង-ស្ថាប័ន នឹងត្រូវមានគណនេយ្យភាពកាន់តែច្រើនចំពោះសមិទ្ធកម្មរបស់ក្រសួង-ស្ថាប័នសាមី។ ដើម្បីគាំទ្រកិច្ចការនេះ ដៃគូអភិវឌ្ឍន៍ស្នើព័តិមានបន្ថែមអំពីការដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្មជាមួយក្រសួង-ស្ថាប័ន ជាផ្នែកមួយដែលភាពបត់បែនកាន់តែច្រើនក្នុងការអនុវត្តថវិកាត្រូវបានអនុញ្ញាត។ |
| | ◈ **ការឆ្លើយតបរបស់អគ្គនាយកដ្ឋានថវិកាអំពីការដាក់ឱ្យអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម ជាមួយក្រសួង-ស្ថាប័ន និង ការផ្តល់ភាពបត់បែនកាន់តែច្រើនក្នុងការអនុវត្តថវិកា។**<br>ស្របតាមផែនការសកម្មភាពនៃយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥, ថវិកាសមិទ្ធកម្មនឹងត្រូវបានសាកល្បងអនុវត្តសម្រាប់ច្បាប់ថវិកានាពេលខាងមុខក្នុងឆ្នាំ២០២៣។ ទន្ទឹមនឹងនេះ ទម្រង់កិច្ចព្រមព្រៀងថវិកាសមិទ្ធកម្មត្រូវបានបង្កើតឡើងចំនួន ៣ រួមមាន÷<br>i) កិច្ចព្រមព្រៀងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ស្តីពីការអនុវត្តថវិកាកម្មវិធី/ថវិកាសមិទ្ធកម្ម<br>ii) កិច្ចព្រមព្រៀងរវាងក្រសួង-ស្ថាប័ន ជាមួយអ្នកគ្រប់គ្រងកម្មវិធី និង<br>iii) កិច្ចព្រមព្រៀងរវាងអ្នកគ្រប់គ្រងកម្មវិធី និងប្រធានអង្គភាពថវិកា<br>ទម្រង់កិច្ចព្រមព្រៀងនេះត្រូវបានអនុវត្តដោយប្រកាសលេខ ១៤៩ សហវ.ប្រក ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០២២ ស្តីពីការណែនាំទម្រង់កិច្ចព្រមព្រៀងថវិកាសមិទ្ធកម្ម។ |

១៣ **មតិយោបល់របស់ដៃគូអភិវឌ្ឍន៍÷**

ដើម្បីគាំទ្រអន្តរកាលឆ្ពោះទៅថវិកាព័ត៌មានសមិទ្ធកម្ម, ដៃគូអភិវឌ្ឍន៍ផ្តល់អនុសាសន៍បន្តពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដោយផ្តោតលើកិច្ចការដូចខាងក្រោម÷

i) អនុវត្តចំណាត់ថ្នាក់ថវិកាឱ្យបានពេញលេញ ដែលជាឧបករណ៍សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តផ្នែកគោលនយោបាយ

ii) បន្តបង្កើតតិចនិច និងអភិវឌ្ឍន៍សមត្ថភាព សម្រាប់វិភាគបច្ច័យថវិកានៃគោលនយោបាយ និងសម្រាប់ផ្សារភ្ជាប់ការងារអាទិភាពទៅនឹងការពង្រាយថវិកា )budget deployment)

iii) ធ្វើសនិទានកម្មរចនាសម្ព័ន្ធថវិកាកម្មវិធីដើម្បីចាប់យកគ្រប់កម្មវិធី ដែលទាក់ទិននឹងចំណាយវិនិយោគ និងចំណាយបន្ទុកបុគ្គលិក

iv) បន្តពង្រីកការអនុវត្តសមាហរណកម្មថវិកា។

### ១៣.១) ការឆ្លើយតបរបស់ក្រុមការងារ FMIS ទៅលើចំណាត់ថ្នាក់ថវិកាទាំង ៧។

បច្ចុប្បន្ន ចំណាត់ថ្នាក់ថវិកាទាំ៧ ត្រូវបានអនុវត្តក្នុងប្រព័ន្ធ FMIS។ របាយការណ៍ប្រើប្រាស់ចំណាត់ថ្នាក់ថវិកាទាំង ៧ អាចទាញបានចេញពីប្រព័ន្ធ។ ដូចនេះ ព័ត៌មានអំពីការរៀបចំ និងការអនុវត្តថវិកា ត្រូវបានកត់ត្រា និងប្រតិបត្តិការកាន់តែលម្អិត ដែលថ្នាក់ដឹកនាំ ឬអ្នកប្រើប្រាស់អាចទាញយកព័ត៌មានទាំងនេះសម្រាប់ធ្វើសេចក្តី-សម្រេចចិត្ត។ ដើម្បីជួយសម្រួលដល់ថ្នាក់ដឹកនាំ ឬអ្នកប្រើប្រាស់, ក្រុមការងារ FMIS បានអភិវឌ្ឍកញ្ចប់ថវិកាជំនាន់ទី២ ដែលជំហានបឋម នឹងត្រូវរៀបចំជូនសម្រាប់ថ្នាក់ដឹកនាំកំពូលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជំហានបន្ទាប់ដាក់ឱ្យអនុវត្តនៅក្រសួង-ស្ថាប័នចំនួន ៩ សម្រាប់ជាការលើកទឹកចិត្តចំពោះក្រសួង-ស្ថាប័នដែលចូលរួម អនុវត្តស្វ័យប្រវត្តិកម្មពេញលេញនូវដំណើរការចំណាយក្នុងប្រព័ន្ធ FMIS។ កញ្ចប់ថវិកានេះ ក៏នឹងត្រូវដាក់ឱ្យអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ននៅឆ្នាំ២០២៣ ផងដែរ។ ការបោះបង់ចោលនូវដំណើរការដោយដៃនៅក្រៅប្រព័ន្ធ FMIS នឹងផ្តល់ឱកាសសម្រាប់រាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់គុណភាព និងភាពទាន់ពេលវេលានៃព័ត៌មាន ហើយនឹងផ្តល់ពេលវេលាសម្រាប់ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន (កម្រិតអគ្គនាយកឡើង) ប្តូរពីតួនាទី និងការទទួលខុសត្រូវទៅលើដំណើរការដែលមិនផ្តល់តម្លៃបន្ថែម ទៅជាការតាមដានត្រួតពិនិត្យ វិភាគ គាំទ្រ និងផ្តល់អនុសាសន៍ណែនាំមន្ត្រីក្រោមឱវាទក្នុងការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើង ព្រមទាំងពង្រឹងការរៀបចំផែនការថវិកា និងការអនុវត្តឱ្យផ្សារភ្ជាប់ជាមួយគោលនយោបាយរបស់រាជរដ្ឋាភិបាល ឱ្យសម្រេចបានលទ្ធផលតាមការរំពឹងទុក។

### ១៣.២) ការឆ្លើយតបរបស់អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិអំពីចំណាត់ថ្នាក់ភូមិសាស្ត្រ និងចំណាត់-ថ្នាក់គម្រោង។

ចំណាត់ថ្នាក់ភូមិសាស្ត្រ និងចំណាត់ថ្នាក់គម្រោង ត្រូវបានរៀបចំរួចរាល់។ ចំណាត់ថ្នាក់ទាំងពីរនេះ នឹងត្រូវដាក់ស្នើសុំការសម្រេចដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** នៅដើមត្រីមាសទី២ ឆ្នាំ២០២២ និងដាក់ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអនុវត្តនៅឆ្នាំ២០២៣។

**១៣.៣) ការឆ្លើយតបរបស់អគ្គនាយកដ្ឋានថវិកាអំពីចំណាត់ថ្នាក់កម្មវិធី និងចំណាត់ថ្នាក់មុខងារ និង ចំណុចទី (ii) បន្តបង្កើតវិធីសាស្ត្រ និងអភិវឌ្ឍន៍សមត្ថភាព សម្រាប់វិភាគបច្ច័យថវិកានៃគោលនយោបាយ និងសម្រាប់ផ្សារភ្ជាប់ការងារអាទិភាពទៅនឹងការពង្រាយថវិកា (budget deployment), (iii) ធ្វើសនិទានកម្មរចនាសម្ព័ន្ធថវិកា កម្មវិធី ដើម្បីចាប់យកគ្រប់កម្មវិធី ដែលទាក់ទិននឹងចំណាយវិនិយោគ និងចំណាយបន្ទុកបុគ្គលិក និង (iv) បន្តពង្រីកការអនុវត្តសមាហរណកម្មថវិកា។**

(i) ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានដាក់ចេញនូវប្រកាសក្នុងឆ្នាំ២០១៧ ដោយតម្រូវឱ្យអនុវត្តចំណាត់ថ្នាក់មុខងារក្នុងការរាយការណ៍អំពីការអនុវត្តថវិកា ដែលអង្គភាពថវិកានានាត្រូវបង្ហាញអំពីអនុវិភាជន៍ថវិកា (sub allocation) នៅកម្រិតកម្មវិធី, អនុកម្មវិធី និងសកម្មភាពជាមួយនឹងការផ្សារភ្ជាប់ទៅនឹង (Mapping) COFOG។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងដាក់ឱ្យអនុវត្តសាកល្បងនូវចំណាត់ថ្នាក់មុខងារផ្អែកលើថវិកាកម្មវិធីតាមពីឆ្នាំ២០១៩ ជាមួយនឹងការបន្តពង្រឹងការអនុវត្តជាបណ្តើរៗ។ ការចូលរួមពីក្រសួង-ស្ថាប័ន គឺពិតជាមានសារៈសំខាន់ក្នុងការសម្រេចបាននូវលទ្ធផលល្អប្រសើរនៃការទទួលយក COFOG មកអនុវត្ត។ ការផ្សារភ្ជាប់រវាង ចំណាត់ថ្នាកថវិកានិង COFOG គ្របដណ្តប់ទាំងចំណាយបន្ទុកបុគ្គលិក។ វិនិយោគក្នុងស្រុកត្រូវបានផ្សារភ្ជាប់រួចរាល់ នៅក្នុងចំណាត់ថ្នាក់មុខងារ ខណៈហិរញ្ញប្បទានអន្តរជាតិ (ទទួលបន្ទុកដោយអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល) នៅមិនទាន់ផ្សារភ្ជាប់នៅនៅក្នុងចំណាត់ថ្នាក់មុខងារនៅឡើយ។

(ii) អគ្គនាយកដ្ឋានថវិកា បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៣ វគ្គតាមប្រព័ន្ធ Zoom អំពីថវិកាសមិទ្ធកម្ម ក្នុងនោះរួមមានដូចខាងក្រោម÷

១. វគ្គបណ្តុះបណ្តាលថ្ងៃទី ៦ - ៧ ខែធ្នូ ឆ្នាំ២០២១ សម្រាប់សិក្ខាកាម និងមន្ត្រីថវិកានៃនាយកដ្ឋានថវិកានីយកម្ម ចំនួន ៧៥ រូប។

២. វគ្គបណ្តុះបណ្តាលថ្ងៃទី ១៥ - ១៦ ខែធ្នូ ឆ្នាំ២០២១ សម្រាប់សិក្ខាកាមនៃក្រសួង-ស្ថាប័នសរុបចំនួន ៣៦៦ រូប

៣. វគ្គបណ្តុះបណ្តាលថ្ងៃទី ៩-១១ ខែមីនា ឆ្នាំ២០២២ សម្រាប់សិក្ខាកាម និងមន្ត្រីថវិកានៃក្រសួង-ស្ថាប័ន (បូករួមទាំងស្ថាប័នសាធារណៈរដ្ឋបាល និងមន្ទីរខេត្ត) សរុបច្រើនជាង ១០០០ រូប។

អគ្គនាយកដ្ឋានថវិកាបន្តកែលម្អចំណាត់ថ្នាក់ថវិកាទាំង ៧ នៅក្នុងប្រព័ន្ធ FMIS ដែលជាកិច្ចខិតខំប្រឹងប្រែងបន្តបង្កើតតិចនិចសម្រាប់វិភាគបច្ច័យថវិកាចំពោះគោលនយោបាយ។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានថវិកា កំពុងកែលម្អគុណភាពផែនការយុទ្ធសាស្ត្រថវិកាតាមរយៈការកែលម្អសូចនាករ។ នៅក្នុងជំហានរៀបចំថវិកា, អគ្គនាយកដ្ឋានថវិកាដាក់ចេញនូវទម្រង់រៀបចំថវិកាថ្មី និងទម្រង់របាយការណ៍ថ្មី (របាយការណ៍ស្តីពីចំណាយបៀវត្សរ៍តាមកម្មវិធី)។ មន្ត្រីថវិកាក៏ទទួលបាននូវវគ្គបណ្តុះបណ្តាលមួយចំនួន ដែលផ្តល់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិអំពីការវិភាគថវិកា, ការគ្រប់គ្រងប្រសិទ្ធភាពចំណាយថវិកា, និងប្រធានបទពាក់ព័ន្ធផ្សេងទៀត។

ក្នុងកិច្ចសហការជាមួយអង្គការ UNICEF, អគ្គនាយកដ្ឋានថវិកាគ្រោងវាយតម្លៃតម្រូវការបណ្តុះបណ្តាល (TNA) ដើម្បីគាំទ្រការអនុវត្តថវិកាសមិទ្ធកម្ម ដែលនឹងត្រូវដាក់ឱ្យអនុវត្តសាកល្បងសម្រាប់ឆ្នាំថវិកា ២០២៣។

<table>
<tr><td></td><td>បន្ថែមពីនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំ និងអនុវត្តគោលការណ៍ណែនាំអំពីការតាមដាននិងវាយតម្លៃថវិកាសមិទ្ធកម្ម ផងដែរ។<br><br>(iii) និង (iv) ជាមួយនឹងការដាក់ចេញនូវ MTFF និង MTBF នៅក្នុងសារាចររៀបចំផែនការយុទ្ធសាស្ត្រថវិកា, ពិតានថវិកាមូលធន បង្ហាញការវិភាជចំណាយសម្រាប់ក្រសួងអាទិភាពចំនួន ៩ ដែលជាមូលដ្ឋានសម្រាប់ផែនការវិនិយោគ ៣ ឆ្នាំរំកិល សម្រាប់ហិរញ្ញប្បទានថវិកាជាតិ ក៏ដូចជាការធ្វើសមាហរណកម្ម និងវិចារណកម្មគម្រោងហិរញ្ញប្បទានក្នុងស្រុក ទៅក្នុងរចនាសម្ព័ន្ធកម្មវិធី និងអនុកម្មវិធីនៃផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ន។ ការណ៍នេះ មានគោលបំណងពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ រហូតមកដល់ពេលនេះ ការធ្វើសមាហរណកម្មថវិកាចរន្តនិងមូលធន ត្រូវបានកែលម្អនៅកម្រិតផែនការយុទ្ធសាស្ត្រថវិកា និងកាន់តែស៊ីជម្រៅថែមទៀតនៅក្នុងរចនាសម្ព័ន្ធថវិកាកម្មវិធី និងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។ ជារួម ផែនការសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ និងផែនការសកម្មភាពរួម (CAP) នឹងពង្រឹងការអនុវត្តលើការធ្វើសមាហរណកម្មថវិកានេះ។</td></tr>
<tr><td>១៤</td><td>មតិយោបល់របស់ដៃគូអភិវឌ្ឍន៍៖<br><br>ដៃគូអភិវឌ្ឍន៍សូមកោតសរសើរអំពីវឌ្ឍនភាពនៃការធ្វើវិមជ្ឈការហិរញ្ញវត្ថុ ដោយផ្ទេរមុខងារទាំង ៥៥ ទៅរដ្ឋបាលក្រុង-ស្រុក។ ដៃគូអភិវឌ្ឍន៍ផ្តល់យោបល់ថា មុខងារថ្មីទាំង ៥៥ នេះគួរត្រូវផ្ទេរធនធានបន្ថែម។</td></tr>
<tr><td></td><td>◆ ការឆ្លើយតបរបស់អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិអំពីការបន្ថែមថវិកាផ្តល់ជូនសម្រាប់មុខងារទាំង ៥៥ នេះ។<br><br>អនុលោមតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ នាកិច្ចប្រជុំថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០២២, ក្រុមការងារចំពោះកិច្ចត្រូវបានបង្កើត ដើម្បីសិក្សាលើការផ្ទេរធនធានបន្ថែមសម្រាប់អនុវត្តមុខងារដែលបានផ្ទេរ។ បច្ចុប្បន្ន, ក្រុមការងារចំពោះកិច្ចបាននិងកំពុងចុះបេសកកម្មទៅកាន់រដ្ឋបាលក្រុង-ស្រុកគោលដៅ ដើម្បីប្រមូលព័ត៌មានបន្ថែមទាក់ទងនឹងការអនុវត្តមុខងារដែលបានផ្ទេរទាំង៥៥ និងត្រៀមរៀបចំបូកសរុបជារបាយ-ការណ៍គោរពជាក់ជូន ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ដើម្បីផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់លើការផ្ទេរធនធានបន្ថែមសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទាំង៥៥នេះ។</td></tr>
</table>

# ឧបសម្ព័ន្ធទី ៩  ÷ បទបង្ហាញស្តីពីរបាយការណ៍ត្រួតពិនិត្យ និងវាយតម្លៃ PFMRP និងរបាយការណ៍វឌ្ឍនភាព ប្រចាំត្រីមាសទី៤ និងឆ្នាំ២០២១ សម្រាប់កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០២១ (ភាសាអង់គ្លេស)

## 2021 Annual Review Meeting
## Implementation of PFM Reform Program Stage3+2

# Report on Monitoring and Evaluation of Implementing PFMRP and PFMRP for 4th Quarter and 2021

**"Improving System, Legal Framework, Institutional Mechanism and Human Resources"**

Video Conference, March 23, 2022



# Contents

1. Introduction

2. Annual progress in 2021

3. Expense on Implementing PFM Reform Program (2004-2021)

4. Development Partner's Comments - Preliminary Results of Evaluating FMIS and Public Expenditure Review

5. Impact on PFM System

6. Conclusion

## 1. Introduction – Background and Purpose

- Circular No.09 SR of the Royal Government of Cambodia dated 28 December 2015 on measures and procedures for preparing, implementing, monitoring and evaluating PFMRP.
- Report on Monitoring and Evaluation of Implementing PFMRP and PFMRP for 4th Quarter and 2021 is very comprehensive through promoting the participations as inputs from all relevant parties, including entities under the Ministry of Economy and Finance (MEF), capital/provincial departments of economy and finance, line ministries (LMs), capital/provincial administrations, and development partners (DPs).
- This report will be used as the main inputs for preparing Consolidated Action Plan – Stage 4 (CAP4).



## 1. Introduction – Methodology of Report Preparation



# 2. Annual Progress in 2021

*2.1. Progress of Implementing Executive Orders*

*2.2. Progress of Implementing Consolidated Action Plan*



## 2.1. Progress of Implementing Executive Orders – Measures achieved

**There are 35 executive orders, of which 8 measures were achieved.**

1. Law on Public-Private Partnership
2. Sub-Decree on Increasing the Number of Budget Entities and Handing Over the Authority to Budget Entities
3. Capacity Development Strategic Plan for PFMRP-Stage 4
4. The interface of FMIS and Payroll System of the Ministry of Civil Service
5. 2021 National PEFA Assessment Report
6. Action plan to reinforce establishing budget entities
7. Study on the possibility of increasing budget entities in the capital/provincial administrations and prepare a specific action plan
8. State land title preparation plan

## 2.1. Progress of Implementing Executive Orders – On-going Progress

Legal framework

1. Draft Law on Public Financial System (New) [GDB ; Q4, 2022 submit to the legislative body]

This draft law is to be completed at MEF, and submitted to the Council of Ministers in Q3, 2022 and the legislative body in Q4, 2022.

2. Draft Law on Non-Tax Revenue Management [GDSPNR; Q4,2022]

Draft Law passed inter-ministerial consultation workshop, development partners, representatives of civil society organizations and MEF's management meeting. The Working Group completely discussed the Chapter 10 (Conviction) With the Ministry of Justice and the Anti-Corruption Unit on January 28, 2022. This draft law will be discussed in the Economic and Financial Policy Committee meeting on 28 March 2022.

3. Policy Framework for Developing Government Bond [GSC & GDICDM; Q4, 2021]

The Technical Working Group continues to draft a Policy Framework on Developing Government Bond 2022-2028.

4. Draft Law on Public Enterprises Management [GDSPNR; Q4, 2022 submit to the legislative body]

The draft law has been completed (in legal format and content) at MEF Technical Working Group level. They plans to arrange consultation workshop in Q1, 2022 and to send to the Council of Ministers in Q3, 2022. It is due to a need to develop Strategy on Reforming Public Enterprise for input in the draft law.



## 2.1. Progress of Implementing Executive Orders – On-going Progress

Legal framework

5. Revision Sub-Decree No.81 ANKr.BK dated 16 November 1995 [GDB; Q1, 2022]

The draft Sub-Decree was completely discussed at the GDB level and sent to a French expert for inputs. GDB plans for inter-general department discussion and to incorporate with the draft Sub-Decree No. 82 in Q3, 2022.

6. Revision Sub-Decree No.82 ANKr.BK dated 16 November 1995 [GDNT; Q1, 2022]

Draft Sub-Decree was prepared and gradually updated based on principles decided by Working Group Preparing draft Law on Public Financial System (New).

7. Government Public Financial Management Manual [GSC; Q1,2021]

The Technical Working Group has been reviewing and revising the sixth draft prior to the consultation workshop.

## 2.1. Progress of Implementing Executive Orders – On-going Progress

Legal framework

8. Draft "Prakas on the Principles and Procedures for Non-Tax Revenue Management in Condition of Functions Transferring for Revenue from Public Services, Revenue from Fines and Penalties, and in Condition of Sharing Revenue from Public Services and Revenue from State Property from National Administrations to Sub-National Administrations". [GSC & GDSPNR; Q4, 2021] ▲

Draft Prakas was prepared and passed the consultation meetings with line ministries both at technical and management level in February 2022. The draft Prakas will be submitted to H.E. Dr. DPM for endorsement in the early Q2, 2022.

9. Government circular to encourage LMs especially LMs within social and economic sectors to disseminate or organize public forum on their own annual budget. [GDB; Q4, 2021] ▲

